**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# សាលក្រមព្រហ្មទណ្ឌ
# របស់សាលាដំបូងរាជធានី ~ ខេត្ត

ស្រាវជ្រាវពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២១ ដល់ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២១


ស្រាវជ្រាវដោយ៖

និស្សិតឈ្មោះ **កញ្ញា ផន ម៉ីជីង**

**កញ្ញា ម៉ម ស្រីនិច**

សាស្ត្រាចារ្យណែនាំ

**លោក ជ្រូ សុភារ៉ា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២១

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

៙✵៙

# សារណាបញ្ចប់ការសិក្សា

# សាលក្រមព្រហ្មទណ្ឌ

# របស់សាលាដំបូងរាជធានី ~ ខេត្ត

ស្រាវជ្រាវពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២១ ដល់ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២១


ស្រាវជ្រាវដោយៈ

និស្សិតឈ្មោះ **កញ្ញា ផន ម៉ីជីង**

**កញ្ញា ម៉ម ស្រីនិច**

សាស្ត្រាចារ្យណែនាំ

**លោក ជ្រ សុភារ៉ា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២១

ឆ្នាំចូលសិក្សា ២០១៧

ឆ្នាំសរសេរសារណា ២០២១

## សេចក្តីថ្លែងអំណរគុណ

៚✵៚

យើងខ្ញុំទាំងពីរឈ្មោះ **ផន មុីជីង** និង **ម៉ម ស្រីនិច** ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្រ្ត ជំនាន់ទី២១ នៃ **សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ក្នុងឆ្នាំសិក្សា ២០១៧-២០២១។

**សូមអនុញ្ញាតគោរព សម្តែងនូវមហាកតញ្ញូតាធម៌**

**ដឹងគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ**

**លោកឪពុក** និង**អ្នកម្តាយ** របស់យើងខ្ញុំទាំងពីរ ដែលលោកទាំងទ្វេបានផ្តល់កំណើតដល់រូបយើងខ្ញុំមានគុណធ្ងន់ពុំអាចកាត់ថ្លៃបានចំពោះកូន ដែលលោកខិតខំចិញ្ចឹមបីបាច់ ថែរក្សា ផ្គត់ផ្គង់ ទូន្មានប្រៀនប្រដៅកូនប្រកបដោយព្រហ្មវិហារធម៌ ទាំងកម្លាំងកាយ និងកម្លាំងចិត្ត ដោយក្តីស្រឡាញ់តាំងពីកូនចាប់កំណើតរហូតដល់កូនពេញវ័យ ដោយមិនគិតពីការនឿយហត់ លំបាកយ៉ាងនោះទេ ដើម្បីឱ្យកូនមានអនាគតភ្លឺស្វាង។ សេចក្តីដឹងគុណចំពោះ លោកឪពុក និងអ្នកម្តាយ ពិតជាធំធេងដែលពុំអាចកាត់ថ្លៃបានឡើយសម្រាប់ជីវិតពួកយើងខ្ញុំទាំងពីរ។

ឯកឧត្តមបណ្ឌិត **លុយ ចណ្ណា** សាកលវិទ្យាធិការ និងសាកលវិទ្យាធិការរង ព្រឹទ្ធបុរស ថ្នាក់ដឹកនាំ គណៈគ្រប់គ្រង ព្រមទាំងលោក លោកស្រីសាស្ត្រាចារ្យ ទាំងអស់នៃ **សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ដែលលោកទាំងអស់បានខិតខំទាំងកម្លាំងកាយ និងកម្លាំងចិត្ត ចូលរួមលើកស្ទួយបណ្តុះបណ្តាលធនធានមនុស្សឱ្យទទួលបាននូវការចំណេះដឹងទូលំទូលាយ និងការអប់រំដ៏ល្អយ៉ាងច្បាស់លាស់ ជាពិសេសនោះគឺការបង្ហាត់បង្រៀន និងផ្តល់ជាដំបូន្មានដល់យើងខ្ញុំទាំងពីរតាំងពីឆ្នាំសិក្សាថ្នាក់មូលដ្ឋាន រហូតបានបញ្ចប់នូវថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ។

ពិសេសជាងនេះទៅទៀតនោះ យើងខ្ញុំទាំងពីរសូមលំឱនកាយគោរព និងសម្តែងការដឹងគុណយ៉ាងជ្រាលជ្រៅបំផុតអស់ពីចិត្ត ជូនចំពោះ **លោកមេធាវី ជ្រ សុនារ៉ា** ដែលលោកជាសាស្ត្រាចារ្យណែនាំ និងដឹកនាំដល់ការសរសេរ សារណារបស់យើងខ្ញុំ ដោយរូបលោកបានខិតខំអស់ទាំងកម្លាំងកាយ និងចិត្ត រួមទាំងចំណាយពេលវេលាដ៏មានតម្លៃមកធ្វើការពន្យល់ណែនាំ បង្ហាញនូវគន្លឹះសំខាន់ៗ ហើយបានផ្តល់នូវដំបូន្មាន គំនិត និងចំណេះដឹងសំខាន់ផ្សេងៗទៀត ព្រមទាំងលើកទឹកចិត្តដល់យើងខ្ញុំទាំងពីរ តាំងពីថ្ងៃដែលចាប់ផ្តើមសរសេរសារណា រហូតដល់ទទួល

បាននូវស្នាដៃមួយនេះជាស្ថាពរ ដែលគុណទាំងអស់ខាងលើនេះ គឺពិតជាមានតម្លៃយ៉ាងវិសេសវិសាលធំធេង ពុំអាចកាត់ថ្លៃបានឡើយមកលើយើងខ្ញុំទាំងពីរ។

ឆ្លៀតក្នុងឱកាសនេះ យើងខ្ញុំសូមថ្លែងអំណរគុណ និងសូមបួងសួងដល់វត្ថុស័ក្តសិទ្ធិមានបារមីទាំងឰងនៅលើសកលលោកយើងនេះ សូមជួយតាមថែរក្សាជនរួមជាតិទាំងអស់ឱ្យសមប្រកប និងជួបប្រទះនូវសេចក្តីសុខសេចក្តីចម្រើន ប្រកបដោយពុទ្ធិពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

៚✵៛

យើងខ្ញុំទាំងពីរជានិស្សិតនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាន់ទី២១ ដោយយើងខ្ញុំបានឆ្លងកាត់ការសិក្សាអប់រំ និងការបណ្ដុះបណ្ដាលក្នុងថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រអស់រយៈពេល ៤ ឆ្នាំមកនេះ បានបង្ហាញឱ្យឃើញថាការសិក្សានៅក្នុងថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រនេះ ពិតជាបានផ្ដល់នូវសារៈសំខាន់យ៉ាងខ្លាំងណាស់ សម្រាប់យើងខ្ញុំទាំងពីរដែលក្នុងនាមជាសសរទ្រូងនៃប្រទេសជាតិនាជំនាន់ក្រោយនេះ។ ជាក់ស្ដែងបន្ទាប់ពីយើងខ្ញុំបានសិក្សាអំពីមុខវិជ្ជាជាច្រើននៅក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចផ្នែកនីតិសាស្ត្ររួចមក យើងខ្ញុំបានក្រេបនូវចំណេះដឹងជាច្រើន ក៏ដូចជាទទួលបាននូវបទពិសោធន៍មួយចំនួនធំផងដែរដោយយើងខ្ញុំប្ដេជ្ញាថា នឹងបញ្ចប់ថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រនេះឱ្យទទួលបានជោគជ័យជាស្ថាពរ និងទទួលបានលទ្ធផលល្អគួរជាទីគាប់ចិត្ត។ ទន្ទឹមនឹងនេះផងដែរ ដើម្បីទទួលការបញ្ចប់បរិញ្ញាបត្រឱ្យបានជោគជ័យគ្រប់គ្រាន់នោះ យើងខ្ញុំទាំងពីរនាក់ក៏មានគោលបំណង និងបានសម្រេចចិត្តជាមួយគ្នាថា ក្នុងការបញ្ចប់ការសិក្សានេះយើងខ្ញុំនឹងបញ្ចប់ដោយការសរសេរសារណាមួយ ដ៏សមប្រកបដែលជាលទ្ធផលក៏ដូចជាស្នាដៃដ៏សំខាន់មួយសម្រាប់យើងខ្ញុំទាំងពីរ បន្ទាប់ពីបានសិក្សាក្រេបជញ្ជក់យកចំណេះដឹងអស់រយៈពេល ៤ ឆ្នាំកន្លងមកនេះ។

ម្យ៉ាងទៀតនោះ ដោយសារតែយើងខ្ញុំបានឆ្លងការសិក្សានូវមុខវិជ្ជាដ៏សំខាន់ៗជាច្រើនកន្លងមកនេះ ក្នុងថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រក៏ដូចជាផ្នែកច្បាប់នេះ យើងខ្ញុំទាំងពីរនាក់មានចំណាប់អារម្មណ៍យ៉ាងខ្លាំងទៅលើមុខវិជ្ជានីតិវិធីព្រហ្មទណ្ឌ ដោយហេតុថាមុខវិជ្ជានេះ គឺជាមុខវិជ្ជាមួយដែលបានសិក្សារៀនសូត្រអំពីនីតិវិធីព្រហ្មទណ្ឌ ដែលជាវិធានច្បាប់មួយដ៏សំខាន់ក្នុងចំណោមវិធានច្បាប់ផ្សេងៗទៀត សម្រាប់ការគ្រប់គ្រងសណ្ដាប់ធ្នាប់សង្គម។

សៀវភៅនេះស្រាវជ្រាវ និងប្រមូលផ្ដុំមកចងក្រងឡើងនូវខ្លឹមសារខ្លះៗ ដែលត្រូវបានដក់ស្រង់មកពីការសិក្សាផ្នែកទ្រឹស្ដីនៅក្នុងសាលា និងការស្រាវជ្រាវតាមប្រព័ន្ធអ៊ីនធើណេត និងសៀវភៅច្បាប់ដែលបានកម្ពុជាបានអនុវត្ត និងកំពុងនៅជាធរមាន។ មិនត្រឹមតែប៉ុណ្ណោះសៀវភៅនេះ ក៏ជាជំនួយស្មារតីដល់សិស្សនិស្សិតជំនាន់ក្រោយក្នុងការសិក្សាពង្រឹងស្មារតីក្នុងការអនុវត្តច្បាប់នៅក្នុងស្ថាប័នតុលាការ មេធាវី អាជ្ញាសាលា និងមន្ត្រីអនុវត្តច្បាប់ផ្សេងៗ។

យើងខ្ញុំសង្ឃឹមថាស្នាដៃនេះនឹងត្រូវបានចូលរួមចំណែកក្នុងការការពារសន្តិសុខ និងសណ្ដាប់ធ្នាប់សាធារណៈអភិវឌ្ឍន៍សង្គមឱ្យមានការរីកចំរើនជឿនលឿនលើគ្រប់វិស័យ ដែលពុំឱ្យកើតមានអស្ថិរភាព នត្ថិភាពនៃបទល្មើស និងពង្រឹងនីតិរដ្ឋក្នុងបំណងប្រាថ្នារបស់ប្រជាពលរដ្ឋទៅអនាគត ដែលប្រជាពលរដ្ឋជាក្ដីសង្ឃឹមនៃសសរស្ដម្ភទ្រទ្រង់ប្រទេស

ជាតិ ទើបគេចាត់ទុកជាសង្គមមួយបានស្របតាមធាតុផ្សំបណ្តាបទដ្ឋាន ឬទម្លាប់គតិយុត្តិនានានៃសង្គមដែលចាំបាច់ត្រូវមានប្រជាជន ទឹកដី លទ្ធិប្រជាធិបតេយ្យ និងបទបញ្ញត្តិច្បាប់ជាលំដាប់។

យើងខ្ញុំសូមសំណូមពរដល់ជនរួមជាតិទាំងអស់ ពិសេសស្ថាប័នតុលាការ ឬស្ថាប័នអនុវត្តច្បាប់នានាផ្តល់ការគាំទ្រ និងចូលរួមចំណែកយ៉ាងសកម្មស្មើៗគ្នានូវ "តួនាទី និងភារកិច្ចរបស់ខ្លួន" ប្រកបដោយចលនា លេចចេញជាផ្លែផ្កានៃឧត្តមប្រយោជន៍ ក្នុងលំហូរសសៃឈាមនៃប្រព័ន្ធយុត្តិធម៌របស់ព្រះរាជាណាចក្រកម្ពុជាយើង។

ក្នុងការជ្រើសរើសប្រធានបទដែលយើងខ្ញុំបានសរសេរនេះ ប្រាកដជាមានចំនុចខ្វះខាត និងមានកំហុសឆ្គងមួយចំនួនជាក់ជាពុំខានឡើយ ហើយស្នាដៃនេះយើងខ្ញុំបានសម្រិតសម្រាងនៅមានកម្រិតនៅឡើយ ហេតុនេះយើងខ្ញុំទាំងពីរនាក់សូមទទួលការរិះគន់ដើម្បីស្ថាបនាកែលម្អពីសំណាក់ លោក លោកស្រីជាសាស្ត្រាចារ្យ បងៗ ប្អូនៗ ក៏ដូចជាមិត្តភក្តិនិស្សិតទាំងអស់ដែលបានអានស្នាដៃមួយនេះ ហើយយើងខ្ញុំនឹងរីករាយទទួល នូវកំហុសណាមួយដែលកើតមានឡើងដោយអចេតនារបស់យើងខ្ញុំទាំងពីរនាក់។

# មាតិកា

**សេចក្តីផ្តើម** ..... ១

**ជំពូកទី១ ៖ សាលក្រមព្រហ្មទណ្ឌរបស់សាលាដំបូងរាជធានី-ខេត្ត**

**ផ្នែកទី១ ៖ មូលហេតុនាំឱ្យមានចេញសាលក្រមរបស់សាលាដំបូងរាជធានី-ខេត្ត** ..... ៥

**១.១. សញ្ញាណទូទៅនៃសាលក្រមព្រហ្មទណ្ឌ** ..... ៥

**១.២. ស្ថាប័នដែលមានសមត្ថកិច្ចក្នុងការចេញសាលក្រម** ..... ៦

**ផ្នែកទី២ ៖ ដំណើរការឆ្លងកាត់នៃនីតិវិធីដែលនាំឱ្យមានចេញសាលក្រមព្រហ្មទណ្ឌ** ..... ៩

**២.១. ដំណាក់កាលស៊ើបអង្កេត** ..... ១០

២.១.១. នៅក្នុងការពិនិត្យស្វែងរកបទល្មើស ..... ១០

២.១.២. នៅក្នុងការស៊ើបអង្កេតស្វែងរកភស្តុតាង ..... ១០

**២.២. ដំណាក់កាលចោទប្រកាន់** ..... ១១

២.២.១. ការបើកការស៊ើបសួរ ..... ១២

២.២.២. ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ..... ១៣

២.២.៣. ការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម ..... ១៣

**២.៣. ដំណាក់កាលស៊ើបសួរ** ..... ១៤

២.៣.១. ដីកាលើកលែងចោទប្រកាន់ ..... ១៥

២.៣.២. ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ ..... ១៦

២.៣.៣. ការបញ្ជូនរឿងទៅជំនុំជម្រះរបស់សភាស៊ើបសួរ ..... ១៧

**២.៤. ដំណាក់កាលជំនុំជម្រះ** ..... ១៧

២.៤.១. នីតិវិធីមុនពេលសវនាការជំនុំជម្រះ ..... ១៨

២.៤.២. នីតិវិធីនាពេលជំនុំជម្រះ ..... ២០

២.៤.២.១. គោលការណ៍ស្តីពីភាពសាធារណៈនៃសវនាការ ..... ២០

២.៤.២.២. ដំណើរការនៃកិច្ចពិភាក្សាដេញដោលនាពេលសវនាការ ..... ២១

## ជំពូកទី ២ ៖ ប្រភេទ និងទម្រង់សាលក្រមព្រហ្មទណ្ឌក្នុងលក្ខខណ្ឌគតិយុត្តិ

**ផ្នែកទី១ ៖ ប្រភេទនៃសាលក្រមព្រហ្មទណ្ឌ** ........ ២៩

**១.១. សាលក្រមមុនអង្គសេចក្តី** ........ ៣០

១.១.១. សញ្ញាណទូទៅនៃសាលក្រមមុនអង្គសេចក្តី ........ ៣០

១.១.២. ប្រភេទនៃសាលក្រមមុនអង្គសេចក្តី ........ ៣០

១.១.២.១. សាលក្រមមុនអង្គសេចក្តីស្តីពីសេរីភាពជនជាប់ចោទ ........ ៣០

១.១.២.២. សាលក្រមមុនអង្គសេចក្តីអំពីអញ្ញាត្រកម្ម ........ ៣១

១.១.២.៣. សាលក្រមមុនអង្គសេចក្តីអំពីការបញ្ចូលសំណុំរឿង ........ ៣៣

១.១.២.៤. សាលក្រមចាត់របៀប ........ ៣៣

**១.២. សាលក្រមលើអង្គសេចក្តី** ........ ៣៤

១.២.១. សញ្ញាណទូទៅនៃសាលក្រមលើអង្គសេចក្តី ........ ៣៤

១.២.២. ប្រភេទនៃសាលក្រមអង្គសេចក្តី ........ ៣៥

១.២.២.១. សាលក្រមចំពោះមុខ ........ ៣៥

១.២.២.២. សាលក្រមចាត់ទុកថាចំពោះមុខ ........ ៣៦

១.២.២.៣. សាលក្រមកំបាំងមុខ ........ ៣៧

**ផ្នែកទី២ ៖ ទម្រង់នៃសាលក្រមព្រហ្មទណ្ឌ** ........ ៣៩

**២.១. លក្ខខណ្ឌជាមូលដ្ឋាន ខ្លឹមសារនៃសាលក្រមព្រហ្មទណ្ឌ** ........ ៣៩

២.១.១. ព្រំដែន និងឯករាជ្យភាពនៃសេចក្តីសម្រេចរបស់តុលាការ ........ ៣៩

២.១.២. គោលការណ៍វិនិច្ឆ័យទូទៅក្នុងការសម្រេចសេចក្តីរបស់ចៅក្រមជំនុំជម្រះ ........ ៤១

២.១.២.១. មូលដ្ឋានអង្គហេតុ និងអង្គច្បាប់ ........ ៤២

២.១.២.២. ការវិនិច្ឆ័យលើភស្តុតាងដែលបង្ហាញនាពេលសវនាការ ........ ៤៣

**២.២. ការតាក់តែងលិខិតសាលក្រម** ........ ៤៤

២.២.១. ផ្នែកក្បាលនៃសាលក្រម ........ ៤៤

២.២.២. ផ្នែកសាលក្រម ........ ៤៦

២.២.២.១. ផ្នែកសំអាងហេតុ ........ ៤៦

២.២.២.២. ផ្នែកសេចក្តីសម្រេច ..................................................................................... ៤៩
ក. ការសម្រេចរបស់តុលាការព្រហ្មទណ្ឌ ..................................................................... ៤៩
ខ. ទណ្ឌកម្មព្រហ្មទណ្ឌ ................................................................................................ ៥០
គ. សេចក្តីសម្រេចផ្សេងទៀត ....................................................................................... ៥២
ឃ. ការសម្រេចពីសំណងរដ្ឋប្បវេណី ............................................................................ ៥៤
ង. ការរួចផុតខ្លួនពីបទចោទប្រកាន់ ............................................................................. ៥៤
**ផ្នែកទី៣ ៖ ការជូនដំណឹងពីសាលក្រមព្រហ្មទណ្ឌ**................................................................. ៥៥
**៣.១. លិខិតជូនដំណឹងពីសាលក្រមកំបាំងមុខ** ............................................................... ៥៥
៣.១.១. ទម្រង់នៃលិខិតជូនដំណឹងពីសាលក្រមកំបាំងមុខ ........................................................ ៥៥
៣.១.២. បុគ្គលដែលមានសិទ្ធិទទួលបានការជូនដំណឹងពីតុលាការ ............................................. ៥៦
៣.១.៣. បុគ្គលដែលទទួលបន្ទុកក្នុងការជូនដំណឹង................................................................... ៥៦
៣.១.៣.១. ព្រះរាជអាជ្ញា ..................................................................................................... ៥៦
៣.១.៣.២. អាជ្ញាសាលា ...................................................................................................... ៥៦
៣.១.៣.៣. បុគ្គលផ្សេងទៀតដែលអាចធ្វើការជូនដំណឹង ......................................................... ៥៧
**៣.២. ដំណើរការនៃការជូនដំណឹង**...................................................................................... ៥៧
៣.២.១. ការឱ្យដំណឹងតាមការដាក់ស្តែង ឬដោយផ្ទាល់ ............................................................ ៥៧
៣.២.២. ការឱ្យដំណឹងតាមការសន្មត ....................................................................................... ៥៨
៣.២.៣. ការប្រគល់លិខិតចម្លងនៃសេចក្តីសម្រេចដល់ភាគីពាក់ព័ន្ធ ............................................ ៥៩
៣.២.៤. គោលបំណង និងផលប្រយោជន៍នៃការជូនដំណឹងពីសាលក្រម ..................................... ៦០
**សេចក្តីសន្និដ្ឋាន**........................................................................................................... ៦១
**អនុសាសន៍**................................................................................................................... ៦៤
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

ព្រះរាជាណាចក្រកម្ពុជា ជាប្រទេសដែលប្រកាន់យករបបលទ្ធិប្រជាធិបតេយ្យសេរីពហុបក្សដោយគោរពសិទ្ធិមនុស្ស។ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារផងដែរ។

យើងសង្កេតឃើញថា ក្នុងសង្គមនីមួយៗតែងតែមាននូវអំពើរំលោភបំពានទៅលើសិទ្ធិក៏ដូចជាអំពើដែលប៉ះពាល់ដល់សន្តិសុខរបស់បុគ្គលណាមួយផ្សេងទៀតដែលយើងអាចហៅបានថាជាបទល្មើស។ ក្នុងករណីមានការរំលោភសិទ្ធិ មនុស្សគ្រប់រូបមានសិទ្ធិបានទទួលការដោះស្រាយប្រកបដោយប្រសិទ្ធិភាព ដែលផ្តល់ដោយអង្គការតុលាការឯករាជ្យមួយដល់ពួកគេ។ នៅពេលណាដែលមានមានរឿងក្តីមួយបានកើតឡើងហើយជាប្រភេទ រឿងក្តីព្រហ្មទណ្ឌផងគឺប្រាកដណាស់ទាមទារអោយអ្នកអនុវត្តន៍ច្បាប់ ដែលមានសិទ្ធអំណាចអនុវត្តន៍សិទ្ធអំណាចរបស់ខ្លួនអោយត្រឹមត្រូវនឹងមានមូលដ្ឋានច្បាប់ច្បាស់លាស់។ ស្ថាប័នតុលាការជាអ្នកមានសិទ្ធិអំណាចក្នុងការផ្តន្ទាទោសទៅលើជនទាំងឡាយណាដែលបានប្រព្រឹត្តនូវបទល្មើស ដែលនាំឱ្យប៉ះពាល់ដល់អ្នកដទៃ ក៏ដូចជាសណ្តាប់ធ្នាប់សាធារណៈ។ សិទ្ធិអំណាចក្នុងការផ្តន្ទាទោសត្រូវចេញជាលិខិតសាលក្រម។

នៅក្នុងរឿងព្រហ្មទណ្ឌ ដំណើរនីតិវិធីមានភាពស្មុគស្មាញណាស់ ដោយមានការឆ្លងកាត់ដំណាក់កាលជាច្រើនមុននឹងឈានដល់ការចេញ "សាលក្រម"។ សាលក្រមព្រហ្មទណ្ឌគឺជាសេចក្តីសម្រេចលើរឿងក្តីព្រហ្មទណ្ឌរបស់ សាលាដំបូងបន្ទាប់ពីបានឆ្លងកាត់លំហូរនៃនីតិវិធី ហើយធ្វើឡើងជាលាយលក្ខណ៍អក្សរ មានលក្ខណៈគ្រប់គ្រាន់តាមទម្រង់ដែលកំណត់ដោយក្រមនីតិវិធីព្រហ្មទណ្ឌ ដែលការចេញសាលក្រមព្រហ្មទណ្ឌរបស់ចៅក្រមត្រូវកើតចេញពីអង្គច្បាប់ដែលចៅក្រមមានកាតព្វកិច្ចអនុវត្ត និងកើតចេញអង្គហេតុជាក់ស្តែងដែលចៅក្រមត្រូវពិនិត្យ។ សាលក្រមព្រហ្មទណ្ឌមានច្រើនប្រភេទទៅតាមស្ថានភាពជាក់ស្តែងនាពេលសវនាការ ។ សាលក្រមព្រហ្មទណ្ឌក៏មានតាមលំដាប់លំដោយទៅតាមស្ថានភាពជាក់ស្តែង ក៏ដូចជាទៅតាមជម្រើសនៃការចោទប្រកាន់របស់តំណាងអយ្យការ។ យើងអាចធ្វើការបែងចែកសាលក្រមជាពីរដំណាក់កាល គឺសាលក្រមមុនអង្គសេចក្តី និងសាលក្រមអង្គសេចក្តី។ ចំពោះសាលក្រមមុនអង្គសេចក្តី មានបែងចែកជាច្រើនប្រភេទជាក់ស្តែងទៅស្ថានភាព ឬហេតុការណ៍ដែលកើតមានឡើង។ ចំពោះសាលក្រមមុនអង្គសេចក្តី អាចបែងចែកជាច្រើនប្រភេទ ដូចជា៖ សាលក្រមមុនអង្គសេចក្តីអំពីសេរីភាពជនជាប់ចោទ,

សាលក្រមមុនអង្គសេចក្តីអំពីអញ្ញាត្រកម្ម សាលក្រមមុនអង្គសេចក្តីអំពីបញ្ចូលសំណុំរឿង និងសាលក្រមចាត់របៀប។ ទន្ទឹមនឹងនេះ សាលក្រមមុនអង្គសេចក្តី មានច្រើនប្រភេទជាក់ស្តែងទៅស្ថានភាព ឬហេតុការណ៍ដែលកើតមានឡើង ។ ចំពោះសាលក្រមអង្គសេចក្តី អាចបែងចែកជា ០៣ ប្រភេទ ដូចជា ៖ សាលក្រមចំពោះមុខ សាលក្រមដែលចាត់ទុកថាចំពោះមុខ និង សាលក្រមកំបាំងមុខ ។ ក្រៅពីនេះការបង្កើតនូវខ្លឹមសារសាលក្រម គឺជាភារកិច្ចចម្បងរបស់ចៅក្រមជំនុំជម្រះ ពីព្រោះខ្លឹមសារសាលក្រមបានកំណត់អំពីអត្ថិភាពនៃបទល្មើសព្រហ្មទណ្ឌណាមួយដែលច្បាប់បានចែង ព្រមទាំងផ្តល់ជាសំណងរដ្ឋប្បវេណីដល់ដើមបណ្តឹងរដ្ឋប្បវេណីទៅតាមពស្សនកម្មជាក់ស្តែងតាមការយល់ឃើញរបស់តុលាការ ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

តាមរយៈការសិក្សាកន្លងមក យើងបានសង្កេតឃើញថា សិស្សនិស្សិត ក៏ដូចជាមន្ត្រី និងប្រជាពលរដ្ឋមួយចំនួនតូចដែលចង់ស្វែងយល់ពីច្បាប់ពុំទាន់បានជ្រាបច្បាស់អំពី **សាលក្រមព្រហ្មទណ្ឌរបស់សាលាដំបូងរាជធានី-ខេត្ត** ដែលជាប្រធានបទនេះនៅឡើយទេ។ ដោយហេតុថាមានបុគ្គលមួយចំនួនពោលថា "**តុលាការជាទីគោរព បើលុយមិនគ្រប់ខ្ញុំកាត់ឲ្យចាញ់**! **តុលាការជាទីស្រលាញ់ ខ្ញុំត្រូវកាត់ក្តីឲ្យចាញ់ ព្រោះលុយមិនគ្រប់**!" ជាពាក្យចំអកលេងសើចលើប្រព័ន្ធយុត្តាធិការកម្ពុជា ដែលតាក់តែងឡើងពីបុគ្គលមួយចំនួនតូចដែលគ្មានទំនុកចិត្តចំពោះសេចក្តីសម្រេចតុលាការ និងប្រព័ន្ធស្វែងរកយុត្តិធម៌តែបែរជាចោទប្រកាន់លើតុលាការថាលំអៀង និងពុករលួយទៅវិញ។ តែបើយើងពិនិត្យមើលឱ្យស៊ីជម្រៅមិនថាក្នុងរឿងក្តីព្រហ្មទណ្ឌ ឬក្នុងរឿងក្តីរដ្ឋប្បវេណីឡើយ ពោលមនុស្សមួយចំនួនដែលស្រែកថាអយុត្តិធម៌ទាំងនោះសុទ្ធតែបុគ្គលដែលមិនគោរពច្បាប់ មិនដែលសិក្សាស្វែងយល់ពីច្បាប់ មិនដឹងខ្លួនថារូបខ្លួនមានកំហុសដោយបានប្រព្រឹត្តអំពើដែលផ្ទុយនឹងការកំណត់នៃច្បាប់ប្រទេសខ្លួនឡើយ ហើយនៅពេលដែលតុលាការបានការកាត់ក្តីដាក់ទោសខ្លួន ឬសម្រេចឱ្យខ្លួនចាញ់ក្តីនោះ ជនទាំងនោះក៏បែរជាស្រែកថា អយុត្តិធម៌ ដោយសារតែការមិនបានទទួលបានការកាត់ក្តីតាមអ្វីដែលចិត្តខ្លួនចង់បាន។ ដោយមើលឃើញពីបញ្ហាខាងលើនេះទើបជំរុញឱ្យយើងខ្ញុំមានបំណងធ្វើការស្រាវជ្រាវអំពី " **សាលក្រមព្រហ្មទណ្ឌរបស់សាលាដំបូងរាជធានី ~ ខេត្ត** " ថាតើសាលក្រមព្រហ្មទណ្ឌជាអ្វី? តើនរណាដែលមានសមត្ថកិច្ចក្នុងការចេញសាលក្រមព្រហ្មទណ្ឌនេះបាន? តើមុននឹងឈានដល់ការចេញសាលក្រមព្រហ្មទណ្ឌត្រូវឆ្លងកាត់ដំណើរការនីតិវិធីអ្វីខ្លះ? តើសាលក្រមបែងចែកជាប្រភេទអ្វីខ្លះ? តើទម្រង់នៃសាលក្រមព្រហ្មទណ្ឌមានលក្ខណៈបែបណា? តើការតាក់តែងសាលក្រមព្រហ្មទណ្ឌត្រូវធ្វើឡើងតាមរបៀបណា?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ចំពោះគោលបំណង ក៏ដូចជាហេតុផលក្នុងការតាក់តែង និងស្រាវជ្រាវប្រធានបទ "**សាលក្រមព្រហ្មទណ្ឌរបស់សាលាដំបូងរាជធានី~ខេត្ត**" នេះគឺយើងខ្ញុំចង់សិក្សាឱ្យច្បាស់អំពីសញ្ញាណទូទៅនៃសាលក្រមព្រហ្មទណ្ឌ និងលំហូរនីតិវិធីដែលនាំឱ្យមានការចេញសាលក្រមព្រហ្មទណ្ឌ។

ម្យ៉ាងទៀតនោះ គឺដើម្បីបង្កើនចំណេះដឹងអមជាមួយបទពិសោធន៍ខ្លះៗ ដើម្បីចងក្រងជាឯកសារមួយសម្រាប់ជាជំនួយស្មារតីទៅដល់អ្នកសិក្សាស្រាវជ្រាវ ឱ្យស្វែងយល់កាន់តែច្បាស់អំពីលក្ខខណ្ឌនៃការចេញសាលក្រមព្រហ្មទណ្ឌ ការបែងចែកប្រភេទសាលក្រមព្រហ្មទណ្ឌ និងទម្រង់នៃសាលក្រមព្រហ្មទណ្ឌ។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ជាការពិតណាស់ ដូចដែលបានដឹងរួចមកហើយថាយុត្តាធិការតុលាការគឺមានបីថ្នាក់ នៅក្នុងដែនកំណត់នៃកិច្ចស្រាវជ្រាវនេះ រួមទាំងបរិបទនៃប្រធានបទនៃការស្រាវជ្រាវនេះ គឺយើងខ្ញុំធ្វើការស្រាវជ្រាវត្រឹមតែ សាលក្រមព្រហ្មទណ្ឌរបស់សាលាដំបូងរាជធានី-ខេត្តតែប៉ុណ្ណោះ ដែលយើងខ្ញុំមិនមានការលើកឡើងអំពីបណ្ដឹងទាស់ និងបណ្ដឹងឧទ្ធរណ៍ចំពោះសាលក្រមនោះទេ ។

## ៥. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

តាមរយៈសារណានេះ ត្រូវបានរៀបចំឡើងដោយបានប្រើប្រាស់នូវ វិធីសាស្ត្របែបពិពណ៌នា ក៏ដូចជាវិភាគយ៉ាងស៊ីជម្រៅ។ ដោយយើងខ្ញុំបានធ្វើការសិក្សាស្រាវជ្រាវដោយផ្អែកលើក្រមនីតិវិធីព្រហ្មទណ្ឌ និងតាមរយៈការប្រមូលយកនូវព័ត៌មានទាំងឡាយ ក៏ដូចជាឯកសារច្បាប់ផ្សេងៗដែលមានជាប់ពាក់ព័ន្ធទៅនឹងប្រធានបទនៃសារណាខាងលើនេះដើម្បីឱ្យសារណាខាងលើនេះមានភាពត្រឹមត្រូវ ច្បាស់លាស់ និងមានប្រសិទ្ធភាពខ្ពស់។ អាស្រ័យហេតុនេះហើយ ព័ត៌មានទាំងឡាយដែលយើងខ្ញុំបានជ្រើសរើស និងដកស្រង់ គឺចេញពីប្រភពមួយដែលល្អៗច្បាស់លាស់ ដែលជាការបកស្រាយ និងសរសេរ ក៏ដូចជារៀបរៀងដោយ អ្នកដែលមានបទពិសោធន៍នៅក្នុងវិស័យនេះផ្ទាល់ រួមទាំងមតិយោបល់ពីអ្នកជំនាញការខាងនីតិវិធីព្រហ្មទណ្ឌ និងអត្ថបទច្បាប់សំខាន់ៗរបស់ព្រះរាជាណាចក្រកម្ពុជាបន្ថែមជាមួយនឹងឯកសារពាក់ព័ន្ធមួយចំនួនទៀតផងដែរ។

## ៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ជាកិច្ចបន្តទៀតនោះ ដើម្បីឱ្យយល់កាន់តែច្បាស់នៃប្រធានបទ « **សាលក្រមព្រហ្មទណ្ឌរបស់សាលាដំបូងរាជធានី ~ ខេត្ត** » នេះ យើងខ្ញុំសូមធ្វើការតាក់តែងរៀបចំខ្លឹមសារនៃសារណានេះ ដោយបែងចែកជា ២ (ពីរ) ជំពូកធំសំខាន់ៗដូចខាងក្រោម៖

- **ជំពូកទី១ ៖ សាលក្រមព្រហ្មទណ្ឌរបស់សាលាដំបូងរាជធានី-ខេត្ត**
- **ជំពូកទី២ ៖ ប្រភេទ និងទម្រង់សាលក្រមព្រហ្មទណ្ឌក្នុងលក្ខខណ្ឌាគតិយុត្តិ។**

# ជំពូកទី១

# សាលក្រមព្រហ្មទណ្ឌរបស់សាលាដំបូងរាជធានី-ខេត្ត

# ជំពូកទី១
# សាលក្រមព្រហ្មទណ្ឌរបស់សាលាដំបូងរាជធានី-ខេត្ត

## ផ្នែកទី១ ៖ មូលហេតុនាំឱ្យមានចេញសាលក្រមរបស់សាលាដំបូងរាជធានី-ខេត្ត

មូលហេតុចម្បងបំផុត ដែលនាំឱ្យមានការចេញសាលក្រមព្រហ្មទណ្ឌ គឺដើម្បីឱ្យរឿងក្តីព្រហ្មទណ្ឌមួយអាចបញ្ចប់បានតាមការសម្រេចសេចក្តីតាមរយៈសាលក្រមព្រហ្មទណ្ឌនេះ ដោយកំណត់ពីអត្ថិភាពនៃបទល្មើស និងដើម្បីឱ្យដឹងច្បាស់ថាជនណាម្នាក់មានទោស ឬគ្មានទោស ដើម្បីឈានទៅរកការអនុវត្តទណ្ឌកម្មដែលច្បាប់បានកំណត់។ សិទ្ធិនៃការសម្រេចសេចក្តីនេះ គឺជាអំណាចរបស់តុលាការ ដែលសិទ្ធិនៃការសម្រេចសេចក្តីរបស់តុលាការ មានអានុភាពគ្របដណ្តប់ទៅលើបុគ្គលគ្រប់រូបដែលស្ថិតក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ទោះបីជាបុគ្គលនោះជាតិសាសន៍អ្វីក៏ដោយ។ កាលចេញនូវសាលក្រមនេះ គឺជាការបង្ហាញពីសម្រេចសេចក្តីចុងក្រោយរបស់ចៅក្រមជំនុំជម្រះទៅលើជនជាប់ចោទដែលត្រូវបានចោទប្រកាន់ ពីអំពើណាមួយដែលជាបទល្មើសដោយបានធ្វើការបើកសវនាការជំនុំជម្រះស្វែងរកការពិត បន្ទាប់ពីគាត់ទទួលបានបណ្តឹងដែលបញ្ជូនមក។ តើសាលក្រមព្រហ្មទណ្ឌជាអ្វី? តើក្នុងលិខិតសាលក្រម ត្រូវមានអ្វីខ្លះ ហើយវាសម្រេចសេចក្តីលើអ្វីខ្លះ? មុននឹងឈានទៅដល់ដល់ការបកស្រាយលម្អិតនៃសាលក្រមព្រហ្មទណ្ឌ យើងនឹងសិក្សាស្វែងយល់ពី សញ្ញាណទូទៅនៃសាលក្រមព្រហ្មទណ្ឌ ព្រមទាំងអំពីស្ថាប័នដែលមានសមត្ថកិច្ចក្នុងការចេញសាលក្រមព្រហ្មទណ្ឌជាមុនសិន ។

### ១.១. សញ្ញាណទូទៅនៃសាលក្រមព្រហ្មទណ្ឌ

សាលក្រម គឺជាសេចក្តីសម្រេចរបស់តុលាការ ដែលត្រូវធ្វើឡើងជាលិខិតសាលក្រម និងមានលក្ខណៈគ្រប់គ្រាន់ស្របទៅតាមទម្រង់ ដែលច្បាប់បានកំណត់ដោយផ្អែកលើការពិភាក្សារដេញដោលហើយកើតមានអានុភាពភាពបាន បន្ទាប់ពីមានការប្រកាសដោយផ្អែកលើលិខិតនៃសាលក្រមនោះផ្ទាល់ ។

សាលក្រមព្រហ្មទណ្ឌ មានតែយុត្តាធិការជម្រះក្តីព្រហ្មទណ្ឌប៉ុណ្ណោះ ដែលមានសមត្ថកិច្ចក្នុងការចេញសាលក្រមព្រហ្មទណ្ឌនេះបាន។ ក្នុងរឿងក្តីព្រហ្មទណ្ឌសាលក្រមអាចត្រូវបានចេញបន្ទាប់ពីបានអនុវត្តតាមនីតិវិធីនៃច្បាប់ព្រហ្មទណ្ឌជាធរមាន។ ការជម្រះក្តី ផ្តល់យុត្តិធម៌ត្រូវធ្វើ ក្នុងនាមប្រជារាស្ត្រខ្មែរតាមនីតិវិធី និងច្បាប់ជាធរមាន ។ មានតែសាលាជម្រះក្តីប៉ុណ្ណោះទើបមានអំណាចកាត់សេចក្តី និងចេញសេចក្តីសម្រេចរបស់តុលាការបាន។ តុលាការត្រូវសម្រេចរឿងក្តីទាំងអស់នៅចំពោះមុខ ដោយមិនលំអៀង ជាពិសេសផ្អែកលើអង្គហេតុ និងអង្គច្បាប់ដោយមិនមានការដាក់កំហិត ការប្រើឥទ្ធិពលមិនត្រឹមត្រូវ ការជំរុញ ការគៀបសង្កត់ ការគំរាមកំហែង ឬការជ្រៀតជ្រែក ទោះដោយផ្ទាល់ ឬដោយប្រយោលពីមជ្ឈមណ្ឌលណាមួយ ឬដោយមូលហេតុណាមួយក៏ដោយ ។

បើតាមក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ដើម្បីធ្វើការជម្រះក្តីរឿងព្រហ្មទណ្ឌមួយដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងធានាបាននូវយុត្តិធម៌នោះត្រូវឆ្លងកាត់ដំណាក់កាលជាច្រើនដូចជា ការស៊ើបអង្កេត ការចោទប្រកាន់ ការស៊ើបសួរ និងដំណាក់កាលនៃការជំនុំជម្រះជាដើម។ ក្នុងន័យនេះគឺថាលំហូរនីតិវិធីនៃការចេញសាលក្រមមួយជាចាំបាច់ត្រូវឆ្លងកាត់នូវរាល់ដំណាក់កាលទាំងអស់នេះ។

ក្នុងនោះនីតិវិធីជំនុំជម្រះ គឺជាដំណាក់កាលសំខាន់មួយហើយជា ដំណាក់កាលដែលនាំទៅឱ្យមានការចេញសាលក្រម។ នេះជាដំណាក់កាលមួយដែលបញ្ជាក់អំពីលក្ខខណ្ឌក្នុងការចេញសាលក្រមរបស់តុលាការ។ ការជំនុំជម្រះក្តី ជាលក្ខខណ្ឌចាំបាច់ឱ្យនីតិព្រហ្មទណ្ឌសារធាតុអាចអនុវត្តបាន ព្រោះគេមិនអាចកំណត់ពីអត្ថិភាពនៃបទល្មើស និងផ្តន្ទាទោសជនល្មើសដោយមិនឆ្លងកាត់ការកាត់ក្តីបានឡើយ ។

សាលក្រមនេះទៀតសោតអាចជាការសម្រេចទៅលើបញ្ហានៃរឿងអង្គសេចក្តី បញ្ហានៃនីតិវិធី និងបញ្ហានៃការដកហូតសិទ្ធិសេរីភាពរបស់ជនជាប់ចោទ តាមរយៈការសម្រេចឃុំខ្លួនជាដើម ។

អាចនិយាយជាខ្លីថាសាលក្រម វាជាលទ្ធផលចុងក្រោយ នៃនីតិវិធីច្បាប់មួយ ដែលសាលក្រមត្រូវផ្តល់នូវដំណោះស្រាយទំនាស់មួយប្រកបដោយតុល្យភាព។

### ១.២. ស្ថាប័នដែលមានសមត្ថកិច្ចក្នុងការចេញសាលក្រម

សាលាជម្រះក្តី គឺជាតុលាការដែលទទួលបន្ទុកក្នុងការជម្រះក្តីលើសំណុំរឿងដែលបុគ្គលណាមួយបានប្រព្រឹត្តខុសនឹងច្បាប់ជាធរមាន ឬមានការមិនសុខចិត្តនឹងអ្វីមួយដោយទាមទារឱ្យមានការដោះស្រាយតាមផ្លូវច្បាប់។ យោងទៅតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ក៏បានចែងដែលថា អំណាចក្នុងការជម្រះក្តី ត្រូវប្រគល់ឱ្យតុលាការកំពូល និងសាលាជម្រះក្តីគ្រប់ផ្នែក[1]។ នៅកម្ពុជា សាលាជម្រះក្តី ត្រូវបានបែងចែកជា ៣ (បី) រួមមាន៖ សាលាដំបូង, សាលាឧទ្ធរណ៍ និងតុលាការកំពូល[2]។ ប៉ុន្តែមានតែសាលាដំបូងរាជធានី - ខេត្តប៉ុណ្ណោះ ដែលមានសិទ្ធអំណាច ក្នុងការចេញសាលក្រមបាន ដោយសាលាឧទ្ធរណ៍និងតុលាការកំពូល មានសមត្ថកិច្ចក្នុងការចេញសាលដីកា ដែលសម្រេចក្តីចំពោះការប្តឹងឧទ្ធរណ៍ និងប្តឹងសើរើ លើសេចក្តីសម្រេចរបស់សាលាដំបូងរបស់ភាគីក្នុងសំណុំរឿងនោះ ។

នៅពេលដែលមានបទល្មើស ឬវិវាទមួយកើតឡើង គឺត្រូវដោះស្រាយដោយតុលាការរបស់រដ្ឋ ដោយគេត្រូវកំណត់អំពីតុលាការណាដែលមានសមត្ថកិច្ច។ ប្រទេសកម្ពុជាមានដែនដីធំទូលាយ ហើយចំនួនប្រជាជនក៏មានបរិមាណច្រើនទៅតាមនោះ ហើយបទល្មើស និងវិវាទដែលកើតឡើងក៏មានច្រើនតាមនោះដែរ ដូច្នេះយើងមិនអាច

[1] មាត្រា ១២៨ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

[2] មាត្រា ៣ និងមាត្រា ៤ នៃច្បាប់ស្តីពីការរៀបចំតុលាការ

មានតែតុលាការជាន់ទាបតែមួយ ក្នុងការដោះស្រាយបញ្ហាទាំងនោះបានទាន់ពេលវេលា នោះឡើយ ដូច្នេះទើបយើងឃើញថា មានការបង្កើតសាលាដំបូងជាច្រើនតាមភូមិសាស្ត្រនៃប្រទេស ដើម្បីភាពងាយស្រួលដល់ប្រជាពលរដ្ឋ និងការអនុវត្តរបស់មន្ត្រីរាជការផងដែរ។ បច្ចុប្បន្ននេះបន្ទាប់ពីបង្កើតសាលដំបូងខេត្តកែបមក ប្រទេសកម្ពុជា មានសាលាដំបូងចំនួន ២៥ ដែលសាលាដំបូងនីមួយៗ មានសមត្ថកិច្ចលាតសន្ធឹងលើដែនដីខេត្ត ឬក្រុងទាំងមូលរបស់ខ្លួន ។

ចំពោះក្នុងការចេញសាលក្រមព្រហ្មទណ្ឌ ស្ថាប័នដែលមានសមត្ថកិច្ច គឺមានតែសាលាដំបូងរាជធានី-ខេត្ត និងតុលាការយោធាប៉ុណ្ណោះ ទើបអាចចេញសាលក្រមព្រហ្មទណ្ឌបាន។ អ្វីដែលពិសេស ច្បាប់កម្ពុជាក៏បានចែងថា អំណាចតុលាការគ្របដណ្តប់ទៅលើរឿងក្តីទាំងអស់រួមទាំងរឿងក្តីរដ្ឋបាលផងដែរ[3]។ មានន័យថាតុលាការនៅកម្ពុជា មានសមត្ថកិច្ចជំនុំជម្រះវិវាទព្រហ្មទណ្ឌ វិវាទរដ្ឋប្បវេណី វិវាទពាណិជ្ជកម្ម វិវាទការងារ និងវិវាទរដ្ឋបាល។ តាមការជាក់ស្តែង តុលាការក្រុង ឬតុលាការខេត្ត មានពីរផ្នែក គឺផ្នែកព្រហ្មទណ្ឌ និងផ្នែករដ្ឋប្បវេណី ដែលផ្នែកព្រហ្មទណ្ឌ គឺជំនុំជម្រះលើបទល្មើសព្រហ្មទណ្ឌ និងការចេញសាលក្រមព្រហ្មទណ្ឌនេះ។ ចំណែកតុលាការយោធាមានតែមួយគត់ ដែលមានទីតាំងនៅក្នុងរាជធានីភ្នំពេញ ជាតុលាការដែលមានសមត្ថកិច្ចជំនុំជម្រះទៅលើតែបទល្មើសយោធា និងបទល្មើសណាមួយដែលប៉ះពាល់ដល់ទ្រព្យសម្បត្តិកងទ័ពតែប៉ុណ្ណោះ[4] ។

សាលាដំបូងរាជធានីខេត្ត មានសមត្ថកិច្ចជំនុំជម្រះលើរឿងក្តី ដែលស្ថិតនៅក្រោមសមត្ថកិច្ចដែនដីរបស់ខ្លួន លើកលែងតែរឿងក្តីទាំងឡាយណា ដែលច្បាប់ប្រគល់សមត្ថកិច្ចទៅឱ្យសាលាជម្រះក្តីផ្សេងទៀត ។

ក្នុងករណីចាំបាច់ ដើម្បីធានាប្រយោជន៍សាធារណៈ សុវត្ថិភាព សន្តិសុខសង្គមនិងដំណើរការល្អនៃយុត្តិធម៌ អាចសម្រេចផ្ទេរសមត្ថកិច្ចក្នុងការចាត់ការរឿងក្តីពីសាលាដំបូងមួយ ទៅសាលាដំបូងមួយទៀត។

តុលាការព្រហ្មទណ្ឌនៃសាលាដំបូងជំនុំជម្រះរឿងក្តីទាំងឡាយដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនដោយអនុវត្តតាមបទបញ្ញត្តិស្តីពីនីតិវិធីព្រហ្មទណ្ឌ លើកលែងតែមានបញ្ញត្តិច្បាប់ចែងផ្សេងពីនេះ។ ដូចនេះដើម្បីឱ្យចៅក្រមនៃតុលាការមួយ អាចធ្វើការជំនុំជម្រះទៅលើរឿងក្តីណាមួយ ច្បាប់តម្រូវឱ្យតុលាការនោះដាច់ខាតត្រូវតែជាតុលាការដែលមានសមត្ថកិច្ច។ ការកំណត់អំពីសមត្ថកិច្ចរបស់តុលាការមានដូចតទៅ ៖

- **តុលាការតាមសមត្ថកិច្ចដែនដី** ៖ ការកំណត់សមត្ថកិច្ចដែនដី ត្រូវធ្វើឡើងដោយផ្អែកទៅលើទីតាំងដែលបទល្មើសកើតមានឡើង និងកន្លែងរបស់ជនជាប់ចោទស្ថិតនៅ ហើយត្រូវបានបែងចែកជា ៣ គឺ [5]៖

[3] មាត្រា ១២៨ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

[4] មាត្រា ៩ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តី ឆ្នាំ១៩៩៣

[5] មាត្រា ២៩០ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ២០០៧

- តុលាការទីកន្លែងបទល្មើស
- តុលាការនាលំនៅឋានរបស់ជនជាប់ចោទ ឬ
- តុលាការនាទីកន្លែងចាប់ខ្លួនជនជាប់ចោទ ។

ប្រសិនបើតុលាការដែលបានទទួលពាក្យបណ្ដឹង យល់ឃើញថាពុំមានសមត្ថកិច្ចតាមដែនដីតុលាការនេះប្រកាសថាពុំមានសមត្ថកិច្ចដោយសាលក្រម និងបង្គាប់ឱ្យបង្វិលសំណុំរឿងជូនព្រះរាជអាជ្ញាដើម្បីឱ្យព្រះរាជអាជ្ញាបញ្ជូនសំណុំរឿងនេះជូនតុលាការ ដែលមានសមត្ថកិច្ចតាមដែនដី។ ជាយថាហេតុ តុលាការនេះសម្រេចលើការបន្តដាក់ជនជាប់ចោទឱ្យស្ថិតនៅក្នុងការឃុំខ្លួន ឬការត្រួតពិនិត្យតាមផ្លូវតុលាការ ។

ក្នុងករណីដែលមានតុលាការពីរ ឬច្រើនស្ថិតនៅក្នុងមណ្ឌលនៃសាលាឧទ្ធរណ៍តែមួយបានទទួលពាក្យបណ្ដឹងលើរឿងក្ដីតែមួយដូចគ្នា ប្រធានសាលាឧទ្ធរណ៍ចាត់តាំងតុលាការ ដែលនឹងត្រូវទទួលបន្ទុកលើសំណុំរឿងវិវាទសមត្ថកិច្ចដែនដីរវាងតុលាការច្រើនដែលមានថ្នាក់ស្មើគ្នាត្រូវសម្រេចដោយប្រធានតុលាការជាន់ខ្ពស់។ ការសម្រេចនេះបិទផ្លូវតវ៉ា ។

- **សមត្ថកិច្ចតាមរឿងក្ដី ៖** ដោយផ្អែកតាមទស្សនៈនៃច្បាប់ព្រហ្មទណ្ឌ បទល្មើសត្រូវបានបែងចែកជាបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ[6] ។ ហើយការបែងចែកនេះត្រូវផ្អែកទាំងស្រុងទៅលើទោសនៃបទល្មើស ពោលគឺបទល្មើសណាដែលត្រូវផ្ដន្ទាទោសឧក្រិដ្ឋនោះ ត្រូវចាត់ទុកជាបទឧក្រិដ្ឋ បទល្មើសណាដែលត្រូវផ្ដន្ទាទោសមជ្ឈិមនោះត្រូវចាត់ទុកជាបទមជ្ឈិម និងបទល្មើសណាដែលត្រូវផ្ដន្ទាទោសជាបទលហុនោះត្រូវចាត់ទុកជាបទលហុ។

ដោយផ្អែកលើក្រមនីតិវិធីព្រហ្មទណ្ឌ សមាសភាពតុលាការត្រូវប្រែប្រួល ទៅតាមប្រភេទនៃបទល្មើសទាំងនេះ។ នៅក្នុងការជំនុំជម្រះបទល្មើសព្រហ្មទណ្ឌ សាលាដំបូងសម្រេចជាក្រុមសមូហភាព ដែលក្រុមប្រឹក្សានេះ មានចៅក្រមចំនួន ០៣ រូប ចំពោះបទឧក្រិដ្ឋ ព្រមទាំងបទមជ្ឈិម និងបទលហុដែលជាប់ទាក់ទង។ កាលណាបើជាការជំនុំជម្រះលើបទល្មើសមជ្ឈិម និងបទលហុ សាលាដំបូងសម្រេចសេចក្ដីដោយចៅក្រមទោល គឺចំនួន ០១ រូប ។

ជាគោលការណ៍ ចៅក្រមណាដែលបានបំពេញមុខងារក្នុងឋានៈជាព្រះរាជអាជ្ញា ជាព្រះរាជអាជ្ញារង ឬជាចៅក្រមស៊ើបសួរ លើរឿងណាមួយ មិនអាចចូលរួមក្នុងការជំនុំជម្រះក្ដីរឿងនោះបានទេ បើពុំដូច្នេះសាលក្រមនឹងទុកជាមោឃៈ ដែលបញ្ជាក់បានថា អំពីវិសមិតភាពរវាងមុខងារទាំងនេះយ៉ាងច្បាស់ ហើយមូលហេតុដែលនាំឱ្យមានគោលការណ៍វិសមិតភាពនេះផងដែរគឺក្នុងគោលដៅដើម្បីធានាការស្វែងរកការពិតមួយ ឱ្យកាន់តែមានភាពសុក្រឹត្យ

[6] មាត្រា ២៨៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ២០០៧

ព្រោះកាលណានៅពេលដែលចៅក្រមស៊ើបសួរណាម្នាក់ គាត់បានធ្វើការស៊ើបសួរសព្វគ្រប់រួច ដោយគាត់នឹងធ្វើការបញ្ចប់ការស៊ើបសួររបស់គាត់ដោយគិតថាជនត្រូវចោទនោះមានពិរុទ្ធភាព ហើយជននោះនឹងត្រូវបញ្ជូនទៅដំណាក់កាលជំនុំជម្រះ។ ការបើកសវនាការជំនុំជម្រះ មានគោលដៅធំមួយទៀត គឺដើម្បីពិភាក្សាដេញដោល ដើម្បីឈ្លេចឱ្យរកឃើញការពិតកាន់តែច្បាស់ តែប្រសិនបើក្នុងដំណាក់កាលនេះ មិនមានការបែងចែកមុខងារនេះទេ ហើយចៅក្រមដែលធ្វើការស៊ើបសួរលើសំណុំរឿងនេះ គាត់នឹងត្រូវកាត់សេចក្តីថាជនជាប់ចោទនោះមានពិរុទ្ធភាព ឬគ្មានពិរុទ្ធភាពនោះប្រាកដណាស់ ចៅក្រមនោះនឹងសម្រេចថាជនជាប់ចោទមានពិរុទ្ធភាពជាក់ជាពុំខាន ដោយសារការវិនិច្ឆ័យរបស់គាត់ផ្អែកតាមការរកឃើញរបស់គាត់ពីមុនមក ។

ក្នុងរឿងព្រហ្មទណ្ឌ ចំណុចដែលចាំបាច់បំផុតនោះក្នុងការសម្រេចសាលក្រមបាន លុះត្រាតែចៅក្រមជំនុំជម្រះបានទទួលបានបណ្តឹង ដែលបានបញ្ជូនមកជាមុនសិន ដើម្បីមានសិទ្ធិបើកការជំនុំជម្រះសម្រេចសេចក្តីលើសំណុំរឿងនោះ បណ្តឹងអាចទទួលដោយៈ

- ដីកាបញ្ជូនរបស់ចៅក្រមស៊ើបសួរ ឬសាលដីកាបញ្ជូនរបស់សភាស៊ើបសួរ
- ដីកាបញ្ជូនទៅជំនុំជម្រះដោយផ្ទាល់របស់ព្រះរាជអាជ្ញា
- កំណត់ហេតុស្តីពីការចូលបង្ហាញខ្លួនភ្លាម ។

## ផ្នែកទី២ ៖ ដំណើរការឆ្លងកាត់នីតិវិធីដែលនាំឱ្យមានចេញសាលក្រមព្រហ្មទណ្ឌ

ក្នុងរឿងក្តីព្រហ្មទណ្ឌ ដើម្បីកំណត់បានថា ជនណាម្នាក់មានទោស ឬ មិនមានទោស គឺអាស្រ័យលើសេចក្តីសម្រេចចុងក្រោយរបស់សាលាជម្រះក្តីនីមួយៗ ដោយត្រូវឆ្លងកាត់នីតិវិធីសវនាការ ដែលក្នុងន័យច្បាប់ត្រូវបានហៅថា "សាលក្រម" ។

គោលការណ៍នៃ ការស្រាវជ្រាវបទល្មើសព្រហ្មទណ្ឌ ជាគោលការណ៍មាននៅក្នុង ក្រមនីតិវិធីព្រហ្មទណ្ឌដែលមាននាពេលបច្ចុប្បន្ន កាលណាដែលមានបទល្មើសបានកើតឡើង តំណាងអយ្យការតែងតែបើកការស៊ើបសួរ មកចៅក្រមស៊ើបសួរ ដើម្បីធ្វើការស្រាវជ្រាវបទល្មើសព្រហ្មទណ្ឌ ឱ្យមានលក្ខណៈមូលពេញលេញសិន មុននឹងបញ្ជូនសំណុំរឿងទៅជំនុំជម្រះ ក្នុងករណី ដែលជាសំណុំរឿងមានភាពស្មុគស្មាញ និងមិនមានភស្តុតាងដាក់បន្ទុកលើជនសង្ស័យគ្រប់គ្រាន់ ឬអាចជាបទល្មើសឧក្រិដ្ឋដែលច្បាប់តម្រូវ។ ដើម្បីអាចឱ្យការស្រាវជ្រាវ បទល្មើសព្រហ្មទណ្ឌមួយមាន ភាពច្បាស់លាស់ ត្រូវជៀសវាងនូវភាពអគតិទាំងបួន។ ដូច្នេះរឿងក្តីព្រហ្មទណ្ឌ ឬក៏នីតិវិធីព្រហ្មទណ្ឌត្រូវបានរៀបចំដើម្បីធានាតុល្យភាពរវាងប្រសិទ្ធភាពនៃការបង្ក្រាបហើយនិងការការពារសិទ្ធសេរីភាពរបស់ជនពាក់ព័ន្ធ ។

ដំណើរការរឿងក្តីព្រហ្មទណ្ឌ យើងអាចចែកជាបួនដំណាក់កាល ទៅតាមលំដាប់លំដោយដូចតទៅ ៖ (២.១) ដំណាក់កាលស៊ើបអង្កេត (២.២) ដំណាក់កាលចោទប្រកាន់ (២.៣) ដំណាក់កាលស៊ើបសួរ និង(២.៤) ដំណាក់កាលជំនុំជម្រះ ។

## ២.១. ដំណាក់កាលស៊ើបអង្កេត

ដំណាក់កាលនៃការស៊ើបអង្កេត គឺជាការស៊ើបអង្កេតត្រួតពិនិត្យបទល្មើស ព្រមទាំងប្រមូលភស្តុតាង ដែលធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌។ នៅដំណាក់កាលនេះ មន្ត្រីនគរបាលយុត្តិធម៌ជាសេនាធិការ និងស្ថិតនៅក្រោមការសម្របសម្រួល របស់ព្រះរាជអាជ្ញាមានសមត្ថកិច្ច ។ តួនាទីចម្បងរបស់មន្ត្រីនគរបាលយុត្តិធម៌នៅដំណាក់កាលស៊ើបអង្កេត យើងអាចបែងចែកជា ២ ប្រភេទ៖ (២.១.១) នៅក្នុងការពិនិត្យស្វែងរកបទល្មើស និង (២.១.២) នៅក្នុងការស៊ើបអង្កេតស្វែងរកភស្តុតាង។

### ២.១.១. នៅក្នុងការពិនិត្យស្វែងរកបទល្មើស

មន្ត្រីនគរបាលយុត្តិធម៌មានតួនាទីដោយស្វ័យប្រវត្តក្នុងការពិនិត្យស្វែងរកបទល្មើសដោយខ្លួនឯង ដែលមិនចាំបាច់រង់ចាំមានពាក្យបណ្តឹងពីប្រជាពលរដ្ឋ ទើបខ្លួនមានសមត្ថកិច្ចត្រួតពិនិត្យនោះទេ។ ដូចយើងបានដឹងហើយថា មន្ត្រីនគរបាលយុត្តិធម៌ ជាអ្នកបម្រើសេវាយុត្តិធម៌ផ្ទាល់ដល់ប្រជាពលរដ្ឋ មន្ត្រីរាជការទាំងអស់ត្រូវតែបម្រើសេវាសាធារណៈដល់ប្រជាពលរដ្ឋឱ្យបានឆាប់រហ័សដល់ទីកន្លែង និងមិនត្រូវរង់ចាំប្រជាពលរដ្ឋមកដល់ការិយាល័យនោះទេ។ ប៉ុន្តែមិនមែនមានន័យថា មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែដឹងគ្រប់រឿងហេតុនោះទេ។ ហេតុនេះហើយបានជាមន្ត្រីនគរបាលយុត្តិធម៌អាចត្រួតពិនិត្យស្វែងរកបទល្មើសតាមរយៈពាក្យបណ្តឹងបានផងដែរ។ ពាក្យបណ្តឹង មិនតម្រូវឱ្យធ្វើឡើងក្រោមទម្រង់ណាមួយជាដាច់ខាតនោះទេ គ្រាន់តែធ្វើយ៉ាងណាឱ្យមន្ត្រីនគរបាលយុត្តិធម៌បានដឹងអំពីហេតុការណ៍នោះតាមរយៈទម្រង់ជាលាយលក្ខណ៍អក្សរ ឬទម្រង់ផ្ទាល់មាត់គឺគ្រប់គ្រាន់។ បន្ទាប់ពីមន្ត្រីនគរបាលយុត្តិធម៌បានដឹងអំពីហេតុការណ៍តាមរយៈមធ្យោបាយដោយខ្លួនផ្ទាល់ក្តី ឬតាមរយៈពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋក្តី មន្ត្រីនគរបាលយុត្តិធម៌ត្រូវមានតួនាទីក្នុងការស៊ើបអង្កេតស្វែងរកភស្តុតាងជាបន្ត។

### ២.១.២. នៅក្នុងការស៊ើបអង្កេតស្វែងរកភស្តុតាង

បន្ទាប់ពីមន្ត្រីនគរបាលយុត្តិធម៌បានដឹងអំពីហេតុការណ៍នោះរួចមក ជាបឋមត្រូវវាយតម្លៃអំពីប្រភេទនៃបទល្មើសជាមុនសិនថាជាបទល្មើសជាក់ស្តែង ឬមិនមែនជាបទល្មើសជាក់ស្តែង ហើយតួនាទីរបស់មន្ត្រីនគរបាលយុត្តិធម៌អាស្រ័យលើប្រភេទនៃបទល្មើសទាំងពីរនេះ។

ការស៊ើបអង្កេតមន្ត្រីនគរបាលយុត្តិធម៌មានតួនាទីចុះទៅកន្លែងកើតហេតុ ឬស្វែងរកស្រាវជ្រាវកំណត់អត្តសញ្ញាណជនល្មើស ឬធ្វើការឆែកឆេរពីកន្លែងប្រព្រឹត្តបទល្មើស។ មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរត្រូវគោរពនីត្យានុកូលនៃការឆែកឆេរដោយយោងទៅតាមប្រភេទនៃបទល្មើស ឬធ្វើការឃាត់ខ្លួនជនល្មើស និងរាល់បុគ្គលដែលបានដឹងហេតុការណ៍ដោយរឹងទទឹងមិនព្រមធ្វើជាសាក្សី ឬធ្វើការឃាត់ខ្លួនរាល់បុគ្គលដែលមានតម្រុយបានប្រព្រឹត្តបទល្មើសទៅការិយាល័យនគរបាលយុត្តិធម៌ ដើម្បីធ្វើកំណត់ហេតុក្នុងការស្តាប់ចម្លើយនិងបញ្ជូនជននោះទៅអយ្យការដើម្បីឱ្យព្រះរាជអាជ្ញាធ្វើចំណាត់ការបន្ត ។

តាមគោលការណ៍ មន្ត្រីនគរបាលយុត្តិធម៌ មិនអាចតម្កល់រឿងព្រហ្មទណ្ឌណាមួយទុកឥតចាត់ការបានទេ ទោះបីជាក្រោយពីមានការសម្រុះសម្រួលគ្នារវាងជនល្មើស និងជនរងគ្រោះ ឬក៏មានការដកពាក្យប្តឹងក៏ដោយ[7]។ ប៉ុន្តែតាមការអនុវត្តជាក់ស្តែងមន្ត្រីនគរបាលយុត្តិធម៌ ក៏អាចសុំយោបល់ពីព្រះរាជអាជ្ញាដែរ ចំពោះករណីដែលគាត់សុំឱ្យសម្របសម្រួល ត្រូវតែបញ្ជូនសំណុំរឿងមកកាន់អយ្យការ ដើម្បីឱ្យព្រះរាជអាជ្ញាពិនិត្យមើលអង្គហេតុ។ ប្រសិនបើព្រះរាជអាជ្ញាយល់ព្រមចំពោះការសម្របសម្រួលនៅក្នុងដំណាក់កាលនេះ សំណុំរឿងនិងត្រូវបញ្ចប់នៅក្នុងដំណាក់កាលនេះ នឹងមិននាំឱ្យមានការចេញសាលក្រមនោះទេ។ ដំណើរការដែលអាចចេញសាលក្រមបាន គឺក្នុងករណីព្រះរាជអាជ្ញា ទទួលបានសំណុំរឿងរួចហើយ គាត់ក៏បានពិនិត្យមើលអង្គហេតុនិងអង្គច្បាប់ចប់សព្វគ្រប់ហើយ គាត់យល់ឃើញថា មានភស្តុតាងគ្រប់គ្រាន់សម្រាប់ធ្វើការចោទប្រកាន់ ព្រះរាជអាជ្ញាក៏សម្រេចធ្វើការចោទប្រកាន់ និងបញ្ជូនសំណុំរឿងទៅចៅក្រមស៊ើបសួរ។

## ២.២. ដំណាក់កាលចោទប្រកាន់

ប្រព័ន្ធនៃការចោទប្រកាន់នៅប្រទេសកម្ពុជា ប្រកាន់យករបបកាលានុវត្តភាពដែលមានន័យថាអយ្យការគឺជានិយ័តករនៃសង្គមដែលជាអ្នកថ្លឹងថ្លែងថាសំណុំរឿងណាគួរចោទប្រកាន់ ឬមិនគួរចោទប្រកាន់។ ការអនុវត្តគោលការណ៍កាលានុវត្តភាពនេះ ព្រះរាជអាជ្ញាអាចសម្រេចតម្កល់រឿងទុកឥតចាត់ការ ឬធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ[8]។ ប៉ុន្តែនៅក្នុងចំណុចនេះគឺយើងលើកយកតែការចោទប្រកាន់មកបង្ហាញតែប៉ុណ្ណោះ ព្រោះការចោទប្រកាន់ទើបជាដំណើរការដែលនាំឱ្យមានចេញសាលក្រមព្រហ្មទណ្ឌ។

[7] មាត្រា ៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧

[8] មាត្រា ៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧

ការចោទប្រកាន់ សំដៅដល់ការកំណត់អំពីអត្ថិភាពនៃបទល្មើសដោយស្ថាប័នអយ្យការដែលជាស្ថាប័នមានសមត្ថកិច្ចក្នុងការកំណត់ថាអំពើណាមួយជាបទល្មើស ហើយធ្វើការចោទប្រកាន់ និងសុំឱ្យយុត្តាធិការស៊ើបសួរ និងយុត្តាធិការជម្រះធ្វើចំណាត់ការបន្ត[9]។

ព្រះរាជអាជ្ញាទទួលពាក្យប្តឹង និងពាក្យបរិហារផ្សេងៗទាក់ទងនឹងបទល្មើសព្រហ្មទណ្ឌដោយផ្ទាល់ពីភាគីជនរងគ្រោះ និងបុគ្គលផ្សេងៗទៀត ឬដោយការបញ្ជូនរបស់មន្ត្រីនគរបាលយុត្តិធម៌[10]។ ពេលខ្លះក្រមនីតិវិធីព្រហ្មទណ្ឌកំណត់ជាកាតព្វកិច្ចសម្រាប់អាជ្ញាធរសាធារណៈ និងមន្ត្រីសាធារណៈផ្សេងទៀតក្នុងការផ្តល់ព័ត៌មានទាក់ទងនឹងបទល្មើសព្រហ្មទណ្ឌដល់ស្ថាប័នអយ្យការ។ ព្រះរាជអាជ្ញាថ្លឹងថ្លែងអំពីចំណាត់ការលើពាក្យប្តឹង និងពាក្យបរិហារដែលខ្លួនបានទទួល ដោយផ្ទាល់ ឬដែលមន្ត្រីនគរបាលយុត្តិធម៌បញ្ជូនមក។

ការចោទប្រកាន់ខាងបទព្រហ្មទណ្ឌអាចធ្វើតាមនីតិវិធី ៣ យ៉ាងគឺ ( ២.២.១) ការបើកការស៊ើបសួរ ( ២.២.២ ) ការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ( ២.២.៣ ) ការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម។

### ២.២.១. ការបើកការស៊ើបសួរ

ការបើកការស៊ើបសួរ គឺជាប្រភេទមួយនៃការចោទប្រកាន់របស់តំណាងអយ្យការ។ ការចោទប្រកាន់តាមរយៈការបើកការស៊ើបសួរធ្វើឡើងដើម្បីសុំឱ្យយុត្តាធិកាធិការស៊ើបសួរអនុវត្តច្បាប់ ពោលគឺដើម្បីឱ្យចៅក្រមស៊ើបសួរធ្វើចំណាត់ការបន្ត។ ការចោទប្រកាន់តាមនីតិវិធីនេះ គឺធ្វើឡើងក្នុងគោលបំណងដើម្បីឱ្យចៅក្រមស៊ើបសួរធ្វើការស្រាវជ្រាវបន្ថែម ព្រោះសំណុំរឿងពុំទាន់មានលក្ខណៈអាចបញ្ជូនទៅជំនុំជម្រះបាន។ តំណាងអយ្យការ អាចចោទប្រកាន់តាមការបើកការស៊ើបសួរដោយត្រូវគោរពតាមលក្ខខណ្ឌ ២ គឺ៖

- **សំណុំរឿងដែលត្រូវបើកការស៊ើបសួរ** ៖ ក្នុងករណីបទល្មើសដែលនឹងត្រូវចោទប្រកាន់ ជាបទឧក្រិដ្ឋ ព្រះរាជអាជ្ញាត្រូវតែបើកការស៊ើបសួរ[11]។

- **សំណុំរឿងដែលអាចប្តឹងទៅចៅក្រមស៊ើបសួរ** ៖ ក្នុងករណីដែលបទល្មើសដែលនឹងត្រូវចោទប្រកាន់ ជាបទមជ្ឈិម ព្រះរាជអាជ្ញាអាចបើកការស៊ើបសួរដោយប្តឹងទៅចៅក្រមស៊ើបសួរ ឬមួយបញ្ជូនសំណុំរឿងទៅតុលាការជំនុំជម្រះ។ ជាទូទៅព្រះរាជអាជ្ញាសម្រេចធ្វើការចោទប្រកាន់តាមរយៈការបើកការស៊ើបសួរ នៅក្នុងករណី ដូចជា ៖ អត្តសញ្ញាណរបស់ជនត្រូវជាប់ចោទ មិនត្រូវបានស្គាល់ (ដែលជាហេតុមិនអាចបញ្ជូនទៅតុលាការដើម្បីជំនុំជម្រះ

[9] មាត្រា ៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧

[10] មាត្រា ៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧

[11] មាត្រា ៤៤ និងមាត្រា ១២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧

ដោយផ្ទាល់បាន) ភស្តុតាងដែលប្រមូលបានពុំគ្រប់គ្រាន់ (ហើយការស៊ើបអង្កេតបឋមមិនអនុញ្ញាតឱ្យទទួលភស្តុតាងទាំងនេះបានទេ) ក្នុងករណីដែលបទល្មើសមជ្ឈិមដែលត្រូវចោទប្រកាន់នោះ មានលក្ខណៈស្មុគស្មាញសាំញុំ ដែលទាមទារឱ្យមានការស្រាវជ្រាវយូរ និងពិបាកក្នុងការស្វែងរកភស្តុតាង។ គួរកត់សម្គាល់ផងដែរថា ចំពោះបទមជ្ឈិម ទោះជាបានបំពេញលក្ខខណ្ឌច្បាប់ ដើម្បីធ្វើការចោទប្រកាន់តាមនីតិវិធីនៃការបង្ហាញខ្លួនភ្លាម ឬការកោះហៅបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ក៏ដោយ ក៏ព្រះរាជអាជ្ញានៅតែអាចសម្រេច បើកការស៊ើបសួរដដែលប្រសិនបើព្រះរាជអាជ្ញាយល់ឃើញថាចាំបាច់[12]។

### ២.២.២. ការបញ្ជូនទៅជំនុំជម្រះផ្ទាល់

ការចោទប្រកាន់តាមរយៈការបញ្ជូនទៅជំនុំជម្រះផ្ទាល់ធ្វើឡើងដោយពុំឆ្លងកាត់ការស៊ើបសួរទេ គឺបញ្ជូនរឿងទៅចៅក្រមជំនុំជម្រះដើម្បីធ្វើការជំនុំជម្រះតែម្តង។

ការចោទប្រកាន់តាមនីតិវិធីនេះអាចធ្វើបានក្នុងករណីបទមជ្ឈិម និងបទលហុ ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញថា សំណុំរឿងមានលក្ខណៈល្មមគ្រប់គ្រាន់ដើម្បីតុលាការអាចជំនុំជម្រះបាន ដោយពុំចាំបាច់មានការស្រាវជ្រាវបន្ថែមទៀត[13]។

### ២.២.៣. ការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម

ការចោទប្រកាន់តាមរយៈការធ្វើកំណត់ហេតុស្តីពីការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម ធ្វើឡើងដោយពុំឆ្លងកាត់ការស៊ើបសួរទេ គឺបញ្ជូនសំណុំរឿង និងជនជាប់ចោទ ទៅចៅក្រមជំនុំជម្រះដើម្បីធ្វើការជំនុំជម្រះ នៅថ្ងៃដែលជនជាប់ចោទចូលមកបង្ហាញខ្លួននៅចំពោះមុខតំណាងអយ្យការតែម្តង។

ការចោទប្រកាន់តាមនីតិវិធីនេះអាចធ្វើបាន ប្រសិនបើមានគ្រប់លក្ខខណ្ឌដូចតទៅ៖

- បទល្មើសជាបទល្មើសជាក់ស្តែង
- ជនជាប់ចោទជានីតិជន
- បទល្មើសត្រូវផ្តន្ទាទោសដាក់ពន្ធនាគារយ៉ាងតិច ១ឆ្នាំ និងយ៉ាងច្រើន ៥ឆ្នាំ
- រឿងក្តីមានលក្ខណៈគ្រប់គ្រាន់ល្មមជំនុំជម្រះបាន[14]។

---

[12] មាត្រា ៤៥ ដល់មាត្រា ៤៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧

[13] មាត្រា ៤៥ និងមាត្រា ៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧

[14] មាត្រា ៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧

## ២.៣. ដំណាក់កាលស៊ើបសួរ

ដំណាក់កាលចៅក្រមស៊ើបសួរ ជាយុត្តាធិការមួយដែលនៅចន្លោះកណ្តាល រវាងអយ្យការក្នុង ការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌ និងជាយុត្តាធិការជំនុំជម្រះ។ ចៅក្រមស៊ើបសួរប្រៀបដូចជាយុត្តាធិការចោទប្រកាន់ផង និងយុត្តាធិការជំនុំជម្រះផងដែរ ដោយសារតែនៅពេលដែលព្រះរាជអាជ្ញាដែលជាម្ចាស់បណ្តឹងអាជ្ញាបានបើកការស៊ើបសួរ មកកាន់ចៅក្រមស៊ើបសួរតាមរយៈដីកាសន្និដ្ឋានបញ្ជូនសំណុំរឿងឱ្យស៊ើបសួរនោះសិទ្ធិអំណាចទាំងស្រុងទៅលើការវិនិច្ឆ័យសម្រេចក្តីតាមរយៈ ដីកាដំណោះស្រាយរបស់ខ្លួនដោយភាពឯករាជ្យ ដោយមិនឈរទៅលើការគាបសង្កត់ពីអំណាចណាមួយឡើយ។ ក្នុងដីកាដំណោះស្រាយនោះ ចៅក្រមស៊ើបសួរ ក៏អាចសម្រេចធ្វើការប្រកាន់បទល្មើស បញ្ជូនទៅយុត្តាធិការជំនុំជម្រះតាមការប្តឹងសុំពីតំណាងអយ្យការ ប្រសិនជាខ្លួនយល់ឃើញថាដូចគ្នា។ ប៉ុន្តែប្រសិនជាករណីដែលខ្លួនយល់ឃើញថាមិនមែនជាបទល្មើសព្រហ្មទណ្ឌខ្លួនអាចលើកលែងបទចោទ និងដោះលែងជនត្រូវចោទឱ្យមានសេរីភាពឡើងវិញ។

ជាគោលការណ៍ចៅក្រមស៊ើបសួរមិនអាចចាប់ផ្តើមស្រាវជ្រាវបទល្មើសណាមួយដោយគ្មាន ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរពីតំណាងអយ្យការឡើយ។ មានតែតំណាងអយ្យការទេដែលមានសិទ្ធិសម្រេចអំពីការបញ្ជូនបទល្មើសព្រហ្មទណ្ឌណាមួយដែលមានភាពស្មុគស្មាញ និងភស្តុតាងមិនទាន់គ្រប់គ្រាន់មកចៅក្រមស៊ើបសួរ ដើម្បីស្រាវជ្រាវ និងស្វែងរកភស្តុតាងដាក់បន្ទុក ឬដោះបន្ទុក។ ករណីអញ្ញត្រកម្ម ចំពោះចៅក្រមស៊ើបសួរគឺអាចធ្វើការស៊ើបសួរបានតាមពាក្យបណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរដែលតំណាងអយ្យការសម្រេចតម្កល់សំណុំរឿងនោះទុកឥតចាត់ការ រួមទាំងអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍យល់ឃើញស្របនឹងសេចក្តីរបស់ព្រះរាជអាជ្ញាអមសាលាដំបូងផងដែរនោះ[15]។

ការស្រាវជ្រាវនេះមានគោលបំណងបង្ហាញនូវវិធានការដែលចៅក្រមស៊ើបសួរបានប្រើប្រាស់ ក្នុងការស្វែងរកការពិតក្នុងអង្គហេតុ។ ចៅក្រមស៊ើបសួរមានវិធានការអ្វីខ្លះក្នុងការស្វែងរកការពិតដែលត្រូវប្រមូលភស្តុតាងស្រាវជ្រាវរកជនត្រូវចោទ ការឆែកឆេរ ឬធ្វើកោសលវិច័យលើវត្ថុតាង ដែលក្រមនីតិវិធីព្រហ្មទណ្ឌបានកំណត់យ៉ាងតឹងរឹងក្នុងការប្រើប្រាស់វិធានការនីមួយៗ ករណីខ្លះទៀតត្រូវតែប្រើប្រាស់វិធានការតាមកាលៈទេសៈ នឹងស្ថានភាពជាក់ស្តែង។

ដើម្បីឆ្លើយតបទៅនឹងតម្រូវការ នៃកិច្ចស្រាវជ្រាវបទល្មើសព្រហ្មទណ្ឌរបស់ ចៅក្រមស៊ើបសួរ និងតម្រូវឱ្យជនត្រូវចោទ ឬបុគ្គលដែលមានតម្រុយពិរុទ្ធចូលមកបង្ហាញខ្លួនដោយស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ខ្លួននោះដោយ

[15]មាត្រា ១២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧

ប្រើប្រាស់នូវ**វិធានការនិរន្តរាយ**ណាមួយ ទើបអាចឱ្យជនត្រូវចោទចូលមកបានតាមរយៈដីកាបង្គាប់ឱ្យចូលខ្លួន ដីកាបង្គាប់ឱ្យនាំខ្លួន ដីកាបង្គាប់ឱ្យចាប់ខ្លួននិងដីកាបង្គាប់ឱ្យឃុំខ្លួនជាបណ្ដោះអាសន្ន។ ដីកាបង្គាប់ឱ្យចូលខ្លួន ដីកាបង្គាប់ឱ្យនាំ និងដីកាបង្គាប់ចាប់ខ្លួនជាវិធានការមានវិសាលភាព អាចចេញទៅលើជនត្រូវចោទ ឬជនជាប់ពាក់ព័ន្ធនឹងអង្គហេតុក្នុង ដីកាសន្និដ្ឋានបញ្ជូនសំណុំរឿងឱ្យស៊ើបសួរនោះ[16]។

ចៅក្រមស៊ើបសួរដែលបានទទួលបន្ទុកក្នុងការស្រាវជ្រាវបទល្មើស ក្រោយពីបានទទួលបណ្ដឹងពីតំណាងអយ្យការរួចមកនោះ ត្រូវតែពិនិត្យមើលទៅលើសំណុំរឿងដែលគេបានបញ្ជូនឱ្យខ្លួនដើម្បីសិក្សា និងចាប់ផ្ដើមបំពេញកិច្ចស្រាវជ្រាវស្វែងរកការពិតក្នុងនាមជាចៅក្រមស៊ើបសួរ។ ការធានានូវគោលការណ៍ រកភស្តុតាងដាក់បន្ទុក និងដោះបន្ទុកជាមូលគ្រឹះនៃប្រព័ន្ធចៅក្រមស៊ើបសួរក្នុងការប្រមូលភស្តុតាងនានា អាចភស្តុតាងជាឯកសារ ភស្តុតាងជាសាក្សី ភស្តុតាងជាសំឡេង គ្រប់សេចក្ដីសន្និដ្ឋានរបស់អ្នកជំនាញ និងរបាយការណ៍សរុបរបស់មន្ត្រីនគរបាលយុត្តិធម៌ ក្នុងការបំពេញតួនាទីជាអ្នកស៊ើបសួរជំនួសតាមការចាត់តាំងរបស់ចៅក្រមស៊ើបសួរ។ ការស៊ើបសួរដាក់បន្ទុកមានន័យថាស្វែងរកភស្តុតាងមកធ្វើមូលដ្ឋាន ក្នុងការបញ្ជូនជនត្រូវចោទទៅធ្វើការជំនុំជម្រះនូវអំពើដែលជនត្រូវចោទបានប្រព្រឹត្ត។ ចំណែកការស៊ើបសួរដោះបន្ទុកស្វែងរកភស្តុតាងនូវអ្វីៗដែលជនត្រូវចោទមិនបានប្រព្រឹត្តដូចជាការចោទប្រកាន់របស់តំណាងអយ្យការ ឬជាភស្តុតាងដែលអាចជួយសម្រាលទោសដល់ជនត្រូវចោទ។[17]

ការបញ្ចប់កិច្ចស្រាវជ្រាវបទល្មើស បើសិនជាចៅក្រមស៊ើបសួរយល់ឃើញថាគ្មានប្រយោជន៍អ្វីដល់កិច្ចនីតិវិធីដែលតម្រូវឱ្យចៅក្រមស៊ើបសួរស្វែងរកនូវភស្តុតាងដាក់បន្ទុក ឬដោះបន្ទុកទៀតទេ និងគ្មានលទ្ធផលអ្វីលើសពីកិច្ចដែលបានធ្វើកន្លងមកហើយ ចៅក្រមស៊ើបសួរអាចបិទស៊ើបសួរត្រឹមតែកិច្ចដែលខ្លួនបានធ្វើកន្លងមកនោះ។ ការបញ្ចប់ពីការទទួលបន្ទុកនៃការស៊ើបសួរនេះបានស្ដែងឡើងតាមរយៈដីកាដំណោះស្រាយ។ ដីកាដំណោះស្រាយនេះអាចជាដីកាលើកលែងចោទប្រកាន់ ឬជាដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ[18]។

### ២.៣.១. ដីកាលើកលែងចោទប្រកាន់

ចៅក្រមស៊ើបសួរចេញដីកាលើកលែងចោទប្រកាន់ ឬមិនបញ្ជូនជននោះទៅចំពោះមុខសាលាជម្រះក្ដីក្នុងករណីដែល ៖

- អំពើប្រព្រឹត្តមិនមែនជាបទឧក្រិដ្ឋ ឬបទមជ្ឈិម ឬបទលហុ

[16]មាត្រា ១៨៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧

[17]មាត្រា ១២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧

[18]មាត្រា ២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧

- ជនប្រព្រឹត្តអំពើនោះនៅតែគេមិនស្គាល់
- គ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទ ។

មួយវិញទៀត បើក្នុងករណីរលត់បណ្តឹងអាជ្ញាដោយមូលហេតុដូចមានកំណត់ក្នុងមាត្រា ៧ (ការរលត់នៃបណ្តឹងអាជ្ញា) ក៏ជាមូលហេតុនៃការថ្លឹងថ្លែងក្នុងការលើកលែងការចោទប្រកាន់ផងដែរ។ ចំពោះការលើកលែងចោទប្រកាន់ មិនអាចនាំឱ្យចេញសាលក្រមនោះទេ។ ប៉ុន្តែដីកាលើកលែងចោទនេះអាចដាក់ពាក្យបណ្តឹងទៅកាន់សភាស៊ើបសួរនៃសាលាឧទ្ធរណ៍បាន។ ប្រសិនបើសភាស៊ើបសួរយល់ឃើញថាសំណុំរឿងនោះអាចនឹងបើកការជំនុំជម្រះបាន សភាស៊ើបសួរត្រូវចេញសាលដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

## ២.៣.២. ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ

ដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ចៅក្រមស៊ើបសួរ គឺជាប្រភេទមួយនៃដីកាដំណោះស្រាយដែលចៅក្រមស៊ើបសួរបានចេញបន្ទាប់ពីបិទការស៊ើបសួរ។ ទន្ទឹមនឹងនោះ មូលហេតុដែលចៅក្រមស៊ើបសួរចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះគឺដោយពិនិត្យឃើញថាសំណុំរឿងដែលខ្លួនបានបើកការស៊ើបសួរនោះជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទហុ។ ក្នុងករណីនេះ ចៅក្រមស៊ើបសួរបញ្ជូនជនត្រូវចោទទៅតុលាការដើម្បីជំនុំជម្រះពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ដោយចៅក្រមស៊ើបសួរត្រូវរៀបរាប់អំពើដែលត្រូវចោទប្រកាន់ និងឈ្មោះបទល្មើសតាមច្បាប់[19]។

ចៅក្រមស៊ើបសួរចេញនូវដីកាបញ្ជូនរឿងទៅជំនុំជម្រះ បន្ទាប់ពីខ្លួនបានយល់ឃើញថាមានបន្ទុកគ្រប់គ្រាន់ចំពោះអំពើរបស់ជនត្រូវចោទ ជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ដើម្បីបើកសវនាការជំនុំជម្រះ។

ប្រសិនបើចៅក្រមស៊ើបសួរ សម្រេចចេញដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះចៅក្រមស៊ើបសួរបញ្ជូនសំណុំរឿងជាបន្ទាន់ទៅប្រធានតុលាការ ដើម្បីកំណត់ពេលវេលាសវនាការជំនុំជម្រះ[20]។ ដីកានេះក៏មានអានុភាពបញ្ចប់សមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរពីសំណុំរឿងបញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការ និងបញ្ចប់ការឃុំខ្លួនបណ្តោះអាសន្នផងដែរ។ ម៉្យាងវិញទៀត ចៅក្រមស៊ើបសួរអាចយោងតាមសេចក្តីសម្រេចដោយឡែកនៃដីកាដំណោះស្រាយ និងក្រោមលក្ខខណ្ឌមួយចំនួនដូចកំណត់នៅក្នុងមាត្រា ២០៥ (ករណីនៃការឃុំខ្លួនបណ្តោះអាសន្ន) ក្នុងករណីនេះ ចៅក្រមស៊ើបសួរអាចរក្សាទុកជនត្រូវចោទឱ្យនៅក្រោមវិធានការឃុំខ្លួនបណ្តោះអាសន្ន រហូតដល់ពេលបង្ហាញខ្លួននៅចំពោះមុខតុលាការ[21] ។

---

[19] មាត្រា ២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧

[20] មាត្រា ២៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧

[21] មាត្រា ២៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧

### ២.៣.៣. ការបញ្ជូនរឿងទៅជំនុំជម្រះរបស់សភាស៊ើបសួរ

បន្ទាប់ពីចៅក្រមស៊ើបសួរបានចេញដីកាសម្រេចលើកលែងការចោទប្រកាន់។ ចំពោះដីកាខាងលើនេះ ចៅក្រមស៊ើបសួរត្រូវធ្វើការជូនដំណឹងក្នុងរយៈពេលដ៏ខ្លីបំផុតដល់ព្រះរាជអាជ្ញា ជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណី។ ក្នុងករណីនេះ ប្រសិនបើអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ព្រះរាជអាជ្ញា ជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណីមិនសុខចិត្តជាមួយដីកាលើកលែងចោទប្រកាន់នោះទេ គឺអាចដាក់ពាក្យបណ្តឹងទៅកាន់ សភាស៊ើបសួរនៃសាលាឧទ្ធរណ៍នោះបាន។

បន្ទាប់ពីសភាស៊ើបសួរ បានទទួលពាក្យបណ្តឹងចំពោះដីកាលើកលែងការចោទប្រកាន់របស់ចៅក្រមស៊ើបសួរពីអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ព្រះរាជអាជ្ញា ជនរងគ្រោះបណ្តឹងរដ្ឋប្បវេណី។ ក្នុងករណីនេះ ប្រសិនបើសភាស៊ើបសួរយល់ឃើញថាការចេញដីកាការចោទប្រកាន់របស់ចៅក្រមស៊ើបសូរសម្រេចត្រឹមត្រូវហើយនោះ សភាស៊ើបសួរត្រូវចេញសាលដីកាសម្រេចតម្កល់ដីកាសម្រេចរបស់ចៅក្រមស៊ើបសួរនៃសាលាដំបូងនោះបាន។ ប៉ុន្តែប្រសិនបើសភាស៊ើបសួរយល់ឃើញថា សំណុំរឿងនោះមានភស្តុតាងគ្រប់គ្រាន់អាចនឹងបើកការជំនុំជម្រះបានពេលនោះសភាស៊ើបសួរត្រូវចេញសាលដីកាបញ្ជូនរឿងទៅជំនុំជម្រះទៅតុលាការដើមវិញ ។

## ២.៤. ដំណាក់កាលជំនុំជម្រះ

ការសម្រេចក្តីផ្តល់យុត្តិធម៌ត្រូវធ្វើក្នុងនាមជាប្រជារាស្ត្រខ្មែរតាមនីតិវិធី និងច្បាប់ជាធរមាន[22]។ ដំណាក់កាលជំនុំជម្រះ គឺជាដំណាក់កាលដ៏សំខាន់មួយបន្ទាប់ពីដំណាក់កាលស៊ើបសួរបានបញ្ចប់ទៅ។ ក្នុងរឿងព្រហ្មទណ្ឌសាលាដំបូងធ្វើការជំនុំជម្រះជនជាប់ចោទតាមរយៈការទទួលបណ្តឹងដោយ ៖

- ដីកាបញ្ជូនរបស់ចៅក្រមស៊ើបសួរ ឬសាលដីកាបញ្ជូនរបស់សភាស៊ើបសួរ
- ដីកាបញ្ជូនទៅតុលាការជំនុំជម្រះដោយផ្ទាល់របស់ព្រះរាជអាជ្ញា
- កំណត់ហេតុស្តីពីការចូលបង្ហាញខ្លួនភ្លាមដែលធ្វើដោយព្រះរាជអាជ្ញា

ជនរងគ្រោះនៃបទល្មើស អាចតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបានទៅចំពោះមុខតុលាការ ប្រសិនបើខ្លួនពុំទាន់បានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមុខចៅក្រមស៊ើបសួរនៅឡើយ[23] ។

ការពិភាក្សាដេញដោលត្រូវបានបញ្ញត្តិចាប់ពីមាត្រា ៣១៦ ដល់ មាត្រា៣៧២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ជនជាប់ចោទ មានសិទ្ធិទទួលបានសវនាការជាសាធារណៈនៅក្នុងការជំនុំជម្រះករណីរបស់ខ្លួន។ លើកលែងតែក្នុងកាលៈ

[22] មាត្រា ១២៥ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

[23] មាត្រា ២៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧

ទេសៈពិសេស ការពិភាក្សាដេញដោលអាចត្រូវបានធ្វើឡើងទាំងស្រុង ឬមួយផ្នែកជាសម្ងាត់ ប្រសិនបើតុលាការយល់ឃើញថាសវនាការជាសាធារណៈអាចបង្កឱ្យមានគ្រោះថ្នាក់ដល់ សណ្តាប់ធ្នាប់សាធារណៈ ឬដល់ទំនៀមទម្លាប់[24]។

ចំពោះបទឧក្រិដ្ឋ និងករណីផ្សេងទៀតដែលបទជ្ឈិម និងបទលហុ មានជាប់ទាក់ទិននឹងបទចោទពីបទឧក្រិដ្ឋ ក្រុមប្រឹក្សាជំនុំជម្រះត្រូវតែមានចៅក្រម បីរូប។ ចំពោះបទមជ្ឈិម និងបទលហុ ចៅក្រមតែម្នាក់ដឹកនាំសវនាការ។ ចៅក្រមជំនុំជម្រះមិនអាចជាចៅក្រមដែលបានបំពេញកិច្ចស៊ើបសួរនៅក្នុងករណីតែមួយនោះទេ។

## ២.៤.១. នីតិវិធីមុនពេលសវនាការជំនុំជម្រះ

មុននឹងសម្រេចបើកសវនាការ ក្រឡាបញ្ជីនៃសវនាការ ត្រូវប្រកាសអំពីបទបញ្ជាផ្ទៃក្នុង និងធ្វើសេចក្តីថ្លែងអំពីសមាសភាពអ្នកដែលចូលរួម ទើបសម្រេចបើកសវនាការដោយចៅក្រម។ តុលាការព្រហ្មទណ្ឌអាចបើកសវនាការជំនុំជម្រះបានតែលើជនណាដែលបានបញ្ជូនមកក្នុងឋានៈជាជនជាប់ចោទតែប៉ុណ្ណោះ។ ដោយនៅដំណាក់កាលនេះស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ចៅក្រមជំនុំជម្រះ ដែលយើងហៅថាជាដំណាក់កាលជំនុំជម្រះចេញសាលក្រម។ ក្នុងដំណាក់កាលនេះមានចៅក្រមថ្មីមួយទៀតដែលមិនធ្លាប់ធ្វើការស៊ើបសួរ ឬធ្វើការចោទប្រកាន់ឡើយ។ រាល់ការជជែកដេញដោល ការតទល់គ្នា ការទាញហេតុផលរៀងៗខ្លួន គឺត្រូវធ្វើឡើងនាពេលសវនាការ។

បន្ទាប់ពីតុលាការបានទទួលសំណុំរឿងដោយយោងតាមនីតិវិធីនៃការប្តឹងទៅតុលាការ ក្នុងករណីនេះប្រធានតុលាការជាអ្នកកំណត់កាលបរិច្ឆេទនៃសវនាការ លើកលែងតែករណីនៃនីតិវិធីបង្ហាញខ្លួនភ្លាម។

ក្នុងករណីតុលាការ បានទទួលបណ្តឹងដោយបញ្ជូនទៅជំនុំជម្រះផ្ទាល់ដោយដីការបស់ចៅក្រមស៊ើបសួរ ឬសាលដីកាបញ្ជូនរឿងរបស់សភាស៊ើបសួរ ប្រធានតុលាការត្រូវថ្លឹងថ្លែងអំពីកាលបរិច្ឆេទនេះដូចមានចែងនៅក្នុងមាត្រា ៤៥៧ (រយៈពេលដែលត្រូវគោរពរវាងការប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ និងការបង្គាប់ឱ្យបង្ហាញខ្លួន) និងមាត្រា ៤៦៦ (រយៈពេលដែលត្រូវគោរពរវាងដីកាកោះហៅ និងការបង្គាប់ឱ្យបង្ហាញខ្លួន) ត្រូវបានយកមកអនុវត្តដូចគ្នាផងដែរ។ ក្នុងករណីនេះការជូនដំណឹងត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញាផងដែរ[25]។

តាមបញ្ញត្តិនៃមាត្រាខាងលើនេះ រយៈពេលរវាងការប្រគល់ដីកាកោះហៅជនជាប់ចោទ និងថ្ងៃកំណត់ឱ្យចូលខ្លួននៅមុខតុលាការ ត្រូវកំណត់ដូចតទៅ ៖

- ១៥ ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅក្នុងដែនដីនៃតុលាការជាន់ដំបូង

[24] មាត្រា ៣១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧

[25] មាត្រា ២៩២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧

- ២០ ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅក្នុងរដ្ឋនៃទីកន្លែងមួយផ្សេងទៀតនៃដែនដីជាតិ
- ២ ខែ ប្រសិនបើជនជាប់ចោទរស់នៅក្នុងរដ្ឋមួយជាប់ព្រំដែននៃព្រះរាជាណាចក្រកម្ពុជា
- ៣ ខែ ប្រសិនបើជនជាប់ចោទរស់នៅទីកន្លែងមួយផ្សេងទៀត។

ប៉ុន្តែក្នុងករណីជនជាប់ចោទត្រូវឃុំខ្លួនគ្មានរយៈពេលណាមួយត្រូវបានទាមទារឡើយ រវាងការប្រគល់ដីកាដល់ជនជាប់ចោទ និងថ្ងៃកំណត់ឱ្យចូលបង្ហាញខ្លួននៅមុខតុលាការ។

ម្យ៉ាងវិញទៀត ការកោះហៅដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះ សាក្សី អ្នកជំនាញ អ្នកបកប្រែ និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ធ្វើឡើងដោយព្រះរាជអាជ្ញា[26]។ នៅក្នុងករណី ដែលតុលាការទទួលបណ្តឹងដោយដីកាបញ្ជូនរបស់ចៅក្រមស៊ើបសួរ ឬសាលដីការបស់សភាស៊ើបសួរ និងលិខិតចម្លងដីកាបញ្ជូន ឬសាលដីកាបញ្ជូន ត្រូវភ្ជាប់ជាមួយនឹងដីកាកោះហៅ ដើម្បីប្រគល់ឱ្យជនជាប់ចោទ។ ប្រសិនបើមានមេធាវីជាដាច់ខាត ព្រះរាជអាជ្ញាត្រូវចេញលិខិតអញ្ជើញមេធាវីមកផងដែរ។

មេធាវីអាចពិនិត្យមើលសំណុំរឿងនៅការិយាល័យក្រឡាបញ្ជីនៃតុលាការ នៅក្រោមការត្រួតពិនិត្យរបស់ក្រឡាបញ្ជី។ មួយវិញទៀត មេធាវី ឬលេខារបស់មេធាវី(ជំនួយការ) អាចត្រូវបានអនុញ្ញាតដោយប្រធានតុលាការឱ្យធ្វើការចម្លងលិខិតនៃសំណុំរឿង ហើយការថតចម្លងនេះទៀតសោត គឺមេធាវីជាអ្នកចេញសោហ៊ុយដោយនៅក្រោមការត្រួតពិនិត្យរបស់ក្រឡាបញ្ជីផងដែរ [27]។

បន្ទាប់ពីព្រះរាជអាជ្ញាបានធ្វើការកោះហៅភាគីពាក់ព័ន្ធដែលត្រូវចូលរួមសវនាការតាមរយៈដីកាកោះហៅ ឬតាមរយៈដីកាបង្គាប់នាំខ្លួន(ករណីជនជាប់ចោទជាប់ឃុំក្នុងពន្ធនាគារ) ហើយរួចភាគីដែលទទួលបានដីកានោះត្រូវតែចូលខ្លួនមកកាន់តុលាការតាមការកំណត់ដែលមានបញ្ជាក់នៅក្នុងដីកា។

ជនជាប់ចោទត្រូវចូលបង្ហាញខ្លួននៅពេលសវនាការដោយផ្ទាល់។ ជនជាប់ចោទត្រូវអមដោយមេធាវីម្នាក់ដែលខ្លួនជ្រើសរើស។ ទន្ទឹមនឹងនោះ ជនជាប់ចោទក៏អាចសុំឱ្យចាត់តាំងមេធាវីឱ្យខ្លួនបានដែរ នៅក្នុងលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ស្តីពីលក្ខន្តិកៈមេធាវី[28]។ យ៉ាងណាមិញជនជាប់ចោទចូលខ្លួនមកកាន់សវនាការតាមនីតិវិធីបីយ៉ាង គឺតាមរយៈនីតិវិធីជំនុំជម្រះផ្ទាល់ នីតិវិធីបង្ហាញខ្លួនភ្លាម ឬតាមរយៈដីកាបញ្ជូនរបស់ចៅក្រមស៊ើបសួរ ឬសាលដីកាបញ្ជូនរបស់សភាស៊ើបសួរ។ ក្នុងករណីនីតិវិធីបញ្ជូនទៅជំនុំជម្រះផ្ទាល់ ជនជាប់ចោទត្រូវចូលបង្ហាញខ្លួនដោយ

[26] មាត្រា ២៩៤ មាត្រា ២៩៥ និងមាត្រា ២៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧

[27] មាត្រា ៣១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧

[28] មាត្រា ៣០០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧

ខ្លួនឯងនៅពេលសវនាការនៃតុលាការជាន់ដំបូង តាមរយៈដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ដែលចេញដោយព្រះរាជអាជ្ញា ដោយក្នុងដីកានេះគឺផ្តល់សិទ្ធិឱ្យជនជាប់ចោទអាចពឹងមេធាវីឱ្យអមខ្លួនបាន។ ចំពោះការចូលខ្លួនតាមនីតិវិធីបង្ហាញខ្លួនភ្លាមវិញនោះ ជនជាប់ចោទត្រូវចូលខ្លួននៅចំពោះមុខតុលាការដោយមានកម្លាំងអម ពីព្រោះថានៅក្នុងនីតិវិធីបង្ហាញខ្លួនភ្លាម ជនជាប់ចោទស្ថិតនៅក្រោមការឃុំគ្រងដោយកងកម្លាំងការពារ រហូតដល់ពេលដែលជននោះត្រូវបានចូលបង្ហាញខ្លួននៅចំពោះមុខតុលាការ។

ក្រៅពីជនជាប់ចោទ ដែលត្រូវចូលខ្លួនមកនៅចំពោះមុខតុលាការដើម្បីបើកសវនាកាធ្វើការជំនុំជម្រះលើរឿងក្តីព្រហ្មទណ្ឌ ក៏មានការចូលរួមពីភាគីពាក់ព័ន្ធផ្សេងក្រៅពីជនជាប់ចោទផងដែរដោយក្នុងនោះមានដូចជា ជនរងគ្រោះដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី សាក្សីអ្នកជំនាញ អ្នកបកប្រែ ចំពោះដើមបណ្តឹងរដ្ឋប្បវេណីនៅពេលចូលបង្ហាញខ្លួននៅចំពោះមុខតុលាការក៏អាចត្រូវបានអមដោយមេធាវីផងដែរ។

មុននឹងតុលាការ ធ្វើការសាកសួរចម្លើយដើម្បីបានជាពត៌មានមកធ្វើជាការពិចារណាអំពី នត្ថិភាព ឬ អត្ថិភាពនៃបទល្មើស តុលាការត្រូវឱ្យបុគ្គលដែលត្រូវសួរចម្លើយនោះស្បថថាខ្លួននិយាយតាមតែការពិតស្របតាមសាសនា ឬជំនឿរបស់ខ្លួន ដែលក្នុងនោះបុគ្គលដែលត្រូវធ្វើសម្បថមានដូចជា សាក្សី អ្នកបកប្រែជាដើម[29]។ ក្រមនីតិវិធីព្រហ្មទណ្ឌក៏បានចែងអំពីសាក្សី និងអ្នកបកប្រែមួយចំនួនឱ្យរួចផុតពីសម្បថផងដែរ[30]។ ក្រឡាបញ្ជីជាអ្នកដឹកនាំជនដែលជាសាក្សី អ្នកបកប្រែឱ្យធ្វើសម្បថមុននឹងការប្រកាសបើកសវនាការ។ ការធ្វើសច្ចាប្រណិធាន ត្រូវធ្វើនៅចំពោះមុខវត្ថុសក្តិសិទ្ធិនៅទីកន្លែងនៃតុលាការ។

### ២.៤.២. នីតិវិធីនាពេលជំនុំជម្រះ

ក្នុងដំណាក់កាលនេះ ជាដំណាក់កាលដែលត្រូវសម្រេចអំពីការពិតណាមួយ និងការទទួលខុសត្រូវតាមផ្លូវច្បាប់ដោយអនុភាពនៃការចាប់បង្ខំគឺ សាលក្រម។ ការប្រកាសបើកសវនាការគឺធ្វើឡើងដើម្បីបើកការពិភាក្សាដេញដោលដើម្បីស្វែងរកឱ្យឃើញពី នត្ថិភាព ឬអត្ថិភាពនៃបទល្មើសមុននឹង តុលាការចេញសេចក្តីសម្រេច។ ទន្ទឹមនឹងនោះកិច្ចនីតិវិធីនៃការបើកសវនាការមានដូចខាងក្រោម ៖

#### ២.៤.២.១. គោលការណ៍ស្តីពីភាពសាធារណៈនៃសវនាការ

ជាគោលការណ៍ការពិភាក្សាដេញដោលប្រព្រឹត្តទៅនៅក្នុងពេលសវនាការសាធារណៈ ដោយអនុញ្ញាតឱ្យប្រជាពលរដ្ឋអាចចូលស្តាប់អំពីចំណាត់ការរបស់តុលាការបាន។ ប៉ុន្តែបើតុលាការយល់ឃើញថាសាធារណៈភាព បង្កឱ្យ

---

[29] មាត្រា ៣២៨ និងមាត្រា ៣៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧

[30] មាត្រា ១៥៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧

មានគ្រោះថ្នាក់ដល់សណ្តាប់ធ្នាប់សាធារណៈ ឬដល់ទំនៀមទំនៀមទម្លាប់ នោះតុលាការតាមសេចក្តីសម្រេចមានសំអាងហេតុ អាចបង្គាប់ឱ្យការពិភាក្សាដេញដោលទាំងស្រុង ឬមួយផ្នែកប្រព្រឹត្តទៅជាសម្ងាត់។ តុលាការសម្រេចតាមសាលក្រមមួយ ដាច់ដោយឡែកពីសាលក្រមអង្គសេចក្តី ឬតាមសេចក្តីសម្រេចពិសេសនៃសាលក្រមលើអង្គសេចក្តី។ សេចក្តីសម្រេចរបស់តុលាការដែលបង្គាប់ឱ្យធ្វើការពិភាក្សាដេញដោលជាសម្ងាត់មិនអាចតវ៉ាបានទេ[31]។

ប្រធានសវនាការ ដឹកនាំការពិភាក្សាដេញដោល និងធានាប៉ារងឱ្យសិទ្ធិខាងការការពារបានប្រព្រឹត្តដោយ សេរី។ ប្រធានសវនាការអាចបដិសេធចេញពីការពិភាក្សាដេញដោលនូវអ្វីដែលមានគោលបំណងអូសបន្លាយការពិភាក្សាដេញដោលឥតប្រយោជន៍ គ្មានរួមវិភាគទានអ្វីដល់ការសំដែងឱ្យឃើញការពិត។ ប្រធានសវនាការធានាឱ្យមានសណ្តាប់ធ្នាប់ល្អនៅក្នុងពេលសវនាការ និងអាចហាមឃាត់អនីតិជនខ្លះឬទាំងអស់មិនឱ្យចូលរួមក្នុងបន្ទប់សវនាការ ហើយក៏អាចបង្គាប់ឱ្យបណ្តេញបុគ្គលគ្រប់រូប ដែលបង្កឱ្យមានការច្របូកច្របល់ដល់ដំណើរការនៃការពិភាក្សាដេញដោល។ ក្នុងការបំពេញមុខងាររបស់ខ្លួន ប្រធានសវនាការអាចប្រើប្រាស់កងកម្លាំងសាធារណៈ[32]។

### ២.៤.២.២. ដំណើរការនៃកិច្ចពិភាក្សាដេញដោលនាពេលសវនាការ

ក្រឡាបញ្ជីហៅឈ្មោះជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណីជនរងគ្រោះ សាក្សី អ្នកជំនាញ ព្រមទាំងផ្ទៀងផ្ទាត់អត្តសញ្ញាណ។ ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណីអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ត្រូវបានតំណាងដោយសហព័ទ្ធ ឬញាតិលោហិតផ្ទាល់ ក្រឡាបញ្ជី ត្រូវពិនិត្យផ្ទៀងផ្ទាត់ពីសុពលភាពនៃការប្រគល់សិទ្ធិ។ ក្រឡាបញ្ជីសរសេរកំណត់ហេតុសវនាការដោយរៀបរាប់អំពីដំណើរការប្រព្រឹត្តទៅនៃសវនាការ និងសំណួរចម្លើយដល់ជនពាក់ព័ន្ធនៅក្នុងសវនាការ[33]។ កំណត់ហេតុនេះ ត្រូវចុះហត្ថលេខាដោយក្រឡាបញ្ជី និងចុះទិដ្ឋាការក្រោយពីការផ្ទៀងផ្ទាត់ដោយប្រធានសវនាការ ក្នុងរយៈពេល ១០ថ្ងៃក្រោយថ្ងៃប្រកាសសាលក្រម។

ភាគីនីមួយៗ អង្គុយនៅតាមកន្លែងដែលទុកសម្រាប់ឱ្យខ្លួន នៅក្នុងពេលសវនាការ។

ប្រធានសវនាការ ប្រាប់ដល់ជនជាប់ចោទ ឱ្យបានដឹងពីអំពើដែលគេចោទប្រកាន់មកលើខ្លួន។

ប្រធានសវនាការ សួរចម្លើយជនជាប់ចោទ ទាំងដាក់បន្ទុក និងដោះបន្ទុក។

ព្រះរាជអាជ្ញា មេធាវី និងភាគី អាចត្រូវបានអនុញ្ញាតឱ្យលើកសំណួរដល់ជនជាប់ចោទ ។ ក្រៅពីសំណួររបស់តំណាងអយ្យការ និងមេធាវី សំណួរផ្សេងទៀត ត្រូវសួរតាមរយៈប្រធានសវនាការ។

[31] មាត្រា ៣១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧

[32] មាត្រា ៣១៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧

[33] មាត្រា ៣៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧

ប្រធានសវនាការ ស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី។

ព្រះរាជអាជ្ញា មេធាវី និងភាគី អាចត្រូវបានអនុញ្ញាតឱ្យលើកសំណួរដល់ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី។ ក្រៅពីសំណួររបស់តំណាងអយ្យការ និងមេធាវីសំណួរផ្សេងទៀតត្រូវសួរតាមរយៈប្រធានសវនាការ។

តុលាការ អាចស្តាប់ចម្លើយរបស់អ្នកប្តឹងបរិហារបានផងដែរ ដើម្បីយកជា ព័ត៌មាន[34]។

ព្រះរាជអាជ្ញា មេធាវី និងភាគី អាចត្រូវបានអនុញ្ញាតឱ្យលើកសំណួរដល់សាក្សី ។ ក្រៅពីសំណួររបស់តំណាងអយ្យការ និងមេធាវី សំណួរផ្សេងទៀត ត្រូវសួរតាមរយៈប្រធានសវនាការ ។ ភាគីអាចសុំឱ្យតុលាការស្តាប់ចម្លើយក្នុងឋានៈជាសាក្សី នូវបុគ្គលដែលមានវត្តមាននៅក្នុងបន្ទប់សវនាការ ប៉ុន្តែបើមិនបានកោះហៅឱ្យបានត្រឹមត្រូវនោះទេការស្តាប់ចម្លើយសាក្សីនេះត្រូវមានការយល់ព្រមពីប្រធានសវនាការទើបបាន។ ក្រឡាបញ្ជីស្រង់អត្តសញ្ញាណ និងអញ្ជើញសាក្សីនេះ ឱ្យថយទៅនៅបន្ទប់រងចាំ។ ប្រសិនបើសាក្សី ពុំអាចចូលមកបង្ហាញខ្លួននៅមុខតុលាការ តាមការកោះហៅនោះតុលាការអាចប្រើកម្លាំងសាធារណៈ ដើម្បីបង្ខំសាក្សីឱ្យចូលបង្ហាញខ្លួនបាន។ ប្រសិនបើជនពាក់ព័ន្ធជាជនគ ថ្លង់ ក្រឡាបញ្ជីសរសេរសំណួរ ហើយឱ្យសាមីខ្លួនអាន និងឆ្លើយជាលាយលក្ខណ៍អក្សរ។ ប្រសិនបើចេះអានទេ ត្រូវរកអ្នកបកប្រែ ដោយត្រូវឱ្យស្បថតាមសាសនា និងជំនឿរបស់ខ្លួនថា ជួយតុលាការ និងបកប្រែចម្លើយឱ្យបានស្មោះត្រង់[35]។ អ្នកបកប្រែនេះ អាចជាអ្នកធ្លាប់ប្រាស្រ័យទាក់ទងជាមួយជននេះ។ ប្រសិនបើសាមីខ្លួនពុំអាចនិយាយភាសាខ្មែរបានទេ ត្រូវរកអ្នកបកប្រែ ដែលត្រូវស្បថតាមសាសនានិងជំនឿរបស់ខ្លួន ថាជួយតុលាការ និងបកប្រែចម្លើយឱ្យបានស្មោះត្រង់[36]។ អ្នកបកប្រែ ពុំអាចជ្រើសរើសក្នុងចំណោមចៅក្រម ក្រឡាបញ្ជី នគរបាល កងរាជអាវុធហត្ថ គូភាគី ឬសាក្សីទេ។

ជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី អាចធ្វើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ និងជូនលិខិតស្នាមទាំងអស់ ដែលខ្លួនយល់ឃើញថា មានប្រយោជន៍ដល់ការសម្តែងឱ្យឃើញថាពិត។ សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរនេះ ត្រូវចុះទិដ្ឋាការដោយប្រធានសវនាការ និងក្រឡាបញ្ជី ហើយភ្ជាប់មកជាមួយក្នុងសំណុំរឿង[37]។ ការដាក់សេចក្តីសន្និដ្ឋាននេះ ត្រូវធ្វើមុនពេលបិទ ការពិភាក្សាដេញដោល។

[34] មាត្រា ៣២៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧

[35] មាត្រា ៣៣១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧

[36] មាត្រា ៣៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧

[37] មាត្រា ៣៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧

ប្រសិនបើការពិភាក្សាដេញដោល មិនបានបញ្ចប់នៅក្នុងពេលសវនាការទេ តុលាការអាចបន្តនៅពេលសវនាការក្រោយ តាមកាលបរិច្ឆេទដែលខ្លួនកំណត់។

- **វិវាទកម្មស្តីពីវិយ័តភាពនៃការកោះហៅ**

ប្រសិនបើ ភាគីបានធ្វើការលើកឡើងពីភាពមិនត្រឹមត្រូវ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ កំណត់ហេតុស្តីពីការបង្ហាញខ្លួនភ្លាម ឬការកោះឱ្យចូលខ្លួននៅពេលសវនាការ ភាគីនោះត្រូវលើកឡើងអំពីវិវាទកកម្មនោះ នៅមុនពេលសួរចម្លើយជនជាប់ចោទលើអង្គសេចក្តី បើពុំដូច្នេះទេ វិវាទកម្មនេះពុំអាចទទួលបានឡើយ[38]។

- **ការសួរចម្លើយជនជាប់ចោទ**

ក្រោយពីបានទទួលដំណឹងអំពីកាលបរិច្ឆេទនៃការចូលបង្ហាញខ្លួន ជនជាប់ចោទត្រូវ បង្ហាញខ្លួននៅពេលសវនាការរបស់តុលាការដោយផ្ទាល់។ ជនជាប់ចោទ ត្រូវអមដោយមេធាវីដែលខ្លួនជ្រើសរើស ឬស្នើសុំឱ្យតុលាការចាត់តាំងមេធាវីជំនួស ឬមិនត្រូវការមេធាវី បើជននោះយល់ថាអាចការពារខ្លួនបាននៅចំពោះមុខតុលាការ។ តែការដែលមិនមានមេធាវី មិនត្រូវអនុវត្តដោយចំពោះបទឧក្រិដ្ឋ ឬកាលណាជនជាប់ចោទជាអនីតិជន។ ម៉្យាងវិញទៀត ការចូលខ្លួនរបស់ជនជាប់ចោទ គឺប្រព្រឹត្តិទៅដោយឡែកពីគ្នា ដូចជាក្នុងករណីបញ្ជូនទៅជំនុំជម្រះផ្ទាល់ ជនជាប់ចោទចូលបង្ហាញខ្លួនដោយខ្លួនឯងនៅពេលសវនាការ[39]។

មុននឹងធ្វើការសួរចម្លើយជនជាប់ចោទ ចៅក្រមជំនុំជម្រះត្រូវប្រាប់ដល់ជនជាប់ចោទឱ្យបានដឹង អំពីបទល្មើសដែលតំណាងអយ្យការចោទប្រកាន់លើខ្លួនជាមុនសិន។ ចៅក្រមជំនុំជម្រះអាចសួរបានគ្រប់សំណួរដែលខ្លួនយល់ឃើញថា មានប្រយោជន៍ដល់ការសម្តែងឱ្យឃើញការពិត។ ចៅក្រមជំនុំជម្រះត្រូវមានករណីយកិច្ចសួរចម្លើយជនជាប់ចោទដែលចូលមកចំពោះមុខខ្លួន ទាំងខាងផ្នែកដាក់បន្ទុក និងផ្នែកដោះបន្ទុក[40]។ ដើម្បីបានចម្លើយទៅតាមអ្វីដែលខ្លួនចង់បាន ចៅក្រមជំនុំជម្រះ ត្រូវមានបច្ចេកទេសច្បាស់លាស់ ក្នុងការសួរចម្លើយជនជាប់ចោទផងដែរ។ ក្រោយពីការប្រាប់ឱ្យដឹងពីបទចោទប្រកាន់ទៅដល់ជនជាប់ចោទរួចហើយ ចៅក្រមជំនុំជម្រះអាចធ្វើការសួរសំណួរទៅជនជាប់ចោទនូវសំណួរទាំងឡាយណា ដែលខ្លួនយល់ឃើញថាមានប្រយោជន៍ក្នុងការសម្តែងឱ្យឃើញការពិត ចៅក្រមជំនុំជម្រះអាចប្រើលំដាប់លំដោយនៃការសាកសួរ ដោយធ្វើការសួរជាសំណួរលក្ខណៈទូទៅមានន័យថាឱ្យជនជាប់ចោទមានឱកាសក្នុងការនិយាយរៀបរាប់អំពីអង្គហេតុដែលបានកើតឡើង។

---

[38]មាត្រា ៣២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧

[39] មាត្រា ៣០២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧

[40] មាត្រា ៣២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ក្នុងករណីដែលជនជាប់ចោទមានភាពរឹងទទឹងក្នុងការឆ្លើយតបចវេស ឬមិនព្រមទទួលស្គាល់នូវបទល្មើស ដែលតំណាងអយ្យការបានធ្វើការចោទប្រកាន់នោះ។ ចៅក្រមជំនុំជម្រះ ឬតំណាងអយ្យការអាចបង្គាប់ឱ្យក្រឡាបញ្ជី សវនាការអានចម្លើយរបស់ជនជាប់ចោទ ដែលបានឆ្លើយនៅដំណាក់កាលនគរបាលយុត្តិធម៌ ដំណាក់កាល អយ្យការ និងដំណាក់កាលចៅក្រមស៊ើបសួរបាន។ ការបង្គាប់ឱ្យក្រឡាបញ្ជីអានកំណត់ហេតុសួរចម្លើយទាំងបី ដំណាក់កាលខាងលើនេះ គឺក្នុងគោលបំណង ដាក់បន្ទុកចំពោះជនជាប់ចោទណា ដែលមានចេតនាទុច្ចរិតផ្តល់ ចម្លើយផ្ទុយពីការពិតដែលបានកើតឡើងជូនដល់អង្គសវនាការ ព្រមទាំងជាវិធីសាស្ត្រមួយដើម្បីឱ្យជនជាប់ចោទអាច សារភាពអំពីអង្គហេតុពិតដែលបានកើតឡើងផងដែរ។

ក្នុងករណីដែលជនជាប់ចោទជាជនបរទេស ឬជាជនគ ថ្លង់ ដើម្បីធ្វើការសួរចម្លើយជនជាប់ចោទបានទៅយ៉ាង រលូនចៅក្រមជំនុំជម្រះត្រូវរកជំនួយ ដូចជាអ្នកបកប្រែជាដើម ដោយអ្នកបកប្រែត្រូវតែធ្វើសម្បថជាមុនសិន ថាខ្លួនជា ជំនួយដល់តុលាការ និងធ្វើការបកប្រែចម្លើយឱ្យបានស្មោះត្រង់ទោះបីជាក្នុងករណីណាក៏ដោយ។ អ្នកបកប្រែមិនត្រូវ រើសចេញពីបុគ្គលដែលជាចៅក្រម ក្រឡាបញ្ជី នគរបាល កងរាជអាវុធហត្ថ គូភាគី ឬសាក្សីឡើយ[41] ។

ក្រោយពីចៅក្រមជំនុំជម្រះសួរចម្លើយរួចហើយ ចៅក្រមជំនុំជម្រះអាចផ្តល់សិទ្ធិចំពោះព្រះរាជអាជ្ញា មេធាវី និង ភាគីអាចលើកជាសំណួរសួរដល់ជនជាប់ចោទផងដែរ។

- **ការស្តាប់ចម្លើយភាគីដែលជាប់ពាក់ព័ន្ធក្នុងសំណុំរឿង**

ប្រធានសវនាការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ជនរងគ្រោះ សាក្សី និងអ្នក ជំនាញតាមលំដាប់លំដោយដែលខ្លួនយល់ឃើញថាប្រយោជន៍ក្នុងការស្វែងឱ្យឃើញពីការពិតដែលបានកើតឡើង។ ប្រធានសវនាការអាចស្តាប់ នូវចម្លើយមន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌ ដែលបានស៊ើបអង្កេត ក្នុងឋានៈជា សាក្សី[42]។

ចំពោះការស្តាប់ចម្លើយរបស់សាក្សី គឺប្រធានសវនាការបានផ្តល់ពេលវេលាជាច្រើនដើម្បីឱ្យសាក្សីរៀបរាប់នូវអ្វី ដែលខ្លួនបានដឹង ឬបានឃើញដោយករណីនេះប្រធានសវនាការត្រូវប្រើបច្ចេកទេសនៃការសាកសួរសំណួរជាប្រភេទ សំណួរបើក។ បន្ទាប់ពីបានស្តាប់នៃការរៀបរាប់របស់សាក្សីហើយ ប្រធានសវនាការអាចធ្វើការសាកសួរជាប្រភេទ សំណួរជាក់លាក់ ដើម្បីទទួលបានពត៌មានច្បាស់លាស់ចំពោះចំណុចណាមួយដែលខ្លួនយល់ថាមានប្រយោជន៍នៅ ក្នុងការចេញសេចក្តីសម្រេចជាដើម។

[41] មាត្រា ៣៣០ និងមាត្រា ៣៣១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[42] មាត្រា ៣២៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

- **សិទ្ធិនិយាយជាបន្តបន្ទាប់**

ក្រោយពិភាក្សាដេញដោលប្រធានសវនាការ បើកឱ្យជនដូចខាងក្រោមនេះនិយាយជាបន្តបន្ទាប់គ្នា ៖

- ដើមបណ្ដឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ជនជាប់ចោទ ដើម្បីធ្វើការកត់សម្គាល់ខ្លីៗ

- មេធាវីរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីធ្វើសេចក្ដីសន្និដ្ឋានការពារ

- ព្រះរាជអាជ្ញា ដើម្បីធ្វើសេចក្ដីសន្និដ្ឋានប្ដឹងសុំ

- មេធាវីរបស់អ្នកទទួលខុសត្រូវរដ្ឋប្បវេណី មេធាវីរបស់ជនជាប់ចោទ ដើម្បីធ្វើសេចក្ដីសន្និដ្ឋានការពារ។

ដើមបណ្ដឹងរដ្ឋប្បវេណី និងព្រះរាជអាជ្ញា អាចធ្វើការឆ្លើយតបទៅវិញបាន។ ប៉ុន្តែ ជនជាប់ចោទ និងមេធាវីរបស់ខ្លួន ត្រូវនិយាយក្រោយគេបង្អស់ជានិច្ច។ តុលាការថយខ្លួន ចូលទៅក្នុងបន្ទប់ពិភាក្សា ដើម្បីសម្រេច។ ចាប់ពីពេលនេះតទៅ គ្មានបណ្ដឹងសុំណាមួយអាចត្រូវដាក់ជូនតុលាការបានឡើយ[43] ។ ក្នុងករណីនេះ គ្មានឡីករណ៍ណាមួយអាចត្រូវបានលើកយកមកសំអាងទៀតបានទៀតទេ។ ព្រះរាជអាជ្ញា និងក្រឡាបញ្ជីមិនឱ្យចូលរួមក្នុងកិច្ចពិភាក្សាសម្រេចនេះទេ។ ការបំពេញទម្រង់ការនេះត្រូវតែកត់ត្រាទុកក្នុងកំណត់ហេតុសវនាការ និងក្នុងសាលក្រម[44]។

- **ករណីមានបទល្មើសនាពេលសវនាការ**

ប្រសិនបើមានបទល្មើសបានកើតឡើងនៅក្នុងពេលសវនាការ នោះប្រធានសវនាការនឹងមានការធ្វើកំណត់ហេតុពិនិត្យរឿងហេតុនេះ មិនត្រឹមតែប៉ុណ្ណោះ ប្រធានសវនការអាចបង្គាប់ឱ្យចាប់ និងនាំខ្លួនជនល្មើសភ្លាមៗ ជូនទៅព្រះរាជអាជ្ញា ដើម្បីថ្លឹងថ្លែងពីវិធានការដែលត្រូវចាត់ការ ។ កាលណាបទល្មើស ជាបទលហុ បទមជ្ឈិម តុលាការអាចជំនុំជម្រះជនល្មើសភ្លាមតែម្ដង បើសិនព្រះរាជអាជ្ញាប្ដឹងសុំ ហើយជនល្មើសក៏បានយល់ព្រម ។

- **សក្ខីកម្ម និងភស្តុតាង**

គ្រប់រឿងក្ដីទាំងអស់ត្រូវប្រមូលផ្តុំទៅលើភស្តុតាងនៃអំណះអំណាងរបស់គូភាគី ប៉ុន្តែក្នុងរឿងក្ដីព្រហ្មទណ្ឌវាសំខាន់ណាស់ដែលគួរតែយកចិត្តទុកដាក់ជាពិសេសក្នុងបញ្ហាភស្តុតាងនេះព្រោះក្នុងរឿងក្ដីព្រហ្មទណ្ឌភស្តុតាងមានសារៈសំខាន់ជាពិសេស ដោយសារវាប៉ះពាល់ដល់សិទ្ធិការពារខ្លួន (ការសន្មត់ទុកជាមុនថាគ្មានទោស) និងជាពិសេសទៅទៀតនោះ ជនត្រូវចោទត្រូវសន្មតថាគ្មានទោស ដរាបណាពិរុទ្ធភាពរបស់ជនជាប់ចោទមិនទាន់ត្រូវបាន

[43] មាត្រា ៣៣៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧

[44] មាត្រា ៣៣៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧

ប្រកាសទទួលស្គាល់ដោយសាលក្រមស្ថាពរ[45]។ អយ្យការ ដើមបណ្តឹងរដ្ឋប្បវេណីជាអ្នកដែលត្រូវបង្ហាញភស្តុតាងពីពិរុទ្ធភាពរបស់ជនជាប់ចោទ ។

ជាគោលការណ៍ ភស្តុតាងអាចបង្ហាញបានតាមគ្រប់មធ្យោបាយ (សក្ខីភាព ឯកសារតម្រុយ ការសារភាព...)។ ភស្តុតាងអាចជូនបានដោយសេរី ប៉ុន្តែគោលការណ៍សេរីភាពនៃភស្តុតាងនេះ ត្រូវបានសម្របសម្រួលជាមួយនឹងគោលការណ៍គ្រឹះមួយផ្សេងទៀត គឺគោលការណ៍នីត្យានុកូលភាព ដែលភស្តុតាងត្រូវតែស្ថិតក្រោមគោលការណ៍នេះចាំបាច់។ តាមការពិត គោលការណ៍សេរីភាពនៃភស្តុតាងអនុញ្ញាតឱ្យអ្នកដែលមានបន្ទុកភស្តុតាង បង្ហាញភស្តុតាងតាមគ្រប់មធ្យោបាយ និងអនុញ្ញាតឱ្យចៅក្រមអាចទទួលយក ឬបដិសេធការបង្ហាញការប្រព្រឹត្តបទល្មើស និងការបង្ហាញពីការដាក់បន្ទុកបទល្មើស[46] ។ តុលាការវាយតម្លៃដោយឥស្សរចិត្តអំពីតម្លៃនៃភស្តុតាងដែលប្រគល់ជូនដោយផ្អែកទៅលើជំនឿស្មោះត្រង់របស់ខ្លួន ។

ចម្លើយសារភាពក៏ដូចជាវិធានបង្ហាញភស្តុតាងដទៃទៀត ត្រូវដាក់ជូនតុលាការវាយតម្លៃ ។ ចម្លើយដែលទទួលបានក្រោមការបង្ខិតបង្ខំលើរូបរាងកាយ ឬផ្លូវចិត្ត ពុំមានតម្លៃជាភស្តុតាងទេ ។ ភស្តុតាងមិនអាចបានមកពីការឆ្លើយឆ្លងរវាងជនជាប់ចោទ និងមេធាវីឡើយ ។

ប្រធានតុលាការអាចបង្គាប់ឱ្យជនណាម្នាក់បង្ហាញវត្ថុតាងបាន[47]។ វត្ថុតាងក៏ត្រូវបានចាត់ទុកថាជាប្រភេទមួយនៃភស្តុតាងផងដែរ ពីព្រោះថាប្រសិនបើតុលាការធ្វើការសម្រេចដោយផ្អែកទៅលើតែបទបញ្ញត្តិច្បាប់ និងចម្លើយដែលទទួលបានពីជនរងគ្រោះ ជនជាប់ចោទសាក្សីនោះ គឺពុំមានលក្ខណៈគ្រប់គ្រាន់នោះទេ។ ដូច្នេះដើម្បីការសម្រេចសេចក្តីទទួលបានយុត្តិធម៌និងមានភាពត្រឹមត្រូវ តុលាការត្រូវឱ្យបុគ្គលពាក់ព័ន្ធយកវត្ថុតាងមកបង្ហាញខ្លួននាពេលសវនាការបាន។ វត្ថុតាងទាំងនោះ អាចជាអាវុធដែលជាមធ្យោបាយនៃការប្រព្រឹត្តបទល្មើស ឬវត្ថុផ្សេងៗទៀតដែលមានចំណងទាក់ទងជាមួយនឹងអំពើល្មើសនោះ។

- **អំពីសេចក្តីសន្និដ្ឋានចុងក្រោយ**

រហូតតល់នឹងការបិទកិច្ចពិភាក្សាដេញដោល ភាគីទាំងអស់មានឱកាស ក្នុងការធ្វើសេចក្តីសន្និដ្ឋានចុងក្រោយរបស់ខ្លួន។ សេចក្តីសន្និដ្ឋានទាំងនេះអាចធ្វើជាលាយលក្ខណ៍អក្សរ និងត្រូវចុះទិដ្ឋាការដោយប្រធានសវនាការ

[45] មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

[46] មាត្រា ៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[47] មាត្រា ៣៣២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

និងក្រឡាបញ្ជីហើយភ្ជាប់ទៅក្នុងសំណុំរឿង[48]។

- **ការពិភាក្សា ថ្លឹងថ្លែង និងសម្រេចសេចក្តីបញ្ចប់រឿង**

ចៅក្រមជំនុំជម្រះ នឹងត្រូវថយទៅធ្វើការពិភាក្សាសម្រេច ។ គ្មានទឡ្ហីករណ៍ណាមួយអាចនឹងត្រូវលើកយកមកសម្អាងទៀតបានឡើយ នៅពេលដែលចៅក្រមថយទៅពិភាក្សាសម្រេច[49]។ ក្រោយពីមានការពិភាក្សាសម្រេចសេចក្តីដោយផ្អែកលើអង្គហេតុ និងអង្គច្បាប់ ព្រមទាំងចម្លើយរបស់ភាគីក្នុងសំណុំរឿងក៏ដូចជាភស្តុតាងជាឯកសារនានារួចតុលាការនិងធ្វើការកាត់ក្តីសម្រេចសេចក្តីលើសំណុំរឿងនោះ ដោយការវិនិច្ឆ័យដោយឯករាជ្យ យុត្តិធម៌ និងសុក្រឹត្យ ។

- **ការប្រកាសសាលក្រមព្រហ្មទណ្ឌ**

ការប្រកាសសាលក្រម ត្រូវធ្វើនៅពេលសវនាការ ដែលធ្វើការពិភាក្សាដេញដោល ឬនៅពេលសវនាការលើកក្រោយ ដែលកាលបរិច្ឆេទត្រូវកំណត់ដោយប្រធានសវនាការ ។ មានន័យថា សេចក្តីសម្រេចអាចត្រូវប្រកាសនៅក្នុងថ្ងៃដដែលដែលតុលាការធ្វើការជំនុំជម្រះ ឬតុលាការអាចលើកទៅប្រកាសសេចក្តីសម្រេចរបស់ខ្លួន នៅកាលបរិច្ឆេទក្រោយទៀតក៏បាន[50]។

នៅក្នុងសាលក្រមព្រហ្មទណ្ឌអាចមានអានុភាពបាន លុះត្រាតែមានការប្រកាសសាលក្រម ហើយគ្រប់សាលក្រមត្រូវតែប្រកាសនៅពេលសវនាការសាធារណៈ ដោយប្រធានសវនាកាអានដោយសម្លេងខ្លាំងៗ ផ្នែកនៃសេចក្តីសម្រេចរបស់សាលក្រមរបស់ខ្លួន ។

ជាគោលការណ៍ដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ករណីណាក៏ដោយ សេចក្តីសម្រេចត្រូវតែធ្វើការប្រកាសក្នុងសវនាការជាសាធារណៈ[51]។ ផ្ទុយទៅវិញ ករណីខ្លះ ការប្រកាសសាលក្រមមិនមែនសុទ្ធតែត្រូវធ្វើការប្រកាសជាសាធារណៈនោះទេ កាលណាបើតុលាការយល់ឃើញថា សាធារណៈភាព បង្កឱ្យមានគ្រោះថ្នាក់ ឬផ្តល់ផលប៉ះពាល់មិនល្អពោលក្នុងរឿងព្រហ្មទណ្ឌមួយចំនួន ច្បាប់ក៏បានកំណត់រួចជាស្រេចថា ចាំបាច់ត្រូវតែប្រកាសជាអសាធារណៈផងដែរ ជាក់ស្តែងដូចជា សំណុំរឿងព្រហ្មទណ្ឌ ដែលមានជនជាប់ចោទដែលប្រព្រឹត្តបទល្មើសជាអនីតិជន[52] ។ ការកម្រិតលើការចូលរួមសវនាការ និងការប្រកាសសាលក្រមរបស់អនីតិជន ជាការស្របច្បាប់មួយ ព្រោះ

---

[48] មាត្រា ៣៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[49] មាត្រា៣៣៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[50] មាត្រា៣៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[51] មាត្រា៣១៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[52] មាត្រា៤៧ នៃច្បាប់ស្តីពីយុត្តិធម៌នីតិជន

ការកំណត់បែបនេះ ដើម្បីការពារសិទ្ធិ និងឯកជនភាពរបស់អនីតិជន និងបញ្ចៀសនូវការជះឥទ្ធិពលមិនល្អទៅលើអនាគតរបស់អនីតិជននៅថ្ងៃក្រោយ[53] ។

[53] មាត្រា៤០ នៃច្បាប់ស្តីពីសិទ្ធិកុមារ

# ជំពូកទី២
# ប្រភេទ និងទម្រង់
# សាលក្រមព្រហ្មទណ្ឌក្នុង
# លក្ខខណ្ឌតតិយុត្តិ

# ជំពូកទី ២
# ប្រភេទ និងទម្រង់សាលក្រមព្រហ្មទណ្ឌក្នុងលក្ខខណ្ឌគតិយុត្តិ

## ផ្នែកទី១ ៖ ប្រភេទនៃសាលក្រមព្រហ្មទណ្ឌ

សាលក្រមព្រហ្មទណ្ឌមានច្រើនប្រភេទទៅតាមស្ថានភាពជាក់ស្តែងនាពេលសវនាការ។ សាលក្រមព្រហ្មទណ្ឌក៏មានតាមលំដាប់លំដោយផងដែរ ទៅតាមស្ថានភាពជាក់ស្តែងក៏ដូចជាទៅតាមជម្រើសនៃការចោទប្រកាន់របស់តំណាងអយ្យការ ។ យើងអាចធ្វើការបែងចែកសាលក្រមជាពីរដំណាក់កាល គឺសាលក្រមមុនអង្គសេចក្តី និងសាលក្រមអង្គសេចក្តី ។

ចំពោះការចេញសាលក្រមព្រហ្មទណ្ឌមួយ ត្រូវការគោរពទៅតាមនីតិវិធីដែលមានកំណត់នៅក្នុងច្បាប់ជាធរមាន ។ ការធ្វើបែបនេះគឺជាការសម្រួលដល់ដំណើរការនៃកិច្ចនីតិវិធី និងការធានាបាននូវសិទ្ធិរបស់ជនជាប់ចោទ និងការផ្តល់យុត្តិធម៌មួយប្រកបដោយភាពត្រឹមត្រូវ ។

សាលក្រមដែលតុលាការចេញអាចទាក់ទងនឹងបញ្ហានៃរឿងអង្គសេចក្តី បញ្ហានីតិវិធី និងការដកហូតសេរីភាពរបស់ជនជាប់ចោទ។ ប៉ុន្តែបើយើងពិនិត្យអំពីប្រភេទនៃសាលក្រម ដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌវិញ ដោយយើងឃើញថា សាលក្រមព្រហ្មទណ្ឌត្រូវបានបែងចែក ជាសាលក្រមចំពោះមុខ សាលក្រមដែលចាត់ទុកថាចំពោះមុខ និងសាលក្រមកំបាំងមុខ ។ ទន្ទឹមនឹងនេះ ក្រៅពីប្រភេទនៃសាលក្រមព្រហ្មទណ្ឌទាំងនេះយើងឃើញថា ក្នុងក្រមនីតិវិធីព្រហ្មទណ្ឌក៏មានការហៅឈ្មោះសាលក្រមព្រហ្មទណ្ឌជាសាលក្រមលើអង្គសេចក្តី និងសាលក្រមមុនអង្គសេចក្តីផងដែរ ។ ក្រៅពីនេះការតាក់តែងសាលក្រមព្រហ្មទណ្ឌ ក៏ជាចំណុចសំខាន់ដើម្បីអាចបញ្ជាក់បានកាន់តែច្បាស់អំពីពិរុទ្ធភាពនិងរក្សាបាននូវសំអាងហេតុ និងសេចក្តីសម្រេចរបស់តុលាការមួយដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយសម្រាប់ការអនុវត្ត ។

តើសាលក្រមទាំងពីរនេះមានលក្ខណៈ និងខ្លឹមសារខុសគ្នាយ៉ាងដូចម្តេចខ្លះ ? ហើយចំពោះសាលក្រមទាំងពីរនេះ ក៏មានការបែងចែកជាប្រភេទផ្សេងៗទៀតដែរឬទេ? ដើម្បីឱ្យយល់ច្បាស់ថែមទៀត យើងនឹងធ្វើការស្វែងយល់ឱ្យកាន់តែក្បោះក្បាយ ពីអត្ថន័យនៃសាលក្រមទាំងពីរនេះ ដោយជាដំបូងយើងនឹងធ្វើការបកស្រាយពី សាលក្រមមុនអង្គសេចក្តី ជាមុនសិន ។

## ១.១. សាលក្រមមុនអង្គសេចក្ដី

### ១.១.១. សញ្ញាណទូទៅនៃសាលក្រមមុនអង្គសេចក្ដី

នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ឃើញថាមិនបានកំណត់ច្បាស់អំពីអត្ថន័យនៃសាលក្រមមុនអង្គសេចក្ដីនេះឡើយ ប៉ុន្តែយោងទៅតាមខ្លឹមសារអត្ថន័យដែលមាននៅក្នុងសាលក្រមនេះ យើងអាចទាញជានិយមន័យមួយបានថា សាលក្រមមុនអង្គសេចក្ដី គឺជាសេចក្ដីសម្រេចរបស់តុលាការដែលធ្វើឡើងដោយចៅក្រមជំនុំជម្រះ ដែលសាលក្រមនេះសម្រេចបញ្ហានីតិវិធី ដែលទាក់ទងនឹងនីតិវិធីផ្សេងៗមុនរឿងអង្គសេចក្ដី ឬក៏សម្រេចពីការចាត់ឱ្យធ្វើការស៊ើបសួរបន្ថែមណាមួយ ម្យ៉ាងទៀតសេចក្ដីសម្រេចនេះមិនប៉ះពាល់ដល់នីតិវិធី ឬអង្គសេចក្ដីនៃរឿងក្ដីនោះឡើយ ។ ជារួមមក សាលក្រមមុនសេចក្ដីនេះ គឺមិនមែនសម្រេចសេចក្ដីទៅលើអង្គហេតុនៃបទល្មើស ក្នុងរឿងព្រហ្មទណ្ឌនោះឡើយ ពោលគឺសម្រេចសេចក្ដីតែទៅលើ អង្គហេតុផ្សេងៗដែលកើតមាននៅក្នុងសំណុំរឿង ដូចជាការសម្រេចឃុំខ្លួនជនជាប់ចោទជាបណ្ដោះអាសន្ន ឬការដោះលែងជនជាប់ចោទឱ្យមានសេរីភាព ដោយដាក់ស្ថិតក្រោមការត្រួតពិនិត្យពីតុលាការ ក៏ដូចជាសម្រេចអំពីដាក់បញ្ចូលសំណុំរឿងជាដើម ។ ជាគោលការណ៍ តុលាការពិនិត្យធាតុផ្សំនៃសំណុំរឿង និងស្ដាប់ចម្លើយភាគីទាំងអស់ដែលពាក់ព័ន្ធទៅនឹងរឿងក្ដី ។ ប្រសិនបើយល់ឃើញថា មានករណីចាំបាច់ត្រូវស្រាវជ្រាវបន្ថែមនោះ តុលាការអាចបង្គាប់តាមសាលក្រមឱ្យស៊ើបសួរបន្ថែមបាន ដើម្បីស្វែងរកការពិតឱ្យបានច្បាស់លាស់ ។

### ១.១.២. ប្រភេទនៃសាលក្រមមុនអង្គសេចក្ដី

សាលក្រមមុនអង្គសេចក្ដី មានបែងចែកជាច្រើនប្រភេទជាក់ស្ដែងទៅស្ថានភាព ឬហេតុការណ៍ដែលកើតមានឡើង។ ចំពោះសាលក្រមមុនសេចក្ដី អាចបែងចែកជា ០៤ ប្រភេទដូចជា៖ សាលក្រមមុនអង្គសេចក្ដីអំពីការឃុំខ្លួន, សាលក្រមមុនអង្គសេចក្ដីអំពីអញ្ញាត្រកម្ម សាលក្រមមុនអង្គសេចក្ដីអំពីបញ្ចូលសំណុំរឿង និងសាលក្រមចាត់របៀប។

#### ១.១.២.១. សាលក្រមមុនអង្គសេចក្ដីស្ដីពីសេរីភាពជនជាប់ចោទ

សាលក្រមនេះ គឺជាសាលក្រមមុនអង្គសេចក្ដីមួយប្រភេទ ដែលតុលាការសម្រេចអំពីបញ្ហាសេរីភាពរបស់ជនជាប់ចោទ ដោយសាលក្រមនេះសម្រេចសេចក្ដីអំពីការឃុំខ្លួនជនជាប់ចោទជាបណ្ដោះអាសន្ន ឬការបង្គាប់ឱ្យដោះលែងជនជាប់ចោទឱ្យមានសេរីភាព មុនពេលមានការសម្រេចដល់រឿងសេចក្ដី ដូចក្នុងលក្ខខណ្ឌតុលាការទទួល

សំណុំរឿងតាមកំណត់ហេតុស្ដីពីការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាមជាដើម[54] ។ ករណីនេះ ជនជាប់ចោទត្រូវឃុំគ្រង ដោយកងការពារ រហូតដល់សាមីខ្លួនចូលបង្ហាញនៅមុខតុលាការ ដោយការបង្ហាញខ្លួននេះ ត្រូវប្រព្រឹត្តនៅក្នុងថ្ងៃ នោះតែម្តង ក្នុងពេលបង្ហាញខ្លួននោះ តុលាការត្រូវធ្វើចំណាត់ការដូចតទៅ ៖

- ជនជាប់ចោទជានីតិជន
- ផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់ជនជាប់ចោទ
- ពិនិត្យមើលរបាយការណ៍សង្ខេបរឿងហេតុ ដែលចោទប្រកាន់
- ប្រាប់ដល់ជនជាប់ចោទថា សាមីខ្លួនមានរយៈពេលដើម្បីរៀបចំការពារខ្លួន ។

ករណីនេះ ប្រសិនបើជនជាប់ចោទសុំពន្យាពេល ដោយសារបញ្ហាចាំបាច់ណាមួយ ដូចជាត្រូវការមេធាវីការពារ សិទ្ធិជាដើម ឬប្រសិនបើតុលាការយល់ឃើញថារឿងនោះមិនទាន់អាចជំនុំជម្រះបាននោះទេ ត្រូវលើកទៅសវនាការ ក្រោយទៀត ដោយក្នុងករណីនេះ តុលាការនឹងចេញសាលក្រមមុនអង្គសេចក្តី ដែលសម្រេចឱ្យឃុំខ្លួនជនជាប់ចោទ ជាបណ្តោះអាសន្ន ដែលមានសំអាងហេតុច្បាស់លាស់ និងត្រូវចេញដីកាបង្គាប់ឱ្យឃុំខ្លួន ដោយយោងតាម លក្ខខណ្ឌនៃមាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ ប៉ុន្តែតុលាការក៏អាចសម្រេចមិនឃុំខ្លួនជនជាប់ចោទជា បណ្តោះអាសន្នក៏បាន តាមឆន្ទានុសិទ្ធិ និងការយល់ឃើញរបស់ខ្លួន ដើម្បីរង់ចាំតុលាការជំនុំជម្រះលើអង្គសេចក្តី ។ តុលាការត្រូវកំណត់កាលបរិច្ឆេទបើកសវនាការ និងការប្រកាសសាលក្រមអង្គសេចក្តីជាថ្មី ក្នុងរយៈពេលមិន អោយលើសពី ០២ សប្តាហ៍ គិតចាប់ពី ថ្ងៃនៃការចូលបង្ហាញខ្លួន នៅតុលាការនោះ ។

តាមការអនុវត្ត មានករណីខ្លះចៅក្រមស៊ើបសួរបានចេញដីកាឱ្យចាប់ខ្លួនជនត្រូវចោទណាម្នាក់ ហើយជននោះ ត្រូវបានចាប់ខ្លួនក្រោយពីចៅក្រមស៊ើបសួរបានបញ្ជូនសំណុំរឿងមកចៅក្រមជំនុំជម្រះរួចហើយ ក្នុងករណីនេះជន ជាប់ចោទមិនអាចត្រូវនាំទៅបង្ហាញខ្លួនចំពោះមុខចៅក្រមស៊ើបសួរទៀតទេ គឺត្រូវបញ្ជូនមកចំពោះមុខចៅក្រមជំនុំ ជម្រះ បន្ទាប់មកចៅក្រមជំនុំជម្រះ ត្រូវបើកសវនាការដើម្បីសម្រេចថាឃុំ ឬមិនត្រូវឃុំជននោះ តាមរយៈសាលក្រម មុនអង្គសេចក្តី ដូចករណីខាងលើផងដែរ ។

### ១.១.២.២. សាលក្រមមុនអង្គសេចក្តីអំពីអញ្ញាត្រកម្ម

សាលក្រមមុនអង្គសេចក្តីនេះ កើតមានឡើងដោយសារមានអំពើអញ្ញាត្រកម្មបានកើតឡើង ។ ក្នុងករណីមាន អញ្ញាត្រកម្ម ត្រូវតែលើកឡើងមុនដំណាក់កាលការពារដល់អង្គសេចក្តី បើពុំដូច្នេះទេ គឺពុំអាចទទួលបានឡើយ ។ តុលាការសម្រេចអំពីអញ្ញាត្រកម្មតាមសាលក្រមមួយដាច់ដោយឡែកពីសាលក្រមអង្គសេចក្តី ប៉ុន្តែតុលាការ ក៏អាច

[54] មាត្រា៣០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

បញ្ចូលឧប្បត្តិហេតុទៅនឹងអង្គសេចក្តី ហើយសម្រេចតាមសាលក្រមតែមួយដូចគ្នា អំពីអញ្ញាត្រកម្មជាមួយនឹងអង្គសេចក្តីដែរ ។[55]

ក្នុងករណីនេះ អញ្ញាត្រកម្មអាចជា៖

• **មោឃភាពនៃនីតិវិធី** ៖ ប្រសិនបើតុលាការទទួលបណ្តឹងតាមរយៈនីតិវិធីបង្គាប់ឱ្យចូលបង្ហាញខ្លួន ឬការបញ្ជូនទៅជំនុំជម្រះផ្ទាល់ តុលាការអាចសម្រេចអំពីអញ្ញត្រកម្មស្តីពីមោឃភាពនៃនីតិវិធី ដែលភាគីដាក់ជូនពិនិត្យ តែលើកលែងតែករណីដែលតុលាការទទួលជំនុំជម្រះតាមដីកាបញ្ជូនរឿងទៅជំនុំជម្រះ ។

• **សមត្ថកិច្ចរបស់តុលាការ** ៖ ភាគីនៃសំណុំរឿងលើកឡើងថា តុលាការ ពុំមានសមត្ថកិច្ចជំនុំជម្រះលើអង្គសេចក្តីនេះទេ ។

• **បញ្ហាបន្ទាប់បន្សំ** ៖ ជាបញ្ហា ដែលអាចនឹងលុបលាងចរិកនៃបទល្មើសពីអំពីដែលចោទប្រកាន់លើជនជាប់ចោទ ។ បញ្ហាបន្ទាប់បង្សំ ច្រើនទាក់ទងនឹងបញ្ហាពីសិទ្ធិខាងកម្មសិទ្ធិ និងសិទ្ធិប្រត្យិក្សលើអចលនវត្ថុ និងឋានៈបុគ្គល ដែលជាសមត្ថកិច្ចផ្តាច់មុខរបស់តុលាការរដ្ឋប្បវេណី[56]។ ក្នុងករណីអំពីបញ្ហានេះ តុលាការអាចសម្រេចសេចក្តីអាចជា ៖ សាលក្រមប្រកាសថា មិនអាចទទួលបាននូវបញ្ហាបន្ទាន់បង្ខំ ។ សាលក្រមប្រកាសថា ទទួលនូវបញ្ហាបន្ទាន់បង្ខំ ដោយត្រូវបង្អង់មិនទាន់សម្រេចលើអង្គសេចក្តី ហើយត្រូវកំណត់រយៈពេលឲ្យភាគីពាក់ព័ន្ធប្តឹងទៅតុលាការមានសមត្ថកិច្ច ។ បើភាគី បានបង្ហាញភស្តុតាងថា បានប្តឹងទៅតុលាការមានសមត្ថកិច្ចរួចហើយ នោះតុលាការនឹងកំណត់រយៈពេលថ្មីមួយទៀត ដើម្បីឱ្យបានសេចក្តីសម្រេចអំពីបញ្ហានេះ ។ ឧទាហរណ៍ តុលាការ បានទទួលសំណុំរឿងព្រហ្មទណ្ឌ មកជំនុំជម្រះពីបទ លួចអចលនវត្ថុរបស់អ្នកដទៃ ដែលមានចែងតាមមាត្រា ២៥៤ នៃច្បាប់ភូមិបាលឆ្នាំ២០០១។ ជនជាប់ចោទ បានលើកឡើងថា អចលនវត្ថុ ដែលខ្លួនបានលក់នោះ ជារបស់ខ្លួន ។ ចំណុចនេះ គឺជាបញ្ហាបន្ទាន់។ ការសម្រេចថា នរណាជាកម្មសិទ្ធិករលើអចលនវត្ថុ គឺជាសមត្ថកិច្ចរបស់តុលាការរដ្ឋប្បវេណី។ ហេតុដូចនេះ តុលាការព្រហ្មទណ្ឌ ត្រូវតែបង្អង់ការសម្រេចសេចក្តីរបស់ខ្លួនសិន ដើម្បីតុលាការរដ្ឋប្បវេណី សម្រេចពីវិវាទកម្មសិទ្ធិជាមុន ។ ប្រសិនបើ តុលាការរដ្ឋប្បវេណី បានសម្រេចជាស្ថាពរថា អចលនវត្ថុនោះ ជាទ្រព្យសម្បត្តិរបស់ជនជាប់ចោទ នោះ តុលាការព្រហ្មទណ្ឌនឹងធ្វើការសម្រេចសេចក្តីតាមសាលក្រមឱ្យជនជាប់ចោទ រួចផុតពីបទចោទប្រកាន់ ព្រោះថាគ្មានបទល្មើសកើតឡើងទេ ។ ក្នុងករណីដែល តុលាការរដ្ឋប្បវេណី បានសម្រេចជាស្ថាពរថា អចលនវត្ថុនោះ មិនមែនជាទ្រព្យសម្បត្តិរបស់ជនជាប់ចោទទេនោះ តុលាការព្រហ្មទណ្ឌនឹងធ្វើការសម្រេចសេចក្តី

[55] មាត្រា ៣៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[56] មាត្រា ៣៤៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

តាមសាលក្រមអង្គសេចក្តី ផ្តន្ទាទោសជនជាប់ចោទ ប្រសិនតុលាការរកឃើញថា ជនជាប់ចោទពិតជាបានលក់អចលនវត្ថុនោះពិតមែន[57] ។

**១.១.២.៣. សាលក្រមមុនអង្គសេចក្តីអំពីបញ្ចូលសំណុំរឿង**

សាលក្រមមុនអង្គសេចក្តីអំពីបញ្ចូលសំណុំរឿងនេះ គឺជាសាលក្រមដែលចៅក្រមសម្រេចបញ្ចូនសំណុំរឿងមួយ ទៅចូលក្នុងសំណុំរឿងមួយទៀត កាលណាតុលការរកឃើញថាក្នុងសំណុំរឿងទាំងពីរនោះមាន អង្គហេតុ និងបុគ្គលដែលជាប្រព្រឹត្តបទល្មើសតែមួយ ។ កាលណាតុលាការបានទទួលនីតិវិធីច្រើន ដែលមានអង្គហេតុច្រើនជាប់ទាក់ទងគ្នា តុលាការអាចបង្គាប់ឱ្យបញ្ចូលសំណុំរឿងទាំងនោះជាមួយគ្នាបាន ។ បើយើងក្រឡេកមើលដំណាក់កាលចោទប្រកាន់ ព្រះរាជអាជ្ញាអាចសម្រេចបំបែកសំណុំរឿង ដូច្នេះនៅក្នុងដំណាក់កាលជំនុះជម្រះនេះ ក្រមនីតិវិធីព្រហ្មទណ្ឌប្រគល់ឱ្យចៅក្រមអាចបញ្ជូនសំណុំរឿងដែលមានអង្គហេតុច្រើនជាប់ទាក់ទងគ្នាបាន ។ ការបញ្ចូលសំណុំរឿងនេះ អាចធ្វើឡើងតាមការស្នើសុំរបស់តំណាងអយ្យការ, ជនជាប់ចោទ, មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ឬតាមការផ្តើមគំនិតរបស់ចៅក្រមផ្ទាល់ ។ សាលក្រមមុនអង្គសេចក្តីអំពីបញ្ចូលសំណុំរឿងនេះ ត្រូវសំអាងហេតុឱ្យបានច្បាស់ផងដែរ ថាសំណុំរឿងទាំងពីរពិតជាមានអំពើប្រព្រឹត្ត កាលបរិច្ឆេទ និងបុគ្គលដែលជាប្រព្រឹត្តបទល្មើសតែមួយ។

**១.១.២.៤. សាលក្រមចាត់របៀប**

សាលក្រមចាត់របៀប គឺជាសេចក្តីសម្រេចចេញក្នុងពេលដំណើរការនីតិវិធី ដើម្បីរៀបចំការស៊ើបអង្កេតណាមួយ ដែលតុលាការយល់ឃើញថា ខ្វះចន្លោះមិនទាន់គ្រប់គ្រាន់ក្នុងការសម្រេចសេចក្តីលើអង្គសេចក្តីលើសំណុំរឿងព្រហ្មទណ្ឌនោះ តាមការស្នើសុំរបស់ភាគីណាមួយ ឬតាមការស្នើសុំរបស់មេធាវីដោយសារតែរឿងនោះមានភាពមិនទាន់ច្បាស់លាស់។ ដូច្នេះចៅក្រមត្រូវតែចេញសាលក្រមចាត់របៀបឱ្យចៅក្រមស៊ើបសួរធ្វើការស៊ើបអង្កេតលើករណីឬសំណុំរឿងក្តីនោះឡើងវិញ។ ការចេញសាលក្រមរបៀប គឺមិនមានកំណត់ រយៈពេលច្បាស់លាស់ទេ ប៉ុន្តែចៅក្រមត្រូវគិតអំពី ចិរវេលា ដែលគូភាគី ឬសមត្ថកិច្ចជំនាញ អាចផ្តល់ភ័ស្តុតាងជូនក្នុងរយៈពេលណាមួយសមរម្យ មិនអាចទុកចោលដោយមិនធ្វើការដាស់តឿនដល់ចៅក្រមស៊ើបសួរ ឬភាគីពាក់ព័ន្ធនោះឡើយ។ យើងក៏អាចធ្វើការកត់សម្គាល់បានផងដែរថា សាលក្រមមួយជាសាលក្រមចាត់របៀបបាន តាមរយៈការពិនិត្យ ផ្នែកសេចក្តីសម្រេចក្នុងលិខិតសាលក្រម ។ ប្រសិនបើ តុលាការបានសម្រេចបង្វិលសំណុំរឿងទៅចៅក្រមស៊ើបសួរឱ្យធ្វើការស៊ើបសួរបន្ថែមដែលតុលាការត្រូវធ្វើមុនដំណាក់កាលសម្រេចលើអង្គសេចក្តី ។

[57] សៀវភៅនីតិវិធីព្រហ្មទណ្ឌ ស្នាដៃនិពន្ធរបស់ សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធិ និងចាំង ស៊ីណាត ទំព័រ ៥៩-៦០ ឆ្នាំ២០១៤

តុលាការបង្គាប់ឱ្យប្រធានសវនាការ ចៅក្រមមួយរូបនៃក្រុមប្រឹក្សាជំនុំជម្រះ ឬចៅក្រមដទៃទៀតនៃសាលាដំបូងធ្វើការសាកសួរបន្ថែម ប្រសិនបើយល់ឃើញថាការស្រាវជ្រាវថ្មីជាការចាំបាច់[58]។ ចៅក្រមដែលទទួលបន្ទុកស៊ើបសួរបន្ថែមនេះ អាចប្រើសិទ្ធិអំណាចដូចចៅក្រមស៊ើបសួរដែរ ។ សាលក្រមចាត់របៀប មិនអាចប្តឹងឧទ្ធរណ៍តែឯងបានទេ មានន័យថា សាលក្រមចាត់របៀប អាចដាក់ជូនសាលាឧទ្ធរណ៍ពិនិត្យបាន លុះត្រាតែព្រមគ្នាជាមួយនឹងសាលក្រមលើអង្គសេចក្តី ។ ប៉ុន្តែសាលក្រមចាត់របៀប ដែលបញ្ចប់នីតិវិធីអាចប្តឹងឧទ្ធរណ៍បាន[59] ។

តុលាការ អាចចុះទៅកាន់គ្រប់ទីកន្លែងនៃដែនដីជាតិ ក្នុងផលប្រយោជន៍សម្តែងឱ្យឃើញការពិត។ ក្នុងករណីនេះ តុលាការត្រូវតែមានព្រះរាជអាជ្ញា និងក្រឡាបញ្ជីអមដំណើរជានិច្ច។ ជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ព្រមទាំងមេធាវី ក៏អាចជូនដំណើរតុលាការបានដែរ ប្រសិនបើខ្លួនបានស្នើសុំឱ្យចុះដល់ទីកន្លែងនោះ។ ប្រតិបត្តិការទាំងនេះ ត្រូវតែមានធ្វើកំណត់ហេតុ[60] ។

- **ការស្វែងរកព័ត៌មានបន្ថែមដោយតុលាការ** ៖ ប្រសិនបើយល់ឃើញថា ការស្រាវជ្រាវថ្មីជាការចាំបាច់តុលាការអាចបង្គាប់តាមសាលក្រមឱ្យស៊ើបសួរបន្ថែម ។ ហើយអ្នកដែលមានសមត្ថកិច្ចធ្វើការស៊ើបសួរបន្ថែមរួមមាន៖

  - ប្រធានសវនាការ
  - ចៅក្រមមួយរូបនៃក្រុមប្រឹក្សាជំនុំជម្រះ កាលណាតុលាការសម្រេចជាក្រុមសមូហភាព
  - ចៅក្រមដទៃទៀត នៃតុលាការជាន់ដំបូង។

សាលក្រមដែលបង្គាប់ឱ្យធ្វើការសាកសួរបន្ថែម ត្រូវចាត់តាំងចៅក្រមឱ្យទទួលភារកិច្ចនេះ ។ នៅក្នុងលក្ខខណ្ឌដូចគ្នានឹងចៅក្រមស៊ើបសួរ ចៅក្រមនេះអាចចុះទៅលើដែនដីវិសាលភាពនៃដែនដីសមត្ថកិច្ចតុលាការ ឬលើគ្រប់វិសាលភាពនៃដែនដីជាតិ ។ ក្នុងករណីនេះ តុលាការអាចស្តាប់ចម្លើយសាក្សី ធ្វើការឆែកឆេរ ចាប់យកវត្ថុតាង បង្គាប់ឱ្យធ្វើកោសលវិច័យ ។ ដើម្បីអនុវត្តការស៊ើបសួរបន្ថែមនេះ ចៅក្រម អាចចេញដីកាបង្គាប់ឱ្យសួរជំនួសបានផងដែរ ។

## ១.២. សាលក្រមលើអង្គសេចក្តី

### ១.២.១. សញ្ញាណទូទៅនៃសាលក្រមលើអង្គសេចក្តី

សាលក្រមអង្គសេចក្តី ជាសាលក្រមដែលតុលាការសម្រេចសេចក្តីទៅលើបញ្ហាអង្គសេចក្តី ដែលចៅក្រមជំនុំជម្រះធ្វើការថ្លឹងថ្លែងកាត់ក្តីអំពីអង្គហេតុ ដែលមាននៅក្នុងសំណុំរឿងព្រហ្មទណ្ឌណាមួយប៉ុណ្ណោះ ដែលសាលក្រម

[58] មាត្រា៣៣៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[59] មាត្រា៣៨៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[60] មាត្រា៣៣៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

នេះសម្រេចថាជនជាប់ចោទមាន ឬគ្មានពិរុទ្ធភាព ចំពោះអំពើទាំងឡាយដែលបង្ហាញក្នុងដីកាបញ្ជូនមកជំនុំជម្រះ, ដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬកំណត់ហេតុនៃការបង្ហាញខ្លួនភ្លាម ។

ចំពោះសាលក្រមមួយ យើងសម្គាល់ថាសាលក្រមនោះជាសាលក្រមលើអង្គសេចក្តី ពោលលក្ខណៈ សម្គាល់ដែលយើងត្រូវពិនិត្យនោះ គឺត្រូវពិនិត្យមើលសេចក្តីសម្រេចរបស់សាលក្រមនោះ ថាតើតុលាការសម្រេចផ្តន្ទាទោស ឬឱ្យរួចខ្លួនពីបទចោទ ក៏ដូចជាសេចក្តីសម្រេចនោះសម្រេចពីសំណងរដ្ឋប្បវេណីជាដើម ។

### ១.២.២. ប្រភេទនៃសាលក្រមអង្គសេចក្តី

សាលក្រមលើអង្គសេចក្តី មានច្រើនប្រភេទជាក់ស្តែងទៅស្ថានភាព ឬហេតុការណ៍ដែលកើតមានឡើង ។ ចំពោះសាលក្រមអង្គសេចក្តី អាចបែងចែកជា ០៣ ប្រភេទ ដូចជា ៖ សាលក្រមចំពោះមុខ សាលក្រមដែលចាត់ទុកថាចំពោះមុខ និងសាលក្រមកំបាំងមុខ[61] ។

#### ១.២.២.១. សាលក្រមចំពោះមុខ

សាលក្រមចំពោះមុខ គឺជាសាលក្រមដែលប្រកាសនាពេលសវនាការជាសាធារណៈ ហើយ មានវត្តមានរបស់គូភាគីនៃបណ្តឹងទាំងអស់ចូលរួមបង្ហាញខ្លួន ។ សាលក្រមចំពោះមុខនេះ នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ មិនបានឱ្យនិយមន័យឱ្យបានច្បាស់លាស់នោះទេ ។ ប៉ុន្តែយើងអាចកំណត់សម្គាល់ចំពោះសាលក្រមនេះបានដោយពិនិត្យលើស្ថានភាពជាក់ស្តែងនាពេលសវនាការ ដែលជាហេតុនាំឲ្យតុលាការចេញសាលក្រមចំពោះមុខ ។ សាលក្រមចំពោះមុខរួមមាន ០៣ប្រភេទផងដែរ ដូចជា៖

- **សាលក្រមចំពោះមុខជនជាប់ចោទ ៖** គឺជាសាលក្រមដែលចេញនៅពេលដែលជនជាប់ចោទបាន បង្ហាញខ្លួននាពេលសវនាការ ។ ពោលបើជនជាប់ចោទបានចូលបង្ហាញខ្លួន នៅពេលសវនាការបានឆ្លងកាត់ដំណើរការជំនុំជម្រះ ដូចជាកិច្ចពិភាក្សាការដេញដោល និងសួរចម្លើយរួច ហើយតុលាការក៏បានចេញសាលក្រម ហើយសាលក្រមដែលចេញនោះ ត្រូវបានកំណត់ថាជាសាលក្រមចំពោះមុខជនជាប់ចោទ ។ ជារួម មានន័យថាកាលណា បើជនជាប់ចោទ មានវត្តមាននៅពេលដែលតុលាការបើកសវនាការជំនុំជម្រះលើសំណុំរឿងរបស់ខ្លួននោះ សាលក្រមដែលតុលាការប្រកាស គឺជាសាលក្រមចំពោះមុខជនជាប់ចោទហើយ ។ម្យ៉ាងទៀត ករណីបើជនជាប់ចោទបានចាកចេញពីបន្ទប់សវនាការក៏ដោយ ក្នុងអំឡុងពេលសវនាការមិនទាន់បញ្ចប់ ឬទោះបីជាជនជាប់ចោទត្រូវបានតុលាការសួរចម្លើយនៅក្រៅបន្ទប់សវនាការ ក្នុងលក្ខខណ្ឌដែលសាមីជនជាប់ចោទ ពុំអាចបង្ហាញខ្លួនបានដោយសារមូលហេតុស្ថានភាពសុខភាព ឬក៏មូលហេតុធ្ងន់ធ្ងរផ្សេងទៀតដែលបណ្តាលឱ្យជនជាប់ចោទមិនអាចចូលបង្ហាញខ្លួននាពេល

[61] មាត្រា ៣៦០ ៣៦១ និងមាត្រា ៣៦២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

សវនាការ[62] ក៏ដោយ ក៏សាលក្រមដែលបានប្រកាសនោះ ក៏នៅតែជាសាលក្រមចំពោះមុខជនជាប់ចោទដដែល ។ សាលក្រមចំពោះមុខនៅក្នុងរឿងព្រហ្មទណ្ឌមិនចាំបាច់ត្រូវបញ្ជូន ឬជូនដំណឹង ដល់ជនជាប់ចោទនោះទេ[63] ។ សាលក្រមចំពោះមុខ ជនជាប់ចោទ អាចប្ដឹងឧទ្ធរណ៍បាន[64]។

- **សាលក្រមចំពោះមុខដើមបណ្ដឹងរដ្ឋប្បវេណី** ៖ គឺជាសាលក្រមដែលប្រកាសនាពេលសវនាការជាសាធារណៈហើយមានការចូលមកបង្ហាញខ្លួននាពេលសវនាការពីដើមបណ្ដឹងរដ្ឋប្បវេណី ឬមានអ្នកតំណាងត្រឹមត្រូវបានចូលរួម ។ កាលណាបើដើមបណ្ដឹងរដ្ឋប្បវេណី ចូលបង្ហាញខ្លួននៅក្នុងពេលសវនាការនោះ តុលាការ នឹងចេញសាលក្រម ហើយសាលក្រមនោះត្រូវកំណត់ថា ជាសាលក្រមចំពោះមុខដើមបណ្ដឹងរដ្ឋប្បវេណី ។ សាលក្រមចំពោះមុខដើមបណ្ដឹងរដ្ឋប្បវេណី មិនចាំបាច់ត្រូវបញ្ជូន ឬជូនដំណឹងដល់ដើមបណ្ដឹងរដ្ឋប្បវេណីទេ ។ សាលក្រមចំពោះមុខនេះ ដើមបណ្ដឹងរដ្ឋប្បវេណី អាចប្ដឹងឧទ្ធរណ៍បាន[65]។ ក្នុងរឿងព្រហ្មទណ្ឌ មិនមែនគ្រប់សំណុំរឿងសុទ្ធតែមានដើមបណ្ដឹងរដ្ឋប្បវេណីទេ ដូចជាសំណុំរឿងនៃបទល្មើស ប្រើប្រាស់ ឬជួញដូរសារធាតុញៀនដោយខុសច្បាប់ជាដើម គឺពុំមានដើមបណ្ដឹងរដ្ឋប្បវេណីទេ ។ ដូច្នេះលុះត្រាតែសំណុំរឿងនោះមានដើមបណ្ដឹងរដ្ឋប្បវេណីផងដែរ ទើបមានសាលក្រមចំពោះមុខដើមបណ្ដឹងរដ្ឋប្បវេណី ។
- **សាលក្រមចំពោះមុខអ្នកទទួលខុសត្រូវរដ្ឋប្បវេណី** ៖ ប្រសិនបើអ្នកទទួលខុសត្រូវរដ្ឋប្បវេណីចូល បង្ហាញខ្លួននៅក្នុងពេលសវនាការនោះ តុលាការនឹងចេញសាលក្រមចំពោះមុខអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ។ សាលក្រមចំពោះមុខអ្នកទទួលខុសត្រូវរដ្ឋប្បវេណី មិនចាំបាច់ត្រូវបញ្ជូន ឬជូនដំណឹងដល់អ្នកទទួលខុសត្រូវរដ្ឋប្បវេណីទេ ។ សាលក្រមចំពោះមុខនេះ អ្នកទទួលខុសត្រូវរដ្ឋប្បវេណី អាចប្ដឹងឧទ្ធរណ៍បាន[66] ។

#### ១.២.២.២. សាលក្រមចាត់ទុកថាចំពោះមុខ

សាលក្រមដែលចាត់ទុកថាចំពោះមុខ គឺជាសាលក្រមដែលត្រូវបានប្រកាសនៅពេលសវនាការជាសាធារណៈ ហើយជនជាប់ចោទមិនបានចូលបង្ហាញខ្លួនក្នុងសវនាការទេ ប៉ុន្តែសាមីខ្លួនបានដឹង ឬក៏បានទទួលពីដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬបានដឹងបានទទួលពីដីកាកោះហៅចូលរួមសវនាការនោះ មានន័យថា សាលក្រម ដែលតុលាការប្រកាសត្រូវចាត់ទុកថាជា សាលក្រមចំពោះមុខជនជាប់ចោទ ។ សាលក្រមចាត់ថាចំពោះមុខ ត្រូវតែឱ្យដំណឹងដល់

[62] មាត្រា៣០៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧
[63] មាត្រា៣៦០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧
[64] មាត្រា៣០៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧
[65] មាត្រា ៣៦៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧
[66] មាត្រា ៣៦៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ជនជាប់ចោទ ។ សាលក្រមចាត់ថាចំពោះមុខនេះ ជនជាប់ចោទ អាចប្តឹងឧទ្ធរណ៍បាន ។ ទោះជានៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មិនបានបញ្ជាក់ឲ្យអំពី សាលក្រមដែលចាត់ទុកថាចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីក្តី តែបើយោងតាមមាត្រា ៣៦១ យើងក៏អាចសន្មតបានថា ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណីមិនបានចូលបង្ហាញខ្លួន នៅក្នុងពេលសវនាការទេ ហើយសាមីខ្លួនបានដឹងពីដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬបានដឹងអំពីការកោះហៅនោះ ហើយតុលាការបានប្រកាសសាលក្រមនោះ សាលក្រមចាត់ទុកថាចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី ។ ចំពោះអ្នកទទួលខុសត្រូវរដ្ឋប្បវេណីក៏ដូចគ្នា កាលណាបើអ្នកទទួលខុសត្រូវរដ្ឋប្បវេណី មិនបានចូលបង្ហាញខ្លួននៅក្នុងពេលសវនាការទេ ហើយសាមីខ្លួនបានដឹងពីដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬបានដឹងអំពីការកោះហៅនោះ ហើយតុលាការបានប្រកាសសាលក្រមនោះ សាលក្រមចាត់ទុកថាចំពោះមុខអ្នកទទួលខុសត្រូវរដ្ឋប្បវេណីបាន ។ សាលក្រមចាត់ថាចំពោះមុខ ត្រូវឱ្យដំណឹងដល់ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ។ សាលក្រមចាត់ថាចំពោះមុខនេះ ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី អាចប្តឹងឧទ្ធរណ៍បាន ។

ម្យ៉ាងទៀត ក្នុងករណីដែលជនជាប់ចោទ, ដើមបណ្តឹងរដ្ឋប្បវេណី, ជនរងគ្រោះ និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណីបន្ទាប់ពីខ្លួនទទួលដំណឹងពីកាលបរិច្ឆេទនៃសវនាការជំនុំជម្រះក្តី ហើយឃើញថាខ្លួនមិនអាចចូលមកបង្ហាញខ្លួននាពេលសវនាការនោះ ដោយខ្លួននឹងអវត្តមាន តែសាមីខ្លួនមានការផ្តល់ដំណឹងជាមុនដល់តុលាការក្នុងអំឡុងពេលសមរម្យមុនថ្ងៃសវនាការ ព្រមទាំងបង្ហាញពីមូលហេតុនៃការអវត្តមានរបស់ខ្លួនផងនោះ ហើយបើមូលហេតុនោះតុលាការយល់ឃើញថាមានហេតុផលសមរម្យ អាចទទួលយកបានតុលាការអាចសម្រេចលើករឿងទៅជំនុំជម្រះនៅសវនាការលើកក្រោយបាន ដោយធ្វើការកំណត់កាលបរិច្ឆេទថ្មី និងធ្វើការជូនដំណឹងតាមរយៈដីកាកោះហៅ ។

### ១.២.២.៣. សាលក្រមកំបាំងមុខ

នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ សាលក្រមកំបាំងមុខ គឺជាសាលក្រម ដែលបានបើកសវនាការ សម្រេចសេចក្តីដោយគ្មានវត្តមានរបស់ភាគីណាមួយ ឬភាគីនោះខកខានមិនបង្ហាញខ្លួន នៅពេលជម្រះក្តី ។ ដែលមានន័យថាបន្ទាប់ពីរឿងហេតុត្រូវបានស៊ើបអង្កេតចប់សព្វគ្រប់តាមនីតិវិធីហើយ តុលាការត្រូវលើកយករឿងហេតុនោះមកជំនុំជម្រះ ហើយនៅពេលដែលដល់ថ្ងៃកំណត់សវនាការ បើភាគីណាមួយអវត្តមាន ក៏តុលាការអាចជំនុំជម្រះលើសំណុំរឿងបានដែរ ទោះបីជាជនជាប់ចោទអវត្តមានក៏ដោយ ក៏តុលាការនោះតែអាចសម្រេចសេចក្តី ដោយតុលាការត្រូវតែស្វែងរកឱ្យឃើញការពិតតាមរយៈ ការស្តាប់ចម្លើយភាគីដទៃ សាក្សី ភស្តុតាងណាដែលមាននៅក្នុងសំណុំរឿង ប៉ុន្តែសេចក្តីវិនិច្ឆ័យ ឬសេចក្តីសម្រេចនោះ គេហៅថា សាលក្រមកំបាំងមុខ ។

សាលក្រមកំបាំងមុខ គឺជាសាលក្រមដែលតុលាការប្រកាសកំបាំងមុខជនជាប់ចោទ ជនរងគ្រោះ ដើមបណ្ដឹងរដ្ឋប្បវេណី និងបុគ្គលដែលពាក់ពន្ធ័នឹងរឿងក្ដីទាំងអស់ ដែលអវត្តមាននៅក្នុងពេលសវនាការ ។ សាលក្រមកំបាំងមុខរួមមាន ០៣ប្រភេទផងដែរ ដូចជា៖

- **សាលក្រមកំបាំងមុខជនជាប់ចោទ** ៖ ប្រសិនបើជនជាប់ចោទមិនបានចូលបង្ហាញខ្លួននៅក្នុងពេលសវនាការទេ ហើយប្រសិនបើគ្មានភស្តុតាងបញ្ជាក់ថា សាមីខ្លួនបានដឹងពីដីកាបញ្ជូនទៅជំនុំជម្រះ ឬបានដឹងអំពីការកោះហៅនោះទេ តុលាការនឹងប្រកាសសាលក្រមកំបាំងមុខជនជាប់ចោទ។ សាលក្រមកំបាំងត្រូវឱ្យដំណឹងដល់ជនជាប់ចោទ។ សាលក្រមកំបាំងមុខនេះអាចប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍បាន [67]។ ពោលជនដែលត្រូវបានតុលាការប្រកាសសាលក្រមកំបាំងមុខនោះ បន្ទាប់ពីខ្លួនបានដឹងដំណឹងពីសាលក្រមនេះរួច ហើយមិនពេញចិត្តទៅលើសេចក្ដីសម្រេចក្នុងសាលក្រម គឺសាមីជននោះមានជម្រើសពីរ គឺទី១ សិទ្ធិប្ដឹងទាស់ទៅនឹងសេចក្ដីសម្រេចនៅតុលាការដែលចេញសាលក្រម ក្នុងរយៈពេល ១៥ថ្ងៃ បន្ទាប់ពីខ្លួនទទួលដំណឹង និងទី២ សិទ្ធិប្ដឹងឧទ្ធរណ៍តែម្ដងចំពោះសេចក្ដីសម្រេចក្នុងសាលក្រម ដែលជននោះមានរយៈពេល ០១ខែ បន្ទាប់ពីខ្លួនទទួលដំណឹង[68] ។
- **សាលក្រមកំបាំងមុខដើមបណ្ដឹងរដ្ឋប្បវេណី** ៖ ប្រសិនបើដើមបណ្ដឹងរដ្ឋប្បវេណីមិនបានចូលបង្ហាញខ្លួននៅក្នុងពេលសវនាការទេ និងមិនមានអ្នកតំណាងត្រឹមត្រូវទេនោះ តុលាការនឹងចេញសាលក្រមកំបាំងមុខដើមបណ្ដឹងរដ្ឋប្បវេណី។ សាលក្រមកំបាំងមុខត្រូវជូនដំណឹងដល់ដើមបណ្ដឹងរដ្ឋប្បវេណី ។ សាលក្រមកំបាំងមុខនេះដើមបណ្ដឹងរដ្ឋប្បវេណីមានជម្រើសពីរដូចជនជាប់ចោទដែរ គឺមានសិទ្ធិអាចប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍បានក្នុងរយៈពេលដែលច្បាប់បានកំណត់[69]។
- **សាលក្រមកំបាំងមុខអ្នកទទួលខុសត្រូវរដ្ឋប្បវេណី** ៖ គឺជាសាលក្រមដែលចេញនៅពេលសវនាការជាសាធារណៈ ហើយបុគ្គលដែលមានឋានៈជាអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ឬអ្នកតំណាងដោយត្រឹមត្រូវ ពុំបានចូលបង្ហាញខ្លួននាពេលសវនាការនោះ សាលក្រមដែល តុលាការនឹងប្រកាសសាលក្រមកំបាំងមុខអ្នកទទួលខុសត្រូវរដ្ឋប្បវេណី។ សាលក្រមកំបាំងមុខនេះ ត្រូវឱ្យដំណឹងដល់អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ហើយសាលក្រមនេះ អ្នក

[67] មាត្រា ៣៦២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[68] មាត្រា ៣៦៥ , ៣៦៨ និងមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[69] មាត្រា ៣៦៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ទទួលខុសត្រូវរដ្ឋប្បវេណីមានជម្រើសពីរដូចជនជាប់ចោទដែរ គឺមានសិទ្ធិអាចប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍បានក្នុងរយៈពេលដែលច្បាប់បានកំណត់[70] ។

## ផ្នែកទី២ ៖ ទម្រង់នៃសាលក្រមព្រហ្មទណ្ឌ

ក្រោយពីបកស្រាយពី ប្រភេទនៃសាលក្រមព្រហ្មទណ្ឌ ទាំងសាលក្រមអង្គសេចក្ដី ក៏ដូចជាសាលក្រមមុនអង្គសេចក្ដីរួចមក អ្វីដែលយើងបកស្រាយបន្ត គឺទាក់ទងនឹងទម្រង់នៃសាលក្រមព្រហ្មទណ្ឌនេះ ដើម្បីធ្វើការសិក្សាអំពីទម្រង់នៃសាលក្រមព្រហ្មទណ្ឌ យើងត្រូវធ្វើការបង្ហាញពីការបង្កើតខ្លឹមសារនៃសាលក្រមសិន ដែលជាវាកត្តាមូលដ្ឋានដែលនាំឱ្យលេចឡើងជាសាលក្រមដែលមានទម្រង់ស្របតាមច្បាប់ មុននឹងអាចឈានដល់ចំណុចការតាក់តែងសរសេរសាលក្រមបាន ។

### ២.១. លក្ខខណ្ឌជាមូលដ្ឋាន ខ្លឹមសារនៃសាលក្រមព្រហ្មទណ្ឌ

ខ្លឹមសារនៃសាលក្រមនីមួយៗមានសារៈសំខាន់ខ្លាំងណាស់ ព្រោះខ្លឹមសារនៃសាលក្រមគឺកំណត់ពីទណ្ឌកម្មចំពោះបទល្មើសដែលជនជនជាប់ចោទបានប្រព្រឹត្ត និងកំណត់អំពីផលប្រយោជន៍ផ្នែករដ្ឋប្បវេណី ចំពោះជនជាប់ចោទ ពោលគឺប្រកាសទោសជនជាប់ចោទទៅតាមបញ្ញត្តិច្បាប់ ក្រោយពីបានពិនិត្យឃើញពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទ ។

ការបង្កើតនូវខ្លឹមសារសាលក្រម គឺជាភារកិច្ចចម្បងរបស់ចៅក្រមជំនុំជម្រះ ពីព្រោះខ្លឹមសារសាលក្រមបានកំណត់អំពីអត្ថិភាពនៃបទល្មើសព្រហ្មទណ្ឌណាមួយដែលច្បាប់បានចែង ព្រមទាំងផ្ដល់ជាសំណងរដ្ឋប្បវេណីដល់ដើមបណ្ដឹងរដ្ឋប្បវេណីទៅតាមពស្សនកម្មជាក់ស្ដែង តាមការយល់ឃើញរបស់តុលាការ ។

#### ២.១.១. ព្រំដែន និងឯករាជ្យភាពនៃសេចក្ដីសម្រេចរបស់តុលាការ

ក្នុងប្រព័ន្ធតុលាការដែលឯករាជ្យ គឺជាប្រព័ន្ធតុលាការមួយ ដែលការពារនូវ លទ្ធិប្រជាធិបតេយ្យ ដ៏សំខាន់បំផុត ។ ទាំងពាក្យថា "ឯករាជ្យភាព និង ភាពមិនលំអៀង" មានន័យថា មិនមានឥទ្ធិពលពុំសមស្របណាមួយ ទៅលើសេចក្ដីសម្រេចរបស់ចៅក្រម ដែលអាចកើតឡើងដោយសារសាច់ញាតិរបស់គូភាគី ឬដោយសារភាគីទីបី ឬប្រភពខាងក្រៅ (ដូចជាឥទ្ធិពលនយោបាយ ការណែនាំតាមរូបភាពជាសារាចររបស់ក្រសួងយុត្តិធម៌ជាដើម) ។ ចំពោះឥទ្ធិពលដែលសមស្របតែមួយគត់ទៅលើសេចក្ដីសម្រេចរបស់ចៅក្រម ត្រូវកើតឡើងចេញពីអង្គច្បាប់ ដែលចៅក្រមមានកាតព្វកិច្ចអនុវត្ត និងកើតចេញពីអង្គហេតុជាក់ស្ដែងដែលចៅក្រមត្រូវពិនិត្យ ។

[70] មាត្រា ៣៦៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ឯករាជ្យភាព ក៏ត្រូវបានចាត់ទុកជា សភាវៈចិត្ត មួយផងដែរ ។ សេចក្តីសម្រេចរបស់តុលាការ ត្រូវចេញដោយចៅក្រមដែលមិនមានភាពភ័យខ្លាចក្នុងនៅពេលដែលគាត់សម្រេចលើសំណុំរឿងនីមួយៗ ។ ដូចនេះចៅក្រមមិនត្រូវមិនត្រូវភ័យខ្លាចចំពោះការដាក់ទោស ឬការដាក់ទណ្ឌកម្មលើជនជាប់ចោទ ឬភាគីណាមួយឡើយ នៅពេលដែលខ្លួនសម្រេចណាមួយនោះ។ ការធ្វើសេចក្តីសម្រេចរបស់គាត់ត្រូវតែធ្វើឡើងដោយគ្មានការបំភិតបំភ័យ ការធ្វើទុក្ខបុកម្នេញ ឬសម្ពាធខាងក្រៅឡើយ ។ លើសពីនេះទៅទៀត សេចក្តីសម្រេចនេះ ចៅក្រមត្រូវធ្វើឡើងដោយគ្មានការរំពឹងចង់បានផលប្រយោជន៍ គុណប្រយោជន៍ និងប្រយោជន៍ផ្ទាល់ខ្លួនណាមួយឡើយ ។

បើក្រឡេកមើលព្រះពុទ្ធសាសនា ក៏មានព្រះពុទ្ធវាទសម្រាប់ការវិន្ន័យទោស ដូចខាងក្រោម ៖

- ចៅក្រមណាក៏ដោយ ត្រូវកាត់ក្តីប្រកាន់យក **អនាគតិធម៌** និងចៀសវាង **អគតិធម៌** ។
- ចៅក្រមត្រូវកុំគិតពីអំពើពុករលួយ មានន័យថា ចៅក្រមមិនត្រូវទទួលសំណូកទេ ។
- ចៅក្រមមិនត្រូវធ្វើការបែងចែករវាងញាតិសន្តាន និងបុគ្គលដទៃទៀតទេ ។
- ចៅក្រមត្រូវត្រងត្រាប់ស្តាប់រាល់ចំណុចទាំងអស់ ទាំងតូច ទាំងធំ ឱ្យបានល្អិតល្អន់ ហើយពិនិត្យមើលទាំងចំណុចដែលខុសនិងចំណុចដែលត្រូវដោយការពិចារណាឱ្យបានហ្មត់ចត់។

ឯករាជ្យភាពនៃតុលាការ មិនគ្រាន់តែទទួលរងគ្រោះថ្នាក់ដោយសារឥទ្ធិពល និងសម្ពាធខាងក្រៅ ទៅលើចៅក្រមស្មោះត្រង់ ដែលប្រាថ្នានូវឯករាជ្យភាពឡើយ តែឯករាជ្យភាពនៃតុលាការក៏ត្រូវរងគ្រោះដោយសារអំពើចៅក្រមដែរ នៅពេលដែលចៅក្រមបានប្រព្រឹត្ត មានអគតិធម៌ និងធ្វើការសម្រេចដោយលំអៀងនោះ ។ ដូច្នេះ វាមានសារៈសំខាន់ណាស់ ដែលត្រូវកត់សម្គាល់ថា ឯករាជភាព មិនមែនជាបុព្វសិទ្ធិផ្ទាល់ខ្លួនរបស់ចៅក្រមទេ គឺដើម្បីទទួលបានចៅក្រមឯករាជ្យ ដែលនោះជាសិទ្ធិដែលប្រជាពលរដ្ឋចង់បាន ។

ចៅក្រមម្នាក់ៗ មានករណីកិច្ចធ្វើជាចៅក្រមឯករាជ្យ ដោយធ្វើសកម្មភាព និងសម្រេចសេចក្តីដោយឯករាជ្យនិងមិនលំអៀង ពីព្រោះប្រជាពលរដ្ឋគ្រប់រូប មានសិទ្ធិក្នុងការទទួលបាននូវចៅក្រមឯករាជ្យក្នុងការសម្រេចសេចក្តីលើរឿងក្តីរបស់ខ្លួន ។ ក្នុងការសម្រេចសេចក្តីក្នុងសំណុំរឿងព្រហ្មទណ្ឌ ចៅក្រមជំនុំជម្រះមានឯករាជ្យក្នុងការវិនិច្ឆ័យ និងថ្លឹងថ្លែងកាត់សេចក្តីតាមការយល់ឃើញរបស់ខ្លួន ដោយផ្អែកទៅតាមច្បាប់កំណត់ ក៏ដូចជាចម្លើយក្នុងការភិភាក្សាដេញដោលនាពេលសវនាការ ក៏ដូចជាភស្តុតាងនានាដែលមាននៅក្នុងសំណុំរឿងនោះ ។ ចៅក្រមជំនុំជម្រះមិនត្រូវទទួលខុសត្រូវខាងបទព្រហ្មទណ្ឌ ឬខាងបទរដ្ឋប្បវេណីណាមួយ ចំពោះការសម្រេចសេចក្តីណាមួយ ដែលធ្វើឡើងនៅក្នុងក្របខណ្ឌសមត្ថកិច្ច និងមុខងាររបស់ខ្លួនឡើយ ។ ចៅក្រមទាំងឡាយ ត្រូវសម្រេចសេចក្តីដោយមិនលំអៀងដោយឈរលើគោលការណ៍គោរពច្បាប់ ដោយគ្មានការគាបសង្កត់ ការគំរាមកំហែង ឬការ

បំភិតបំភ័យ ការបង្គាប់បញ្ជាដោយផ្ទាល់ ឬប្រយោលណាមួយពីភាគីណាមួយក្នុងរឿងក្តី ឬបុគ្គលណាម្នាក់នោះឡើយ ។

ជាមួយគ្នានេះដែរ ទោះបីជាការសម្រេចសេចក្តីរបស់ចៅក្រមជំនុំជម្រះមានឯករាជ្យភាពក៏ដោយ ដោយគេបានកំណត់ពីព្រំដែននៃការសម្រេចសេចក្តីរបស់ចៅក្រមជំនុំជម្រះផងដែរ ដោយគាត់មិនអាចសម្រេចសេចក្តីតាមតែការនឹកឃើញ ឬយល់ឃើញរបស់គាត់ឡើយ ។ ចំពោះព្រំដែននៃការសម្រេចរបស់ចៅក្រមជំនុំជម្រះ មានពីរ គឺព្រំដែននៃការសម្រេចសេចក្តីចំពោះអង្គហេតុ និងព្រំដែននៃការសម្រេចសេចក្តីចំពោះបុគ្គល ។

- **ព្រំដែននៃការសម្រេចសេចក្តីចំពោះអង្គហេតុ** ៖ ចៅក្រមជំនុំជម្រះអាចសម្រេចសេចក្តីបានតែទៅលើអំពើទាំងឡាយណា ដែលមានបង្ហាញនៅក្នុងដីកាបញ្ជូនរបស់ចៅក្រមស៊ើបសួរ ឬសាលដីកាបញ្ជូនរបស់សភាស៊ើបសួរ, ដីកាបញ្ជូនទៅជំនុំជម្រះដោយផ្ទាល់របស់ព្រះរាជអាជ្ញា និងកំណត់ហេតុស្តីពីការចូលបង្ហាញខ្លួនភ្លាមប៉ុណ្ណោះ ។ ក្នុងករណីដែលតុលាការសម្រេចដោយមានចៅក្រមតែម្នាក់គត់ ហើយចៅក្រមនោះយល់ឃើញថា អង្គហេតុដែលត្រូវបានប្តឹងនោះ បង្កើតជាបទឧក្រិដ្ឋ តុលាការនោះត្រូវបង្វិលសំណុំរឿងជូនព្រះរាជអាជ្ញា ដើម្បីបើកការស៊ើបសួរ[71] ។
- **ព្រំដែននៃការសម្រេចសេចក្តីចំពោះបុគ្គល** ៖ ចៅក្រមជំនុំជម្រះអាចជំនុំជម្រះតែលើបុគ្គលដែលបញ្ជូនទៅចំពោះខ្លួន ក្នុងឋានៈជាជនជាប់ចោទតែប៉ុណ្ណោះ ។ ប្រសិនបុគ្គលណាម្នាក់ដែលកោះហៅចូលចំពោះមុខតុលាការក្នុងឋានៈជាសាក្សី អាចត្រូវចោទប្រកាន់ក្នុងឋានៈជាជនដៃដល់ ឬអ្នកសមគំនិត បុគ្គលនោះអាចត្រូវបានជំនុំជម្រះបានក្រោយពេលត្រូវបានចោទប្រកាន់ដូចមានចែងនៅមាត្រា៤៣ (ការចោទប្រកាន់)[72]។

### ២.១.២. គោលការណ៍វិនិច្ឆ័យទូទៅក្នុងការសម្រេចសេចក្តីរបស់ចៅក្រមជំនុំជម្រះ

ចំពោះការវិនិច្ឆ័យក្នុងការសម្រេចសេចក្តីរបស់ចៅក្រមជំនុំជម្រះ អ្វីដែលសំខាន់បំផុតនោះគឺត្រូវផ្អែកលើអង្គហេតុ និងអង្គច្បាប់ និងការវាយតម្លៃទៅលើភស្តុតាងរបស់ចៅក្រមជំនុំជម្រះផ្ទាល់ ដែលចំណុចទាំងពីរនេះបង្ហាញពីគំនិត និងការយល់ឃើញរបស់តុលាការ ក្នុងការចេញសេចក្តីសម្រេច ថាតុលាការសម្រេចដោយផ្អែកតាមមូលដ្ឋានអង្គហេតុ និងអង្គច្បាប់អ្វីខ្លះ ព្រមទាំងវាយតម្លៃលើភស្តុតាងបែបណា ? ដែលពន្យល់បង្ហាញនូវហេតុផល និងជាមូលដ្ឋាន ដែលនាំឱ្យតុលាការសម្រេចសេចក្តីបែបណាមួយនៃរឿងព្រហ្មទណ្ឌនោះ ដើម្បីឱ្យភាគីពិចារណា ថាគប្បីចាំបាច់ត្រូវប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ដែរឬទេ ? ដោយយើងនឹងធ្វើការបកស្រាយពីចំណុចទាំងពីរ ដូចតទៅ៖

[71] មាត្រា ៣៤៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[72] មាត្រា ៣៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

### ២.១.២.១. មូលដ្ឋានអង្គហេតុ និងអង្គច្បាប់

សេចក្តីសម្រេចនៅក្នុងសាលក្រមដែលខ្លួននឹងប្រកាស ចៅក្រមគ្រប់រូបត្រូវបង្ហាញឲ្យភាគីក្នុងរឿងក្តី ដោយលំអិតថា អង្គហេតុ និងទសន្សៈច្បាប់នានា ដែលពួកគេទទួលបានត្រូវបានពិចារណា និងត្រូវបានថ្លឹងថ្លែង យ៉ាងសមស្រប ។

- **អង្គហេតុ** : សាលក្រម គឺជាលទ្ធផលនៃការអនុវត្តន៍ច្បាប់ចំពោះអង្គហេតុដែលកើតឡើង ។ អង្គហេតុទាំងអស់ត្រូវប្រមូលពិនិត្យដោយចៅក្រមជំនុំជម្រះ ចាប់តាំងពីដំណាក់កាលស៊ើបអង្កេត ដល់ដំណាក់ជំនុំជម្រះនេះផ្ទាល់ ។ ចៅក្រមប្រមូលអង្គហេតុពីគូភាគីទាំងពីរ នៅក្នុងនីតិវិធីរឿងក្តីដោយយុត្តិធម៌មួយ ។ ដូច្នេះអង្គហេតុ ជាចំណុចក៏សំខាន់មួយ ព្រោះនៅពេលចាប់ផ្តើមនៃសាលក្រម ត្រូវតែមានអង្គហេតុសង្ខេបក៏ពិតប្រាកដមួយ នៃរឿងក្តីព្រហ្មទណ្ឌនោះ ។

តាមគោលការណ៍ កំណត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម៌ត្រូវទុកជាបន្ទាល់ "ឯកសារដើម" ដែលមានន័យថា អង្គហេតុនៅក្នុងកំណត់ហេតុនោះ ត្រូវទុកជាអង្គហេតុ ដែលតុលាការអាចជឿរហូតដល់មានភស្តុតាងផ្ទុយបញ្ជាក់ពីអង្គហេតុដែលកើតឡើងនោះ[73] ។ ដូច្នេះ ប្រសិនបើមិនពុំមានភាគីនៅក្នុងរឿងក្តីណា ផ្តល់នូវអំណះអំណាង ឬភស្តុតាងណាមួយ បញ្ជាក់ពីអង្គហេតុផ្ទុយពីអង្គហេតុដែលមាននៅក្នុងឯកសាររបស់មន្ត្រីនគរបាលយុត្តិធម៌ទេនោះ អង្គហេតុនោះត្រូវទុកជាបានការដដែល ។

- **អង្គច្បាប់** : មានតែអំពើរបស់ជនជាប់ចោទដែលបានធ្វើសកម្មភាពនោះ បានធ្វើឲ្យប៉ះពាល់ដល់ សន្តិសុខសណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈក្នុងសង្គម និងជាពិសេសប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់ជនរងគ្រោះ ដែលច្បាប់ព្រហ្មទណ្ឌ ឬច្បាប់ដទៃទៀត បានការពារដោយបញ្ញត្តិជាបទល្មើសណាមួយ ដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ក្នុងច្បាប់ជាធរមានទាំងនោះ ទើបត្រូវផ្តន្ទាទោសបាន ។ ដូច្នេះ មានន័យថា ទាល់តែមានច្បាប់កំណត់ ពីអំពើដែលជនជាប់ចោទបានប្រព្រឹត្តថា ជាអំពើល្មើស ទើបតុលាការបានពិចារណា និងសម្រេចសេចក្តីផ្អែកតាមច្បាប់យ៉ាងយុត្តិធម៌ យោងទៅតាមគោលការណ៍នីត្យានុកូលភាពនៃទោស មានតែទោសដែលមានចែងក្នុងបទបញ្ញត្តិព្រហ្មទណ្ឌ នៅពេលដែលបទល្មើសត្រូវបានប្រព្រឹត្តប៉ុណ្ណោះ ទើបត្រូវប្រកាសបាន ។ ចៅក្រមអាចធ្វើការប្រកាសទោសបាន លុះត្រាតែមានចែងកំណត់ជាមុនក្នុងច្បាប់ ។ បើច្បាប់ មិនបានចែងអំពីទោស នៃសកម្មភាពដែលជនជាប់ចោទបានប្រព្រឹត្តទេនោះ ចៅក្រមមិនអាចបង្កើតទោសដោយខ្លួនឯងបានឡើយ ។

---

[73] មាត្រា ១១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧

### ២.១.២.២. ការវិនិច្ឆ័យលើភស្តុតាងដែលបង្ហាញនាពេលសវនាការ

ការវាយតម្លៃទៅលើភស្តុតាង គឺជាការសរុបលទ្ធផលមួយ ដែលកើតចេញពី ការផ្ទៀងផ្ទាត់ទៅលើ អត្ថិភាពនៃភស្តុតាងទាំងឡាយដែលមាននៅក្នុងរឿងក្តី ដោយលទ្ធផលបែបនេះបានដាក់ចេញអំពី ការទទួលស្គាល់ទៅលើអត្ថិភាព ឬនត្ថិភាពនៃអង្គហេតុទាំងនោះ។ យើងក៏អាចនិយាយ ម្យ៉ាងទៀតថាការវាយតម្លៃទៅលើភស្តុតាង គឺជាការធ្វើសេចក្តីសន្និដ្ឋានសរុបអំពីភាពអាចជឿជាក់បាន ឬភាពមិនអាចជឿជាក់បានទៅលើភស្តុតាង។

ក្នុងការវិនិច្ឆ័យសេចក្តីណាមួយ ចៅក្រមសម្រេចសេចក្តីបានត្រូវផ្អែកលើភស្តុតាង។ ភស្តុតាងមានច្រើនប្រភេទ មានកម្រិត និងបន្ទុកនៃភស្តុតាងដែលចៅក្រមត្រូវដឹងនឹងអនុវត្តតាម ដើម្បីឱ្យសេចក្តីសម្រេចរបស់ខ្លួនសមស្រប និងប្រកបដោយយុត្តិធម៌ ។

ការវាយតម្លៃទៅលើភស្តុតាង គឺជាភារកិច្ចរបស់ចៅក្រមដែលជាភារកិច្ចរបស់គាត់ត្រូវបានស្តែងចេញតាមរយៈការធ្វើអំណះអំណាង ក្នុងលក្ខខណ្ឌនៃបរមត្ថធម៌ជាពិសេសអំណះអំណាងទាំងនេះ ត្រូវឈរលើមូលដ្ឋាននៃការពិចារណាទៅលើភស្តុតាងនានា រួមមានបណ្តុំនៃភស្តុតាងទាំងនោះប្រកបដោយលក្ខណៈពេញលេញចំគោលដៅ និងគ្រប់ជ្រុងជ្រោយសមស្របតាមច្បាប់ និងមនសិការគតិយុត្តិ ។ ចៅក្រមជំនុំជម្រះត្រូវដោះស្រាយអង្គហេតុនានាប្រកបដោយបញ្ញាស្មារតី នៃភាពដែលអាចទទួលយកបាន ភាពទាក់ទិននឹងអង្គហេតុ ភាពជឿជាក់ទៅលើភស្តុតាងនីមួយៗ ព្រមទាំងភាពគ្រប់គ្រាន់នៃភស្តុតាងទាំងអស់សម្រាប់ធ្វើការអនុម័ត ដើម្បីអាចទទួលយកបាននូវសេចក្តីសម្រេចមួយប្រកបដោយវិជ្ជាជីវៈ និងយុត្តិធម៌ ។ ផ្អែកតាមភស្តុតាង ចៅក្រមអាចដាក់ទោសពន្ធនាគារធ្ងន់ ឬស្រាល ។ ដូច្នេះ ការវាយតម្លៃលើភស្តុតាងរបស់ចៅក្រមជំនុំជម្រះ ពិតជាមានសារៈសំខាន់ណាស់ ក្នុងការសម្រេចសេចក្តីកាត់ទោសលើជនជាប់ចោទ ឬលើសំណងរដ្ឋប្បវេណីជាដើម ។ តាមក្រមនីតិវិធីព្រហ្មទណ្ឌមាត្រា ៣២១ ចែងថា៖ "តុលាការថ្លឹងថ្លែងដោយឥស្សរចិត្ត អំពីតម្លៃភស្តុតាង ដែលគេដាក់ជូនមកខ្លួនពិនិត្យ ដោយផ្អែកទៅលើជំនឿស្មោះត្រង់ ពិតប្រាកដរបស់ខ្លួន" ជាបង្ហាញពីកម្រិតនៃភស្តុតាងដែលបង្កើតនូវពិរុទ្ធភាព ផ្អែកតាមការពិចារណាដោយអព្យាក្រឹត្យ ។ ប្រសិនបើការវាយតម្លៃរបស់ចៅក្រមជំនុំជម្រះយល់ឃើញថា មានភស្តុតាងដាក់បន្ទុកទៅលើជនជាប់ចោទ អានុភាពនៃការវាយតម្លៃទៅលើភស្តុតាងនេះត្រូវធ្វើការចោទប្រកាន់ទៅលើជនជាប់ចោទនោះ តែបើការវាយតម្លៃរបស់ចៅក្រមជំនុំជម្រះយល់ឃើញថា ពុំមានតម្លៃគ្រប់គ្រាន់ ភស្តុតាងនោះមិនអាចដាក់បន្ទុកបានទេ ដែលជនជាប់ចោទត្រូវបានសម្រេចឱ្យរួចផុតពីការចោទប្រកាន់។

## ២.២. ការតាក់តែងលិខិតសាលក្រម

ជាការអនុវត្តនៅតាមសាលាដំបូងរាជធានីខេត្តនីមួយៗ តែងតែមានសាលក្រមគម្រូ ឬរូបមន្តដែលសម្រាប់ចៅក្រមប្រើប្រាស់ក្នុងសំណុំរឿងទាំងឡាយ ដែលវាបង្កភាពងាយស្រួលក្នុងការសរសេរតាក់តែងលិខិតសាលក្រមនេះឡើង។ យ៉ាងណាក៏ដោយ ក្រមនីតិវិធីព្រហ្មទណ្ឌយើងក៏បានកំណត់យ៉ាងច្បាស់ថា ការសរសេរសាលក្រមសំខាន់ត្រូវតែមានពីរផ្នែក ៖ ផ្នែកសំអាងហេតុ ពោលគឺទឡ្ហីករណ៍នៃអង្គហេតុ និងអង្គច្បាប់ ដែលនាំឱ្យតុលាការចេញសេចក្តីសម្រេច និងផ្នែកសម្រេច ដែលគឺជាសេចក្តីសម្រេចរបស់តុលាការ ។ ប៉ុន្តែសាលក្រមព្រហ្មទណ្ឌនីមួយៗ ក៏មិនអាចខ្វះបាននូវផ្នែកក្បាលនៃសាលក្រមដែរ តើផ្នែកនេះមានលក្ខណៈ និងភាពសំខាន់ដូចម្តេច ?

### ២.២.១. ផ្នែកក្បាលនៃសាលក្រម

ផ្នែកក្បាលនៃសាលក្រមនេះ ជាផ្នែកខាងលក្ខណៈសម្បត្តិនៃសាលក្រម ដែលផ្នែកក្បាលនៃសាលក្រមនេះ ជាចំណុចដំបូងនៃសាលក្រម ហើយគឺជាផ្នែកដ៏សំខាន់មួយដែលមិនអាចខ្វះបាន ព្រោះផ្នែកនេះបង្ហាញពី ពត៌មានលំអិតអំពីគូភាគី វាក៏បានបង្ហាញយ៉ាងច្បាស់ពីប្រភេទសាលក្រម និងបង្ហាញពីទីកន្លែងនៃតុលាការដែលចេញសាលក្រម ។ សាលក្រមផ្នែកនេះ ត្រូវមាន ៖

- **កាលបរិច្ឆេទនៃសវនាការ** ៖ សំដៅដល់ពេលវេលានៃការបើកសវនាការរបស់តុលាការ។
- **កាលបរិច្ឆេទនៃការប្រកាសសាលក្រម** ៖ សំដៅទៅដល់ពេលវេលានៃ ការប្រកាសសាលក្រម របស់តុលាការ។
- **ទីកន្លែង ឈ្មោះតុលាការ និងលេខសំណុំរឿង** ៖ ជាការកំណត់អំពីតុលាការដែលមានសមត្ថកិច្ចអាចទទួលយកសំណុំរឿង មកចាត់ការតាមនីតិវិធីច្បាប់ ហើយបានបញ្ជាក់ពីលេខលំដាប់នៃសំណុំរឿងព្រហ្មទណ្ឌ ដែលមានទាំងលេខបណ្តឹង លេខស៊ើបសួរ លេខជំនុំជម្រះ និងលេខសាលក្រម ដើម្បីងាយស្រួលសម្គាល់ ។
- **សមាសភាពនៃចៅក្រមដែលជំនុំជម្រះ** ៖ សំដៅដល់ឈ្មោះ និងឋានៈរបស់ចៅក្រមដែលទទួលការចាត់តែងទទួលសំណុំរឿងមកចាត់ការពីប្រធានតុលាការ ។ ការជំនុំជម្រះអាចជាក្រុមប្រឹក្សាដែលមានចៅក្រមចំនួន ០៣ រូប ចំពោះបទឧក្រិដ្ឋ និងការជំនុំជម្រះដោយចៅក្រមចំនួន ០១រូប ចំពោះបទល្មើស លហុ និងបទមជ្ឈិម ។
- **សមាសភាពនៃតំណាងអយ្យការ** ៖ សំដៅដល់ឈ្មោះ និងឋានៈរបស់តំណាងអយ្យការដែលចូលរួមក្នុងសំណុំរឿងនេះ ព្រោះរឿងព្រហ្មទណ្ឌ តំណាងអយ្យការត្រូវមានវត្តមានជាចាំបាច់ខានមិនបាន ព្រោះតំណាងអយ្យការជាម្ចាស់បណ្តឹងអាជ្ញា ដែលធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌលើជនជាប់ចោទ ម៉្យាងទៀត គាត់គឺជាអ្នក

ធានារ៉ាប់រងការអនុវត្តសេចក្តីសម្រេចនៃសាលក្រមរបស់តុលាការ និងផ្សព្វផ្សាយពីដីកាបង្គាប់ចាប់ខ្លួនតាមអំណាចសាលក្រម ។

• **សមាសភាពនៃក្រឡាបញ្ជី** ៖ សំដៅដល់ឈ្មោះ និងឋានៈរបស់ក្រឡាបញ្ជីដែលត្រូវបានចាត់ទាំងដោយចៅក្រមជំនុំជម្រះ ឱ្យជួយទទួលបន្ទុកកាន់ និងរៀបចំសំណុំរឿង ។

• **អត្តសញ្ញាណរបស់ជនជាប់ចោទ និងភាគីផ្សេងទៀត** ៖ ត្រូវសរសេរអំពីឈ្មោះ សាវតា និងទីកន្លែងកំណើត ទីលំនៅបច្ចុប្បន្ន មុខរបរ របស់ជនជាប់ចោទ ជនរងគ្រោះ ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ។

• **អត្តសញ្ញាណរបស់មេធាវីការពារសិទ្ធិ** ៖ ត្រូវសរសេរអំពីឈ្មោះមេធាវីការពារសិទ្ធិរបស់ជនជាប់ចោទ និងមេធាវីការពារសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី បើមាន។ រឿងក្តីព្រហ្មទណ្ឌ មិនចាំបាច់មានមេធាវីគ្រប់សំណុំរឿងនោះទេ រឿងខ្លះមិនចាំបាច់មេធាវីការពារសិទ្ធិក៏បាន ព្រោះជាជម្រើសរបស់ភាគី ប៉ុន្តែបើសំណុំរឿង បទល្មើសដែលចោទប្រកាន់ជាបទឧក្រិដ្ឋ ឬជនជាប់ចោទជាអនីតិជននោះ មេធាវីការពារសិទ្ធិជនជាប់ចោទត្រូវតែមានជាចាំបាច់[74]។

• **ការចោទប្រកាន់ជាក់លាក់** ៖ សំដៅដល់ការចោទប្រកាន់របស់តំណាងអយ្យការដែលតុលាការទទួលតាមដីកាដំណោះស្រាយ ឬតាមនីតិវិធីបង្ហាញខ្លួនភ្លាម ដែលបានបញ្ជូនមក ។

• **អង្គហេតុ** ៖ រៀបរាប់អំពីអង្គហេតុដែលកើតឡើងនាំកើតមានជាបទល្មើសព្រហ្មទណ្ឌ ។

• **សេចក្តីរំលឹកពីនីតិវិធី** ៖ ដែលបានប្រព្រឹត្ត ដោយមានចុះនូវអំពើ និងកិច្ចធំៗ ព្រមទាំងឧប្បហេតុនានា ។

• **សំនួរ - ចម្លើយនៅពេលសវនាការ** ៖ សំដៅដល់ការឆ្លើយរបស់ជនជាប់ចោទ, ជនរងគ្រោះ, ដើមបណ្តឹងរដ្ឋប្បវេណី, អ្នកទទួលខុសត្រូវដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានសួរនាពេលសវនាការ ។

• **សេចក្តីសម្រេចនានាដែលតុលាការបានធ្វើនៅក្នុងអំឡុងពេលនីតិវិធី** ៖ ដែលបង្ហាញពីភស្តុតាងដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរដែលគូភាគីលើកសំអាង, សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ, សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិ, សម្តីចុងក្រោយរបស់ជនជាប់ចោទជាដើម ។

**ចំណុចដែលបានបង្ហាញពីខាងលើត្រូវ** ត្រូវធ្វើសរសេរនៅខាងផ្នែកក្បាលនៃសាលក្រម និងត្រូវសរសេរដោយកំណត់ទៅតាមលំដាប់លំដោយទៅតាមទម្រង់ ប៉ុន្តែបច្ចុប្បន្ននៅតាមតុលាការរាជធានី-ខេត្ត គឺសុទ្ធតែមានគំរូសម្រាប់សរសេរសាលក្រម ដែលបង្កជាភាពងាយស្រួលមួយចំនួនដល់ចៅក្រម ។

---

[74] មាត្រា ៣៥៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

លើសពីនេះទៅទៀត យើងឃើញថានៅផ្នែកក្បាលនៃគ្រប់សាលក្រមព្រហ្មទណ្ឌទាំងអស់ មានផ្ដើមឃ្លាសរសេរថា " **តាងនាមប្រជារាស្ត្រខ្មែរ** " តើហេតុអ្វីបានជាមានការផ្ដើមឃ្លាដូច្នេះ ? ចំពោះមូលហេតុដែលនាំឱ្យមានការផ្ដើមឃ្លាបែបនេះ ព្រោះជាគោលការណ៍យោងទៅតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ក៏បានចែងថា អំណាចទាំងអស់នៅក្នុងរដ្ឋរាប់បញ្ចូលទាំងអំណាចតុលាការ គឺបានមកប្រជាជនកម្ពុជា ហើយការជម្រះក្ដីផ្ដល់នូវយុត្តិធម៌ ត្រូវធ្វើក្នុងនាមជាប្រជារាស្ត្រខ្មែរ តាមនីតិវិធីនិងច្បាប់ជាធរមាន ។ ដោយឃ្លានេះបានបង្ហាញឱ្យដឹងថា សាលក្រមនេះ ដែលសម្រេចសេចក្ដីរបស់ចៅក្រម គឺជាការសម្រេចសេចក្ដីរបស់ប្រជារាស្ត្រខ្មែរទាំងមូល មិនមែនជាការសម្រេចរបស់ចៅក្រមតែម្នាក់ឯងនោះទេ ។

### ២.២.២. ផ្នែកសាលក្រម

នៅក្នុងផ្នែកនេះត្រូវចែកជាពីរ ដែលកំណត់នូវសេចក្ដីសម្រេចរបស់តុលាការ ដោយយោងតាមច្បាប់ សាលក្រម គឺមានផ្នែកសំអាងហេតុ និងផ្នែកសេចក្ដីសម្រេច ។ ចំណុចនេះមានកំណត់នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌមាត្រា ៣៥៧ ចែងថា "គ្រប់សាលក្រម ត្រូវមានពីរផ្នែក គឺផ្នែកសំអាងហេតុ និងផ្នែកសម្រេច" ។ ផ្នែកនេះគឺជា ចំណុចសំខាន់ ព្រោះបង្ហាញអំពី សេចក្ដីសម្រេចរបស់តុលាការដោយផ្អែកទៅលើសំអាងហេតុ និងការចង្អុលបង្ហាញអំពីអត្ថបទច្បាប់ដើម្បីធ្វើការ កំណត់ថាមានបទល្មើសកើតឡើង ឬក៏ពុំមានបទល្មើស។ ការសម្រេចសេចក្ដីរបស់តុលាការអាស្រ័យទៅលើ អំណះអំណាងដែលបង្ហាញពីភាពស៊ីសង្វាក់ និងអត្ថបទច្បាប់ក៏ដូចជា ឆន្ទៈនុសិទ្ធិរបស់ចៅក្រម ដែលអ្វីទាំងនេះ ត្រូវបង្ហាញនៅក្នុងសាលក្រម ។

#### ២.២.២.១. ផ្នែកសំអាងហេតុ

សំអាងហេតុ គឺជាយោបល់ទាំងឡាយដែលនាំឱ្យកំណត់ចេញសេចក្ដីសម្រេចរបស់តុលាការ ដែលបានបង្ហាញពីការយល់ឃើញរបស់ចៅក្រមក្រោយពីការបានធ្វើការជំនុំជម្រះ។ ក្នុងចំណុចនេះមានន័យថា ចៅក្រម បានស្វែងយល់អំពីអង្គហេតុនៃរឿងក្ដី ចម្លើយរបស់ជនជាប់ចោទ និងការអះអាងរបស់ជនរងគ្រោះ សេចក្ដីសន្និដ្ឋាន ក៏ដូចជាសំណើររបស់តំណាងអយ្យការ សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិជនជាប់ចោទ មូលហេតុនានាដែលពាក់ព័ន្ធ ជាពិសេសគឺអត្ថបទច្បាប់ដែល ចង្អុលបង្ហាញពីការកំណត់បទល្មើស។ សំអាងហេតុជាចំណុចមួយដ៏សំខាន់ ព្រោះបង្ហាញពីការយល់ឃើញ របស់តុលាការអំពីការសម្រេចឱ្យមានការផ្ដន្ទាទោស ឬមួយក៏ជាការសម្រេចឱ្យរួចខ្លួន។ សំអាងហេតុជាផ្នែកមួយដ៏សំខាន់ដែលក្នុងផ្នែកនេះ ត្រូវសរសេរដោយត្រូវលើកឡើងអំពីទឡ្ហីករណ៍ នៃអង្គហេតុ និងអង្គច្បាប់ដែលនាំឱ្យតុលាការចេញសេចក្ដីសម្រេចនេះបាន ។ នៅក្នុងសំអាងហេតុនេះតុលាការ ត្រូវធ្វើ

ការឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍របស់គូភាគី[75]។ ចំពោះអង្គហេតុត្រូវតែច្បាស់លាស់ និងគ្មានការសង្ស័យ ព្រោះថាវាចំណុចដែលបញ្ជាក់អំពីអត្ថិភាព និងនត្ថិភាពនៃបទល្មើសរបស់ជនជាប់ចោទ។ តុលាការត្រូវពិនិត្យមើល ទឡ្ហីករណ៍ ភស្តុតាង និងធាតុផ្សំនៃបទចោទនីមួយៗដែលបានលើកនៅពេលសវនាការ។

ទឡ្ហីករណ៍នៃអង្គហេតុ និងអង្គច្បាប់ គឺជាការសំអាងអ្វីៗ ដែលគេយកមកធ្វើជាតឹកតាង ដើម្បីចោទប្រកាន់ ឬបញ្ជាក់អំពីធាតុពិតនៃអ្វីមួយ ។ ទឡ្ហីករណ៍ មិនមែនជាភស្តុតាងទេ វាគឺជាអំណះអំណាងឱ្យអ្នកស្តាប់ជឿជាក់ និងជួយគាំទ្រឱ្យលំហូរគំនិតឱ្យកាន់តែមានទម្ងន់ ជួយបង្ហាញប្រាប់គេថាអ្នកមានជំនឿជឿខ្លាំង ជាគំនិតគាំទ្រនូវគំនិតសំខាន់ ជួយឱ្យការបកស្រាយមានរបៀបតាមស្តង់ដារ ។ ទឡ្ហីករណ៍នៃអង្គហេតុ និងអង្គច្បាប់ គឺបង្ហាញពីការបានប្រមូលពត៌មានបានពេញលេញ និងគ្រប់គ្រាន់របស់ចៅក្រម ដែលជាហេតុនាំឱ្យមានការជឿជាក់លើអត្ថិភាពនៃអង្គហេតុនោះ ដែលជាសំអាងរបស់ចៅក្រមទៅលើការយល់ឃើញរបស់គាត់ទៅលើអង្គហេតុ នឹងអង្គច្បាប់ក្នុងសំណុំរឿង ។

ចំពោះភស្តុតាងគឺមានតែភស្តុតាងដែលមាននៅក្នុងសំណុំរឿង ឬត្រូវបានគេយកមកបង្ហាញ នាពេលសវនាការប៉ុណ្ណោះដែលតុលាការមានសិទ្ធិសំអាងក្នុងសេចក្តីសម្រេចរបស់ខ្លួនបាន ចៅក្រមមិនអាចសម្រេចសេចក្តីបានឡើយ ចំពោះភស្តុតាងដែលគ្រាន់តែដឹងលឺដោយផ្ទាល់ខ្លួន មិនមានក្នុងសំណុំរឿងនោះទេ ។ មានន័យថា តុលាការធ្វើការសម្រេចក្តី ដោយផ្អែកការវាយតម្លៃ និងថ្លឹងថ្លែងលើភស្តុតាងជាមូលដ្ឋានសំខាន់ៗ ក្នុងការចេញសេចក្តីសម្រេច។ ភស្តុតាងក្នុងរឿងព្រហ្មទណ្ឌមានច្រើនប្រភេទ អាចជាកំណត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម៌ កំណត់ហេតុកោលសល្យវិច័យ ដូចជាការសារភាពរបស់ជនជាប់ចោទ, វត្ថុតាងដែលមាននៅក្នុងសំណុំរឿង ការឆ្លើយបំភ្លឺរបស់ដើមបណ្តឹងរដ្ឋប្បវេណី, ជនរងគ្រោះ និងសាក្សី ហើយត្រូវបានដាក់ជូនតុលាការថ្លឹងថ្លែង ។ តែផ្ទុយទៅវិញចំពោះចម្លើយសារភាពដែលទទួលបានក្រោមការបង្ខិតបង្ខំ និងការសន្ទនាឆ្លងឆ្លើយរវាងជនជាប់ចោទ និងមេធាវីរបស់ខ្លួន មិនថានាពេលសវនាការក្តី តុលាការមិនទទួលយកការឆ្លើយឆ្លងទាំងនោះមកធ្វើជាភស្តុតាងបានឡើយ ។ ភស្តុតាងត្រូវមានលក្ខណៈច្បាស់លាស់មិនមែនមានលក្ខណៈស្រពិចស្រពិលទេ ភាពច្បាស់លាស់គឺការគ្មានការភ័ន្តច្រឡំគ្នា គ្មានភាពស្រពិចស្រពិល ដែលអាចឱ្យយើងយកមកធ្វើជាមូលដ្ឋាន ដើម្បីកំណត់បាននូវអង្គហេតុ និងអង្គច្បាប់។ ដើម្បីភាពច្បាស់លាស់ ភស្តុតាងទាមទារឱ្យមាន ការវិភាគ និងពិចារណាតាមបែបផែនបច្ចេកទេសវិទ្យាសាស្ត្រផងដែរ។ ទោះបីជានៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌមិនបានចែងឱ្យជាក់លាក់ទៅលើប្រភេទនៃភស្តុតាងក្តី ប៉ុន្តែច្បាប់

[75] មាត្រា ៣៥៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ផ្តល់សិទ្ធិទៅឱ្យតុលាការទទួលថ្លឹងថ្លែង ដោយឥស្សរចិត្តអំពីតម្លៃនៃភស្តុតាង ដែលគេដាក់ជូនមកខ្លួនពិនិត្យដោយផ្អែកទៅលើជំនឿស្មោះត្រង់ពិតប្រាកដរបស់ខ្លួន ដើម្បីសំអាងក្នុងការសម្រេចសេចក្តីរបស់គាត់ ។ ហេតុផលដែលច្បាប់មិនបានកំណត់ឱ្យច្បាស់លាស់អំពីវិធាននៃភស្តុតាងបែបនេះ អាចមកពីភស្តុតាងមានសភាពប្រែប្រួលច្រើនអាស្រ័យទៅតាមបទល្មើសដែលបានកើតឡើង។ កាលណាបើច្បាប់នីតិវិធីបានកំណត់នូវវិធាននិងគោលការណ៍ឱ្យបានច្រើនទាក់ទិននឹងភស្តុតាងនោះ វាជាគុណវិបត្តិមួយដល់ការវាយតម្លៃទៅលើភស្តុតាងមុនឈានដល់ការធ្វើសេចក្តីសម្រេចរបស់តុលាការ។ ម្យ៉ាងទៀតបើច្បាប់នីតិវិធីបានកំណត់ពីគោលការណ៍ និងវិធានដែលមានលក្ខណៈ ស៊ីជម្រៅពេក ហើយចៅក្រមមានការយល់ដឹងខាងផ្នែកទ្រឹស្តីនៃនីតិសាស្ត្រនៅមានកំរិត ក៏អាចជាហេតុនាំឱ្យមានការប៉ះពាល់ដល់ការវិនិច្ឆ័យច្បាប់ ឬក៏ចៅក្រម អាចយកតែទម្លាប់មកប្រើជំនួសវិញ ជាជាងយកច្បាប់ដែលកំណត់អំពីវិធានភស្តុតាងមកប្រើ ។ ដូច្នេះហើយបានជាលេចឡើងនូវគោលការណ៍ « ជំនឿស្មោះត្រង់ពិតប្រាកដរបស់ខ្លួន » ន័យបែបនេះ គឺចង់សំដៅទៅលើអគតិធម៌បួនរបស់ចៅក្រមក្នុងការសម្រេចសេចក្តីដែលមាន ឆន្ទាគតិទោសាគតិ ភយាគតិ និងមោហាគតិ ដោយធម៌បួននេះ ចៅក្រមត្រូវប្រកាន់ភ្ជាប់ក្នុងខ្លួនជានិច្ចពេលធ្វើការសម្រេចសេចក្តី ក្នុងរឿងក្តីណាមួយដែលខ្លួនទទួលភារកិច្ច។

តុលាការក៏ត្រូវសំអាងហេតុពីធាតុផ្សំនៃបទល្មើសផងដែរ នៅក្នុងច្បាប់ដើម្បីកំណត់អំពើណាមួយរបស់ជនជាប់ចោទ ថាជាបទល្មើសព្រហ្មទណ្ឌបាន លុះត្រាតែអំពើនោះមានធាតុផ្សំចំនួន ០៣ គឺ ធាតុនីត្យានុកូល, ធាតុសត្យានុម័ត និងធាតុអន្តោម័ត។ ជាទូទៅនៅក្នុងអំពើណាមួយជាបទល្មើសព្រហ្មទណ្ឌ តែងតែមានធាតុផ្សំទាំងបីនេះជាចាំបាច់ ដរាបណា បើខ្វះធាតុណាមួយក្នុងចំណោមធាតុទាំងបីខាងលើនោះ អំពើដែលជនជាប់ចោទបានប្រព្រឹត្តនោះគឺមិនអាចចាត់ទុកជាបទល្មើសព្រហ្មទណ្ឌបានឡើយ ហើយម្យ៉ាងទៀតធាតុផ្សំទាំងបីនេះត្រូវមានភាពស៊ីចង្វាក់ និងស្របគ្នា ។ ដូច្នេះដើម្បីសម្រេចសេចក្តី ក៏ដូចជាកំណត់អំពីទណ្ឌកម្មលើអំពើដែលជនណាមួយបានប្រព្រឹត្តនោះ ជាចាំបាច់តុលាការគឺត្រូវតែធ្វើការបង្ហាញឱ្យច្បាស់ពីធាតុផ្សំនៃបទល្មើសដែលមាននៃអំពើនោះ។ វាមិនទាមទារនូវភាពច្បាស់លាស់ទេ តែគ្រាន់តែមានការបង្ហាញពីវត្តមាននៃធាតុផ្សំនៃបទល្មើស ព្រមទាំងអត្តសញ្ញាណនៃអ្នកប្រព្រឹត្ត ។

ចៅក្រមជំនុំជម្រះ ត្រូវបង្ហាញពីអំពើដែលជនជាប់ចោទបានប្រព្រឹត្តនោះថា អំពើនោះបានប៉ះពាល់ដល់អធិបតេយ្យភាព ព្រះមហាក្សត្រ សាសនា អាជ្ញាធរសាធារណៈ សណ្តាប់ធ្នាប់និងរបៀបរៀបរយសង្គម អាយុជីវិត សុខភាព សិទ្ធិសេរីភាព ទ្រព្យសម្បត្តិស្របច្បាប់របស់ប្រជាពលរដ្ឋ និងទ្រព្យសម្បត្តិសារធារណៈជាដើម ដែលអំពើទាំងនោះមានចែងនៅក្នុងច្បាប់ដែលប្រទេសកំពុងអនុវត្ត ។

### ២.២.២.២. ផ្នែកសេចក្តីសម្រេច

ផ្នែកសេចក្តីសម្រេច ជាផ្នែកចុងក្រោយដែលត្រូវសរសេរនៅក្នុងសាលក្រម ហើយគឺជាវិធានការទាំងឡាយដែលត្រូវចាត់ការ ឬផ្តន្ទាទោសដែលតុលាការបានសម្រេចបើជនជាប់ចោទមានពិរុទ្ធ ឬការដោះលែងឱ្យរួចខ្លួនបើគ្មានពិរុទ្ធ ដែលត្រូវមានសំអាងហេតុគ្រប់ចំណុចសំខាន់ៗនៃបទចោទប្រកាន់ និងគ្រប់ចំណុចនៃពាក្យសុំរបស់ភាគី ។ សេចក្តីសម្រេច ជាផ្នែកសំខាន់នៃសាលក្រម ដែលត្រូវសរសេរឱ្យបានច្បាស់លាស់ដូចសំអាងហេតុដែរ ។

នៅក្នុងផ្នែកនេះ ចៅក្រមជំនុំជម្រះមានតួនាទី សម្រេចអំពីពិរុទ្ធភាព ឬនិរទោស របស់ជនជាប់ចោទដោយផ្អែកលើភស្តុតាងដែលមាននៅក្នុងសំណុំរឿង ឬត្រូវយកមកបង្ហាញនាពេលសវនាការ ស្របតាមការវិនិច្ឆ័យរបស់ខ្លួន ។ តុលាការនឹងសម្រេចឱ្យជនជាប់ចោទរួចខ្លួនពីបទចោទប្រកាន់ កាលណាពុំមានភស្តុតាងណាមួយ បញ្ជាក់អំពីពិរុទ្ធភាពរបស់ជនជាប់ចោទឡើយ តែករណីបើសិនបើចៅក្រមរកឃើញថាជនជាប់ចោទមានពិរុទ្ធភាពពិតមែននោះចៅក្រមជំនុំជម្រះ នឹងសម្រេចសេចក្តីដាក់ទោសទណ្ឌកម្មព្រហ្មទណ្ឌលើជននោះ[76]។ ក្នុងចំនុចនេះក៏អាចមានកំណត់ផងដែរចំពោះវត្ថុតាងនានា ដែលត្រូវរឹបអូសជាសម្បត្តិរដ្ឋ ឬបំផ្លាញចោល ឬក៏ប្រគល់ឱ្យជនរងគ្រោះវិញ ហើយតុលាការក៏ត្រូវតែសម្រេចពីសំណងរដ្ឋប្បវេណីផងដែរ កាលណាមានបណ្តឹងទាមទារ ។

ផ្នែកសេចក្តីសម្រេចនេះ ត្រូវចុះនិទ្ទេស អំពីបទល្មើស ដែលជនជាប់ចោទបានប្រព្រឹត្ត និងទីកន្លែងដែលជនជាប់ចោទបានប្រព្រឹត្តបទល្មើស ដែលអំពើជនជាប់ចោទបានប្រព្រឹត្តខុសអត្ថបទច្បាប់ ដែលកំពុងអនុវត្ត ។

#### ក. ការសម្រេចរបស់តុលាការព្រហ្មទណ្ឌ

នៅក្នុងផ្នែកនេះតុលាការសម្រេចអំពីភាពមានពិរុទ្ធ ដែលមានបញ្ជាក់ពីមូលទោស ដែលកំណត់អំពីរយៈ ពេលនៃការជាប់ពន្ធនាគារ និងទោសពិន័យ ដែលការសម្រេចនេះត្រូវផ្អែកលើអត្ថបទច្បាប់ដែលបានកំណត់អំពីទោសដែលត្រូវទទួល ។

នៅក្នុងរឿងព្រហ្មទណ្ឌ ទោសព្រហ្មទណ្ឌត្រូវបានបែងចែកជា បីប្រភេទ រួមមាន ៖ មូលទោស ទោសបន្ថែម និងទោសជំនួស ។ ប៉ុន្តែករណីបើគ្មានភស្តុតាងណាមួយ ដែលអាចបញ្ជាក់ពីពិរុទ្ធភាពរបស់ជនជាប់ចោទបាននោះ តុលាការនឹងសម្រេចឱ្យជននោះរួចខ្លួនពីបទចោទប្រកាន់ ។ ក្នុងចំណុចនេះក៏អាចមានកំណត់ផងដែរ ចំពោះវត្ថុតាងនានា ដែលត្រូវរឹបអូសជាសម្បត្តិរដ្ឋ ឬបំផ្លាញចោល ឬក៏ប្រគល់ឱ្យជនរងគ្រោះវិញ ។

[76] មាត្រា ៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ការកំណត់អំពីការប្រកាសសាលក្រមដែលអាចមានកំណត់ ពីការប្រកាសជាសាធារណៈ ឬមិនសាធារណៈ ដោយសារស្ថានភាពចាំបាច់ណាមួយ និងបញ្ជាក់ពីការប្រកាស សាលក្រមចំពោះមុខ ឬ កំបាំងមុខភាគី ហើយព្រម ទាំងការបើកសិទ្ធិឱ្យគ្រប់ភាគីក្នុងការប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

ផ្នែកសេចក្ដីសម្រេចត្រូវចុះនិទ្ទេស អំពីបទល្មើសដែលជនជាប់ចោទបានប្រព្រឹត្តខុសអត្ថបទច្បាប់ ដែលអនុវត្ត ទោស និងទណ្ឌកម្មរដ្ឋប្បវេណី ។ ដើម្បីឱ្យកាន់តែក្បោះក្បាយ យើងខ្ញុំនឹងធ្វើការបកស្រាយដូចខាងក្រោម៖

**ខ. ទណ្ឌកម្មព្រហ្មទណ្ឌ**

ក្រមព្រហ្មទណ្ឌ បានកំណត់អំពីទោសព្រហ្មទណ្ឌមាន បីប្រភេទ ដែលតុលការអាចធ្វើការជ្រើសរើសយកមក ប្រកាសប្រភេទទោសណាមួយ ឱ្យសមាមាត្រនឹងបទល្មើស ក៏ប៉ុន្តែទោសដែលតុលាការប្រកាសនោះ ត្រូវតែស្របទៅ នឹងខ្លឹមសារដែលក្រមព្រហ្មទណ្ឌបានកំណត់ ។ ប្រភេទនៃទោសទាំងបីនោះ រួមមាន ៖

- **មូលទោស ៖** មូលទោស គឺជាទោសមូលដ្ឋាន ឬជាទោសចម្បងសំខាន់ជាងគេ ដែលតុលាការធ្វើការ ប្រកាស ដែលទោសនេះតម្រូវឱ្យជនណាម្នាក់រាងចាល ឈប់ប្រព្រឹត្តបទល្មើសតទៅទៀត ហើយមូលទោសនោះ មានដូចជា ទោសដាក់ពន្ធនាគារ និងទោសពិន័យ[77]។ ចំពោះទោសពិន័យ មានន័យថាជាទោសដែលត្រូវបានពិន័យ ជាប្រាក់ ដោយគិតជាប្រាក់រៀល ដែលជារូបិយវត្ថុនៃព្រះរាជណាចក្រកម្ពុជា ។ ចំណែកទោសដាក់ពន្ធនាគារ មាន ន័យថាជាទោសដែលឱ្យដាក់ទណ្ឌិតក្នុងមណ្ឌលឃុំខ្លួន។ មូលទោសទាំងពីរ មិនថាទោសពន្ធនាគារ ឬទោសពិន័យ ដែលប្រកាសដោយតុលាការ ត្រូវប្រកាសស្របតាមកម្រិតអប្បរមា និងអតិបរិមានៃទោសដែលច្បាបកំណត់ ។

មូលទោស គឺជាទោសដែលចៅក្រមយកទៅសម្រេចតែឯងបាន ឬអាចបញ្ចូលទោសបន្ថែមក៏បាន ឬក៏មិន បញ្ចូលក៏បាន។ ជាខ្លី អាចនិយាយបានថា រាល់បទល្មើសទាំងអស់ ត្រូវតែផ្តន្ទាទោសយ៉ាងហោចណាស់ ដោយមូល ទោសណាមួយ[78] ។ ដូចដឹងរួចហើយថា មូលទោស គឺជាទោសទាំងឡាយណាដែលច្បាប់បានបញ្ញត្តិជាលក្ខណៈ សារវន្ត ចំពោះបទល្មើសនីមួយៗ ។

ទោសពន្ធនាគារ គឺទោសដែលត្រូវបំបាត់ស្ទើរទាំងស្រុងនៃសេរីភាពជាមូលដ្ឋាន ឬនិយាយបានថា ដកហូតនូវ សិទ្ធិសេរីភាពរបស់ជនជាប់ចោទ ដោយមានការកំណត់ ។ ដូចយើងបានដឹងហើយថា ទោសព្រហ្មទណ្ឌ ត្រូវបាន បែងចែកជា ទោសឧក្រិដ្ឋ ទោសមជ្ឈិម ទោសលហុ ដែលសមស្របទៅនឹងការបែងចែកប្រភេទបទល្មើស ។ ជាទូទៅ តាមច្បាប់ ទោសពន្ធនាគារ អាចជាទោសដាក់ពន្ធនាគារមួយជីវិត ឬទោសដាក់ពន្ធនាគារមានរយៈពេលកំណត់

[77] មាត្រា ៤៣ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

[78] សៀវភៅនីតិវិធីព្រហ្មទណ្ឌ ស្នាដៃនិពន្ធរបស់ សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធិ និងសាស្ត្រាចារ្យ ចាំង ស៊ីណាត ទំព័រ ៥៧១

ដែលអាចចាប់ពីមួយថ្ងៃ ទៅ៣០ឆ្នាំ ទៅតាមទោសព្រហ្មទណ្ឌដែលបានប្រព្រឹត្ត ។ ដោយហេតុថាបទល្មើសដែលមានចែងក្នុងក្រមព្រហ្មទណ្ឌត្រូវបានចាត់ថ្នាក់ជាបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ ទៅតាមទម្ងន់នៃបទល្មើសនោះ។ ដូច្នេះទោសពន្ធនាគារ ដែលតុលាការ ត្រូវធ្វើការប្រកាស ត្រូវអនុវត្តទៅតាមទោសដែលជនជាប់ចោទបានប្រព្រឹត្ត ដែលក្រមព្រហ្មទណ្ឌក៏បានកំណត់រួចហើយដែរ ដូចខាងក្រោម ៖

- ទោសពន្ធនាគារចំពោះបទឧក្រិដ្ឋ ៖ ដាក់ពន្ធនាគារមួយជីវិត និងដាក់ពន្ធនាគារមានអតិបរិមាលើសពី០៥ ឆ្នាំ និងក្រោមឬស្មើ ៣០ ឆ្នាំ ។

- ទោសពន្ធនាគារចំពោះបទមជ្ឈិម ៖ ដាក់ពន្ធនាគារមានអតិបរិមាលើសពី០៦ថ្ងៃ និងក្រោម ឬស្មើ ០៥ ឆ្នាំ។

- ទោសពន្ធនាគារចំពោះបទលហុ ៖ ដាក់ពន្ធនាគារមានអតិបរិមានិងក្រោម ឬស្មើ ០៦ ថ្ងៃ ។

ចំណែកទោសពិន័យជាប្រាក់វិញ ជាទោសបង្ខំដែលតម្រូវអោយទណ្ឌិតបង់ប្រាក់នូវចំនួនដែលកំណត់ដោយបញ្ញត្តិច្បាប់ ដែលកំណត់អប្បបរិមា និងអតិបរមានៃចំនួនទឹកប្រាក់ពិន័យដែលទណ្ឌិតត្រូវទទួល ។ ទឹកប្រាក់នោះត្រូវកំណត់ជាប្រាក់រៀល[79]។ ប្រាក់ជាផលនៃពិន័យដែលតុលាការសម្រេចនោះ ជាចំណូលរបស់រដ្ឋ ត្រូវបង់ចូលថវិការដ្ឋ ដែលត្រូវបានដាក់ចូលរតនាគារជាតិ ។ ប៉ុន្តែការពិន័យជាប្រាក់នេះ មិនមែនជាប្រាក់សំណងរដ្ឋប្បវេណី ដែលពិរុទ្ធជន សងសំណងជម្ងឺចិត្ត ទៅជនរងគ្រោះទេ តែជាប្រាក់ដែលតុលាការសម្រេចចំពោះបទល្មើសដែលជននេះបានប្រព្រឹត្ត ។

• **ទោសបន្ថែម** ៖ ទោសបន្ថែម គឺជាទោសដែលត្រូវបានប្រកាសដើម្បីបន្ថែមលើមូលទោស ប៉ុន្តែពុំត្រូវធ្វើឡើងដោយស្វ័យប្រវត្តិនោះទេ ពោលគឺអាស្រ័យលើតុលាការ ដែលចៅក្រមជំនុំជម្រះ មានឆន្ទានុសិទ្ធិក្នុងការសម្រេចថាប្រកាសទោសបន្ថែម ឬមួយមិនប្រកាស បើផ្អែកតាមគោលការណ៍ឯកត្តកម្មនៃទោស ។ ប៉ុន្តែទោសនេះ ក៏នៅតែត្រូវប្រកាសឡើង ប្រសិនបើទោសនេះត្រូវបានចែងនៅក្នុងច្បាប់ដោយជាក់លាក់ចំពោះបទឧក្រិដ្ឋ បទមជ្ឈឹម បទលហុ ដែលត្រូវបានចោទប្រកាន់ ។ អនុលោមតាមមាត្រា ៥៣ នៃក្រមព្រហ្មទណ្ឌ ទោសបន្ថែមមាន ១៩ ប្រភេទ ប៉ុន្តែបញ្ញាត្តិដោយឡែកអាចបង្កើតទោសបន្ថែមផ្សេង ។

• **ទោសជំនួស** ៖ ទោសជំនួស គឺជាប្រភេទទោសមួយនៃទោសព្រហ្មទណ្ឌ ក្រៅពីមូលទោសនិងទោសបន្ថែម ហើយត្រូវបានប្រកាស ដើម្បីជំនួសឲ្យមូលទោស ។ យោងតាមការកំណត់នៃច្បាប់ កាលណាទោសជំនួសត្រូវ

[79] មាត្រា ៤៣ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

បានប្រកាសនោះ មូលទោសមិនអាចប្រកាសបាននោះទេ[80] ។ ពាក្យថា ទោសបន្ថែម គឺជាការយកទណ្ឌកម្មផ្សេង មកជំនួសឱ្យមូលទោស ដែលទណ្ឌកម្មផ្សេងនោះរួមមាន ទោសការងារសហគមន៍ និងទោសស្តីបន្ទោស ។

ទោសការងារសហគមន៍ គឺជាទម្រង់មួយនៃទោសជំនួស ដែលជាកាតព្វកិច្ចត្រូវបំពេញក្នុងថេរវេលាចន្លោះពី ៣០ ម៉ោង ទៅ ២០០ ម៉ោង នូវការងារគ្មានកម្រៃជាប្រយោជន៍ដល់រដ្ឋ រដ្ឋបាលថ្នាក់ក្រោមជាតិ ឬនីតិបុគ្គលនៃនីតិសាធារណៈផ្សេងទៀត ដល់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ។ លក្ខខណ្ឌដែលនាំឱ្យប្រកាសទោសសហគមន៍នេះបាន លុះត្រាតែជនជាប់ចោទទទួលទោសដាក់ពន្ធនាគារ ដែលមានអតិបរិមាតិចជាង ឬស្មើនឹង០៣ឆ្នាំ និងការងារសហគមន៍នោះ គឺបម្រើប្រយោជន៍នីតិបុគ្គលសាធារណៈ មិនមែនបំពេញជាប្រយោជន៍នៃរូបវន្តបុគ្គលទេ។ ម៉្យាងទៀត ករណីនាអំឡុងពេល នៃការអនុវត្តការងារសហគមន៍ ប្រសិនបើមានការខូចខាតណាមួយដល់អ្នកដទៃដែលបង្កឡើងទណ្ឌិតនោះ រដ្ឋត្រូវចេញសាហ៊ុយជួសជុលការខូចខាតនោះ តែរដ្ឋមានសិទ្ធិទទួលបានមកវិញនៃសាហ៊ុយនោះពីទណ្ឌិតបាន[81] ។

ទោសស្តីបន្ទោស គឺជាទម្រង់មួយនៃទោសជំនួស ដែលប្រើប្រាស់វិធាននៃការស្តីបន្ទោសទៅលើទណ្ឌិត ដើម្បីជំនួសឱ្យមូលទោស។ ទោសជំនួសក្រោមទម្រង់ជាការស្តីបន្ទោសនេះ អាចត្រូវបានប្រកាសឱ្យអនុវត្តបាន កាលបើជនជាប់ចោទរងទោសដាក់ពន្ធនាគារដែលមានអតិបរមាតិចជាង ឬស្មើនឹង ០៣ឆ្នាំ និងប្រសិនបើបានបំពេញលក្ខខណ្ឌចំនួន ០៣ទៀត ដូចជា៖ ភាពចលាចលដល់សណ្តាប់ធ្នាប់សាធារណៈ បង្កដោយបទល្មើសបានបញ្ចប់, ការខូចខាតត្រូវបានជួសជុលរួចហើយ និងជនជាប់ចោទបង្ហាញការធានាក្នុងការចូលទៅរួមរស់ក្នុងសង្គមវិញ ។

### គ. សេចក្តីសម្រេចផ្សេងទៀត

- **ការអនុវត្តវិធានការណ៍ចាប់ខ្លួន និងឃុំខ្លួន** ៖ ក្រៅពីសម្រេចអំពីទោសព្រហ្មទណ្ឌ និងសំណងរដ្ឋប្បវេណី តុលាការក៏អាចសម្រេចសេចក្តីបង្គាប់ឱ្យចាប់ខ្លួន និងឃុំខ្លួន ទៅលើជនជាប់ចោទ ដែលរកឃើញមានពិរុទ្ធភាពនេះដែរ ។ ការសម្រេចនេះ ជាឆន្ទានុសិទ្ធិរបស់តុលាការ មានន័យថា តុលាការអាចចេញ ឬមិនចេញក៏បានដែរ ។

លក្ខខណ្ឌចាំបាច់មួយចំនួនដែលចៅក្រមត្រូវតែគោរព មុននឹងចេញសម្រេចការចេញដីកាចាប់ខ្លួន និងឃុំខ្លួនជនជាប់ចោទនេះបាន លុះត្រាតែ ៖ តុលាការប្រកាសផ្តន្ទាទោសជនជាប់ចោទដាក់ពន្ធនាគាររយៈពេល ០១ឆ្នាំយ៉ាងតិច ដោយមិនមានការព្យួរទោស មិនថាព្យួរទោសមួយផ្នែក ឬទាំងស្រុង ក្នុងលក្ខខណ្ឌណាមួយឡើយ ហើយចំណុច

[80] មាត្រា៤៣ នៃក្រមនីតិព្រហ្មទណ្ឌ ឆ្នាំ២០០៩

[81] មាត្រា ៧៥ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩

ចាំបាច់មួយទៀតនោះ តុលាការត្រូវសំអាងហេតុក្នុងផ្នែកសំអាងហេតុឱ្យបានច្បាស់លាស់ពីមូលហេតុនាំឱ្យតុលាការចេញដីកាចាប់ខ្លួន និងឃុំខ្លួនជនជាប់ចោទនេះ [82]។

ឧទាហរណ៍ ៖ ជនជាប់ចោទឈ្មោះ សុខ ខា ហៅ អាវែង បានអវត្តមាននៅដំណាក់អយ្យការ, ចៅក្រមស៊ើបសួរ និងនាពេលសវនាការ ដោយជននេះបានរត់គេចខ្លួន ។ ដោយមានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់ដាក់បន្ទុកលើជនជាប់ចោទ ក្នុងការចោទប្រកាន់នេះ និងពិនិត្យដល់ភាពធ្ងន់ធ្ងរនៃបទល្មើស ដែលជនជាប់ចោទបានប្រព្រឹត្ត ហើយជនជាប់ចោទអាចប្រព្រឹត្តបទល្មើសតទៅទៀត ។ ហេតុនេះ គប្បីតុលាការចេញដីកាបង្គាប់ឱ្យចាប់ខ្លួនជនជាប់ចោទមកឃុំខ្លួន ដើម្បីអនុវត្តទណ្ឌកម្ម យោងតាមមាត្រា៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ ទោះបី ជាក្នុងផ្នែកសេចក្តីសម្រេចនៃសាលក្រម បានសរសេរសម្រេចពីការបង្គាប់ឲ្យចាប់ខ្លួន និងឃុំខ្លួនជនជាប់ចោទរួចហើយក៏ដោយ ក៏ចៅក្រមត្រូវធ្វើដីកាចាប់ខ្លួន និងឃុំខ្លួន មួយដាច់ដោយឡែកពីសាលក្រមផងដែរ ដែលដីកានោះត្រូវបញ្ជាក់ថាធ្វើឡើងតាមអំណាចនៃសាលក្រម ។

- **ការសម្រេចពីវត្ថុចាប់យក៖** តុលាការក៏ត្រូវសម្រេចអំពីវត្ថុដែលចាប់យកដែលមាននៅក្នុងសំណុំរឿងព្រហ្មទណ្ឌនោះដែរ[83]។ ការសម្រេចនេះ គឺតុលាការមានសិទ្ធិសម្រេចតែចំពោះវត្ថុចាប់យក ដែលមានក្នុងកំណត់ហេតុទទួលវត្ថុចាប់យក របស់អយ្យការអមសាលាដំបូងរាជធានី-ខេត្ត ប៉ុណ្ណោះ ។ វត្ថុចាប់យកនោះ អាចមានដូចជា សារធាតុញៀន, សម្ភារៈផ្សេងៗដែលជនជាប់ចោទយកមកធ្វើសកម្មភាពប្រព្រឹត្តបទល្មើសណាមួយនោះ, សម្ភារៈរបស់ជនរងគ្រោះដែលត្រូវបានជនជាប់ចោទលួចយក ជាដើម ។

តុលាការអាចសម្រេចប្រគល់វត្ថុចាប់យកនោះទៅឱ្យម្ចាស់ដើមវិញ ឬរឹបអូសជាសម្បត្តិរដ្ឋ និងរឹបអូសដើម្បីបំផ្លាញចោល។ តាមការជាក់ស្តែង ប្រសិនបើវត្ថុចាប់យកណាមួយពុំពាក់ព័ន្ធនឹងបទល្មើសក្នុងសំណុំរឿងនេះទេ ប្រាកដជាតុលាការនឹងសម្រេចប្រគល់វត្ថុនោះទៅឱ្យម្ចាស់ដើមវិញ ប៉ុន្តែផ្ទុយទៅវិញ បើវត្ថុចាប់យកណាមួយ គឺជាមធ្យោបាយសម្រាប់ប្រព្រឹត្តបទល្មើស ឬពាក់ព័ន្ធនឹងការបានផលពីបទល្មើស តុលការនឹងសម្រេចរឹបអូសវត្ថុនោះតែម្តង។ ជាពិសេសចំពោះវត្ថុចាប់យក ជាប្រភេទសារធាតុញៀន តុលាការនឹងធ្វើការរឹបអូសយកមកបំផ្លាញចោលដោយគ្មានការលើកលែងឡើយ ។

[82] មាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[83] មាត្រា ៣៥៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

### ឃ. ការសម្រេចពីសំណងរដ្ឋប្បវេណី

ចៅក្រមជាអ្នកដែលដើរតួនាទីអព្យាក្រឹត និងផ្តល់យុត្តិធម៌សម្រាប់គ្រប់ភាគី រួមទាំងជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី ចំពោះការទាមទារសំណងរបស់ពួកគេ ។ ជាពិសេស ប្រសិនបើមានបណ្តឹងរដ្ឋប្បវេណី ដែលធ្វើឡើងក្នុងពេលជាមួយបណ្តឹងអាជ្ញា តុលាការដាច់ខាតត្រូវសម្រេចអំពីផលប្រយោជន៍រដ្ឋប្បវេណីនេះ[84]។ ចៅក្រមត្រូវតែគោរពតាមគោលការណ៍ជាក់លាក់ និងនីតិវិធីច្បាស់លាស់ ដើម្បីសម្រេចពីសំណងទៅឱ្យភាគីដែលទាមទារឱ្យធនល្មម និងសមាមាត្រទៅនឹងកម្រិតនៃព្យសនកម្មដែលកើតមាន ហើយព្យសនកម្មនេះទៀតសោត ត្រូវតែកើតឡើងដោយសារអំពើរបស់ជនជាប់ចោទបានប្រព្រឹត្ត។ ករណីការទាមទារសំណងជម្ងឺចិត្តរបស់ជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណី មានកម្រិតខ្ពស់ហួសពីព្យសនកម្មជាក់ស្តែង ម្យ៉ាងទៀតដើមបណ្តឹងរដ្ឋប្បវេណីពុំបានបង្ហាញភស្តុតាងណាមួយបញ្ជាក់ពីការខូចខាតដែលខ្លួនបានទទួលរង ជូនតុលាការពិនិត្យទេ តុលាការគប្បីធ្វើការពិនិត្យពិចារណា និងសម្រេចបន្ធូរបន្ថយសំណង ធ្វើយ៉ាងណាឱ្យមានតុល្យភាពទៅនឹងពន្យសនកម្មដែលបានកើតឡើង ក៏ដូចជាពិចារណាអំពីស្ថានភាពជីវភាពជាក់ស្តែងរបស់ជនជាប់ចោទផងដែរ ។ ជាការពិត ចំពោះការសម្រេចសេចក្តី ក្នុងការប្រគល់សំណងទៅឱ្យភាគីដែលទាមទារនោះ មិនមែនជារឿងសាមញ្ញសម្រាប់ចៅក្រមនោះទេ ។ ដូច្នេះ ចៅក្រមត្រូវតែពិចារណាប្រកបដោយវិចារណញ្ញាណខ្ពស់ និងប្រកបដោយវិជ្ជាជីវៈក្នុងការកំណត់ពីសំណង ។

តុលាការព្រហ្មទណ្ឌ អាចសម្រេចពីការជួសជុលព្យសនកម្មបាន លុះត្រាតែបានពិនិត្យជាមុនអំពីធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌ ហើយមានការប្រកាសថាជនជាប់ចោទត្រូវមានពិរុទ្ធភាពពិតមែន។ ប៉ុន្តែប្រសិនបើតុលាការប្រកាសថា ជនជាប់ចោទគ្មានពិរុទ្ធភាពនោះទេ នាំឱ្យមិនមានការសងសំណងរដ្ឋប្បវេណីទៅដើមបណ្តឹងរដ្ឋប្បវេណីពីសំណាក់ជនជាប់ចោទ ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណីទេ ។ នោះមានន័យថា កាលណាគ្មានបទល្មើសព្រហ្មទណ្ឌណាមួយបានកើតឡើង ហើយការសម្រេចពីសំណងរដ្ឋប្បវេណី ក៏មិនអាចកើតមានដែរ ។ ប៉ុន្តែករណីជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណីបានទទួលសំណងនានា ពីភាគីជនជាប់ចោទរួចរាល់ហើយ ឬពុំបានទាមទារសំណងណាមួយពីជនជាប់ចោទទេ នោះតុលាការពុំចាំបាច់លើកយកមកពិចារណា នឹងសម្រេចឡើយ ។

### ង. ការរួចផុតខ្លួនពីបទចោទប្រកាន់

ចំពោះអង្គហេតុដែលកើតឡើង នៅក្នុងសំណុំរឿងប្រសិនបើតុលាការយល់ឃើញថា ពុំមានធាតុផ្សំបទល្មើសគ្រប់គ្រាន់ និងគ្មានភស្តុតាងណាមួយ ដើម្បីដាក់បន្ទុកលើជនជាប់ចោទនោះ តុលាការនឹងធ្វើការសម្រេចឱ្យជនជាប់

[84] មាត្រា ៣៥៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ចោទរួចខ្លួនពីការចោទប្រកាន់ពីបទចោទបាន ព្រោះចៅក្រមជំនុំជម្រះពុំចងកាតព្វកិច្ចទាមទារឱ្យត្រូវតែលិខិតចោទប្រកាន់នោះទេ ដូច្នេះករណីខ្លះបទល្មើសមួយចំនួន មិនត្រូវបានរកឃើញពិរុទ្ធភាព ឬមិនមានធាតុផ្សំបទល្មើសគ្រប់គ្រាន់នោះ តុលាការអាចសម្រេចឱ្យជននោះរួចខ្លួនបាន [85]។ ជារួមមានន័យថា តុលាការសម្រេចឱ្យរួចទោស កាលណាគ្មានបទល្មើស ។ ជាក់ស្តែងដូចជាតាមមាត្រា៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចែងថា " វិមតិសង្ស័យត្រូវតែជាអត្ថប្រយោជន៍ដល់ជនជាប់ចោទ...." ចំពោះអង្គហេតុណាមួយ តុលាការយល់ឃើញថា មានវិមតិសង្ស័យច្រើនចំពោះបទចោទប្រកាន់លើជនជាប់ចោទ តុលាការក៏អាចសម្រេចឱ្យជននោះរួចខ្លួនបានដែរ ។

ឧទាហរណ៍៖ ករណីតុលាការរកឃើញថា អនីតិជន ដែលជាជនជាប់ចោទមានអាយុក្រោម ១៤ ឆ្នាំ នៅពេលដែលជននេះបានប្រព្រឹត្តបទល្មើសនោះ តុលាការត្រូវសម្រេចឱ្យអនីតិជននោះរួចផុតពីការចោទប្រកាន់ និងបង្គាប់ឱ្យដោះលែងជាបន្ទាន់ ។

## ផ្នែកទី៣ ៖ ការជូនដំណឹងពីសាលក្រមព្រហ្មទណ្ឌ

ជាគោលការណ៍ នៅពេលដែលតុលាការព្រហ្មទណ្ឌចេញសេចក្តីសម្រេចលើអង្គសេចក្តី តុលាការមានកាតព្វកិច្ចក្នុងការជូនដំណឹងអំពីសេចក្តីសម្រេចនោះ ប៉ុន្តែប្រសិនបើសេចក្តីសម្រេចនោះជាប្រភេទនៃសេចក្តីសម្រេចកំបាំងមុខ និងចាត់ទុកថាចំពោះមុខ ។ មានន័យថាចំពោះការប្រកាសសាលក្រមកំបាំងមុខ និងសាលក្រមចាត់ទុកចំពោះមុខ តុលាការនឹងធ្វើការជូនដំណឹង ដល់ភាគីដែលអវត្តមាននាពេលសវនាការនោះ ដើម្បីឱ្យភាគីដែលពាក់ព័ន្ធទទួលបានដំណឹងអំពីសេចក្តីសម្រេចនោះ ។ ការជូនដំណឹងនេះ ត្រូវធ្វើឡើងជាលិខិត ជាលាយលក្ខណ៍អក្សរ ដែលធ្វើឡើងដោយតុលាការដែលមានសមត្ថកិច្ចដែលចេញសាលក្រមនោះ ហើយលិខិតនោះ គេហៅថា លិខិតជូនដំណឹងអំពីសាលក្រមកំបាំងមុខ ។

### ៣.១. លិខិតជូនដំណឹងពីសាលក្រមកំបាំងមុខ

ដីកាឱ្យដំណឹង គឺជាលិខិតដែលឱ្យដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការដែលបញ្ញត្តិច្បាប់តម្រូវឱ្យជូនដំណឹងដល់ភាគីពាក់ព័ន្ធ ដើម្បីឱ្យភាគីពាក់ព័ន្ធទទួលបានដំណឹងពីសេចក្តីសម្រេចនៃសាលក្រម [86]។

#### ៣.១.១. ទម្រង់នៃលិខិតជូនដំណឹងពីសាលក្រមកំបាំងមុខ

ដីកាជូនដំណឹងពីសាលក្រមកំបាំងមុខ ចំណុចសំខាន់ៗដែលមិនអាចខ្វះបានគឺត្រូវមានសរសេរអំពី៖

- ប្រភេទនៃដីកា និងការយោងពីសេចក្តីសម្រេចដែលត្រូវជូនដំណឹង

[85] មាត្រា ៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[86] មាត្រា ៤៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

- អត្តសញ្ញាណ និងទីលំនៅដ្ឋាននៃភាគីដែលត្រូវទទួលដំណឹងអំពីសេចក្តីសម្រេច

- កាលបរិច្ឆេទ និងហត្ថលេខារបស់អ្នកធ្វើការជូនដំណឹង

- បញ្ជាក់អំពីផ្លូវតវ៉ាទៅនឹងសេចក្តីសម្រេចដែលភាគីពាក់ព័ន្ធអាចធ្វើបាន ព្រមទាំងរយៈពេលនៃសិទ្ធិប្តឹងតវ៉ានោះ

- លិខិតចម្លងនៃសេចក្តីសម្រេចដែលត្រូវជូនដំណឹងត្រូវភ្ជាប់ទៅនឹងដីកាឱ្យដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការ [87]។

**៣.១.២. បុគ្គលដែលមានសិទ្ធិទទួលបានការជូនដំណឹងពីតុលាការ**

យោងទៅតាមច្បាប់ ចំពោះការជូនដំណឹងត្រឹមត្រូវតុលាការ បុគ្គលដែលមានសិទ្ធិទទួលការជូនដំណឹងនេះ មានតែភាគីដែលពាក់ព័ន្ធក្នុងសំណុំរឿង ដែលបានអវត្តមាន ។ បុគ្គលទាំងនោះ មានដូចជា ពិរុទ្ធជន , ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ឬជនរងគ្រោះជាដើម ។ ការជូនដំណឹងដែលត្រឹមត្រូវពីតុលាការ គឺជាការជូនដំណឹងដោយលិខិតជាលាយលក្ខណ៍អក្សរ ដែលត្រូវភ្ជាប់ទៅនឹងលិខិតចម្លងនៃសេចក្តីសម្រេច ដែលត្រូវជូនដំណឹង ។

**៣.១.៣. បុគ្គលដែលទទួលបន្ទុកក្នុងការជូនដំណឹង**

បុគ្គលដែលទទួលបន្ទុកក្នុងការជូនដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការ មានដូចខាងក្រោម៖

**៣.១.៣.១. ព្រះរាជអាជ្ញា**

ការជូនដំណឹងដល់ភាគីដែលពាក់ព័ន្ធ អាចត្រូវធ្វើដោយព្រះរាជអាជ្ញា ។ ក្នុងករណីនេះ ព្រះរាជអាជ្ញាត្រូវប្រគល់លិខិតចម្លងនៃសេចក្តីសម្រេចរបស់តុលាការ ដល់ភាគីដែលពាក់ព័ន្ធ ។ ព្រះរាជអាជ្ញាចុះនិទ្ទេសលើសេចក្តីសម្រេចដើមអំពីកាលបរិច្ឆេទ និងទីកន្លែង នៃការប្រគល់លិខិតចម្លងនៃសេចក្តីសម្រេចរបស់តុលាការ ។ ភាគីដែលពាក់ព័ន្ធត្រូវចុះហត្ថលេខានៅលើសេចក្តីសម្រេចដើមនោះ [88]។

**៣.១.៣.២. អាជ្ញាសាលា**

ការជូនដំណឹងដល់ភាគីដែលពាក់ព័ន្ធ អាចត្រូវធ្វើដោយអាជ្ញាសាលាផងដែរ។ អាជ្ញាសាលាប្រើគ្រប់មធ្យោបាយដើម្បីជូនដំណឹងដល់បុគ្គលពាក់ព័ន្ធអំពីសេចក្តីសម្រេចរបស់តុលាការ [89] ។

---

[87] មាត្រា ៤៨៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[88] មាត្រា ៤៨៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[89] មាត្រា ៤៨៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

#### ៣.១.៣.៣. បុគ្គលផ្សេងទៀតដែលអាចធ្វើការជូនដំណឹង

ក្នុងករណីខ្លះក្នុងការអនុវត្តការឱ្យដំណឹង អាចមានរបៀបផ្សេងទៀតនៃការជូនដំណឹង ដោយគេអាចប្រគល់ទៅឱ្យបុគ្គលមួយចំនួនផ្សេងទៀត តាមការបញ្ជារបស់ព្រះរាជអាជ្ញា ដែលបុគ្គលទាំងនោះមានដូចជា(៤៨៩) ៖

- តុលាការទីកន្លែងបទល្មើស
- ក្រឡាបញ្ជី
- តាមផ្លូវរដ្ឋបាលរបស់សាលាដំបូងរាជធានី-ខេត្ត
- ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន (ប្រសិនបើពិរុទ្ធជនត្រូវបានឃុំខ្លួនពីបទដទៃទៀត)
- តាមអង្គភាពគរបាលជាតិ ឬកងរាជអាវុធហត្ថ ។

### ៣.២. ដំណើរការនៃការជូនដំណឹង

កាតព្វកិច្ចឱ្យដំណឹងអំពីសេចក្ដីសម្រេចរបស់តុលាការជាពិសេសចំពោះសេចក្ដីសម្រេចកំបាំងមុខ ផ្អែកតាមក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០១៧ បានកំណត់ចាប់ពី មាត្រា ៤៨២ រហូតដល់មាត្រា ៤៩០ ដែលតទៅនេះយើងនឹងធ្វើការបែងចែកការឱ្យដំណឹងជាពីរគឺ ការឱ្យដំណឹងតាមការជាក់ស្ដែង ឬដោយផ្ទាល់ និងការឱ្យដំណឹងតាមការសន្មត។ តើអ្វីទៅហៅថា ការឱ្យដំណឹងតាមមការជាក់ស្ដែង ឬដោយផ្ទាល់ និងការឱ្យដំណឹងតាមការសន្មត?

#### ៣.២.១. ការឱ្យដំណឹងតាមការជាក់ស្ដែង ឬដោយផ្ទាល់

ជាគោលការណ៍គ្រប់ភាគីពាក់ព័ន្ធទាំងអស់ ត្រូវបានទទួលដំណឹងអំពីសេចក្ដីសម្រេចរបស់តុលាការដោយផ្ទាល់ដៃដែលត្រូវភ្ជាប់ដោយលិខិតចម្លងនៃសេចក្ដីសម្រេចនោះ ហេតុនេះវិធានដែលត្រូវអនុវត្តក្នុងការឱ្យដំណឹងតាមការជាក់ស្ដែង ឬដោយផ្ទាល់ដែលធ្វើឡើងអាជ្ញាធរមានសមត្ថកិច្ចពោល គឺព្រះរាជអាជ្ញា អាជ្ញាសាលាជាដើមនោះត្រូវប្រើគ្រប់មធ្យោបាយ ដើម្បីជូនដំណឹងសំដៅយ៉ាងណាឱ្យតែបុគ្គលដែលពាក់ព័ន្ធ ទទួលដំណឹងអំពីសេចក្ដីសម្រេចរបស់តុលាការដោយផ្ទាល់ដៃ។ សេចក្ដីសម្រេចដើមដែលបានចុះនិទ្ទេសរួច ត្រូវបង្វិលទៅព្រះរាជអាជ្ញាវិញជាបន្ទាន់ដើម្បីធ្វើជាភស្តុតាងដល់តុលាការថា ភាគីពាក់ព័ន្ធបានទទួលដំណឹងរួចរាល់ហើយ[៩០]។

ឧទាហរណ៍ ៖ ប្រសិនបើព្រះរាជអាជ្ញា ឬអាជ្ញាសាលាចុះដល់លំនៅឋាន ឬកន្លែងណាមួយរបស់ពិរុទ្ធជន ឬភាគីពាក់ព័ន្ធដទៃទៀត ហើយជួបជននោះនៅនឹងកន្លែង ព្រះរាជអាជ្ញា ឬអាជ្ញាសាលាជាត្រូវប្រគល់លិខិតចតចំលងនៃសេចក្ដីសម្រេចដល់ជនទាំងនោះ ។ ចំពោះអាជ្ញាសាលានៅពេលដែលប្រគល់លិខិតចម្លងនៃសេចក្ដីសម្រេចដល់ភាគីដែលពាក់ព័ន្ធហើយ ត្រូវចារលើនៅសេចក្ដីសម្រេចដើមថា ត្រូវបានប្រគល់លិខិតចម្លងឱ្យភាគីពាក់ព័ន្ធដោយផ្ទាល់ដៃ

[៩០] មាត្រា ៤៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ហើយត្រូវចុះនិទ្ទេស អំពីកាលបរិច្ឆេទ និងទីកន្លែងដែលបានប្រគល់លិខិតចម្លងនោះ និងតំរូវឱ្យភាគីពាក់ព័ន្ធចុះហត្ថលេខាលើសេចក្តីសម្រេចដើមនោះ ។

ប៉ុន្តែប្រសិនបើករណីដែលព្រះរាជអាជ្ញា ឬអាជ្ញាសាលាធ្វើការស្វែងរកភាគីពាក់ព័ន្ធអស់ពីសមត្ថភាពហើយនៅតែមិនឃើញភាគីពាក់ព័ន្ធដើម្បីប្រគល់លិខិតចម្លងនៃសេចក្តីសម្រេច ឬក៏ភាគីពាក់ព័ន្ធអវត្តមានព្រះរាជអាជ្ញា ឬអាជ្ញាសាលាត្រូវធ្វើការឱ្យដំណឹងតាមការសន្មត។

### ៣.២.២. ការឱ្យដំណឹងតាមការសន្មត

សំដៅទៅលើស្ថានភាពមួយដែលអាជ្ញាធរ មិនអាចធ្វើការឱ្យដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការដោយផ្ទាល់ដៃដល់ភាគីពាក់ព័ន្ធបាន ប៉ុន្តែគេនៅតែអាចធ្វើការឱ្យដំណឹងបានដែរ ដែលស្ថានភាពយើងនឹងធ្វើការបង្ហាញដូចខាងក្រោម៖

- ***ភាគីពាក់ព័ន្ធអវត្តមានពីលំនៅឋាន*** : ប្រសិនបើភាគី អវត្តមានពីលំនៅឋាន អាជ្ញាសាលាត្រូវប្រគល់លិខិតចម្លងនៃសេចក្តីសម្រេចឱ្យបុគ្គលជានីតិជនដែលមានវត្តមាននៅក្នុងលំនៅឋាន [91]។ ប៉ុន្តែប្រសិនបើភាគីពាក់ព័ន្ធមានវត្តមានតែមិនព្រមទទួលសេចក្តីសម្រេច ឬគ្មានបុគ្គលណាម្នាក់មានវត្តមាន នៅក្នុងលំនៅឋានរបស់ភាគីពាក់ព័ន្ធទេ ឬគ្មានបុគ្គលណាម្នាក់ដែលមានវត្តមាននៅក្នុងលំនៅឋានរបស់ភាគីពាក់ព័ន្ធយល់ព្រមទទួលសេចក្តីសម្រេចនោះទេ អាជ្ញាសាលាអាចប្រគល់លិខិតចម្លងនៃសេចក្តីសម្រេចទៅមេឃុំ ឬចៅសង្កាត់ ឬទៅជំទប់ ឬចៅសង្កាត់រងណាមួយក៏បាន[92]។ ហេតុនេះបុគ្គលដែលទទួលលិខិតចម្លងនៃសេចក្តីសម្រេចត្រូវសន្យាថា នឹងប្រគល់ឱ្យដល់ភាគីពាក់ព័ន្ធក្នុងរយៈពេលដ៏ខ្លីបំផុត ។ ក្នុងករណីនេះតុលាការនឹងធ្វើសច្ចាធារណ៍ថា ភាគីពាក់ព័ន្ធដែលអវត្តមាននោះបានដឹងអំពីសេចក្តីសម្រេចរបស់តុលាការនៅថ្ងៃនោះតែម្តង ប៉ុន្តែភាគីពាក់ព័ន្ធអាចបង្ហាញភស្តុតាង នៅថ្ងៃដែលខ្លួនបានដឹងអំពីសេចក្តីសម្រេចនោះនៅពេលដែលខ្លួនធ្វើបណ្តឹងទាស់លើសេចក្តីសម្រេចនោះ ។

ប្រសិនបើភាគីពាក់ព័ន្ធកំពុងតែជាប់ឃុំពីបទដទៃទៀត ក្នុងករណីនេះព្រះរាជអាជ្ញាអាចធ្វើការឱ្យដំណឹងប្រគល់ទៅឱ្យប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ហើយប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនមានតួនាទីដូចអាជ្ញាសាលាដែរ បានន័យថាគាត់ត្រូវប្រគល់លិខិតចម្លងនៃសេចក្តីសម្រេចទៅភាគីពាក់ព័ន្ធដោយផ្ទាល់ដៃ និងចុះនិទ្ទេសដូចអ្វីដែលអាជ្ញាសាលាធ្វើរួច ត្រូវប្រគល់សេចក្តីសម្រេចដើមទៅព្រះរាជអាជ្ញាវិញ[93] ។

---

[91] មាត្រា ៤៨៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[92] មាត្រា ៤៨៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[93] មាត្រា ៤៨៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

• **ករណីភាគីពាក់ព័ន្ធពុំមានលំនៅឋាន ឬទីសំណាក់ដែលគេស្គាល់ ឬរស់នៅក្រៅដែនដីជាតិ** : សេចក្តីសម្រេចរបស់តុលាការក៏អាចជូនដំណឹងដល់សាមីខ្លួនបានដែរ គឺតុលាការនឹងធ្វើការសន្មតថាកាលបរិច្ឆេទនៃសេចក្តីសម្រេចរបស់តុលាការត្រូវចាត់ទុកថាជាកាលបរិច្ឆេទនៃការជូនដំណឹង ។ ករណីនេះ គេអាចធ្វើបានតែក្នុងស្ថានភាពដែលតុលាការមានភស្តុតាងយ៉ាងច្បាស់ថាភាគីដែលពាក់ព័ន្ធពិតជាពុំមានលំនៅឋាន ឬទីស្នាក់ដែលគេស្គាល់ ឬរស់នៅក្រៅដែនដីជាតិយ៉ាងប្រាកដ[94]។ ម្យ៉ាងទៀតដើម្បីធានាថា ភាគីពាក់ព័ន្ធបានដឹងអំពីសេចក្តីសម្រេចនោះ តុលាការចាំបាច់ត្រូវ ធ្វើការផ្សព្វផ្សាយជាសាធារណៈអាចតាមរយៈ កាសែត វិទ្យុជាតិ និងអន្តរជាតិ ឬទូរទស្សន៍ជាតិ និងអន្តរជាតិ ជាដើម ។

### ៣.២.៣. ការប្រគល់លិខិតចម្លងនៃសេចក្តីសម្រេចដល់ភាគីពាក់ព័ន្ធ

ប្រសិនបើអាជ្ញាសាលាជួបប្រទះ ភាគីដែលពាក់ព័ន្ធដែលត្រូវបានតុលាការប្រកាសសាលក្រមកំបាំងមុខនោះ អាជ្ញាសាលាត្រូវចារលើសេចក្តីសម្រេចដើម ថាលិខិតចម្លងត្រូវបានប្រគល់ឱ្យភាគីពាក់ព័ន្ធដោយផ្ទាល់ដៃ ។ អាជ្ញាសាលាចុះនិទ្ទេសអំពីកាលបរិច្ឆេទ និងទីកន្លែងដែលបានប្រគល់លិខិតចម្លងភាគីពាក់ព័ន្ធចុះហត្ថលេខាលើសេចក្តីសម្រេចដើម ។ សេចក្តីសម្រេចដើមនេះត្រូវបង្វិលទៅព្រះរាជអាជ្ញាវិញជាបន្ទាន់ ។

• ករណីអវត្តមានភាគីពាក់ព័ន្ធ ៖ ប្រសិនបើភាគីពាក់ព័ន្ធអវត្តមានពីលំនៅឋានអាជ្ញាសាលា ត្រូវប្រគល់លិខិតចម្លងនៃសេចក្តីសម្រេចឱ្យបុគ្គលជានីតិជនដែលមានវត្តមាននៅក្នុងលំនៅឋាន ដែលអាចជាឪពុកម្តាយ ឬសាច់ញាតិរបស់ភាកីដែលអវត្តមាន ។ អាជ្ញាសាលាត្រូវចារលើសេចក្តីសម្រេចដើមថាលិខិតចម្លងនៃសេចក្តីសម្រេចត្រូវបានប្រគល់ឱ្យដល់ដៃបុគ្គលដែលមានវត្តមាននៅក្នុងលំនៅឋាន ។ អាជ្ញាសាលាត្រូវចុះនិទ្ទេសអំពីអត្តសញ្ញាណនៃបុគ្គលនោះ កាលបរិច្ឆេទប្រគល់លិខិតចម្លងនៃសេចក្តីសម្រេច ។ បុគ្គលដែលទទួលលិខិតត្រូវចុះហត្ថលេខា នៅលើ សេចក្តីសម្រេចដើម ។ សេចក្តីសម្រេចដើមនេះត្រូវបង្វិលទៅព្រះរាជអាជ្ញាវិញភ្លាម ។ បុគ្គលដែលទទួលលិខិតចម្លងនៃសេចក្តីសម្រេចត្រូវសន្យាថានឹង ប្រគល់ឱ្យដល់ភាគីពាក់ព័ន្ធក្នុងរយៈពេលដ៏ខ្លីបំផុត។

• **ការប្រគល់លិខិតចម្លងនៃសេចក្តីសម្រេចដល់មេឃុំ ឬ ចៅសង្កាត់ :** អាជ្ញាសាលាប្រគល់លិខិតនៃសេចក្តីសម្រេចទៅមេឃុំ ឬចៅសង្កាត់ ឬទៅជំទប់ ឬចៅសង្កាត់រងណាមួយនៅក្នុងករណីដូចតទៅ ៖

- ចៅក្រមមិនត្រូវធ្វើការបែងចែករវាងញាតិសន្តាន និងបុគ្គលដទៃទៀតទេ
- ភាគីពាក់ព័ន្ធមិនព្រមទទួលសេចក្តីសម្រេច

[94] មាត្រា ៤៩០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

- គ្មានបុគ្គលណាម្នាក់មានវត្តមាននៅក្នុងលំនៅឋានរបស់ភាគីពាក់ព័ន្ធទេ

- គ្មានបុគ្គលណាម្នាក់ដែលមានវត្តមាន នៅក្នុងលំនៅឋានរបស់ភាគីពាក់ព័ន្ធ ព្រមទទួលសេចក្តីសម្រេច នោះទេ។

• **ការប្រគល់លិខិតចម្លងនៃសេចក្តីសម្រេចចំពោះភាគីដែលពុំមានលំនៅឋានឬទីសំណាក់ដែលគេស្គាល់** : ប្រសិនបើភាគីពាក់ព័ន្ធគ្មានលំនៅឋាន ឬទីសំណាក់ទេ ឬប្រសិនបើភាគីពាក់ព័ន្ធនេះរស់នៅក្រៅដែនដីជាតិសេចក្តីសម្រេចរបស់តុលាការក៏អាចត្រូវជូនដំណឹងដល់សាមីខ្លួនបានដែរ។ ក្នុងករណីនេះកាលបរិច្ឆេទ នៃសេចក្តីសម្រេចតុលាការត្រូវចាត់ទុកថាជាកាលបរិច្ឆេទនៃការជូនដំណឹង។ ក្នុងករណីដែលការប្រគល់ការជូនដំណឹងត្រូវបានធ្វើតាមវិធីដូចដែលបានរៀបរាប់ខាងលើ គឺមានន័យថាការជូនដំណឹងត្រូវបានធ្វើត្រឹមត្រូវតាមនីតិវិធីរួចហើយ។

### ៣.២.៤. គោលបំណងនិងផលប្រយោជន៍នៃការជូនដំណឹងពីសាលក្រម

គោលបំណងនៃការជូនដំណឹងអំពីសេចក្តីសម្រេចរបស់តុលាការ ដើម្បីសាលក្រមដែលប្រកាសនោះបង្កើតឱ្យអនុភាពនៃការអនុវត្តបានតាមរយៈការរងចាំចូលជាស្ថាពរ ប្រសិនគ្មានភាគីណាមួយប្តឹងទាស់ ឬប្តឹងឧទ្ធរណ៍ចំពោះសេចក្តីសម្រេចនោះឡើយ ក្នុងរយៈពេលដែលច្បាប់កំណត់ឱ្យនោះ ម្យ៉ាងទៀតការជូនដំណឹងនេះ ក៏ផ្តល់ផលប្រយោជន៍ដល់ភាគីដែលអវត្តមានបានទទួលដំណឹងពីសេចក្តីសម្រេចដែលពាក់ព័ន្ធជាមួយខ្លួននោះមានសិទ្ធិប្តឹងតវ៉ាអំពីសេចក្តីសម្រេចនោះ ដោយបុគ្គលនោះពុំពេញចិត្តលើសេចក្តីសម្រេចនៅក្នុងសាលក្រមនោះ ករណីខ្លួនយល់ឃើញថា វាប៉ះពាល់ដល់សិទ្ធិ និងសេរីភាព ឬក៏ប៉ះពាល់ដល់ផលប្រយោជន៍របស់ខ្លួន ។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ដោយឆ្លងកាត់តាមការធ្វើសិក្សាស្រាវជ្រាវក្រោមប្រធានបទ «**សាលក្រមព្រហ្មទណ្ឌរបស់សាលាដំបូងរាជធានី ~ ខេត្ត**» រួចមកយើងខ្ញុំយល់ឃើញថាសាលក្រមព្រហ្មទណ្ឌមានសារៈសំខាន់ណាស់ ព្រោះវាជាការសម្រេចទៅលើជោគវាសនារបស់ជនជាប់ចោទ ជនរងគ្រោះ ដើមបណ្ដឹងរដ្ឋប្បវេណី ការការពារផលប្រយោជន៍សាធារណៈ និងបុគ្គលឯកជន ការធានានូវតុល្យភាពរវាងផលប្រយោជន៍សាធារណៈ និងផលប្រយោជន៍របស់បុគ្គលឯកជន បញ្ចប់នូវការតវ៉ាផ្សេងៗ ជាមូលដ្ឋានរបស់ប្រជាពលរដ្ឋក្នុងការជឿទុកចិត្តទៅលើស្ថាប័នតុលាការ និងមានសារៈសំខាន់ណាស់សម្រាប់នីតិវិធីរបស់តុលាការជាន់ខ្ពស់។ សាលក្រម ជាលទ្ធផលចុងក្រោយ នៃនីតិវិធីច្បាប់មួយដែលសាលក្រមត្រូវផ្តល់នូវដំណោះស្រាយទំនាស់មួយប្រកបដោយតុល្យភាព ។

សាលក្រម គឺជាសេចក្តីសម្រេចរបស់តុលាការ ដែលត្រូវធ្វើឡើងជាលិខិតសាលក្រម និងមានលក្ខណៈគ្រប់គ្រាន់ស្របទៅតាមទម្រង់ ដែលច្បាប់បានកំណត់ដោយផ្អែកលើការពិភាក្សារដេញដោលហើយកើតមានអនុភាពភាពបាន បន្ទាប់ពីមានការប្រកាសដោយផ្អែកលើលិខិតនៃសាលក្រមនោះផ្ទាល់ ។

សាលក្រមព្រហ្មទណ្ឌ មានតែយុត្តាធិការជម្រះក្តីព្រហ្មទណ្ឌប៉ុណ្ណោះ ដែលមានសមត្ថកិច្ចក្នុងការចេញសាលក្រមព្រហ្មទណ្ឌនេះបាន ។

ក្នុងរឿងក្តីព្រហ្មទណ្ឌ ដើម្បីកំណត់បានថា ជនណាម្នាក់មានទោស ឬមិនមានទោស គឺអាស្រ័យលើសេចក្តីសម្រេចចុងក្រោយរបស់សាលាជម្រះក្តីនីមួយៗ ដោយត្រូវឆ្លងកាត់នីតិវិធីសវនាការ ដែលក្នុងន័យច្បាប់ត្រូវបានហៅថា "សាលក្រម" ។ លំហូរនៃនីតិវិធីដែលនាំឲ្យមានការចេញសាលក្រមត្រូវឆ្លងកាត់ដំណើរការរឿងក្តីព្រហ្មទណ្ឌដែលមានបួនដំណាក់កាល ទៅតាមលំដាប់លំដោយទៅតាមពេលវេលាដូចជា ដំណាក់កាលស៊ើបអង្កេត ដំណាក់កាលចោទប្រកាន់ ដំណាក់កាលស៊ើបសួរ និងដំណាក់កាលជំនុំជម្រះ ។ ដំណាក់កាលជំនុំជម្រះ គឺជាដំណាក់កាលដែលត្រូវសម្រេចអំពីការពិតណាមួយ និងការទទួលខុសត្រូវតាមផ្លូវច្បាប់ ដោយអនុភាពនៃការចាប់បង្ខំគឺ សាលក្រម។ ក្នុងដំណាក់កាលនេះ ជាដំណាក់កាលដែលត្រូវសម្រេចអំពីការពិតណាមួយ និងការទទួលខុសត្រូវតាមផ្លូវច្បាប់ ដោយអនុភាពនៃការចាប់បង្ខំគឺ សាលក្រម។ ការប្រកាសបើកសវនាការគឺធ្វើឡើងដើម្បីបើកការពិភាក្សាដេញដោលដើម្បីស្វែងរកឱ្យឃើញពី នត្ថិភាព ឬ អត្ថិភាពនៃបទល្មើសមុននឹងតុលាការចេញសេចក្តីសម្រេច។

សាលក្រមព្រហ្មទណ្ឌមានច្រើនប្រភេទទៅតាមស្ថានភាពជាក់ស្តែងនាពេលសវនាការ។ សាលក្រមដែលតុលាការចេញអាចទាក់ទងនឹងបញ្ហានៃរឿងអង្គសេចក្តី បញ្ហានីតិវិធី និងការដកហូតសេរីភាពរបស់ជនជាប់ចោទ។

ប៉ុន្តែបើយើងពិនិត្យអំពីប្រភេទនៃសាលក្រម ដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌវិញ ដោយយើងឃើញថា សាលក្រមព្រហ្មទណ្ឌត្រូវបានបែងចែកជាសាលក្រមមុនអង្គសេចក្តី និងសាលក្រមលើអង្គសេចក្តី។ សាលក្រមមុនអង្គសេចក្តី គឺជាសេចក្តីសម្រេចរបស់តុលាការដែលធ្វើឡើងដោយចៅក្រមជំនុំជម្រះ ដែលសាលក្រមនេះសម្រេចបញ្ហានីតិវិធី ដែលទាក់ទងនឹងនីតិវិធីផ្សេងៗមុនរឿងអង្គសេចក្តី ឬក៏សម្រេចពីការចាត់ឱ្យធ្វើការស៊ើបសួរបន្ថែមណាមួយ ម្យ៉ាងទៀតសេចក្តីសម្រេចនេះមិនប៉ះពាល់ដល់នីតិវិធី ឬអង្គសេចក្តីនៃរឿងក្តីនោះឡើយ ។ ជារួមមកសាលក្រមមុនសេចក្តីនេះ គឺមិនមែនសម្រេចសេចក្តីទៅលើអង្គហេតុនៃបទល្មើស ក្នុងរឿងព្រហ្មទណ្ឌនោះឡើយ ពោលគឺសម្រេចសេចក្តីតែទៅលើ អង្គហេតុផ្សេងៗដែលកើតមាននៅក្នុងសំណុំរឿង ដូចជាការសម្រេចឃុំខ្លួនជនជាប់ចោទជាបណ្តោះអាសន្ន ឬការដោះលែងជនជាប់ចោទឱ្យមានសេរីភាពដោយដាក់ស្ថិតក្រោមការត្រួតពិនិត្យពីតុលាការ ក៏ដូចជាសម្រេចអំពីដាក់បញ្ចូលសំណុំរឿងជាដើម ។ សាលក្រមមុនអង្គសេចក្តី មានបែងចែកជាច្រើនប្រភេទជាក់ស្តែងទៅស្ថានភាព ឬហេតុការណ៍ដែលកើតមានឡើង ។ ចំពោះសាលក្រមមុនសេចក្តី អាចបែងចែកជា ០៤ ប្រភេទ ដូចជា ៖ សាលក្រមមុនអង្គសេចក្តីអំពីការឃុំខ្លួន, សាលក្រមមុនអង្គសេចក្តីអំពីអញ្ញាត្រកម្ម សាលក្រមមុនអង្គសេចក្តីអំពីបញ្ចូលសំណុំរឿង និងសាលក្រមចាត់របៀប។

សាលក្រមអង្គសេចក្តី ជាសាលក្រមដែលតុលាការសម្រេចសេចក្តីទៅលើបញ្ហាអង្គសេចក្តី ដែលចៅក្រមជំនុំជម្រះធ្វើការថ្លឹងថ្លែងកាត់ក្តីអំពីអង្គហេតុ ដែលមាននៅក្នុងសំណុំរឿងព្រហ្មទណ្ឌណាមួយប៉ុណ្ណោះ ដែលសាលក្រមនេះសម្រេចថាជនជាប់ចោទមាន ឬគ្មានពិរុទ្ធភាព។ សាលក្រមអង្គសេចក្តី មានច្រើនប្រភេទជាក់ស្តែងទៅស្ថានភាព ឬហេតុការណ៍ដែលកើតមានឡើង ។ ចំពោះសាលក្រមមុនសេចក្តី អាចបែងចែកជា ០៣ ប្រភេទ ដូចជា ៖សាលក្រមកំបាំងមុខ សាលក្រមចំពោះមុខ និងសាលក្រមដែលចាត់ទុកថាចំពោះមុខ ។

ក្រៅពីនេះការតាក់តែងសាលក្រមព្រហ្មទណ្ឌ ក៏ជាចំណុចសំខាន់ដើម្បីអាចបញ្ជាក់បានកាន់តែច្បាស់អំពីពិរុទ្ធភាពនិងរក្សាបាននូវសំអាងហេតុ និងសេចក្តីសម្រេចរបស់តុលាការមួយដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយសម្រាប់ការអនុវត្ត ។ ការបង្កើតនូវខ្លឹមសារសាលក្រម គឺជាភារកិច្ចចម្បងរបស់ចៅក្រមជំនុំជម្រះ ពីព្រោះខ្លឹមសារសាលក្រមបានកំណត់អំពីអត្ថិភាពនៃបទល្មើសព្រហ្មទណ្ឌណាមួយដែលច្បាប់បានចែង ព្រមទាំងផ្តល់ជាសំណងរដ្ឋប្បវេណីដល់ដើមបណ្តឹងរដ្ឋប្បវេណីទៅតាមពស្សនកម្មជាក់ស្តែង តាមការយល់ឃើញរបស់តុលាការ ។ ការតាក់តែងលិខិតសាលក្រមត្រូវមាន ផ្នែកក្បាលនៃសាលក្រម និងផ្នែកសាលក្រមដែលនៅក្នុងផ្នែកនេះត្រូវចែកជាពីររួមមានផ្នែកសំអាងហេតុ និងផ្នែកសេចក្តីសម្រេច។

សរុបសេចក្តីមកយើងឃើញថា សាលក្រមព្រហ្មទណ្ឌអាចមានភាពពេញលេញទៅបាន ត្រូវតែគោរពទៅតាមលក្ខខណ្ឌ និងនីតិវិធីដែលច្បាប់កំណត់ដូចដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។ ហេតុដូចនេះការតាក់តែងលិខិតសាលក្រមជាការបញ្ជាក់ឱ្យកាន់តែច្បាស់លាស់អំពីខ្លឹមសារច្បាប់ផ្អែកតាមរឿងក្តីជាក់ស្តែង និងជាការធានានូវភាពយុត្តិធម៌នៃការសម្រេចដោយធ្វើការលើកឡើងអំពីការវិនិច្ឆ័យ និងដំណាក់កាលនៃការវិនិច្ឆ័យរបស់តុលាការទៅប្រជាជនទូទៅ។

# អនុសាសន៍

# អនុសាសន៍

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវ និងជ្រើសយកប្រធានបទស្តីពី **សាលក្រមព្រហ្មទណ្ឌរបស់សាលាដំបូងរាជធានី - ខេត្ត** ដើម្បីជាការសរសេរសារណាបញ្ចប់ថ្នាក់ បរិញ្ញាបត្ររួចមក។ យើងខ្ញុំយល់ឃើញថាមានភាពខ្វះខាតមួយចំនួន ដែលទាក់ទងទៅនឹងការផ្សព្វផ្សាយអំពីច្បាប់ ដែលធ្វើឱ្យអ្នកសិក្សាស្រាវជ្រាវ និងអ្នកអនុវត្តច្បាប់ ប្រជាពលរដ្ឋ មិនយល់ពីច្បាប់ ទើបមិនគោរពច្បាប់បានត្រឹមត្រូវ។ ប្រជាពលរដ្ឋ យល់ពីច្បាប់ ស្រលាញ់ច្បាប់ ទើបប្រជាពលរដ្ឋគោរពច្បាប់។ អាស្រ័យហេតុនេះសូមឱ្យមានការសហការចូលរួមនិពន្ធអត្ថបទច្បាប់ ឬសៀវភៅដែលពាក់ព័ន្ធទៅនឹងច្បាប់ ពីសំណាក់សាស្ត្រាចារ្យផ្នែកនីតិសាស្ត្រ រួមទាំងអ្នកប្រកបវិជ្ជាជីវៈក្នុងវិស័យនេះ ដោយធ្វើការបកស្រាយ ក៏ដូចជាពន្យល់ឱ្យបានក្បោះក្បាយ និងបន្តពង្រឹងទៅលើវិស័យអប់រំផ្នែក ក្នុងគោលបំណងដែលធ្វើឱ្យប្រជាពលរដ្ឋមានការយល់ដឹងកាន់តែខ្ពស់ ហើយមានភាពខ្លាចរអាក្នុងការបំពានច្បាប់ដែលបានចែង ដើម្បីជាផ្លូវមួយអាចកាត់បន្ថយបទល្មើសដែលកើតឡើងជាយថាហេតុ និងគ្មានការប្រព្រឹត្តបទល្មើសណាមួយទៀត។

ម្យ៉ាងទៀតចំពោះការជូនដំណឹងពីសាលក្រមកំបាំងមុខ តុលាការចាំបាច់ត្រូវតែជូនដំណឹងអំពីសាលក្រមកំបាំងមុខនេះដល់ភាគីដែលអវត្តមាននោះ ។ ការជូនដំណឹងនេះ ត្រូវធ្វើឡើងជាលិខិត ជាលាយលក្ខណ៍អក្សរ ដែលធ្វើឡើងដោយតុលាការដែលមានសមត្ថកិច្ចដែលចេញសាលក្រមនោះ ។ ប៉ុន្តែចំពោះការអនុវត្តជាក់ស្តែងយើងមើលឃើញថាមានលក្ខណៈខ្វះខាតនៅឡើយ។ បញ្ហានេះនាំឱ្យមានការប៉ះពាល់ដល់សិទ្ធិ និងផលប្រយោជន៍ របស់ជនដែលត្រូវទទួលបានការជូនដំណឹងនេះ។ ហេតុដូច្នេះហើយសូមក្រសួងយុត្តិធម៌ និងស្ថាប័នដែលពាក់ព័ន្ធគួរតែពង្រឹងការអនុវត្តឱ្យបានត្រឹមត្រូវ។ ជាពិសេសរាជរដ្ឋាភិបាលគួរតែយកចិត្តទុកដាក់ ចំពោះមន្ត្រីដែលស្ថិតនៅថ្នាក់ក្រោមជាតិដោយផ្តោតសំខាន់ទៅលើប្រាក់បៀវត្ស ដើម្បីធ្វើឱ្យមន្ត្រីទាំងនោះបំពេញការងារ ប្រកបដោយការទទួលខុសត្រូវ និងមានមនសិការវិជ្ជាជីវៈខ្ពស់។

ជាចុងក្រោយយើងខ្ញុំសំណូមពរដល់ ចៅក្រម និងអ្នកអនុវត្តច្បាប់ អនុវត្តឲ្យត្រឹមត្រូវ មានតម្លាភាព មានយុត្តិធម៌ គោរពឱ្យបានហ្មត់ចត់នូវគោលការណ៍ទាំងឡាយដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ និងចៀសឱ្យផុតពីការប្រព្រឹត្តនូវអំពើពុករលួយ ដើម្បីកាត់បន្ថយភាពអយុត្តិធម៌ដល់ប្រជាពលរដ្ឋស្លូតត្រង់ ក៏ដូចជាកសាងនីតិរដ្ឋឱ្យមានប្រសិទ្ធភាព និងសន្តិភាព។ ក្នុងនោះដែរដើម្បីចូលរួមក្នុងការរីកចម្រើនទៅមុខលើវិស័យយុត្តិធម៌នេះ យើងទាំងអស់គ្នាដែលជាប្រជាពលរដ្ឋ គួរតប្បីត្រូវគោរពច្បាប់ទាំងអស់គ្នា ដែលជាមាគ៌ាមួយក្នុងការទទួលបាននូវ សុខសន្តិភាព មានសណ្តាប់ធ្នាប់របៀបរៀបរយនៅក្នុងសង្គមជាតិ និងនាំឱ្យសង្គមជាតិទាំងមូលមានការអភិវឌ្ឍន៍ផងដែរ។

# ឯកសារយោង

# ឯកសារយោង

## ក. លិខិតបទដ្ឋានគតិយុត្តិជាតិ

### ១.រដ្ឋធម្មនុញ្ញ

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឲ្យប្រើនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣។

### ២. ក្រម

- ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឲ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧
- ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឲ្យប្រើនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩

### ៣.ច្បាប់

- ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ប្រកាសឲ្យប្រើនៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤
- ក្រមសីលធម៌ចៅក្រម ប្រកាសឲ្យប្រើនៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៧
- ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ប្រកាសឲ្យប្រើនៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៦
- ច្បាប់ស្តីពីសិទ្ធិកុមារ ចូលជាធរមានថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៩០
- ច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៤៧ មាត្រា ៣៦៨ មាត្រា ៣៧២ និងមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៣។

## ខ. លិខិតបទដ្ឋានគតិអន្តរជាតិ

- សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស អនុម័ត និងប្រកាសនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨។

## គ. សៀវភៅ និងឯកសារជំនួយស្មារតី

- សេចក្តីពន្យល់ក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា (អ.វ.ត.ក )
- លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត សៀវភៅមេរៀន "នីតិព្រហ្មទណ្ឌទូទៅ" ឆ្នាំ២០១១
- លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត សៀវភៅមេរៀន "នីតិព្រហ្មទណ្ឌ និងនីតិគ្រួសារ" ឆ្នាំ២០១៧
- លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត សៀវភៅមេរៀន "នីតិវិធីព្រហ្មទណ្ឌ" ឆ្នាំ២០១៥
- លោកសាស្ត្រាចារ្យ អៀង សំណាង សៀវភៅមេរៀន "នីតិវិធីព្រហ្មទណ្ឌ " ឆ្នាំ២០១៥

- អង្គការសហប្រជាជាតិ "គោលការណ៍ជាមូលដ្ឋានស្តីពីឯករាជ្យភាពរបស់តុលាការ"
- "នីតិវិធីមុនការជំនុំជម្រះ និងការជំនុំជម្រះ" សៀវភៅមគ្គុទេសក៍ ស្តីពីនីតិវិធីព្រហ្មទណ្ឌនៅតុលាការកម្ពុជា ( ម.ស.ម.ក)

# ឧបសម្ព័ន្ធ

# តារាងឧបសម្ព័ន្ធ

១. ដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់

២. កំណត់ហេតុស្តីពីការបង្គាប់ឱ្យបង្ហាញខ្លួនភ្លាម

៣. ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ

៤. ដីកាកោះហៅជនជាប់ចោទឱ្យចូលរួមសវនាការ

៥. ដីកាកោះហៅជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណីឱ្យចូលរួមសវនាការ

៦. សាលក្រមព្រហ្មទណ្ឌមុនអង្គសេចក្តី (ស្តីពីសេរីភាពជនជាប់ចោទ)

៧. សាលក្រមព្រហ្មទណ្ឌមុនអង្គសេចក្តី (ស្តីពីការបញ្ចូលសំណុំរឿង)

៨. សាលក្រមរបៀប

៩. សាលក្រមអង្គសេចក្តី (សវនាការជាសាធារណៈ)

១០. សាលក្រមអង្គសេចក្តី (សវនាការជាអសាធារណៈ)

១១. លិខិតជូនដំណឹងអំពីសាលក្រមកំបាំងមុខ

ឧបសម្ព័ន្ធទី ១

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

អយ្យការអមសាលាដំបូង
រាជធានីភ្នំពេញ
លេខៈ ...១២០... អ.យ.ជ

# ដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់[1]

**យើង** **ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។**

- បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខៈ ៤៦០៦ ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០២០ របស់អយ្យការអមសាលាដំបូង រាជធានីភ្នំពេញ ។

-បានឃើញ របាយការណ៍លេខៈ ១១២ រ.ប.ក ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០២០ របស់ការិយាល័យព្រហ្មទណ្ឌកំរិតស្រាល នៃ ក្រសួងមហាផ្ទៃ ។

- បានឃើញ មាត្រា៤៦ មាត្រា៤៩ មាត្រា២៩១ មាត្រា២៩៥ និង មាត្រា៤៥៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រម នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ។

ក្រោយពីបានពិនិត្យសំណុំរឿងចប់សព្វគ្រប់ឃើញថា[2]: ឈ្មោះ និងឈ្មោះ ជាប្តីប្រពន្ធនឹងគ្នា បានស្នាក់នៅក្នុងផ្ទះរបស់ឈ្មោះ ភេទប្រុស អាយុ ៤៦ឆ្នាំ ស្ថិតនៅក្នុងភូមិអូរគោល ឃុំគោកដូង ស្រុកអង្គរជុំ ខេត្តសៀមរាប ហើយនៅថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៩ ឈ្មោះ និងឈ្មោះ បានឈ្លោះប្រកែកគ្នាតាមរយៈទូរស័ព្ទ ហើយស្រាប់តែនៅថ្ងៃ.ខែ.ឆ្នាំ ដដែលវេលាម៉ោងប្រហែល ០១ និង ១០ នាទី រំលងអាធ្រាត្រ ឈ្មោះ , និងឈ្មោះ , បានឈ្លោះគ្នាប្រតាយប្រតប់គ្នាទៅវិញទៅមកពិតមែន បណ្តាលឱ្យភាគីទាំងសងខាងរងរបួសស្រាលរៀងៗខ្លួន ។

**បានឃើញ[3]**

-បានឃើញរបាយការណ៍សំយោគលេខៈ ១១២ រ.ប.ក ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០២០ របស់ការិយាល័យព្រហ្មទណ្ឌកំរិតស្រាល នៃ ក្រសួងមហាផ្ទៃ ។

-ពាក្យបណ្តឹង ចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០២០ និងកំណត់ហេតុស្តាប់ចម្លើយរបស់ឈ្មោះ ភេទស្រី អាយុ៦៣ឆ្នាំ ថា៖ ខ្លួនសូមចូលឆ្លើយបំភ្លឺជូនលោកតំណាងអយ្យការនៅថ្ងៃនេះ ខ្លួនសូមរក្សាពាក្យបណ្តឹង ចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៩ និងកំណត់ហេតុបណ្តឹង ចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ២០១៩ ទុកនៅដដែលពុំកែប្រែទេ ប្តឹងពីឈ្មោះ ពីបទ៖ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស ។

ខ្លួនសូមបញ្ជាក់ថាខ្លួនបានរៀបការជាមួយនឹងឈ្មោះ តាំងពីឆ្នាំ ២០០២ មក ពុំមានកូនជាមួយគ្នាទេ ពុំមានបញ្ហាអ្វីធំដុំជាមួយគ្នាទេ មានតិចតួចៗ តែប៉ុណ្ណោះ រហូតមកដល់យប់ថ្ងៃទី២៦ ខែ មេសា ឆ្នាំ

---

[1] ដីកានេះ ប្រើសំរាប់ ព្រះរាជអាជ្ញា ធ្វើដីកាសន្និដ្ឋានចោទប្រកាន់ជូនរឿងទៅជំនុំជម្រះផ្ទាល់ ចំពោះបទល្មើសជាក់ស្តែង ឬមិនជាក់ស្តែង ដែលមានទណ្ឌកម្មកំណត់ ក្នុងច្បាប់មិនលើសពីមួយឆ្នាំ ហើយដែលមានភស្តុតាង និងធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់ ។
[2] សង្ខេបអំពីដំណើររឿង ឬអង្គហេតុសង្ខេបតាមសំណុំរឿង ក្រោយពីបញ្ចប់ការស៊ើបអង្កេត ។
ជនជាប់ ត្រូវធ្វើដីកាកោះហៅឱ្យ ចូល ទៅបង្ហាញខ្លួននៅមុខតុលាការ នាពេលសវនាការ (មាត្រា ៤៥៧)
[3] លើកយកវិធានការ និងភស្តុតាងសំខាន់ៗ សំរាប់ធ្វើជាមូលដ្ឋាន ក្នុងការយល់ឃើញរបស់ខ្លួន ដើម្បីសម្រេចឱ្យបានត្រឹមត្រូវតាមច្បាប់ ។

២០១៩ វេលាម៉ោងប្រហែល ១១ យប់ នៅផ្ទះសុំគេស្នាក់នៅ២ ទៅ ៣ យប់ ភូមិ.ឃុំ.ស្រុក មិនចាំ ខេត្តសៀមរាប ពុំស្គាល់ម្ចាស់ផ្ទះទេ ខ្លួនបានកាន់កន្ត្រៃហើយក៏បានដួលប៉ះជើងបណ្តាលឱ្យកន្ត្រៃខ្ទាតទៅបាត់ ស្រាប់តែឈ្មោះ ងើបឡើងស្ទុះមកវាយខ្លួនពីរដៃចំក្បាល និងធាក់ទ្រូងខ្លួនសាប់យកៗតែម្តង ហើយបណ្តាលឱ្យខ្លួនដួលទៅនឹងគំនរអុសបណ្តាលឱ្យខ្លួនសន្លប់បាត់ស្មារតី ហើយពេលខ្លួនដឹងខ្លួនឡើងក៏វាឡើងទៅលើផ្ទះ ហើយខ្លួនឱ្យឈ្មោះ ដឹកខ្លួនមកពេទ្យ តែគាត់ពុំព្រមដឹកខ្លួនទៅពេទ្យទេ ពីព្រោះខ្លួនចុកដើមទ្រូងខ្លាំង បែរជាឈ្មោះ ជេរខ្លួនយកៗ ហើយខ្លួនបានពុំតបតអ្វីទេ ហើយឈ្មោះ ថែមទាំងរកវាយខ្លួនថែមទៀត បន្ទាប់មកឈ្មោះ ក៏បានរត់គេចខ្លួនបាត់តែម្តង ។

បន្ទាប់មកកូនប្រុសរបស់ខ្លួនបានមកយកខ្លួននៅទីរួមខេត្តសៀមរាបទៅព្យាបាលមន្ទីរខេត្តសៀមរាប ដេកសំរាកព្យាបាលប្រហែល ១ ម៉ោង ទើបដឹកតាមរថយន្តមកព្យាបាលនៅមន្ទីរពេទ្យ ១៧៩ ដេកសំរាក ប្រហែល ១០ ថ្ងៃ សំរាប់ឯកសារពេទ្យ និងការព្យាបាលចំណាយអស់ប៉ុន្មានខ្លួនចាំទេ ភ្លេចហើយ ។

ចាប់តាំងពីពេលមានរឿងកើតហេតុនៅថ្ងៃនោះ ខ្លួន និងឈ្មោះ ពុំដែលមានបញ្ហាអ្វីជាមួយគ្នាទៀតទេ ហើយក៏បែកលំនៅសង្វាស់គ្នាចាប់តាំងពីពេលនោះមករហូតដល់សព្វថ្ងៃនេះ ។

ខ្លួនសូមសំណូមពរ លោកតំណាងអយ្យការ មេត្តាជួយផ្តន្ទាទោសជនល្មើសតាមច្បាប់ និងទាមទារសំណងជំងឺចិត្តចំនួន ១០០,០០០ (ដប់ម៉ឺន) ដុល្លារអាមេរិក និងថ្លៃព្យាបាលជំងឺចំនួន ១៥,០០០ (មួយម៉ឺនប្រាំពាន់) ដុល្លារអាមេរិក ។

- កំណត់ហេតុស្តាប់ចម្លើយរបស់ឈ្មោះ ភេទប្រុស អាយុ៤៧ឆ្នាំ ថា៖ ខ្លួនអាចឆ្លើយបំភ្លឺចំពោះមុខលោកតំណាងអយ្យការបាន ដោយមានកញ្ញា ជាមេធាវីការពារក្តីខ្លួន ចូលរួមស្តាប់ចម្លើយជាមួយខ្លួន ។

ខ្លួនសូមចូលឆ្លើយបំភ្លឺជូនតំណាងអយ្យការនៅថ្ងៃនេះ ពីព្រោះនៅថ្ងៃដែលតុលាការកោះហៅខ្លួន ខ្លួនមានជាប់ធុរៈពុំអាចចូលមកឆ្លើយបំភ្លឺទើបខ្លួន សូមចូលឆ្លើយបំភ្លឺជូនលោកតំណាងអយ្យការនៅថ្ងៃនេះ ។

ខ្លួនសូមបដិសេធចំពោះពាក្យបណ្តឹងចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៩ របស់ឈ្មោះ ដែលប្តឹងចោទប្រកាន់ខ្លួនថា បានប្រព្រឹត្តអំពើហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស កាលពីថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៩ វេលាម៉ោងប្រហែល ០១ និង ១០ នាទី រំលងអាធ្រាត្រ នោះខ្លួនសូមបដិសេធចោទទាំងស្រុង ពីព្រោះខ្លួនពុំបានប្រព្រឹត្តអំពើហិង្សាទៅលើគាត់ឡើយ ។

ខ្លួនសូមបញ្ជាក់ថា ខ្លួនសូមរៀបការជាមួយឈ្មោះ តែពុំបានចុះសំបុត្រអាពាហ៍ពិពាហ៍ទេ ក្នុងការរស់រួមជាប្តីប្រពន្ធពុំមានកូនទេ ហើយពួកខ្លួនទាំងពីរនាក់ បានរស់នៅបែកលំនៅសង្វាសគ្នាចាប់តាំងពីថ្ងៃដែលមានរឿងនៅថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៩ ដែលគាត់ប្តឹងចោទប្រកាន់ខ្លួនថាបានវាយទៅលើគាត់ នោះពុំពិតទេ គឺរឿងហេតុប្រពន្ធរបស់ខ្លួនឈ្មោះ គាត់រករឿងឈ្លោះជាមួយខ្លួនរហូតមក តែនៅថ្ងៃកើតនោះ គាត់មករករឿងឈ្លោះជាមួយនឹងខ្លួនខ្លាំងតែម្តង ហើយពេលនោះខ្លួនកំពុងតែដេកលើអង្រឹងវេលាម៉ោង ៩ ទៅ ១០ យប់ នៅផ្ទះជួល ភូមិគោកជូង ស្រុកអង្គរជុំ ខេត្តសៀមរាប ស្រាប់តែឈ្មោះ គាត់យកកន្ត្រៃទឹកនោម មកវាយក្បាលខ្លួន ហើយគាត់បានមកស្ទុះច្របាច់ករខ្លួន ហើយខ្លួនក៏បានរើសបំរាស់ចេញពីគាត់ គាត់ក៏បានមកប្រតាយប្រតាប់ជាមួយនឹងខ្លួន ហើយខ្លួនក៏ចាប់ដៃគាត់កុំឱ្យគាត់វាយខ្លួនតទៀត ហើយក៏ប្រតាយប្រតប់គ្នាទៅវិញទៅមកទើបបណ្តាលឱ្យគាត់ដួលទៅលើអុស ស្រាប់ពេលនោះម្ចាស់ផ្ទះមកទាន់ក៏ចាប់បំបែកគ្នា ហើយក៏ឈ្លោះជជែកគ្នាប្រហែលជិត ១ ម៉ោងទៀត ហើយក៏បែកឈប់ឈ្លោះគ្នា ពេលនោះខ្លួនពុំបានគេចទៅណាទេ ។ លុះព្រឹកឡើងទើបប្រពន្ធរបស់ខ្លួនទៅក្រុងសៀមរាប ពេលនោះខ្លួនបានឱ្យប្រាក់គាត់ចំនួន ៥ ម៉ឺនរៀល ដើម្បីធ្វើដំណើរ ។

ចាប់តាំងពីពេលនោះមក ខ្លួន និងឈ្មោះ ពុំដែលបានរួមរស់នៅជាមួយគ្នាទៀតទេ ធ្លាប់ជួបមុខគ្នាពេលមកតុលាការ និងតាមរយៈទូរស័ព្ទតែប៉ុណ្ណោះ ហើយគាត់ និងកូនដើមគាត់ នៅតែជេរប្រមាថខ្លួន តាម រយៈទូរស័ព្ទ និងតាមបណ្តាញទំនាក់ទំនងសង្គម Facebook រហូតមក ។

រហូតមកដល់អំឡុងថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១៩ ទើបខ្លួនសម្រេចចិត្តដាក់ពាក្យបណ្តឹងសុំផ្តាច់អនីតិសង្វាសពីឈ្មោះ សុំបែងចែកទ្រព្យរួម និង បំណុលរួម ជាពីរស្មើគ្នា ឥឡូវសំណុំរឿងនេះ សាលាដំបូងរាជធានីភ្នំពេញកំពុងតែចាត់ការនៅឡើយ ។

ខ្លួនសូមបញ្ជាក់បន្ថែមទៀតថា ខ្លួនធ្លាប់ដាក់ពាក្យបណ្តឹងពីឈ្មោះ មកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ពីបទ៖ ប៉ុនប៉ងមនុស្សឃាត ពាក្យបណ្តឹងចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០២០ តែតំណាងអយ្យការបានតម្កល់រឿងទុកឥតចាត់ការរួចហើយ តាមរយៈដីកាតម្កល់លេខ៖ ៩១៧ អ.យ.ជ ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០២០ ហើយខ្លួនបានប្តឹងឧទ្ធរណ៍នឹងដីកាសម្រេចនេះហើយសាលាឧទ្ធរណ៍កំពុងតែចាត់ការ ។

ខ្លួននឹងដាក់ភស្តុតាងបន្ថែមទៀត ព្រមទាំងសាក្សី ក្នុងរឿងនេះ មកតំណាងអយ្យការពិនិត្យនៅពេលក្រោយទៀត ហើយខ្លួនបានដាក់សេចក្តីឆ្លើយបំភ្លឺ ចុះថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០២០ ជូនតំណាងអយ្យការពិនិត្យរួចហើយពីរឿងហេតុទាំងមូល ។

ខ្លួនសូមសំណូមពរលោកតំណាងអយ្យការមេត្តាជួយយុត្តិធម៌ឱ្យខ្លួនផង ពីព្រោះខ្លួនពុំបានប្រព្រឹត្តអំពើដូចឈ្មោះ ចោទប្រកាន់ឡើយ សូមលោកតំណាងអយ្យការមេត្តាតម្កល់រឿងទុកឥតចាត់ ។

-កំណត់ហេតុស្តាប់ចម្លើយរបស់ឈ្មោះ ភេទប្រុស អាយុ ៤៦ឆ្នាំ ថា៖ កាលពីថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៩ ឈ្មោះ ភេទស្រី អាយុ ៦៤ឆ្នាំ ប្តីគាត់ឈ្មោះ (ត្រូវជាម្តាយឪពុកធម៌របស់ខ្លួន) បានទៅលេងខេត្តសៀមរាបហើយស្នាក់នៅផ្ទះរបស់ខ្លួននៅភូមិអូរគោល ឃុំគោកដូង ស្រុកអង្គរជុំ ខេត្តសៀមរាប បានពិភាក្សាគ្នាជួលផ្ទះខ្លួនដើម្បីបើកគ្លីនិក និងបានធ្វើកិច្ចព្រមព្រៀងផងដែរ ។ នៅវេលាម៉ោង ១២ ថ្ងៃត្រង់ ខ្លួនបានឃើញឈ្មោះ ឈ្លោះគ្នាជាមួយនឹងឈ្មោះ តាមទូរស័ព្ទ ។ លុះដល់ម៉ោងប្រហែល ៩ ជាង ពេលយប់ខ្លួនបានឃើញឈ្មោះ កាន់កន្ត្រៃទឹកនោម ដើរចេញពីក្នុងផ្ទះដើរសំដៅទៅរកប្តីគាត់ដែលកំពុងដេកលើអង្រឹងនៅក្នុងរោងមុខផ្ទះ បន្ទាប់មកខ្លួនក៏ឃើញឈ្មោះ យកកន្ត្រៃវាយក្បាលរបស់ឈ្មោះ ដោយវាយយកៗ ពេលនោះខ្លួនក៏ចូលទៅឃាត់ តែឈ្មោះ មិនព្រមស្តាប់ នៅតែវាយក្បាលប្តីគាត់បន្ត ហើយឈ្មោះ បានចាប់កដៃឈ្មោះ ជាប់ ហើយឈ្មោះ បានច្រានប្តីគាត់បណ្តាលឱ្យគាត់ដួលលើគំនរអុសខ្លួនឯង ខ្លួនក៏បានពឹកដៃគាត់ចូលផ្ទះកុំឱ្យឈ្លោះគ្នាទៀត ។ ពេលចូលក្នុងផ្ទះហើយឈ្មោះ បានចេញមកក្រៅម្តងទៀត និងបានស្រែកជេរបញ្ចោរឈ្មោះ ថែមទៀត ខ្លួនឃើញបែបនោះក៏បានទៅលួងគាត់ឱ្យឈប់ឈ្លោះគ្នាហើយចូលទៅសម្រាកក្នុងផ្ទះវិញ ចំណែកប្តីគាត់ឈ្មោះ បានទៅសម្រាកនៅបន្ទប់ផ្សេង ។ លុះព្រឹកឡើងគាត់បានជេរប្តីគាត់ទៀត ខ្លួនឃើញដូច្នេះ ក៏បានឱ្យឪពុកម្តាយខ្លួនជូនឈ្មោះ ទៅផ្ទះបងបង្កើតរបស់ខ្លួននៅ ខេត្ត ដើម្បីចាំកូនប្រុសរបស់គាត់មកយកគាត់ទៅភ្នំពេញវិញ ។

-ពិនិត្យភស្តុតាង និង ឯកសារផ្សេង ... ។

## យល់ឃើញថា[4]:

-តាមពាក្យបណ្តឹងចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០២០ និងកំណត់ហេតុស្តាប់ចម្លើយរបស់ឈ្មោះ          ភេទស្រី អាយុ ៦៣ឆ្នាំ ,របាយការណ៍សំយោគលេខ៖ ១១២ រ.ប.ក ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០២០ របស់ការិយាល័យព្រហ្មទណ្ឌកំរិតស្រាល នៃក្រសួងមហាផ្ទៃ , កំណត់ហេតុចម្លើយរបស់ឈ្មោះ          ភេទប្រុស អាយុ ៨៧ឆ្នាំ និងកំណត់ហេតុស្តាប់ចម្លើយសាក្សីឈ្មោះ          ភេទប្រុស អាយុ៨៦ឆ្នាំ ខាងលើ និងពិនិត្យភស្តុតាងមានភាពសង្វាក់គ្នាថាឈ្មោះ ।          ភេទស្រី អាយុ ៦៣ឆ្នាំ និងឈ្មោះ ।          ភេទប្រុស អាយុ៨៧ឆ្នាំ ពិតជាបានប្រព្រឹត្តអំពើ ហិង្សាដោយចេតនាទៅវិញទៅមក ពិតមែន កាលពីថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០២០នៅ ខេត្តសៀមរាប ។

-មានភស្តុតាងគ្រប់គ្រាន់ ដើម្បីដាក់បន្ទុកលើជនជាប់ចោទ ឈ្មោះ          ភេទស្រី អាយុ៦៣ឆ្នាំ និងឈ្មោះ          ភេទប្រុស អាយុ៨៧ឆ្នាំ ពីបទ:ហិង្សាស្រាលទៅវិញទៅមក កាលពីថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២០នៅ ខេត្តសៀមរាប បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២២៨ នៃ ក្រមព្រហ្មទណ្ឌ ។

## ហេតុដូច្នេះសម្រេច[5]

១-ចោទប្រកាន់ ៖

ក.ឈ្មោះ          ភេទស្រី អាយុ ៦៨ឆ្នាំ (ក្រៅឃុំ) ទីលំនៅបច្ចុប្បន្នផ្ទះលេខ២៦ ផ្លូវលេខ៤៧៨ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ។

ខ.ឈ្មោះ          ភេទប្រុស អាយុ៨៧ឆ្នាំ (ក្រៅឃុំ) ទីលំនៅបច្ចុប្បន្នលេខ២៦ ផ្លូវលេខ៤៧៨ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ។

ពីបទ: ហិង្សាស្រាលទៅវិញទៅមក ប្រព្រឹត្តនៅកាលពីថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០២០នៅ ខេត្តសៀមរាប បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២២៨ នៃ ក្រមព្រហ្មទណ្ឌ ព្រះរាជាណាចក្រកម្ពុជា ។

ខ-បញ្ជូនជនជាប់ចោទ ដូចមានឈ្មោះខាងលើនិងសំណុំរឿងព្រហ្មទណ្ឌលេខ: ៨៦០៦ ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០២០ និងវត្ថុតាង ដែលទាក់ទិនក្នុងសំណុំរឿង នេះទៅសាលាដំបូងរាជធានីភ្នំពេញ ដើម្បីជំនុំជម្រះតាមច្បាប់ ។

ថ្ងៃ..................ខែ..........ឆ្នាំ.....ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី ......... ខែ តុលា ឆ្នាំ ២០២០

**តំណាងអយ្យការ**

---

[4] សន្និដ្ឋានវាយតម្លៃ ពីអំពើរបស់ជនត្រូវចោទ ទៅលើធាតុផ្សំនៃបទល្មើស សំរាប់បញ្ជាក់ថា មានឬគ្មានពិរុទ្ធភាពគ្រប់គ្រាន់ ឬស្តាប់ ឬភេចខ្លួនបាត់ មានឬគ្មានអត្តសញ្ញាណគ្រប់គ្រាន់ ។

[5] ផ្អែកតាមសំអាងហេតុ និងការយល់ឃើញរបស់ខ្លួន តំណាងអយ្យការត្រូវសំរេចឱ្យបានច្បាស់លាស់ អំពីការចោទប្រកាន់ ការបង្អង់បណ្តឹងអាជ្ញា និងការលើកលែងបណ្តឹងអាជ្ញា ដោយលើក យកមាត្រាច្បាប់មកសំអាងឱ្យបានត្រឹមត្រូវ ។

ឧបសម្ព័ន្ធទី ២

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌលេខ ៤២០៦
ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០

## កំណត់ហេតុស្តីពីការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម

លេខៈ 0C3 អ.យ.ច

ឆ្នាំពីរពាន់ម្ភៃ ខែមិថុនា ថ្ងៃទីដប់មួយ វេលាម៉ោងដប់ប្រាំ និងសាមសិបនាទីរសៀល

**យើង ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ**

-របាយការណ៍លេខ ២០៤/២០ ព្រ.ទ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០ របស់ការិយាល័យប្រឆាំងគ្រឿងញៀន នៃកងរាជអាវុធហត្ថរាជធានីភ្នំពេញ ។

បុគ្គលដែលនៅចំពោះមុខយើង បានផ្តល់ព័ត៌មានអំពីអត្តសញ្ញាណដូចខាងក្រោមៈ

១. នាមត្រកូល-នាមខ្លួន ហៅម៉ាប់ ភេទប្រុស អាយុ ៣១ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ ទីកន្លែងកំណើត និងទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅផ្ទះលេខ៣៤៣E₄ ភូមិ០៩ សង្កាត់ផ្សារដេប៉ូ៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ មុខរបរកម្មករសំណង់ នៅលីវ ឪពុកឈ្មោះ "រស់" ម្តាយឈ្មោះ "រស់" ជាទីតិជន ទោសពីមុនគ្មាន ។ (ឃាត់ខ្លួននៅថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២០)

២. នាមត្រកូល-នាមខ្លួន ហៅ ភេទប្រុស អាយុ ៣៤ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ ទីកន្លែងកំណើតសង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ សាសនាព្រះពុទ្ធ ទីលំនៅមុនពេលឃាត់ខ្លួនផ្ទះលេខ៤២០E₂ ផ្លូវលេខ២១៧ សង្កាត់អូរឬស្សី២ ខណ្ឌ៧មករា រាជធានីភ្នំពេញ មុខរបរសន្តិសុខ នៅលីវ ឪពុកឈ្មោះ "ស្លាប់" ម្តាយឈ្មោះ "រស់" កម្រិតវប្បធម៌ថ្នាក់ទី០៨ ជាទីតិជន ទោសពីមុនគ្មាន ។ (ឃាត់ខ្លួននៅថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២០)

យើងប្រាប់ដល់បុគ្គលនេះនូវអង្គហេតុដែលខ្លួនត្រូវបានចោទប្រកាន់មានដូចតទៅ: កាលពីថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង១២ និង១០នាទី កម្លាំងរបស់ការិយាល័យប្រឆាំងគ្រឿងញៀន បានចុះល្បាតក្នុងមូលដ្ឋាន ដើម្បីការពារ ទប់ស្កាត់ករណីពាក់ព័ន្ធគ្រឿងញៀនផ្សេងៗ លុះល្បាតដល់ចំណុចលើផ្លូវលេខ១៣២ សង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ក៏ប្រទះឃើញជនសង្ស័យឈ្មោះ ហៅ ភេទប្រុស និងឈ្មោះ ហៅ ភេទប្រុស កំពុងដើរនៅតាមផ្លូវ សមត្ថកិច្ចមានការសង្ស័យ ក៏ហៅឱ្យឈប់ធ្វើការត្រួតពិនិត្យ រកឃើញមានថ្នាំញៀនចំនួនមួយកញ្ចប់តូចទម្ងន់ ០.២៥ក្រាម ដែលជនសង្ស័យឈ្មោះ ហៅ លាក់ទុកក្នុងហោប៉ៅខោមុខខាងស្តាំ រួចសមត្ថកិច្ចដកហូតថ្នាំញៀនទាំងនោះ និងបញ្ជូនជនសង្ស័យមកកាន់ការិយាល័យប្រឆាំងគ្រឿងញៀន ។ បន្ទាប់ពីសមត្ថកិច្ច បានធ្វើតេស្តជំហានដំបូងលើវត្ថុតាងខាងលើ ចំពោះមុខជនសង្ស័យជាមួយតេស្តប្រភេទ ជាលទ្ធផលបង្ហាញថាក្រាមពណ៌សថ្លាចេញពណ៌លឿងទុំសង្ស័យមានតម្រុយជាគ្រឿងញៀនប្រភេទមេតំហ្វេតាមីន ហើយជនសង្ស័យទាំងពីរនាក់បានឆ្លើយសារភាពថា "នៅថ្ងៃកើតហេតុពួកខ្លួនបានចូលលុយគ្នាម្នាក់ ១០,០០០៛ ទិញថ្នាំញៀនចំនួន ០១កញ្ចប់ជង់តូចនៅម្តុំផ្លូវរថភ្លើង ហើយប៉ុងយកមកប្រើប្រាស់នៅម្តុំជីឡូតិ៍វត្តនាគវ័ន្ត ស្រាប់តែជួបសមត្ថកិច្ចចុះមកបង្ក្រាបឃាត់ពួកខ្លួនតែម្តង ។

អង្គហេតុនេះជាបទល្មើសៈ រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចផ្ទះលេខ១៣២ សង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២០ តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

យើងបានទទួលចម្លើយពីជននេះដូចតទៅ:

១ ឈ្មោះ ហៅ ភេទប្រុស អាយុ ៣១ឆ្នាំ បានឆ្លើយនៅជំណាក់កាលសមត្ថកិច្ចនិងតំណាងអយ្យការដូចតទៅៈ កាលពីថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង១២ និង១០នាទី ខ្ញុំបានចូលលុយគ្នាជាមួយឈ្មោះ ហៅ ម្នាក់ ១០,០០០៛ រួចនាំគ្នាដើរទៅទិញថ្នាំញៀននៅមុំផ្ទះថេក្លើងបានចំនួន ០១កញ្ចប់ថង់តូច តម្លៃ ២០,០០០៛ ហើយបំរុងយកថ្នាំញៀនដែលទិញបានទៅប្រើប្រាស់នៅមុំដីឡូតិ៍វត្តនាគវន្ត ក៏ជួបកម្លាំងសមត្ថកិច្ចហៅខ្ញុំឆែកឆេរកឃើញថ្នាំញៀននៅក្នុងហោប៉ៅមុខខោខាងស្ដាំរបស់ខ្ញុំ រួចសមត្ថកិច្ចឃាត់ខ្លួនខ្ញុំទាំងពីរនាក់តែម្ដង ។

២ ឈ្មោះ ហៅ ភេទប្រុស អាយុ ៣៤ឆ្នាំ បានឆ្លើយនៅជំណាក់កាលសមត្ថកិច្ចនិងតំណាងអយ្យការដូចតទៅៈ កាលពីថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២០ វេលាម៉ោង១២ និង១០នាទី ខ្ញុំបានចូលលុយគ្នាជាមួយឈ្មោះ ហៅ ម្នាក់ ១០,០០០៛ រួចនាំគ្នាដើរទៅទិញថ្នាំញៀននៅមុំផ្ទះថេក្លើង បានចំនួន ០១កញ្ចប់ថង់តូច តម្លៃ ២០,០០០៛ ហើយបំរុងយកថ្នាំញៀនដែលទិញបានទៅប្រើប្រាស់នៅមុំដីឡូតិ៍វត្តនាគវន្ត ក៏ជួបកម្លាំងសមត្ថកិច្ចហៅខ្ញុំឆែកឆេរកឃើញថ្នាំញៀននៅក្នុងហោប៉ៅមុខខោខាងស្ដាំរបស់ឈ្មោះ ហៅ រួចសមត្ថកិច្ចឃាត់ខ្លួនខ្ញុំទាំងពីរនាក់តែម្ដង ។

យើងបានប្រាប់ដល់ជននេះថាៈ ខ្លួនមានសិទ្ធិសុំពីងមេធាវី តាមការជ្រើសរើសរបស់ខ្លួន ឬ ស្នើសុំឱ្យមានការចាត់តាំងមេធាវីដោយអនុលោមតាមបញ្ញត្តិច្បាប់ ។

ជនទាំងពីរនេះបានឆ្លើយថា: ពួកខ្ញុំមិនត្រូវការមេធាវីទេក្នុងពេលនេះ ពួកខ្ញុំអាចការពារដោយខ្លួនឯងបាន ។

បានឃើញមាត្រា ៤៧ មាត្រា ៤៨ និងមាត្រា ៣០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

**<u>ហេតុដូច្នេះសម្រេច:</u>**

បញ្ជូនជនជាប់ចោទៈ

ក ឈ្មោះ ឈ្មោះ ហៅ ភេទប្រុស អាយុ ៣១ឆ្នាំ (ឃាត់ខ្លួន)

ខ. ឈ្មោះ ហៅ ភេទប្រុស អាយុ ៣៤ឆ្នាំ (ឃាត់ខ្លួន)

ទៅតុលាការដំបូងរាជធានីភ្នំពេញ ដើម្បីធ្វើការជំនុំជម្រះ តាមនីតិវិធីនៃការបង្ហាញខ្លួនភ្លាមចំពោះ អង្គហេតុ និងបទល្មើស ដូចខាងលើ។

ក្រោយពីបានអានឱ្យ ជនជាប់ចោទស្ដាប់ ជននេះយល់ព្រមផ្ដិតមេដៃជាមួយយើង។

ជនជាប់ចោទ

**ជ.ព្រះរាជអាជ្ញា**

ព្រះរាជអាជ្ញា

ឧបសម្ព័ន្ធទី ៣

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំ...
ចូល ថ្ងៃទី.. ខែ..08..ឆ្នាំ..21..

សាលាដំបូងរាជធានីភ្នំពេញ

បន្ទប់ស៊ើបសួរ "១"

លេខ: ..៣៦៤៣.."១" ដ.ង

# ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ

យើង ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

អមដោយលោក ជាក្រឡាបញ្ជី ។

-បានឃើញ មាត្រា ២៤៧ មាត្រា២៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌ លេខ: ៧២៤២ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៩ ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ លេខ: ២៥៦៩ អ.យ.ណ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៩ របស់តំណាងអយ្យការ អមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ សំណុំរឿងស៊ើបសួរ លេខ: ២៦០០ ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២១។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរ លេខ: ២៨៣១ អ.យ.ណ ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

ក្រោយពីបានពិនិត្យលើសំណុំរឿងស៊ើបសួរ ចប់សព្វគ្រប់ហើយ យល់ឃើញថា មានពិរុទ្ធភាពគ្រប់គ្រាន់លើ:

១-ឈ្មោះ ភេទប្រុស អាយុ៤០ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតនៅភូមិក្រាំងតាវត្ត ឃុំព្រាយ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ទីលំនៅមុនពេលឃាត់ខ្លួននៅបុរីពិភពថ្មីកំបូល ផ្ទះលេខ:៨២ ផ្លូវជាតិលេខ៤ ភូមិត្រពាំងគល់ សង្កាត់កន្ទោក ខណ្ឌកំបូល រាជធានីភ្នំពេញ ឪពុកឈ្មោះ (ស) ម្តាយឈ្មោះ (រ) ប្រពន្ធឈ្មោះ មានកូន០៣នាក់ ជានីតិជន ទោសពីមុន គ្មាន។ (ឃាត់ខ្លួន)

-ឃុំខ្លួននៅមណ្ឌលអប់រំកែប្រែទី១ (ម₁) តាមដីកាបង្គាប់ឱ្យឃុំខ្លួន លេខ: ២១២១ "ឃ" ដ.ឃ.ស ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១។

២-ឈ្មោះ ភេទប្រុស អាយុ៣៨ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតនៅភូមិទួលខ្ពស់ ឃុំឈើកាច់ ស្រុកបាភ្នំ ខេត្តព្រៃវែង ទីលំនៅមុនពេលឃាត់ខ្លួននៅបុរីពិភពថ្មីកំបូល ផ្ទះលេខ:៨២ ផ្លូវជាតិលេខ៤ ភូមិត្រពាំងគល់ សង្កាត់កន្ទោក ខណ្ឌកំបូល រាជធានីភ្នំពេញ ឪពុកឈ្មោះ (ស) ម្តាយឈ្មោះ (ស) នៅលីវ ជានីតិជន ទោសពីមុន គ្មាន។ (ឃាត់ខ្លួន)

-ឃុំខ្លួននៅមណ្ឌលអប់រំកែប្រែទី១ (ម₁) តាមដីកាបង្គាប់ឱ្យឃុំខ្លួន លេខ: ២១២២ "ឃ" ដ.ឃ.ស ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១។

ដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ: ក្លែងបន្លំ និង ប្រើប្រាស់លិខិតក្លែង ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៨ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៦២៦, ៦២៧ និងមាត្រា ៦២៨ នៃក្រមព្រហ្មទណ្ឌ ។

## យល់ឃើញថា៖

១-តាមពាក្យបណ្តឹង ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៩ របស់ឈ្មោះ បានបញ្ជាក់ថា៖ កាលពីថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៨ ឈ្មោះ និងឈ្មោះ បានយកប្លង់ដីមានវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុ ដែលមានក្បាលដីលេខ ៦៤១ ទំហំ ៨១៩១ ម៉ែត្រការ៉េ មកដាក់ធានាយកប្រាក់ចំនួន ១៧០០០ (មួយម៉ឺនប្រាំពីរពាន់) ដុល្លារអាមេរិក បូកបន្ថែម ២៥០០ (ពីរពាន់ប្រាំរយ) ដុល្លារអាមេរិក ស្មើនិងចំនួនទឹកប្រាក់ ១៩៥០០ (មួយម៉ឺនប្រាំបួនពាន់ប្រាំរយ) ដុល្លារអាមេរិក ។ ពេលនោះឈ្មោះ និងឈ្មោះ បានធ្វើកិច្ចសន្យាយកប្រាក់មួយសន្លឹក ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៨ ដែលមានឈ្មោះ តែឈ្មោះ ជាអ្នកក្លែងមេដៃជំនួសឈ្មោះ ចាប់ពីពេលទទួលប្រាក់នោះមកឈ្មោះ និងឈ្មោះ ពុំដែលបានសងប្រាក់ដែលយកនោះត្រឡប់មកវិញទេ ព្រមទាំងគេចវេសទៀតផង ។

២-តាមចម្លើយរបស់ជនត្រូវចោទឈ្មោះ បានឆ្លើយនៅតំណាក់កាលអយ្យការ និងចៅក្រមស៊ើបសួរប្រហាក់ប្រហែលគ្នាថា៖ ខ្ញុំបាទត្រូវបានសមត្ថកិច្ចឃាត់ខ្លួននៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១ វេលាម៉ោង ១១ និង ៣០នាទី និងសូមរក្សាខ្លឹមសារដូចមានក្នុងកំណត់ហេតុស្តាប់ចម្លើយ នៅអយ្យការ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ដែលមានខ្លឹមសារ៖

ខ្ញុំបាទសូមទទួលស្គាល់ពាក្យបណ្តឹងរបស់ឈ្មោះ ខ្លះ និងសូមបដិសេធខ្លះដោយហេតុថាខ្ញុំបាទខ្ចីប្រាក់លើកទី១ សរុបចំនួន ២៥០០០ (ពីរម៉ឺនប្រាំពាន់) ដុល្លារអាមេរិក ពិតមែនខ្ញុំបាទព្រមទាំងបានដាក់ប្លង់ដីបញ្ចាំចំនួន ០៣ កន្លែង (កម្មសិទ្ធិរបស់ម្តាយខ្ញុំឈ្មោះ និងរបស់ប្អូនឈ្មោះ និងឈ្មោះ ដោយសងប្រាក់ខ្លះទៅប្រពន្ធរបស់ឈ្មោះ (ឈ្មោះ ) លើកទី១ចំនួន ៨០០០(ប្រាំបីពាន់) ដុល្លារអាមេរិក នៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៨ និងលើកទី២ ចំនួណ ៥០០០(ប្រាំពាន់) ដុល្លារអាមេរិក នៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៨ ។ នៅថ្ងៃទីមិនចាំ ខែវិច្ឆិកា ឆ្នាំ២០១៨ ដោយខ្ញុំបាទលំបាកពេកក៏បានទៅខ្ចីប្រាក់ពីឈ្មោះ បន្ថែមចំនួន ២០០០(ពីរពាន់) ដុល្លារអាមេរិក ។ ចំពោះប្រាក់ដែលខ្ញុំបានខ្ចីពីឈ្មោះ ភេទប្រុស អាយុ៦២ឆ្នាំ គឺគាត់បានបូកបញ្ចូលនូវការប្រាក់នោះជាមួយនិងប្រាក់ដែលខ្ញុំបាទបានខ្ចីរួចជាស្រាច់ចំនួន ១៧០០០ (មួយម៉ឺនប្រាំពីរពាន់) ដុល្លារអាមេរិក បូកបន្ថែម ២៥០០(ពីរពាន់ប្រាំរយ) ដុល្លារអាមេរិក សរុបទាំងអស់១៩៥០០(មួយម៉ឺនប្រាំបួនពាន់ប្រាំរយ) ដុល្លារអាមេរិក។ ចំពោះប្រាក់ដែលខ្ញុំបាទបានខ្ចីនោះគឺខ្ញុំធ្លាប់បាននិយាយជាមួយនឹងឈ្មោះ ដែរដោយខ្ញុំបាទសូមឱ្យគាត់កាត់នូវប្លង់ផ្ទះមួយកន្លែងរបស់ខ្ញុំ តែគាត់មិនព្រមនោះទេខ្ញុំបាទថែមទាំងសុំប្លង់ដីពីឈ្មោះ យកទៅថតចម្លង ដើម្បីទៅដាក់បញ្ចាំធនាគារចំនួន ២០.០០០ (ពីរម៉ឺន) ដុល្លារអាមេរិក តែខាងធនាគារឱ្យបានត្រឹមចំនួន ១០.០០០(មួយម៉ឺន) ដុល្លារអាមេរិក ហើយខ្ញុំបាទបានយកទៅសងគាត់វិញតែគាត់ពុំយក គាត់ថាប្រាក់តិចពេកគាត់ពុំចង់បាននោះទេ។ នៅពេលធ្វើកិច្ចសន្យាលុយចុះថ្ងៃទី ០១ ខែឧសភា ឆ្នាំ២០១៨ ដោយខ្ញុំបាទដាក់ឈ្មោះ ត្រូវជាប្អូនបង្កើតព្រោះប្លង់នោះជារបស់ឈ្មោះ តែខ្ញុំជាអ្នកប្តិតមេដៃជាអ្នកខ្ចី និងជាសាក្សីផង ដោយនៅពេលនោះប្អូនឈ្មោះ , ទៅធ្វើការនៅប្រទេសថៃ។ កន្លងមកខ្ញុំបាទមានបំណងសងប្រាក់ទៅឈ្មោះ ដែរតែខ្ញុំបាទពុំមានលទ្ធភាព ហើយនៅពេលនេះខ្ញុំបាទស្នើសុំតម្កល់ប្រាក់ដើម្បីធានាខ្លួនទៅផ្ទះវិញចំនួន ៥០០០ (ប្រាំពាន់) ដុល្លារអាមេរិក និងស្នើសុំប្លង់ដីដែលខ្ញុំបាទដាក់បញ្ចាំពីឈ្មោះ មក ដើម្បីខ្ចីលុយធនាគារសងគាត់។ សូមណ្ឌូមពរ សុំឱ្យតុលាការមេត្តាអនុញ្ញាតឱ្យខ្ញុំបាទបានទៅផ្ទះវិញ។

៣-តាមចម្លើយរបស់ជនត្រូវចោទឈ្មោះ បានឆ្លើយនៅតំណាក់កាលអយ្យការ និងចៅក្រមស៊ើបសួរប្រហាក់ប្រហែលគ្នាថា៖ ខ្ញុំបាទត្រូវសមត្ថកិច្ចឃាត់ខ្លួននៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១ វេលាម៉ោង ១១ និង៣០នាទីព្រឹក និងសូមរក្សាខ្លឹមសារដូចមានក្នុងកំណត់ហេតុស្តាប់ចម្លើយនៅអយ្យការ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៩ ដែលមានខ្លឹមសារ៖ ខ្ញុំបាទសូមជបិដេធចោលនូវពាក្យបណ្តឹងរបស់ឈ្មោះ ទាំងស្រុងដោយហេតុថាខុសពីការពិត ចំពោះវិញ្ញាបនប័ត្រសម្គាល់អចលនវត្ថុដែលមានក្បាលដីលេខ:៤២១ ទំហំ៨១៩១ ម៉ែត្រការ៉េ ដែលខ្ញុំបាទបានដាក់បញ្ចាំនោះគឺម្ចាស់កម្មសិទ្ធិរបស់ប្អូនជីដូនមួយខ្ញុំឈ្មោះ មានទីតាំងផ្ទះលេខ:៨២ ផ្លូវជាតិលេខ:៤ ភូមិត្រពាំងគល់ សង្កាត់កំបូល ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។ នៅពេលខ្ញុំយកវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុខាងលើនោះទៅបញ្ចាំឈ្មោះ គឺឈ្មោះ បានឯកភាពឱ្យខ្ញុំបាទយកទៅបញ្ចាំ ហើយគាត់ក៏មិនបានប្តឹងខ្ញុំដែរ។ ខ្ញុំសូមបញ្ជាក់បន្ថែមថា នៅពេលដែលខ្ចីប្រាក់លើកដំបូងចំនួន ២៥០០០ (ពីម៉ឺនប្រាំពាន់) ដុល្លារអាមេរិក ពេលនោះខ្ញុំបាទទៅខ្ចីប្រាក់តែពីរនាក់ឈ្មោះ នោះទេដោយឈ្មោះ រវល់ទៅធ្វើការនៅប្រទេសថៃ ហើយកិច្ចសន្យានោះគឺប្តិតមេដៃនៅចំពោះមុខឈ្មោះ និងប្រពន្ធរបស់គាត់ ពេលនោះពួកខ្ញុំបានប្រាប់ឈ្មោះ ដែរពីប្លង់ដីជារបស់ឈ្មោះ ហើយឈ្មោះ ក៏យល់ព្រមនិងបន្តខ្ចីប្រាក់លើកក្រោយមកទៀតផងដែរ។ សូមណ្ឌូមពរ សូមឱ្យតុលាការមេត្តាអនុញ្ញាតឱ្យខ្ញុំបាទបានទៅផ្ទះវិញ។

៤-មានពិរុទ្ធភាពលើជនត្រូវចោទឈ្មោះ ភេទប្រុស អាយុ៤០ឆ្នាំ ជនជាតិខ្មែរ និងឈ្មោះ ភេទប្រុស អាយុ៣៨ឆ្នាំ ជាតិខ្មែរ ពីបទ ៖ **ក្លែងបន្លំ** និង **ប្រើប្រាស់លិខិតក្លែង** ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៨ បទល្មើសដែលមានបញ្ញាតិឱ្យផ្តន្ទាទោសតាមមាត្រា ៦២៦, ៦២៧ និងមាត្រា ៦២៨ នៃក្រមព្រហ្មទណ្ឌ ។

## ហេតុដូច្នេះសម្រេច

-បញ្ជូនជនត្រូវចោទឈ្មោះ ភេទប្រុស អាយុ៤០ឆ្នាំ ជនជាតិខ្មែរ និងឈ្មោះ ភេទប្រុស អាយុ ៣៨ឆ្នាំ ជាតិខ្មែរ និងសំណុំរឿងព្រហ្មទណ្ឌលេខ: ៧២៤២ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៩ ព្រមទាំងវត្ថុតាង និងបញ្ជីរាយនាមជនដែលទាក់ទងក្នុងរឿងនេះទៅប្រធានសាលាដំបូងរាជធានីភ្នំពេញ ដើម្បីកំណត់ពេលសវនាការជំនុំជម្រះ។

ពីបទ៖ ក្លែងបន្លំ និង ប្រើប្រាស់លិខិតក្លែង ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៨ [illegible] ល្មើសដែលមានបញ្ញាតិឱ្យផ្តន្ទាទោសតាមមាត្រា ៦២៦, ៦២៧ និងមាត្រា ៦២៨ នៃក្រមព្រហ្មទណ្ឌ ។

ថ្ងៃ.[illegible]...០១.កើត...ខែ.[illegible]... ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី.០៥... ខែសីហា ឆ្នាំ២០២១

**ចៅក្រមស៊ើបសួរ**

បានទទួលដំណឹង

រាជធានីភ្នំពេញ, ថ្ងៃទី០៥...ខែសីហា ឆ្នាំ២០២១

**តំណាងអយ្យការ**

ព្រះរាជអាជ្ញារង

**ក្រឡាបញ្ជី**

ឧបសម្ព័ន្ធទី ៤

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងរាជធានីភ្នំពេញ

# ដីកាកោះឲ្យចូលរួមសវនាការ

យើង        តំណាងអយ្យការ នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

-ក្រោយពីបានពិនិត្យ សំណុំរឿងព្រហ្មទណ្ឌលេខ ៨៦៨១ ចុះថ្ងៃទី ១៣ ខែធ្នូ ឆ្នាំ២០១៨ ។

-បានឃើញ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ២៣៨៣ "ណជ" ដ.ដ ចុះថ្ងៃទី ១៣ ខែឧសភា ឆ្នាំ២០២១ ។

ជាប់ចោទពីបទ: រំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលអំឡុងខែតុលា ឆ្នាំ២០១៨ តាមមាត្រា៣៩១ និងមាត្រា៣៩២ នៃក្រមព្រហ្មទណ្ឌ ។

## ក្រោយពីដាក់រឿងជំនុំជម្រះសម្រេច:

បង្គាប់ឲ្យឈ្មោះ        ភេទប្រុស ៤៥ឆ្នាំ ជនជាតិខ្មែរ ទីលំនៅសព្វថ្ងៃស្នាក់នៅភូមិព្រែកតាពៅ ឃុំ[illegible] ស្រុកតាខ្មៅ ខេត្តកណ្ដាល ។ (ក្រៅឃុំ)

ឲ្យចូលខ្លួនទៅចំពោះមុខសាលាដំបូងរាជធានីភ្នំពេញ នៅបន្ទប់សវនាការទី៤ ជាន់ទី១ នៅថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២១ វេលាម៉ោង ០៨ : ៣០ នាទីព្រឹក ជាកំហិតដើម្បីឆ្លើយដោះសារពីការចោទប្រកាន់លើខ្លួន ។

## ចៅក្រមជំនុំជម្រះ

-លោក        ចៅក្រមជំនុំជម្រះ នៃសាលាដំបូងរាជធានីភ្នំពេញ

## តំណាងអយ្យការ

-លោក        ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

## ក្រឡាបញ្ជីសវនាការ

-លោក        ជាក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ថ្ងៃ.ចន្ទ.... .១២កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី....២៥.... ខែសីហា ឆ្នាំ២០២១

**តំណាងអយ្យការ**

[illegible]

[illegible]:

- [illegible]ទទួល[illegible]ដ[illegible]ប់ទិតកោទប្រកាន់ទោស និងដីកាកោះឲ្យចូលខ្លួន
- [illegible]បង្ហាញភស្តុតាង សំអាងសាក្សី និងធ្វើសំណូមពរផ្សេងៗ
- [illegible]ចៅក្រមជំនុំជម្រះ
- [illegible]ខ្លួនឯង ឬសុំឲ្យមេធាវីជួយការពារ
- [illegible]
- [illegible]សម្ដីចុងក្រោយបង្អស់ ។

ឧបសម្ព័ន្ធទី ៥

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

៚៙៚

អយ្យការអម

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌ

លេខ: ៨៦៩១

ចុះថ្ងៃទី ១៣.១២.២០១៩

## **ដីកាកោះ**

**យើង** **តំណាងអយ្យការ នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ**

ឈ្មោះ ភេទស្រី អាយុ៥៨ឆ្នាំ ជនជាតិខ្មែរ ជាដើមបណ្តឹងរដ្ឋប្បវេណី ទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះលេខ៧៨ ផ្លូវA សង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

នៅថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២១ វេលាម៉ោង ០៨ : ៣០នាទីព្រឹក (សវនាការទី៤)

ដើម្បី: ចូលរួមសវនាការ

ពីដំណើររឿង: រំលោភបំពានលើទំនុកចិត្ត

សាមីខ្លួនត្រូវអញ្ជើញតាមដីកាកោះ ឲ្យទាន់ពេលវេលា និងយកលិខិតផ្សេងៗ ដែលទាក់ទង នឹងរឿងខាងលើមកជាមួយផងប្រសិនបើមាន។

## **សមាសភាព**

-លោក ចៅក្រមជំនុំជម្រះ នៃសាលាដំបូងរាជធានីភ្នំពេញ

-លោក ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

-លោក ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

អំពីសិទ្ធិរបស់ជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណី

១.សិទ្ធិបង្ហាញភស្តុតាង សំអាងសាក្សី និងសំណូមពរផ្សេងៗ ។

២.សិទ្ធិបដិសេធចៅក្រមជំនុំជម្រះ ។

៣.សិទ្ធិការពារខ្លួនដោយខ្លួនឯង ឬសុំមេធាវីការពារ ឬអ្នកដទៃណាមួយផ្សេងទៀត ។

ថ្ងៃអង្គារ ៩កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២១

**តំណាងអយ្យការ**

18.08.21

ព្រះរាជអាជ្ញារង

នៅថ្ងៃ..............................បានប្រគល់ដីកាកោះនេះឱ្យឈ្មោះ..............................................មានទីលំនៅបច្ចុប្បន្នផ្ទះលេខ
..............................ផ្លូវ..............................ឃុំ/សង្កាត់..............................ស្រុក/ខណ្ឌ..............................ខេត្ត/ក្រុង
.............................. នៅថ្ងៃទី..........ខែ..................ឆ្នាំ២០២១ ដោយផ្ទាល់រួចហើយ ដោយយើងបានទុកចុងដីកានេះមួយច្បាប់ឱ្យសាមីខ្លួន ហើយប្រាប់ថាអោយសាមីខ្លួនប្រគល់ចុងដីកានេះដល់ក្រឡាបញ្ជីនៅពេលចូលទៅតុលាការ ។

| | |
|---|---|
| **អ្នកទទួលលិខិត** | **អ្នកប្រគល់** |
| **ហត្ថលេខា ឬផ្តិតមេដៃ** | **ហត្ថលេខា** |

ឧបសម្ព័ន្ធទី ៦

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ

**សាលក្រមព្រហ្មទណ្ឌ**
**មុនរង្គសេចក្តី**

-លេខៈ ៩៣ "ក្រពជ"
ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២១
-សំណុំរឿងព្រហ្មទណ្ឌលេខៈ៨១០១
ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២០
-សំណុំរឿងស៊ើបសួរលេខៈ៥៨៥១
ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២០
-សំណុំរឿងជំនុំជម្រះលេខៈ១១៣៧
ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១

**តាងនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងរាជធានីភ្នំពេញ**

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២១ វេលាម៉ោង ២,០០ នាទីរសៀលនៅសាលសវនាការទី៣ ដោយមានសមាសភាព ៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

-លោក ជាប្រធានក្រុមប្រឹក្សា
-លោក ជាចៅក្រមប្រឹក្សា
-លោក ជាចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

-លោក ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

-លោកស្រី ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៨១០១ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២០ ដែលមានជនជាប់ចោទ៖

១-ឈ្មោះ ភេទប្រុស អាយុ២១ឆ្នាំ ជាតិខ្មែរ មានមុខរបរលក់ដូរ មានទីលំនៅកំណើតនៅស្រុក ពាធាយ ខេត្តកំពង់ចាម មានទីលំនៅសព្វថ្ងៃនៅផ្ទះលេខ២៧H ផ្លូវលំ ភូមិម៉រ សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ឪពុកឈ្មោះ (រ) ម្តាយឈ្មោះ (រ) ប្រពន្ធឈ្មោះ (លែងលះ) ជាឪតិជន ទោសពីមុនគ្មាន ។

-ឃាត់ខ្លួននៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២០ ។

-ឃុំខ្លួនតាមដីលេខ១៣៥២៣ (ខ) ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២០ ។

ដោយមានលោក ជាមេធាវីការពារសិទ្ធិ ។

ត្រូវជាប់ចោទពីបទ លួចមានស្ថានទម្ងន់ទោសដោយការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចផ្លូវ៥០ម៉ែត្រ ភូមិអន្លង់គង សង្កាត់ព្រៃស ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងផ្តន្ទាទោសតាមមាត្រា៣៥៣,៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

**អង្គហេតុនៃរឿងមានដូចតទៅ**

កាលពីថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២០ វេលាម៉ោង២១,៣០នាទីនៅចំណុចផ្លូវ៥០ម៉ែត្រ ភូមិអន្លង់គង សង្កាត់ព្រៃស ខណ្ឌដង្កោ រាជធានីភ្នំពេញ មានករណីលួចមានស្ថានទម្ងន់ទោសប្រព្រឹត្តអំពើហិង្សាដែលបានបង្កដោយជនត្រូវចោទមួយក្រុមមានគ្នាចំនួន៨នាក់រួមមានឈ្មោះ , ឈ្មោះ , ឈ្មោះ , ឈ្មោះ , ឈ្មោះ , ឈ្មោះ , ឈ្មោះ ,ឈ្មោះ និងឈ្មោះ បានជិះម៉ូតូចំនួន៤គ្រឿង ធ្វើដំណើរតាមបណ្តោយផ្លូវ៥០ម៉ែត្រលុះដល់ចំណុចកើតហេតុក៏បានឃើញជនរងគ្រោះឈ្មោះ កំពង់ជិះម៉ូតូម៉ាកBeat ពណ៌ខៀវពាក់ស្លាក់លេខតាកែវ1V-2523ភ្លាមនេះជនរងគ្រោះឈ្មោះ ដែលជិះម៉ូតូឌុបជនត្រូវចោទឈ្មោះ បានជិះម៉ូតូទៅកៀរជនរងគ្រោះ ហើយជនត្រូវចោទឈ្មោះ ក៏បានធាក់ម៉ូតូរបស់ជនរងគ្រោះបណ្តាលឱ្យដួលរួចក៏យកកាំបិតប៉ុងតោដេញកាប់ជនរងគ្រោះភ្លាមនេះជនត្រូវចោទឈ្មោះ បានឡើងជិះម៉ូតូរបស់ជនរងគ្រោះគេចខ្លួនបាត់លុះដល់ម៉ោង១,០០រំលងអាធ្រាត ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២០ឈ្មោះ ,ឈ្មោះ និង

ឈ្មោះ បានយកម៉ូតូរបស់ជនរងគ្រោះទៅលក់ឱ្យបុរសម្នាក់មិនស្គាល់ឈ្មោះនៅផ្ទះសំណាក់សារិកា២ ក្នុងខណ្ឌជ្រោយចង្វាក្នុងតម្លៃ៥៥០$ ។

-បានឃើញ: របាយការណ៍សំយោគលេខ៧៩.រ.ប.ក ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២០ របស់ការិយាល័យព្រហ្មទណ្ឌកំរិតស្រាល នៃស្នងការរដ្ឋាននគរបាលជាតិ ។

-បានឃើញ: ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ៥៩៨៧ អ.យ.ខ ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២០ របស់ព្រះរាជអាជ្ញាអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ: ដីកាសន្និដ្ឋានស្ថាពរលេខ ៩៩៣ អ.យ.ខ ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ: ដីកាដំណោះស្រាយលេខ ១៣៣២ "ឃ១".ដ.ដ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ ឆ្លើយនៅពេលសវនាការថា៖ នៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២០ វេលាម៉ោងប្រហែល២១,៣០នាទីពួកខ្ញុំមានគ្នាច្រើននាក់មានរូបខ្ញុំ មានឈ្មោះ ,ឈ្មោះ ,ឈ្មោះ , ឈ្មោះ ,ឈ្មោះ , ឈ្មោះ ,ឈ្មោះ និងឈ្មោះ បានជិះម៉ូតូ៧ ទៅ៨គ្រឿងដោយខ្ញុំបានជិះម៉ូតូម៉ាកហុងដាម៉ាកស្កុបពីពណ៌សសេរីឆ្នាំ២០១៩ឌុបឈ្មោះ លុះមកដល់ចំណុចផ្លូវ៥០ម៉ែត្រខ្ញុំឃើញឈ្មោះ ដែលបានជិះម៉ូតូឌុបឈ្មោះ បានជិះម៉ូតូជនរងគ្រោះម៉ាកហុងដាប៊ិតពេលនេះឈ្មោះ បានធ្វើសកម្មភាពធាក់ម៉ូតូរបស់ជនរងគ្រោះបណ្តាលឱ្យដួល ឃើញដូច្នេះខ្ញុំក៏បានជិះម៉ូតូចេញទៅផ្ទះមិនដឹងថាពួកវាធ្វើអ្វីបន្តទៀតនេះទេ ។ លុះស្អែកឡើងឈ្មោះ បានយកប្រាក់មកឱ្យខ្ញុំចំនួន៥០$ ។

## សេចក្តីសន្និដ្ឋានម្តឹងសុំរបស់តំណាងអយ្យការ

តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានថា: ក្រោយពីបានសួរដេញដោលខាងលើឃើញថាការស្នើសុំរបស់មេធាវីការពារឱ្យជនជាប់ចោទឈ្មោះ ពុំមានហេតុផលគ្រប់គ្រាន់សម្រាប់ឱ្យតុលាការពិចារណាឡើយ ដូច្នេះតំណាងអយ្យការនៅតែរក្សាការចោទប្រកាន់ទុកនៅដដែលដោយចោទពីបទ លួចមានស្ថានទម្ងន់ទោសដោយការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចផ្លូវ៥០ម៉ែត្រ ភូមិអន្លង់គង សង្កាត់ព្រែស ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៣៥៣,៣៥៧ នៃក្រមព្រហ្មទណ្ឌ និងស្នើសុំឱ្យលោកប្រធានក្រុមប្រឹក្សាផ្តន្ទាបន្តការឃុំខ្លួនជនជាប់ចោទជាបណ្តោះអាសន្នសិន រង់ចាំតុលាការសម្រេចដល់រឿងអង្គសេចក្តី ។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

មេធាវីឈ្មោះ ជាមេធាវីការសិទ្ធិឱ្យជនជាប់ចោទឈ្មោះ ធ្វើសេចក្តីសន្និដ្ឋានការពារថា៖ បើតាមការពិត្យចម្លើយរបស់ជនជាប់ចោទឈ្មោះ ដែលជាកូនក្តីរបស់ខ្លួន សំណុំរឿងឃើញថានៅក្នុងរឿងនេះកូនក្តីរបស់ខ្លួនមិនបានចូលរួមប្រព្រឹត្តបទល្មើសនេះទេ នៅពេលសមត្ថកិច្ចចុះទៅឃាត់ខ្លួនកូនក្តីខ្ញុំគាត់នៅផ្ទះមិនបានដឹងអ្វីទេ ដូច្នេះក្នុងនាមខ្ញុំជាមេធាវីការពារសិទ្ធិឱ្យស្នើសុំឱ្យលោកប្រធានក្រុមប្រឹក្សាមេត្តាជួយដោះលែងឱ្យកូនក្តីរបស់ខ្ញុំនៅក្រៅឃុំជាបណ្តោះអាសន្ន ។

## សំដីចុងក្រោយរបស់ជនជាប់ចោទ

-ជនជាប់ចោទឈ្មោះ ស្នើសុំឱ្យលោកប្រធានក្រុមប្រឹក្សាជួយបន្ធូរបន្ថយទោសឱ្យខ្លួន ។

-ក្រោយពីបានស្តាប់ចម្លើយចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារជនជាប់ចោទ

-ក្រោយពីបានស្តាប់ជនជាប់ចោទនិយាយសំដីចុងក្រោយ

-ក្រោយពីបានពិនិត្យលើឯកសារ ភស្តុតាងនានា

ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**សំអាងហេតុ**

១-បទល្មើសដែលតំណាងអយ្យការធ្វើការចោទប្រកាន់ជាបទល្មើសឧក្រិដ្ឋ ដែលត្រូវផ្តន្ទាទោសតាមមាត្រា ៣៥៣,៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

២- មេធាវីការពារជនត្រូវចោទឈ្មោះ បានដាក់ពាក្យស្នើសុំឱ្យក្ខនក្តីនៅក្រៅឃុំ ដោយពុំមានហេតុផលច្បាស់លាស់ ដើម្បីរក្សាជនជាប់ចោទទុកជូនតុលាការចាត់ការតាមនីតិវិធី គប្បីសម្រេចបន្តឃុំខ្លួនជាបណ្តោះអាសន្នរហូតដល់តុលាការជំនុំជម្រះដល់រឿងអង្គសេចក្តីតាមបញ្ញាតិមាត្រា២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៣-នៅពេលតំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំឱ្យលោកចៅក្រមជំនុំជម្រះ បន្តឃុំខ្លួនលើជនជាប់ចោទឈ្មោះ ជាបណ្តោះអាសន្នដើម្បីបញ្ចប់បទល្មើសឬបង្ការបទល្មើសកុំឱ្យកើតមានសារជាថ្មី និងធានារក្សាជនជាប់ចោទទុកជូនតុលាការតាមនីតិវិធី គប្បីតុលាការបន្តឃុំខ្លួនជាបណ្តោះអាសន្នលើជនជាប់ចោទឈ្មោះ សៅរាសីតាមមាត្រា២០៤,២០៥នៃក្រមនីតិវិធីព្រហ្មទណ្ឌរងចាំតុលាការបើកអង្គសវនាការជំនុំជម្រះរឿងអង្គសេចក្តី។

**ហេតុដូច្នេះសម្រេច**

-បន្តឃុំខ្លួនលើជនជាប់ចោទឈ្មោះ ភេទប្រុស អាយុ២១ឆ្នាំ ជាតិខ្មែរ នៅមណ្ឌលអប់រំកែប្រែទី ១"ម១" នៃក្រសួងមហាផ្ទៃជាបណ្តោះអាសន្នរង់ចាំតុលាការជំនុំជម្រះរឿងអង្គសេចក្តី ពីបទលួចមានស្ថានទម្ងន់ទោសដោយការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចផ្លូវ៥០ម៉ែត្រ ភូមិអន្លង់គង សង្កាត់ព្រៃស ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៣៥៣,៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

-សាលក្រមនេះជំនុំជម្រះ នឹងប្រកាសសាធារណៈនៅថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទឈ្មោះ បើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

**ក្រឡាបញ្ជីសវនាការ** **ចៅក្រមប្រឹក្សា** **ចៅក្រមប្រឹក្សា** **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

ឧបសម្ព័ន្ធទី ៧

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

-សំណុំរឿងព្រហ្មទណ្ឌលេខ: ៦៨១២
ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០
-សំណុំរឿងស៊ើបសួរលេខ: ៤៨១៥
ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២០
-សំណុំរឿងជំនុំជម្រះលេខ: ៨០៦
ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២១
សាលក្រមមុនអង្គសេចក្តី
លេខ: ៨៥ "ព"ក្រ៣
ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២១

# សាលក្រមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈនៅសាលាដំបូងរាជធានីភ្នំពេញ នាថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២១ ដោយមានសមាសភាពជំនុំជម្រះដូចតទៅ៖

### ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

លោក ៖ ជាអនុប្រធានសាលាដំបូងរាជធានីភ្នំពេញ

### ចៅក្រមប្រឹក្សាជំនុំជម្រះ

លោក ជាចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

លោក ជាចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

### តំណាងអយ្យការ

លោក ៖ ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

### ក្រឡាបញ្ជីសវនាការ

លោកស្រី ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើ សំណុំរឿងព្រហ្មទណ្ឌលេខ ៦៨១២ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០ ដែលមានជនជាប់ចោទ៖

- ឈ្មោះ ភេទប្រុស អាយុ១៧ឆ្នាំ (កើតថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៣) ជាតិខ្មែរ មុខរបរសិស្ស ទីកន្លែងកំណើតនៅភូមិ៧ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះលេខ១៦៦ ផ្លូវនរោត្តម ក្រុម៣៧ ភូមិ៧ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ នៅលីវ ឪពុកឈ្មោះ , "រស់" ម្តាយឈ្មោះ "រស់" ជាអនីតិជនកំរិតវប្បធម៌ រៀនថ្នាក់ទី១០ ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការគ្មាន។

ត្រូវបានឃុំខ្លួនតាម៖ ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ១១៤៤២"ភ" ដឃដ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ ។ (ម២)

ជាប់ចោទពីបទ លួចមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចនៅមុខក្លឹបDOS ផ្លូវសហ៊ីត ក្រុម៧៨ ភូមិ១៤ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០២០ បទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

### មេធាវី

លោក ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ ।

លោកស្រី ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ ។

## អង្គហេតុនៃរឿងនេះមានដូចតទៅ

កាលពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង០៥ និង៣០នាទី មានករណី លួចមានស្ថានទម្ងន់ទោស បានកើតឡើង ដោយមុនពេលកើតហេតុ ជនត្រូវចោទឈ្មោះ និងឈ្មោះ បានជិះម៉ូតូមួយគ្រឿងម៉ាកសេ១២៥ ពាក់ផ្លាកលេខភ្នំពេញ1HR-1455 ធ្វើសកម្មភាពឆក់ទូរស័ព្ទដៃពីស្ត្រីជនជាតិបរទេសម្នាក់ កំពុងដើរកាន់ទូរស័ព្ទដៃនៅចំណុចមុខក្លឹបDOS ផ្លូវសហ៊ិត ក្រុម៧៨ ភូមិ១៤ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ដោយជនសង្ស័យឈ្មោះ ជាអ្នកបើកម៉ូតូ ហើយជនត្រូវចោទឈ្មោះ ជាអ្នកធ្វើសកម្មភាពឆក់ទូរស័ព្ទ តែមិនបានសម្រេចដោយជនរងគ្រោះដឹងខ្លួនទាន់ ពេលនោះសមត្ថកិច្ចកំពុងល្បាតបានឃើញទាន់ ក៏បានដេញតាមចាប់ជនត្រូវចោទឈ្មោះ ព្រមទាំងវត្ថុតាងនានាដែលពាក់ព័ន្ធ បញ្ជូនទៅកាន់ប៉ុស្តិ៍នគរបាលរដ្ឋបាលទន្លេបាសាក់ ដើម្បីចាត់ការតាមច្បាប់ ។ ចំណែកឯជនត្រូវចោទឈ្មោះ បានរត់គេចខ្លួន រហូតដល់ម៉ោង០២ និង៣០នាទី រំលងអធ្រាត្រ ឈានចូលថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០ កម្លាំងសមត្ថកិច្ចប៉ុស្តិ៍នគរបាលរដ្ឋបាលទន្លេបាសាក់ បានស្រាវជ្រាវរកឃើញ និងចាប់ជនត្រូវចោទឈ្មោះ នៅចំណុចស្ថានីយ៍ប្រេងសូគីមិច ផ្លូវនរោត្តម ភូមិ៧ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ បញ្ជូនទៅកាន់អធិការដ្ឋាននគរបាលខណ្ឌចំការមន ដើម្បីចាត់ការតាមនីតិវិធី ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ៤៩១១ អ.យ.ន ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ២៦៩ អ.យ.ន ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៩២៧ "ភ" ជ.ជ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

បានឃើញ ពាក្យសុំបញ្ចូលសំណុំរឿងតែមួយ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២១ របស់លោក ជាមេធាវីការពារសិទ្ធឱ្យជនជាប់ចោទឈ្មោះ ។

## នាពេលសវនាការ

-តាមចំណាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ បានឆ្លើយនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ថា: មុនពេលកើតហេតុឈ្មោះ បានបបួលខ្លួនទៅរកឆក់ទ្រព្យសម្បត្តិអ្នកដទៃ រួចពួកខ្លួនក៏បានចូលក្នុងបរិវេនកោះពេជ្រ ហើយក៏បានជិះចេញមកក្រៅកោះពេជ្រវិញ ក៏បានឃើញស្ត្រីជនជាតិបរទេសម្នាក់ដើរកាន់ទូរស័ព្ទតាមផ្លូវ លុះដល់ចំណុចកើតហេតុ ក៏បានបើម៉ូតូទៅក្រោយអែមស្តាំដៃ រួចខ្លួនក៏ធ្វើសកម្មភាពឆក់តែម្តង តែមិនបានសម្រេចនោះទេ ក៏ស្រាប់តែមានកម្លាំងសមត្ថកិច្ចដេញតាមពួកខ្លួន រួចពួកខ្លួនក៏ជិះម៉ូតូគេចខ្លួនដល់មុខផ្សារចិន ក្បែរស្ពានហាង្ស (កោះពេជ្រ) ខ្លួនក៏បានលោតពីលើម៉ូតូ រួចរត់គេខ្លួនបាត់ទៅ ។ លុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង ០២ និង៣០ នាទីរំលងអធ្រាត្រ សមត្ថកិច្ចបានឃើញខ្លួនកំពុងនៅក្នុងការ៉ាស់សាំងសូគីមិច ក៏បានឃាត់រូបខ្លួនតែម្តង ។

-តាមចំណាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ បានឆ្លើយនៅដំណាក់កាលចៅក្រមស៊ើបសួរថា: ខ្លួនសុំបដិសេធចម្លើយដែលខ្លួនឆ្លើយនៅមុខមន្ត្រីនគបាលយុត្តិធម៌ ដោយសារតែប៉ូលីសបានប្រើកែកាំភ្លើងវាយក្បាលខ្លួន តែវាយមិនខ្លាំងទេ ហើយថែមទាំងសម្លុតខ្លួនឱ្យទទួលស្គាល់ចម្លើយដែលគាត់កត់ទៀត ។ ខ្លួនមិនដឹងថាហេតុអ្វីបានជាប៉ូលីសឃាត់រូបខ្លួនទេ ព្រោះពេលនោះគឺខ្លួនកំពុងចាក់សាំងម៉ូតូ ស្រាប់តែប៉ូលីសមកពីក្រោយបានចាប់គ្រៀកខ្លួនជាប់ ហើយវាយខ្លួនថែមទៀត ។ ខ្លួនស្គាល់ឈ្មោះ ស្គាល់តាមរយៈមិត្តភ័ក្ត ស្គាល់គ្នាបានរយៈពេលពីរបីខែតែមិនបានស្និតស្នាលគ្នានោះ

ទេ ។ ខ្លួនមិនបានដឹងថាឈ្មោះ លួចទ្រព្យសម្បត្តិគេទេ ព្រោះនៅថ្ងៃទី០១ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង០៥ និង៣០នាទីព្រឹក ខ្លួនកំពុងនៅដេកក្នុងផ្ទះ រហូតដល់ម៉ោង០៦ជាង ទើបខ្លួនជិះម៉ូតូទៅទិញកាហ្វេ ហើយខ្លួនមានសាក្សីចំនួនពីរនាក់ មានឈ្មោះ ភេទស្រី ត្រូវជាបងស្រីខ្លួន និងឈ្មោះ ជាសន្តិសុខយាមម៉ូតូ បានឃើញខ្លួនទៅយកម៉ូតូជិះចេញទៅក្រៅនៅម៉ោងប្រាំមួយព្រឹក ។ ខ្លួនសុំជួបសួរតទល់ជាមួយឈ្មោះ ជាមុនសិន ថាហេតុអ្វីបានជាឆ្លើយដាក់ខ្លួន ។ ខ្លួនសុំសំណូមពរដល់តុលាការជួយរកយុត្តិធម៌ដល់ខ្លួនផង និងអនុញ្ញាតឱ្យរូបខ្លួនបានត្រឡប់ទៅផ្ទះវិញ ព្រោះខ្លួនត្រូវរៀនសូត្រតាមអនឡាញ ។

-តាមអំណានចម្លើយតទល់របស់សាក្សីឈ្មោះ ហៅ បានឆ្លើយនៅដំណាក់កាលចៅក្រមស៊ើបសួរថា: ខ្លួនមិនស្គាល់ឈ្មោះ ដែលលោកចៅក្រមបង្ហាញរូបនេះ ព្រោះថាឈ្មោះ ដែលធ្វើសកម្មភាពលួចជាមួយខ្លួននោះ មានសម្បុរខ្មៅ មានស្នាមស្នៀង មិនមែនសម្បុរស មានមាឌធំដូចក្នុងរូបនេះទេ ។ ហើយចម្លើយដែលខ្លួនឆ្លើយនៅសមត្ថកិច្ចថាឈ្មោះ មាឌធំល្មម ខ្លួនទទួលស្គាល់ចម្លើយនោះ ។ ខ្លួនមិនស្គាល់ឈ្មោះ ដែលមានវត្តមាននៅពេលនេះទេ ហើយក៏មិនបានធ្វើសកម្មភាពឆក់ជាមួយខ្លួនដែរ ។ និងតាមអំណានចម្លើយតទល់របស់ជនជាប់ចោទឈ្មោះ បានឆ្លើយនៅដំណាក់កាលចៅក្រមស៊ើបសួរថា: ខ្លួនមិនស្គាល់ឈ្មោះ ហៅ : ដែលមានវត្តមានតទល់នាពេលនេះទេ ហើយខ្លួនមិនដឹងថាឈ្មោះនេះធ្វើសកម្មភាពឆក់គេដែរ ។

-តាមអំណានពាក្យសុំបញ្ចូលសំណុំរឿងតែមួយ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២១ របស់លោក ភេស សាម៉ន ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ ដែលមានខ្លឹមសារថា: សំណូមពរ ឯកឧត្តមប្រធាន មេត្តាពិនិត្យរោត់របៀបសម្រេចបញ្ចូលសំណុំរឿងព្រហ្មទណ្ឌលេខ ៦៨១២ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ បានបញ្ជូនមកជំនុំជម្រះ ដែលមានលោក ជាចៅក្រមជំនុំជម្រះ និងសំណុំរឿងព្រហ្មទណ្ឌលេខ ៦៦០៩ ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ បានបញ្ជូនមកជំនុំជម្រះ ដែលមានលោក ជាចៅក្រមជម្រះ រួមគ្នាតែមួយ ព្រោះជាអង្គហេតុតែមួយ ដោយផ្អែកតាមរបាយការណ៍លេខ ៧៤/២០ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០២០ របស់ប៉ុស្តិ៍នគរបាលរដ្ឋបាលទន្លេបាសាក់ និងរបាយការណ៍សំយោគលេខ ០៨០/២០ រ.ប.ក ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០ របស់អធិការដ្ឋាននគរបាលខណ្ឌចំការមន នៃសំណុំរឿងព្រហ្មទណ្ឌលេខ ៦៨១២ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ និងតាមរបាយការណ៍លេខ ៧៣/០២០ រ.ប.ភ ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០២០ របស់ប៉ុស្តិ៍នគរបាលរដ្ឋបាលទន្លេបាសាក់ និងរបាយការណ៍សំយោគលេខ ០៧៩/២០ រ.ប.ក ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០២០ របស់អធិការដ្ឋាននគរបាលខណ្ឌចំការមន នៃសំណុំរឿងព្រហ្មទណ្ឌលេខ ៦៦០៩ ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ ។

## សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

ក្រោយពីពិនិត្យភស្តុតាងនៅក្នុងសំណុំរឿងរួចមក តំណាងអយ្យការស្នើសុំបញ្ចូលសំណុំរឿងព្រហ្មទណ្ឌលេខ: ៦៨១២ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ មកសំណុំរឿងព្រហ្មទណ្ឌលេខ: ៦៦០៩ ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ ។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

លោកស្រី ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ ; បានសន្និដ្ឋានថា: ខ្លួនសុំបញ្ចូលសំណុំរឿងព្រហ្មទណ្ឌលេខ:៦៦០៩ ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២០ មកសំណុំរឿងព្រហ្មទណ្ឌលេខ: ៦៨១២ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០ វិញ មូលហេតុដោយសារតែសំណុំរឿងព្រហ្មទណ្ឌលេខ:៦៦០៩ មិនមានឃាត់ខ្លួនកូនក្តីខ្លួន ដូចនេះខ្លួនសុំ

បញ្ចូលរឿងក្តីតែមួយ និងសុំឱ្យកូនក្តីខ្លួនរួចផុតពីបទចោទ និងសុំដោះលែងកូនក្តីខ្លួនឱ្យមានសេរីភាពឡើងវិញ ។ ខ្លួននឹងភ្ជាប់សេចក្តីសន្និដ្ឋានចូលមកតាមក្រោយ ។

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនជាប់ចោទ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ។

-ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

## សំអាងហេតុ

១. កាលពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង០៥ និង៣០នាទី មានករណី លួចមានស្ថានទម្ងន់ទោស បានកើតឡើង ដោយមុនពេលកើតហេតុ ជនជាប់ចោទឈ្មោះ និងឈ្មោះ បានជិះម៉ូតូមួយគ្រឿង ម៉ាកសេ១២៥ ពាក់ផ្លាកលេខភ្នំពេញ1HR-1455 ធ្វើសកម្មភាពឆក់ទូរស័ព្ទដៃពីស្ត្រីជនជាតិបរទេសម្នាក់ កំពុងដើរកាន់ទូរស័ព្ទដៃនៅចំណុចមុខក្លឹបDOS ផ្លូវសហ៊ិត ក្រុម៧៨ ភូមិ១៤ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ដោយជនជាប់ចោទឈ្មោះ ជាអ្នកបើកម៉ូតូ ហើយជនត្រូវចោទឈ្មោះ ជាអ្នកធ្វើសកម្មភាពឆក់ទូរស័ព្ទ តែមិនបានសម្រេចដោយជនរងគ្រោះដឹងខ្លួនទាន់ ពេលនោះសមត្ថកិច្ចកំពុងល្បាតបានឃើញទាន់ ក៏បានដេញតាមចាប់ជនជាប់ចោទឈ្មោះ ព្រមទាំងវត្ថុតាងនានាដែលពាក់ព័ន្ធ បញ្ជូនទៅកាន់ប៉ុស្តិ៍នគរបាលរដ្ឋបាលទន្លេបាសាក់ ដើម្បីចាត់ការតាមច្បាប់ ។ ចំណែកឯជនត្រូវចោទឈ្មោះ បានរត់គេចខ្លួន រហូតដល់ម៉ោង០២ និង៣០នាទី រំលងអធ្រាត្រ ឈានចូលថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០ កម្លាំងសមត្ថកិច្ចប៉ុស្តិ៍នគរបាលរដ្ឋបាលទន្លេបាសាក់ បានស្រាវជ្រាវរកឃើញ និងចាប់ជនត្រូវចោទឈ្មោះ នៅចំណុចស្តានីយទ៍ប្រេងស្តូគីបិច ផ្លូវនរោត្តម ភូមិ៧ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ បញ្ជូនទៅកាន់អធិការដ្ឋាននគរបាលខណ្ឌចំការមន ដើម្បីចាត់ការតាមនីតិវិធី ។

២. តាមអំណានពាក្យសុំបញ្ចូលសំណុំរឿងតែមួយ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២១ របស់លោក ជាមេធាវីការពារសិទ្ធឱ្យជនជាប់ចោទឈ្មោះ បញ្ជាក់ថា អង្គហេតុក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ ៦៨១២ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ និងអង្គហេតុក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ:៦៦០៩ ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ ជាអង្គហេតុតែមួយ ។

៣. តាមសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការស្នើសុំបញ្ចូលសំណុំរឿងព្រហ្មទណ្ឌលេខ:៦៨១២ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ មកសំណុំរឿងព្រហ្មទណ្ឌលេខ: ៦៦០៩ ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ គប្បីតុលាការពិចារណា និងសម្រេចតាមច្បាប់។

៤. លោកស្រី ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ បានសន្និដ្ឋានថា: ខ្លួនសុំបញ្ចូលសំណុំរឿងព្រហ្មទណ្ឌលេខ:៦៦០៩ ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២០ មកសំណុំរឿងព្រហ្មទណ្ឌលេខ: ៦៨១២ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០ វិញ មូលហេតុដោយសារតែសំណុំរឿងព្រហ្មទណ្ឌលេខ:៦៦០៩ មិនមានឃាត់ខ្លួនកូនក្តីខ្លួន ដូចនេះ ខ្លួនសុំបញ្ចូលរឿងក្តីតែមួយ និងសុំឱ្យកូនក្តីខ្លួនរួចផុតពីបទចោទ និងសុំដោះលែងកូនក្តីខ្លួនឱ្យមានសេរីភាពឡើងវិញ គប្បីពិចារណា ។

៥. តាមរយៈអំពើប្រពឹត្ត កាលបរិច្ឆេទ ឃើញថា សំណុំរឿងព្រហ្មទណ្ឌទាំងពីរនេះមានហេតុតែមួយ ដើម្បីងាយស្រួលសម្រេចដល់ខ្លឹមសារនៃរឿងក្តី គប្បីបញ្ចូលសំណុំរឿងព្រហ្មទណ្ឌលេខ ៦៨១២ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០ ទៅក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ ៦៦០៩ ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២០ តទៅ ។

## វិនិច្ឆ័យសេចក្តី

- បញ្ចូលសំណុំរឿងព្រហ្មទណ្ឌលេខ ៦៨១២ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ ទៅក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ ៦៦០៩ ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការតាមច្បាប់ជាធរមាន ។

សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ នៅថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២១ ។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
| --- | --- | --- | --- |
| ហត្ថលេខា និងត្រា: | ហត្ថលេខា: | ហត្ថលេខា: | ហត្ថលេខា និងត្រា: |

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃសុក្រ ៩រោច ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២១

**ក្រឡាបញ្ជី**

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

ឧបសម្ព័ន្ធទី ៨

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សាលក្រមរបៀប
លេខ៖១១១
ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២១
-សំណុំរឿងព្រហ្មទណ្ឌលេខ៖ ៧១៨៩
ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៩
-សំណុំរឿងស៊ើបសួរលេខ៖១១៦១
ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២០
-សំណុំរឿងជំនុំជម្រះលេខ៖ ១០៤៤
ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១

## តាមនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២១ វេលាម៉ោង ០៨ និង ៣០ នាទីព្រឹក នៅសាលសវនាការទី៣ ដោយមានសមាសភាព៖

### ចៅក្រមជំនុំជម្រះ

លោក ជាចៅក្រមជំនុំជម្រះ

### តំណាងអយ្យការ

លោក ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

### ក្រឡាបញ្ជីសវនាការ

លោកស្រី ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ: ៧១៨៩ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៩ ដែលមានជនជាប់ចោទ ៖

-ឈ្មោះ **រហៅ** ភេទប្រុស អាយុ២៩ឆ្នាំ ជនជាតិម៉ាឡេស៊ី កាន់លិខិតឆ្លងដែនលេខA៤១១២៥៤០៧៩ ទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះលេខ៤៧បេ ផ្លូវ១១៥ សង្កាត់បឹងព្រលិត ខណ្ឌ៧មករា រាជធានីភ្នំពេញ ជានីតិជន។

ជាប់ចោទពីបទ: **ប្រើប្រាស់លិខិតក្លែង** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៦២៨ នៃក្រមព្រហ្មទណ្ឌ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ភេទប្រុស អាយុ៤៦ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរមេធាវី ទីកន្លែងកំណើតនៅភូមិកោះដាច់ ឃុំកោះដាច់ ស្រុកមុខកំពូល ខេត្តកណ្តាល ទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះលេខ១០ ផ្លូវ០៧ បុរីអង្គរភ្នំពេញ សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

-មេធាវីឈ្មោះ អត្តលេខ៖៦៤៥ និងមេធាវីឈ្មោះ អត្តលេខ៖៦៤៥ ជាសមាជិកនៃគណៈមេធាវីកម្ពុជា និងមានការិយាល័យឈ្មោះ **វ៉ែនម៉េកឃើ(កម្ពុជា)** ស្ថិតនៅផ្ទះលេខF១០៨ ផ្លូវវៀមហ្គុងណេស ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ជាមេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ។

### អង្គហេតុនៃរឿងមានដូចតទៅ:

-កាលពីថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៩ ឈ្មោះ បានទទួលដំណឹងថាឈ្មោះ ហៅ ភេទប្រុស ជនជាតិម៉ាឡេស៊ី កាន់លិខិតឆ្លងដែនលេខ A៤១១២៥៤០៧៩ ទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ៤៧បេ ផ្លូវ១១៥ សង្កាត់បឹងព្រលិត ខណ្ឌ៧មករា រាជធានីភ្នំពេញ ដែលជាមេធាវីមកពីប្រទេសម៉ាឡេស៊ី បានបើកគណនីធនាគារចំនួន០២ មួយនៅធនាគារវឌ្ឍនៈអាស៊ីចំកាត់(ABA) មានទីតាំងនៅព្រះរាជាណាចក្រកម្ពុជា និងមួយផ្សេងទៀតគឺគណនី ដែលមានទីស្នាក់ការ កណ្តាលនៅប្រទេសសិង្ហបុរី ដោយបានយកឈ្មោះ ឡ ខេមបូឌា ទៅប្រើដោយគ្មានការដឹងលឺ និងដោយគ្មានការអនុញ្ញាតក្រុមមេធាវី ឡ ខេមបូឌា ឡើយ។នៅថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៩ ឈ្មោះ ទៅជួបឈ្មោះ ប្រធាននាយកដ្ឋានធនាគារពាណិជ្ជកម្មស្នាក់ការកណ្តាលនៃធនាគារវឌ្ឍនៈអាស៊ីចំកាត់(ABA) អគារលេខ ១៤៨ មហាវិថីព្រះសីហនុ សង្កាត់បឹងកេងកង រាជធានីភ្នំពេញ ដើម្បីសុំការឆ្លើយបំភ្លឺ និងសុំពិនិត្យមើលឯកសារ។ ក្រោយពីមានការបញ្ជាក់បំភ្លឺរបស់ឈ្មោះ និងសហការី របស់គាត់ចំនួន០២រូបទៀត និងបានពិនិត្យមើលទម្រង់បែបបទ

ឯកសារដែលឈ្មោះ **ហៅ** បានស្កែនហត្ថលេខារបស់ឈ្មោះ និងបានក្លែងត្រារបស់មេធាវី ជាភាសាអង់គ្លេសថា " Law Cambodia" ដែលកន្លងមក ឡ ខេមបូឌា ពុំដែលបានធ្វើ និងប្រើប្រាស់ត្រានេះទាល់តែសោះ។ ឈ្មោះ **ហៅ** បានលួចស្កែនវិញ្ញាបនប័ត្រ វិជ្ជាជីវៈមេធាវី វិញ្ញាបនប័ត្រចុះបញ្ជីការិយាល័យវិជ្ជាជីវៈមេធាវី និងលួចថតចម្លងលិខិតឆ្លងដែន របស់ឈ្មោះ ដើម្បីបំពេញទម្រង់ស្នើសុំទៅបើកគណនីនៅធនាគារឌ្បនៈអាស៊ីចំកាត់(ABA) និងគណនី ' នៅធនាគារប្រទេសសឹង្ហបុរី។

-**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ: ១០០១ អ.យ.ល ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២០ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-**បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ: ៣៥១ អ.យ.ថ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-**បានឃើញ** ដីកាដំណោះស្រាយលេខ: ៨២៥ "ឡ" ង.ដ ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

## យោបល់របស់តំណាងអយ្យការ

-តំណាងអយ្យការបានផ្តល់យោបល់សុំឱ្យតុលាការចាត់របៀបបង្វិលឱ្យស៊ើបសួររកអត្តសញ្ញាណជនជាប់ចោទឱ្យបានច្បាស់លាស់ ដើម្បីផ្តន្ទាទោសជនជាប់ចោទមិនច្រឡំទៅនឹងបុគ្គលផ្សេងទៀត។អត្តសញ្ញាណជនជាប់ចោទដែលចៅក្រមស៊ើបសួរបញ្ជូនជនជាប់ចោទមកជំនុំជម្រះនេះឃើញថាមិនគ្រប់គ្រាន់និងច្បាស់លាស់ទេ អាចច្រឡំទៅបុគ្គលផ្សេងទៀតបាន។អាចស្រាវជ្រាវរកអត្តសញ្ញាណជនជាប់ចោទតាមរយៈស្ថានទូតម៉ាឡេស៊ីបាន ដែលពុំទាន់បានឃើញមានការស្រាវជ្រាវនោះឡើយ។សរុបមកតំណាងអយ្យការស្នើសុំឱ្យតុលាការចាត់របៀបឱ្យស៊ើបសួរបន្ថែម។

## យោបល់របស់មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី

-មេធាវីការពារឱ្យដើមបណ្តឹងរដ្ឋប្បវេណីបានយល់ស្របតាមការផ្តល់យោបល់របស់តំណាងអយ្យការ ដែលស្នើសុំឱ្យតុលាការសម្រេចចាត់របៀប។

## តុលាការ

-ក្រោយពីបានស្តាប់យោបល់របស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់យោបល់របស់មេធាវីការពារដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

**១**.ចៅក្រមស៊ើបសួរបានសម្រេចបញ្ជូនជនជាប់ចោទឈ្មោះ ភេទប្រុស ជនជាតិម៉ាឡេស៊ី កាន់លិខិតឆ្លងដែនលេខ អាសយដ្ឋានបច្ចុប្បន្នស្នាក់នៅបណ្តោះអាសន្ននៅផ្ទះលេខ៤៧បេ ផ្លូវ១១៥ សង្កាត់បឹងព្រលិត ខណ្ឌ៧មករា រាជធានីភ្នំពេញ ដោយជាប់ចោទពីបទ **ប្រើប្រាស់លិខិតក្លែង** ប្រព្រឹត្តនៅរាជធានីភ្នំពេញ ឆ្នាំ២០១៩ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៦២៨ តាមដីកាសម្រេចបញ្ជូនសំណុំរឿងជំនុំជម្រះលេខ ៨២៥ "ឡ"ង.ដ ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២១។

២.តំណាងអយ្យការបានផ្តល់យោបល់សុំឱ្យតុលាការចាត់របៀបបង្វិលឱ្យស៊ើបសួររកអត្តសញ្ញាណជនជាប់ចោទឱ្យបានច្បាស់លាស់ ដើម្បីផ្តន្ទាទោសជនជាប់ចោទមិនច្រឡំទៅនឹងបុគ្គលផ្សេងទៀត។អត្តសញ្ញាណជនជាប់ចោទដែលចៅក្រមស៊ើបសួរបញ្ជូនជនជាប់ចោទមកជំនុំជម្រះនេះឃើញថាមិនគ្រប់គ្រាន់និងច្បាស់លាស់ទេ អាចច្រឡំទៅបុគ្គលផ្សេងទៀតបាន។អាចស្រាវជ្រាវរកអត្តសញ្ញាណជនជាប់ចោទតាមរយៈស្ថានទូតម៉ាឡេស៊ីបាន ដែលពុំទាន់បានឃើញមានការស្រាវជ្រាវនោះឡើយ។សរុបមកតំណាងអយ្យការស្នើសុំឱ្យតុលាការចាត់របៀបឱ្យស៊ើបសួរបន្ថែម។យោបល់របស់តំណាងអយ្យការត្រឹមត្រូវតាមច្បាប់ តុលាការទទួលមកពិចារណាបាន។

៣.មេធាវីការពារឱ្យដើមបណ្តឹងរដ្ឋប្បវេណីយល់ស្របតាមការផ្តល់យោបល់របស់តំណាងអយ្យការ ដែលស្នើសុំ

ឱ្យតុលាការសម្រេចចាត់របៀប។

៤.តាមខ្លឹមសារមាត្រា៣៣៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌចែងថា ប្រសិនបើយល់ឃើញថាការស្រាវជ្រាវជាថ្មីជាការចាំបាច់ តុលាការអាចបង្គាប់តាមសាលក្រមឱ្យធ្វើការស៊ើបសួរបន្ថែម។សាលក្រមដែលបង្គាប់ធ្វើការស៊ើបសួរបន្ថែម ត្រូវចាត់តាំងចៅក្រមឱ្យទទួលភារកិច្ចនេះ។

៥.តុលាការយល់ឃើញថា ការស្រាវជ្រាវជាថ្មី រកអត្តសញ្ញាណជនជាប់ចោទឱ្យច្បាស់លាស់គឺជាការចាំបាច់ ដើម្បីជៀសវៀងបាន កុំឱ្យច្រឡំទៅនឹងបុគ្គលផ្សេងទៀត។

៦.តាមខ្លឹមសារមាត្រា២៤៧ថ្មីនៃច្បាប់ស្តីពីវិសោធនកម្មមាត្រា២៤៧,មាត្រា៣៦៨,មាត្រា៣៧២ និងមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចៅក្រមស៊ើបសួរចេញដីកាលើកលែងការចោទប្រកាន់ នៅក្នុងករណីជនជាប់ចោទដែលប្រព្រឹត្តអំពើនោះនៅតែគេមិនស្គាល់ ពោលគឺអត្តសញ្ញាណមិនច្បាស់លាស់ គប្បីចៅក្រមស៊ើបសួរពិនិត្យសមត្ថកិច្ចអំពីការលើកលែងការចោទប្រកាន់ ក្នុងករណីដែលស៊ើបសួររកអត្តសញ្ញាណជនជាប់ចោទពុំបានច្បាស់លាស់។

## ហេតុដូច្នេះសម្រេច

១.ចាត់របៀបបង្វិលសំណុំរឿងព្រហ្មទណ្ឌលេខ៧១៨៩ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៩ ទៅចៅក្រមស៊ើបសួរ ឱ្យស៊ើបសួរបន្ថែមរកអត្តសញ្ញាណរបស់ជនជាប់ចោទឈ្មោះ ឱ្យបានច្បាស់លាស់។

២. ចាត់តាំងលោកចៅក្រម ឱ្យទទួលភារកិច្ចស៊ើបសួរនេះ។ តាមមាត្រា៣៣៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៣.ពិនិត្យសមត្ថកិច្ចលើកលែងចោទប្រកាន់ តាមមាត្រា២៤៧ថ្មី ចំណុច២ នៃច្បាប់ស្តីពីវិសោធកម្មមាត្រា២៤៧, មាត្រា៣៦៨,មាត្រា៣៧២ និងមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៤.ឱ្យបញ្ជូនលទ្ធផលមកតុលាការវិញក្រោយពីបានបំពេញភារកិច្ចចប់។

សាលក្រមនេះជំនុំជម្រះជាសារធារណៈនៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២១ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២១។

**ក្រឡាបញ្ជីសវនាការ**
ហត្ថលេខា និង ត្រា ៖

**ចៅក្រមជំនុំជម្រះ**
ហត្ថលេខា និង ត្រា ៖

---

**បានឃើញ**
**ចៅក្រម**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃពុធ ០៤រោច ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២១
**ក្រឡាបញ្ជី**

ឧបសម្ព័ន្ធទី ៩

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

សាលក្រមព្រហ្មទណ្ឌ

លេខ ៧៣៨ "ព"

ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៩

សំណុំរឿងព្រហ្មទណ្ឌលេខ៖ ៤៩៦៨

ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៨

សំណុំរឿងស៊ើបសួរលេខ៖ ២៩១១

ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៨

សំណុំរឿងជំនុំជម្រះលេខ៖ ៣០៦

ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៩

**តាងនាមប្រជារាស្ត្រខ្មែរ**

**សាលាដំបូងរាជធានីភ្នំពេញ**

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៩ វេលាម៉ោង ០៨ និង ៣០ នាទី ព្រឹក នៅសាលសវនាការទី១ ដោយមានសមាសភាព ៖

**ចៅក្រមជំនុំជម្រះ**

-លោក ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

**តំណាងអយ្យការ**

-លោក ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

-កញ្ញា ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៤៩៦៨ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៨ ដែលមានជនជាប់ចោទ៖

១-ឈ្មោះ ហៅ ភេទប្រុស អាយុ៣៦ឆ្នាំ ជនជាតិខ្មែរ មុខរបរធ្វើចំការ ទីកន្លែងកំណើតនៅភូមិកោះក្របី ឃុំព្រែកថ្មី ស្រុកកៀនស្វាយ ខេត្តកណ្តាល ទីលំនៅមុនពេលឃុំខ្លួននៅផ្ទះគ្មានលេខ ផ្លូវបេតុងលេខ៣៦៩ ភូមិកោះក្របី សង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ប្រពន្ធឈ្មោះ ៖ មានកូនចំនួន ០២ នាក់ ឪពុកឈ្មោះ "រ" ម្តាយឈ្មោះ "រ" ជាទីតិជន ទោសពីមុនគ្មាន។

-ឃាត់ខ្លួននៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៨។

-ឃុំខ្លួនតាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៦៦៩៩ "ផ" ដ.ឃ.ដ ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៨។

២-ឈ្មោះ ហៅ ភេទប្រុស អាយុ៣២ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅផ្ទះគ្មានលេខ ផ្លូវលំ ក្រុម១៧ ភូមិកោះក្របី សង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។

-ដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ ៨៤៦ "ផ" ដ.ច.ខ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៨។

ជាប់ចោទពីបទ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចលើផ្លូវជាតិលេខ២ ខាងមុខមណ្ឌលសុខភាពចាក់អង្រែក្រោម សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**អង្គហេតុនៃរឿងមានដូចតទៅ**

កាលពីថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៨ វេលាម៉ោង ១៥ និង ៣០ នាទី ដោយមានការសម្របសម្រួលពីស្ថាប័នអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ កម្លាំងសមត្ថកិច្ចនៃការិយាល័យប្រឆាំងគ្រឿងញៀន បានចុះបង្ក្រាបករណីជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ដែលប្រព្រឹត្តនៅចំណុចផ្ទះគ្មានលេខ ផ្លូវលំ ក្រុម១៧ ភូមិកោះក្របី សង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ បានឃាត់ខ្លួនជនសង្ស័យឈ្មោះ ហៅ ភេទប្រុស អាយុ៣៦ឆ្នាំ រួមទាំងវត្ថុតាង .

នាំមកសាកសួរនៅការិយាល័យប្រឆាំងគ្រឿងញៀន។ ក្រោយពីសាកសួររួច ជនសង្ស័យឈ្មោះ ហៅ បានឆ្លើយសារភាពថា ចំពោះថ្នាំញៀនដែលសមត្ថកិច្ចធ្វើការដកហូតខាងលើ គឺខ្លួនទិញពីឈ្មោះ ហៅ ភេទប្រុស អាយុប្រហែល៣២ឆ្នាំ ចំនួន០១កញ្ចប់ តម្លៃ ២០០០០ រៀល យកមកវិលែកលក់បន្តឱ្យគេតម្លៃ ២០០០០ និង នៅសល់ទុកប្រើប្រាស់ខ្លះ និងគ្រឿងញៀនចំនួន០១កញ្ចប់ទៀត គឺជារបស់ឈ្មោះ ហៅ បោះចោលពេល សមត្ថកិច្ចបង្ក្រាប។

-បានឃើញ របាយការណ៍សំយោគលេខ ៣៣៣/១៨ រ.ប.ក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៨ របស់ការិយាល័យបទល្មើសប្រឆាំងគ្រឿងញៀន។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ០៨៥ អ.យ.ទ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១៩ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ១៦៩ "ជ" ដ.ជ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

**នាពេលសវនាការ**

-ជនជាប់ចោទឈ្មោះ បានឆ្លើយថា៖ កូនខ្លួនតូចជាងគេមានអាយុ ៥ឆ្នាំ។ ខ្លួនធ្លាប់ទិញគ្រឿងញៀនយកប្រើប្រាស់ចំនួន២ដង ទិញពីឈ្មោះ ហៅ ដោយក្នុង១ដងតម្លៃ ២០.០០០៛ (ពីរម៉ឺនរៀល) យកមកប្រើប្រាស់។ ខ្លួនប្រើប្រាស់តែម្នាក់ឯង ពីមុនមកប្រើជាមួយមិត្តភក្តិយូរហើយ ដោយលើកទី១នៅភូមិកោះក្របីទិញហើយប្រើប្រាស់នៅក្បែរកន្លែងគេ ប្រើប្រាស់ជាមួយឈ្មោះ ។ ខ្លួនមិនដែលលក់ចែកចាយគ្រឿងញៀនទេ។

-ក្រឡាបញ្ជីអានកំណត់ហេតុសួរចម្លើយរបស់ជនជាប់ចោទឈ្មោះ នៅតំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ថា៖ ខ្លួនបានធ្វើសកម្មភាពជួញដូរដោយខុសច្បាប់នូវសារធាតុញៀន បានរយៈពេលប្រហែល៣ខែមកហើយរហូតមកដល់បច្ចុប្បន្ន។ ចំពោះគ្រឿងញៀនខ្លួនទិញឈ្មោះ ( ) "គេចខ្លួន" ភេទប្រុស អាយុ៣២ឆ្នាំ ជនជាតិខ្មែរ មានកិនភាគ កម្ពស់ប្រហែល ១.៦៣ម៉ែត្រ មានខាត់ សម្បុរសណ្តែកបាយ មុខមូល សក់ស្កូតពុះកណ្តាល ទិញបានជាច្រើនលើក មួយលើកមួយកូនកញ្ចប់តម្លៃ ពីរម៉ឺនរៀល ដោយធ្វើសកម្មភាពជួញដូរនៅផ្ទះចំណុចទីតាំងបង្ក្រាប (ផ្ទះគ្មានលេខ ផ្លូវលំ ក្រុម១៧ ភូមិកោះក្របី សង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ) ពេលទិញគ្រឿងញៀនពីឈ្មោះ ភេទប្រុស (គេចខ្លួន) បានយកលក់ឱ្យអ្នកស្គាល់មួយកូនកញ្ចប់ ក្នុងតម្លៃមួយម៉ឺនរៀល ទៅពីរម៉ឺនរៀល និងប្រើប្រាស់ខ្លួនឯងខ្លះ។ ខ្លួនចេះប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនបានប្រហែលកន្លះឆ្នាំមកហើយ ជាគ្រឿងញៀនប្រភេទម៉ាទឹកកក។ លុះនៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៨ វេលាម៉ោងប្រហែលជា ១រសៀលខ្លួនបានចេញពីផ្ទះទៅផ្ទះឈ្មោះ (គេចខ្លួន) ដើម្បីទិញថ្នាំញៀនមួយកញ្ចប់តម្លៃប្រាំដុល្លារ ហើយបានអង្គុយជុំគ្នាជាមួយអ្នកស្គាល់នៅផ្ទះរបស់ ក៏ត្រូវសមត្ថកិច្ចបង្ក្រាបជាក់ស្តែងចាប់យកវត្ថុតាងគ្រឿងញៀន និងសម្ភារៈពាក់ព័ន្ធជាមួយបទល្មើសគ្រឿងញៀនមួយចំនួនទៀត ហើយបាននាំខ្លួនមកកាន់ការិយាល័យប្រឆាំងគ្រឿងញៀនតែម្តង។

-ជនជាប់ចោទឈ្មោះ បានឆ្លើយបញ្ជាក់បន្ថែមថា៖ ចំពោះចម្លើយដែលក្រឡាបញ្ជីបានអានឱ្យស្តាប់នាពេលសវនាការ គឺត្រឹមត្រូវ ហើយខ្លួនទទួលស្គាល់ការពិតទាំងអស់ ដោយគ្មានការបង្ខិតបង្ខំទេ។

-ក្រឡាបញ្ជីអានកំណត់ហេតុទទួលវត្ថុចាប់យក (១) លេខ ២៤៨៣ រ.វ.ត ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៨ រួមមាន៖

១-វត្ថុចាប់យករបស់ជនសង្ស័យឈ្មោះ ហៅ មាន ស្រោមសំបុត្រពណ៌ស បិទជិត ចំនួនមួយ មានផ្តិតខ្មៅដៃជនសង្ស័យឈ្មោះ ដោយមានចុះហត្ថលេខារបស់អ្នកចូលរួម សរសេរថា ក្រោមពណ៌សថ្លា

./..

ចេញពណ៌លឿងទុំ ចំនួនមួយកូនកញ្ចប់ ទម្ងន់សរុប ០,១៣ (សូន្យកណ្តាក់សញ្ញាដប់បី) ក្រាម និងសំបកថង់ប្លាស្ទិចចំនួនមួយ។

២-វត្ថុចាប់យករបស់ជនសង្ស័យឈ្មោះ ហៅ មាន

២.១-ស្រោមសំបុត្រពណ៌ស បិទជិតចំនួនមួយជារបស់ជនសង្ស័យឈ្មោះ ដោយមានចុះហត្ថលេខារបស់អ្នកចូលរួម សរសេរថា ក្រាមពណ៌សថ្លា ចេញពណ៌លឿងទុំ ចំនួនពីរកូនកញ្ចប់ ទម្ងន់សរុប ០,០៨ (សូន្យកណ្តាក់សញ្ញាសូន្យប្រាំបី) ក្រាម និងសំបកថង់ប្លាស្ទិចចំនួនពីរ។

២.២-ទូរស័ព្ទដៃម៉ាក ណូគា អិនចុចពិល "ចាស់ខ្លាំងមិនប្រក្រតី" ចំនួនបីគ្រឿង (ពណ៌ខៀវចំនួនមួយគ្រឿង និងពណ៌ក្រហមចំនួនពីរគ្រឿង)។

២.៣-កាំបិតដងឈើចំនួនប្រាំដើម។

-ក្រឡាបញ្ជីអានលទ្ធផលកោសលវិច័យគ្រឿងញៀនលេខ ១៥៨៣៤/១៨ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់មន្ទីរពិសោធន៍ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ឃើញ សំណាកជាគ្រឿងញៀនប្រភេទក្រាមម្សៅឈ្មោះ **មេតំហ្វេតាមីន** (ហៅ អាយ ឬ ម៉ាទឹកកក) របស់ឈ្មោះ ដែលមានកម្រិតភាពសុទ្ធ ៧៩.៤០ % នៃទម្ងន់ សរុប វាស្ថិតក្នុង តារាងទី២ មាត្រា៥ ចំណាត់ថ្នាក់គ្រឿងញៀន ដូចមានចែងលម្អិតក្នុងតារាងឧបសម្ព័ន្ធច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនកម្ពុជា។

-ក្រឡាបញ្ជីអានលទ្ធផលកោសលវិច័យគ្រឿងញៀនលេខ ១៥៨៣៥/១៨ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់មន្ទីរពិសោធន៍ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ឃើញ សំណាកជាគ្រឿងញៀនប្រភេទក្រាមម្សៅឈ្មោះ **មេតំហ្វេតាមីន** (ហៅ អាយ ឬ ម៉ាទឹកកក) របស់ឈ្មោះ ដែលមានកម្រិតភាពសុទ្ធ ៧១.២១ % នៃទម្ងន់ សរុប វាស្ថិតក្នុង តារាងទី២ មាត្រា៥ ចំណាត់ថ្នាក់គ្រឿងញៀន ដូចមានចែងលម្អិតក្នុងតារាងឧបសម្ព័ន្ធច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនកម្ពុជា។

## សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

**-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា៖** ក្រោយពីស្តាប់ការសាកសួរដេញដោលនាពេលសវនាការ ឃើញថាជនជាប់ចោទនៅតែរឹងតតឹងមិនព្រមសារភាពនូវអំពើដែលខ្លួនបានប្រព្រឹត្ត ប៉ុន្តែតាមចម្លើយរបស់ជនជាប់ចោទនៅគ្រប់ដំណាក់កាលនៃនីតិវិធី ឃើញថាជនជាប់ចោទបានឆ្លើយសារភាពថាពិតជាបានប្រព្រឹត្តអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀនប្រាកដមែន ដូច្នេះតំណាងអយ្យការស្នើសុំតម្កល់ការចោទប្រកាន់ និងផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

## សំដីចុងក្រោយរបស់ជនជាប់ចោទ

-ជនជាប់ចោទឈ្មោះ , ហៅ បាននិយាយសំដីចុងក្រោយថា៖ ខ្លួនស្នើសុំតុលាការសម្រេចបន្ធូរបន្ថយទោសឱ្យខ្លួនផង។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនជាប់ចោទនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សំដីចុងក្រោយបង្អស់របស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើឯកសារ ភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់រួចហើយ

## សំអាងហេតុ

១-តាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ១៦៩ "ជ" ង.ង ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ បានបញ្ជូនជនជាប់ចោទឈ្មោះ ហៅ ភេទប្រុស អាយុ៣៦ឆ្នាំ ជនជាតិខ្មែរ និងឈ្មោះ ហៅ ភេទប្រុស អាយុ៣២ឆ្នាំ ជនជាតិខ្មែរ ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចលើផ្លូវជាតិលេខ២ ខាងមុខមណ្ឌលសុខភាពចាក់អង្រែក្រោម សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២-តាមរបាយការណ៍សំយោគលេខ ៣៣៣/១៨ រ.ប.ក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៨ របស់ការិយាល័យប្រឆាំងគ្រឿងញៀន នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញបានសន្និដ្ឋានថា៖ ឈ្មោះ , ហៅ ភេទប្រុស អាយុ៣៦ឆ្នាំ និងឈ្មោះ ភេទប្រុស អាយុប្រហែល៣២ឆ្នាំ ពិតជាបាន ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន កាលពីថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៨ ប្រាកដមែន។

៣-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ ហៅ នាពេលសវនាការបានឆ្លើយបដិសេធថា៖ ខ្លួនមិនបានប្រព្រឹត្តបទអំពើ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀនទេ ដោយហេតុថា ពេលសមត្ថកិច្ចឃាត់ខ្លួន ស្របពេលដែលខ្លួនកំពុងអង្គុយលេងនៅមុខផ្ទះរបស់ឈ្មោះ ប៉ុណ្ណោះ។ ចម្លើយនេះគ្រាន់តែជាចម្លើយដោះសារដើម្បីយករួចខ្លួនប៉ុណ្ណោះ ដោយហេតុថា គ្មានភស្តុតាង និងសាក្សីណាមួយយកមកបញ្ជាក់ដើម្បីដោះបន្ទុកឡើយ ម្យ៉ាងវិញទៀត ជនជាប់ចោទ បានឆ្លើយសារភាពនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ថា ខ្លួនពិតជាទិញគ្រឿងញៀនពីឈ្មោះ ដើម្បីយកទៅរ៉ែលែកលក់បន្តប្រាកដមែន។

៤-មួយវិញទៀត ក្រោយពីបានឆ្លើយបដិសេធរួច ក្រឡាបញ្ជីសវនាការបានអានចម្លើយរបស់ជនជាប់ចោទនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ ហើយជនជាប់ចោទបានទទួលស្គាល់ចម្លើយនៅសមត្ថកិច្ចរបស់ខ្លួនវិញ ដែលបញ្ជាក់ឱ្យឃើញថា ជនជាប់ចោទពិតជាបានប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់មែន ដែលចម្លើយនេះមានភាពស៊ីសង្វាក់គ្នាទៅនឹងភស្តុតាងនានាមានក្នុងសំណុំរឿងដែលនាំឱ្យតុលាការជឿជាក់បានថាជនជាប់ចោទឈ្មោះ . ហៅ ភេទប្រុស អាយុ ៣៦ឆ្នាំ និងឈ្មោះ ហៅ ភេទប្រុស អាយុ៣២ឆ្នាំ ពិតជាបានលក់ថ្នាំញៀនឱ្យគេប្រាកដមែន។

៥-អំពើរបស់ជនជាប់ចោទដែលបានធ្វើសកម្មភាពយកថ្នាំញៀនទៅឱ្យគេ ដើម្បីទទួលបានប្រាក់ចំណេញ ឆ្លើយតបទៅនឹងធាតុផ្សំនៃបទល្មើស ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ដែលជាបទល្មើសព្រហ្មទណ្ឌមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៦-តាមលទ្ធផលកោសល្យវិច័យគ្រឿងញៀនលេខ ១៥៨៣៤/១៨ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់មន្ទីរពិសោធន៍ប្រឆាំងគ្រឿងញៀន, តាមកំណត់ហេតុធ្វើតេស្តបឋម និងវេចខ្ចប់វត្ថុតាងរបស់ការិយាល័យប្រឆាំងគ្រឿងញៀន ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៨ និងតាមកំណត់ហេតុទទួលវត្ថុតាងចាប់យក ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៨ បញ្ជាក់ឱ្យតុលាការឃើញថា ក្រាមសថ្លាចំនួន ០១កញ្ចប់ថង់តូច មានទម្ងន់សរុបចំនួន ០,១៣ (សូន្យគណ្តាក់សញ្ញាដប់បី) ក្រាម ដែលដកហូតពីឈ្មោះ កាលពីថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៨ គឺមានវត្ថុមានបរិមាណសារធាតុមេតំហ្វេតាមីន គិតជាភាគរយនៃទម្ងន់ គឺ ៧៩.៤០% (ចិតសិបប្រាំបួនគណ្តាក់សញ្ញាសែសិបភាគរយ) និងមានបរិមាណភាពសុទ្ធជាសារធាតុញៀនគិតជាក្រាមសរុបចំនួន ០.១០៣២២១ ហើយវាជាប្រភេទក្រាមម្សៅឈ្មោះ

មេតំហ្វេតាមីន (ហៅក្រៅម៉ាទឹកកក ឬអាយ) និងជាថ្នាំញៀនដែលស្ថិតនៅក្នុងតារាង II មាត្រា ៥ នៃតារាងឧបសម្ព័ន្ធច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន បញ្ញត្តិឱ្យផ្តន្ទាទោសដាក់ពន្ធនាគារពី ២(ពីរ) ឆ្នាំ ទៅ ៥(ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០(បួនលាន) រៀល ទៅ ១០.០០០.០០០(ដប់លាន)រៀល។

៧-តាមលទ្ធផលកោសល្យវិច័យគ្រឿងញៀនលេខ ១៥៨៣៥/១៨ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់មន្ទីរពិសោធន៍ប្រឆាំងគ្រឿងញៀន, តាមកំណត់ហេតុធ្វើតេស្តបឋម និងវេចខ្ចប់វត្ថុតាងរបស់ការិយាល័យប្រឆាំងគ្រឿងញៀន ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៨ និងតាមកំណត់ហេតុទទួលវត្ថុតាងចាប់យក ចុះថ្ងៃទី ២០ ខែសីហា ឆ្នាំ២០១៨ បញ្ជាក់ឱ្យតុលាការឃើញថា ក្រាមសថ្លាចំនួន ០១កញ្ចប់ថង់តូច មានទម្ងន់សរុបចំនួន ០,០៨ (សូន្យកណ្តាក់សញ្ញាសូន្យប្រាំបី) ក្រាម ដែលដកហូតពីឈ្មោះ កាលពីថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៨ គឺមានវត្ថុមានបរិមាណសារធាតុមេតំហ្វេតាមីន គិតជាភាគរយនៃទម្ងន់ គឺ ៧១.២១% (ចិតសិបមួយកណ្តាក់សញ្ញាម្ភៃមួយភាគរយ) និងមានបរិមាណភាពសុទ្ធជាសារធាតុញៀនគិតជាក្រាមសរុបចំនួន ០.០៥៦៩៦៨៧ ហើយវាជាប្រភេទក្រាមម្សៅឈ្មោះមេតំហ្វេតាមីន (ហៅក្រៅម៉ាទឹកកក ឬអាយ) និងជាថ្នាំញៀនដែលស្ថិតនៅក្នុងតារាង II មាត្រា ៥ នៃតារាងឧបសម្ព័ន្ធច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន បញ្ញត្តិឱ្យផ្តន្ទាទោសដាក់ពន្ធនាគារពី ២(ពីរ) ឆ្នាំ ទៅ ៥(ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០(បួនលាន) រៀល ទៅ ១០.០០០.០០០(ដប់លាន)រៀល។

៨-តាមកំណត់ហេតុទទួលវត្ថុចាប់យក (១) លេខ ២៤៨៣ រ.វ.ត ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៨ រួមមាន៖

ក-វត្ថុចាប់យករបស់ជនសង្ស័យឈ្មោះ ហៅ មាន ស្រោមសំបុត្រពណ៌ស បិទជិតចំនួនមួយមានផ្តិតខ្មៅដៃជនសង្ស័យឈ្មោះ ដោយមានចុះហត្ថលេខារបស់អ្នកចូលរួម សរសេរថា ក្រាមពណ៌សថ្លា ចេញពណ៌លឿងទុំ ចំនួនមួយកូនកញ្ចប់ ទម្ងន់សរុប ០,១៣ (សូន្យកណ្តាក់សញ្ញាដប់បី) ក្រាម និងសំបកថង់ប្លាស្ទិចចំនួនមួយ។

ខ-វត្ថុចាប់យករបស់ជនសង្ស័យឈ្មោះ ហៅ មាន

ខ.១-ស្រោមសំបុត្រពណ៌ស បិទជិតចំនួនមួយជារបស់ជនសង្ស័យឈ្មោះ ដោយមានចុះហត្ថលេខារបស់អ្នកចូលរួម សរសេរថា ក្រាមពណ៌សថ្លា ចេញពណ៌លឿងទុំ ចំនួនពីរកូនកញ្ចប់ ទម្ងន់សរុប ០,០៨ (សូន្យកណ្តាក់សញ្ញាសូន្យប្រាំបី) ក្រាម និងសំបកថង់ប្លាស្ទិចចំនួនពីរ។

ខ.២-ទូរស័ព្ទដៃម៉ាក ណូគា អិនចុចពិល "ចាស់ខ្លាំងមិនប្រក្រតី" ចំនួនបីគ្រឿង (ពណ៌ខៀវចំនួនមួយគ្រឿង និងពណ៌ក្រហមចំនួនពីរគ្រឿង)។

ខ.៣-កាំបិតដងឈើចំនួនប្រាំដើម។

វត្ថុតាងទាំងនេះមានជាប់ពាក់ព័ន្ធនឹងបទល្មើស គប្បីតុលាការសម្រេចរឹបអូសតាមមាត្រា ៦២ និងមាត្រា ៦៣ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៩៣ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៩-ជនជាប់ចោទ ត្រូវបានតុលាការធ្វើការកោះឱ្យចូលខ្លួនតាំងពីដំណាក់កាលស៊ើបសួរ រហូតដល់ដំណាក់កាលជំនុំជម្រះ ប៉ុន្តែជនជាប់ចោទ បានគេចខ្លួនមិនបង្ហាញខ្លួននៅចំពោះមុខតុលាការទេ នេះសរបញ្ជាក់ឱ្យឃើញពីចេតនាទុច្ចរិតក្នុងការគេចវេសពីការទទួលខុសត្រូវចំពោះអំពើដែលខ្លួនប្រព្រឹត្ត។

១០-តាមចម្លើយសារភាពរបស់ជនជាប់ចោទ របាយការណ៍សំយោគ និងភស្តុតាងផ្សេងៗទៀត ដែលមានភាពស៊ីសង្វាក់គ្នា គឺបង្ហាញឱ្យឃើញថាជនជាប់ចោទឈ្មោះ ហៅ ភេទប្រុស អាយុ ៣៦ឆ្នាំ ជនជាតិខ្មែរ និង

ឈ្មោះ ហៅ ភេទប្រុស អាយុ៣២ឆ្នាំ ជនជាតិខ្មែរ ពិតជាបានប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់ប្រាកដមែន។

១០-ជនជាប់ចោទ ជានីតិជនដែលមានស្មារតី មានការយល់ដឹងគ្រប់គ្រាន់ក្នុងការពិចារណា ព្រមទាំងបានដឹងយ៉ាងច្បាស់នូវអំពើរបស់ខ្លួនថាជាអំពើខុសច្បាប់ ហេតុនេះត្រូវតែទទួលខុសត្រូវលើអំពើរបស់ខ្លួនចំពោះមុខច្បាប់។

១១-អំពើរបស់ជនជាប់ចោទ បានធ្វើឱ្យប៉ះពាល់ដល់សុខភាព និងសណ្តាប់ធ្នាប់សាធារណៈ ដែលច្បាប់តម្រូវឱ្យផ្តន្ទាទោស។

១២-មានភស្តុតាងដាក់បន្ទុក និងមានពិរុទ្ធភាពគ្រប់គ្រាន់ដើម្បីដាក់បន្ទុកលើឈ្មោះ ហៅ ភេទប្រុស អាយុ ៣៦ឆ្នាំ ជនជាតិខ្មែរ និងឈ្មោះ ហៅ ភេទប្រុស អាយុ៣២ឆ្នាំ ជនជាតិខ្មែរ ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចលើផ្លូវជាតិលេខ២ ខាងមុខមណ្ឌលសុខភាពចាក់អង្រែក្រោម សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

១៣-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ ហៅ និងឈ្មោះ ហៅ ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន។ គប្បីតុលាការលើកយកមកពិចារណាក្នុងការសម្រេចសេចក្តី។

១៤-ជនជាប់ចោទឈ្មោះ ហៅ បាននិយាយសំដីចុងក្រោយបង្អស់ សូមតុលាការបន្ធូរបន្ថយទោស។ គប្បីតុលាការលើកយកមកពិចារណាក្នុងការសម្រេចសេចក្តី។

១៥-នៅដំណាក់កាលស៊ើបសួរ ចៅក្រមស៊ើបសួរបានចេញដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ ៨៤៦ "ផ" ដ.ច.ន ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៨ គប្បីតុលាការសម្រេចបញ្ឈប់ដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ ៨៤៦ "ផ" ដ.ច.ន ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៨ របស់ចៅក្រមស៊ើបសួរ និងសម្រេចចេញដីកាបង្គាប់ឱ្យចាប់ និងឃុំខ្លួនជនជាប់ចោទឈ្មោះ ហៅ ភេទប្រុស អាយុ៣២ឆ្នាំ ស្របតាមមាត្រា៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

## ហេតុដូច្នេះសម្រេច

១-ផ្តន្ទាទោសលើ ៖

ក-ឈ្មោះ ហៅ ភេទប្រុស អាយុ ៣៦ឆ្នាំ ជនជាតិខ្មែរ

ខ-ឈ្មោះ ហៅ ភេទប្រុស អាយុ៣២ឆ្នាំ ជនជាតិខ្មែរ

ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់ចំនួន ០២ (ពីរ) ឆ្នាំ និង ០៦ (ប្រាំមួយ) ខែ និងពិន័យជាប្រាក់ចំនួន ៤.០០០.០០០ (បួនលាន) រៀល ពីបទៈ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចលើផ្លូវជាតិលេខ២ ខាងមុខមណ្ឌលសុខភាពចាក់អង្រែក្រោម សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២-បញ្ឈប់ដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ ៨៤៦ "ផ" ដ.ច.ន ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៨ របស់ចៅក្រមស៊ើបសួរ សាលាដំបូងរាជធានីភ្នំពេញ។

៣-បង្គាប់ឱ្យចាប់ និងឃុំខ្លួនជនជាប់ចោទឈ្មោះ ហៅ ភេទប្រុស អាយុ៣២ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅផ្ទះគ្មានលេខ ផ្លូវលំ ក្រុម១៧ ភូមិកោះក្របី សង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។

៤-រឹបអូសវត្ថុចាប់យកដូចមាននៅក្នុងកំណត់ហេតុទទួលវត្ថុចាប់យក (១) លេខ ២៤៨៣ វ.វ.ត ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៨ រួមមាន៖

ក-វត្ថុចាប់យករបស់ជនសង្ស័យឈ្មោះ ហៅ មាន ស្រោមសំបុត្រពណ៌ស បិទជិតចំនួនមួយមានផ្តិតខ្មៅដៃជនសង្ស័យឈ្មោះ ដោយមានចុះហត្ថលេខារបស់អ្នកចូលរួម សរសេរថា ក្រាមពណ៌សថ្លា ចេញពណ៌លឿងទុំ ចំនួនមួយកូនកញ្ចប់ ទម្ងន់សរុប ០,១៣ (សូន្យកណ្តាក់សញ្ញាដប់បី) ក្រាម និងសំបកថង់ប្លាស្ទិចចំនួនមួយ។

ខ-វត្ថុចាប់យករបស់ជនសង្ស័យឈ្មោះ ហៅ មាន

ខ.១-ស្រោមសំបុត្រពណ៌ស បិទជិតចំនួនមួយជារបស់ជនសង្ស័យឈ្មោះ ដោយមានចុះហត្ថលេខារបស់អ្នកចូលរួម សរសេរថា ក្រាមពណ៌សថ្លា ចេញពណ៌លឿងទុំ ចំនួនពីរកូនកញ្ចប់ ទម្ងន់សរុប ០,០៨ (សូន្យកណ្តាក់សញ្ញាសូន្យប្រាំបី) ក្រាម និងសំបកថង់ប្លាស្ទិចចំនួនពីរ។

ខ.២-ទូរស័ព្ទដៃម៉ាក ណូគា អិនចុចពិល "ចាស់ខ្លាំងមិនប្រក្រតី" ចំនួនបីគ្រឿង (ពណ៌ខៀវចំនួនមួយគ្រឿង និងពណ៌ក្រហមចំនួនពីរគ្រឿង)។

ខ.៣-កាំបិតដងឈើចំនួនប្រាំដើម។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៩ ចំពោះមុខជនជាប់ចោទឈ្មោះ ហៅ និងកំបាំងមុខជនជាប់ចោទឈ្មោះ ហៅ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៩ ។

ទុកសិទ្ធិឱ្យប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ៕

ក្រឡាបញ្ជីសវនាការ

ចៅក្រមជំនុំជម្រះ

ឧបសម្ព័ន្ធទី ១០

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សាលក្រមព្រហ្មទណ្ឌ

លេខ ៤៤០ ក្រម

[illegible] ឆ្នាំ២០២១

-សំណុំរឿងព្រហ្មទណ្ឌលេខ ៤៧៥៤

ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៩

-សំណុំរឿងស៊ើបសួរលេខ ៥២៨១

ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៩

-សំណុំរឿងជំនុំជម្រះលេខ ២៧៨១

ចុះថ្ងៃទី[illegible] ខែកុម្ភៈ ឆ្នាំ២០២០

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាអសាធារណៈ នៅថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២១ វេលាម៉ោង ០២ និង ៣០ នាទី រសៀល នៅសាលសវនាការទី៤ ដោយមានសមាសភាព ៖

### ចៅក្រមជំនុំជម្រះ

-លោក ជាប្រធានក្រុមប្រឹក្សា

-លោក ជាចៅក្រមក្រុមប្រឹក្សា

-លោក ជាចៅក្រមក្រុមប្រឹក្សា

### តំណាងអយ្យការ

-លោក ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

### ក្រឡាបញ្ជីសវនាការ

-លោកស្រី ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៤៧៥៤ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៩ ដែលមានជនជាប់ចោទឈ្មោះ ភេទប្រុស អាយុ១៥ឆ្នាំ (កើតថ្ងៃខែឆ្នាំ ២០.១០.២០០៤) ជនជាតិខ្មែរ មុខរបរសិស្ស ទីកន្លែងកំណើតនៅ ភូមិផ្សារតូច សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះលេខ៩០៩ ផ្លូវហានណូយ ភូមិអន្លង់ក្ងាន សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ ឪពុកឈ្មោះ "រស់" និងម្តាយឈ្មោះ "រស់" នៅលីវ ជាអនីតិជន ។ (ក្រៅឃុំ)

ជាប់ចោទពីបទ: ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយសារមានមនុស្សច្រើនរាក់ក្នុងឋានៈជាតារា សហការី អ្នកផ្តើមគំនិត និងជាអ្នកសមគំនិត ប្រព្រឹត្តនៅចំណុចមុខកាស៊ីសសាំងតេណា សង្កាត់ទួលសង្កែ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២១៨ នៃក្រមព្រហ្មទណ្ឌ ។

-ឈ្មោះ ភេទប្រុស អាយុ១៧ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះលេខ៧២២A ក្រុម៣ ភូមិផ្សារតូច ផ្លូវលេខ៦២ សង្កាត់ទួលសង្កែ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ជាជនរងគ្រោះ ។

-ឈ្មោះ ភេទប្រុស អាយុ៤៤ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះលេខ៧២២A ក្រុម៣ ភូមិផ្សារតូច ផ្លូវលេខ៦២ សង្កាត់ទួលសង្កែ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ជាដើមបណ្តឹងរដ្ឋប្បវេណី ។

-មេធាវី " អត្តលេខ ១៦០៣ ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ ។

## អង្គហេតុនៃរឿងមានដូចតទៅ

ថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៩ វេលាម៉ោងប្រហែល១២ និង៤០នាទី ឈ្មោះ ភេទប្រុស អាយុ១៦ឆ្នាំ និងឈ្មោះ សក្កដា ភេទប្រុស អាយុប្រហែល១៥ឆ្នាំ បានចេញពីសាលារៀនវត្តភ្នំ ឆ្ពោះទៅកន្លែងធ្វើទូរស័ព្ទនៅម្តុំវត្តមួល ពេលជិះទៅដល់ចំណុចហាងកាហ្វេ ម្តុំផ្លូវវាយកូនហ្គោល មុខការ៉ាសាំងតេលា សង្កាត់ទួលសង្កែ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ដោយឈ្មោះ និងឈ្មោះ បានចូលទៅផឹកកាហ្វេនៅហាងខាងលើ បាន ប្រហែល០៥នាទី ស្រាប់តែឈ្មោះ និងបក្ខពួកបានជិះម៉ូតូចំនួន ០៦គ្រឿង មានគ្នាប្រហែល១៥នាក់ និងរថយន្តមួយគ្រឿងម៉ាកតាកូម៉ា មិនចាំផ្លាកលេខ មានគ្នាប្រហែល០៥នាក់ មកចុះមកវាយលើឈ្មោះ បណ្តាលឱ្យហោមច្រមុះ និងខៀវក្រោមភ្នែកខាងស្តាំ រួចឈ្មោះ បានចាប់ឈ្មោះ ដាក់លើរថយន្តតាកូម៉ា រួចបើកចេញប្រហែល ១០គីឡូម៉ែត្រ ដល់វត្តទួលសង្កែ ឈ្មោះ និងបក្ខពួកបានរុញឈ្មោះ ចេញពីរថយន្តបណ្តាលឱ្យធ្លាក់អុកគូថ ភ្លាមនោះឈ្មោះ បានរត់ឡើងលើម៉ូតូមិត្តភក្រដែលជិះតាមពីក្រោយនោះ ត្រលប់ទៅហាងកាហ្វេវិញ ចំណែកឈ្មោះ និងបក្ខពួកបានរត់គេចខ្លួនបាត់ ។

-បានឃើញ របាយការណ៍សំយោគលេខ ០១៥/១៩ រ.ប.ក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៩ របស់អធិការដ្ឋាននគរបាលខណ្ឌឫស្សីកែវ នៃអគ្គស្នងការនគរបាលរាជធានីភ្នំពេញ ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ៥១៧៩ អ.យ. ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាសន្និដ្ឋានស្ពាពរលេខ ២២៨៥ អ.យ.ជ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះលេខ ២៩១៧ " " ជ.ជ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាចាត់ឱ្យស៊ើបសួរជំនួសលេខ ១១៥៩ " " ព្រ.ទ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

### នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ បានអវត្តមាននៅគ្រប់ដំណាក់កាល នៃនីតិវិធីតុលាការ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ បានឆ្លើយថា ៖ កាលពីថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៩ វេលាម៉ោងប្រហែល ០១ថ្ងៃត្រង់ ខ្លួនកំពុងនៅផ្ទះរបស់ខ្លួន ស្រាប់តែកូនរបស់ខ្លួនឈ្មោះ បានទូរស័ព្ទមកខ្លួនដោយប្រាប់ថា វាត្រូវបានគេវ៉ៃនៅហាងកាហ្វេរបស់ឈ្មោះ នៅម្តុំផ្លូវវាយកូនហ្គោល ។ ខ្លួនក៏បានទៅដល់ទីនោះ ឃើញកូនរបស់ខ្លួនមានរបួសត្រង់ថ្ពាស ហោមច្រមុះ និងត្រូវកែងដៃ ដោយខ្លួនបានសួរអ្នកនៅទីនោះ គេប្រាប់ថា ឈ្មោះ និងបក្ខពួកប្រហែលជាង១០នាក់ ជិះម៉ូតូ០៧គ្រឿង និងឡានតាកូម៉ាមួយគ្រឿងទៀត បានព្រួតវាយកូនរបស់ខ្លួន រួចចាប់កូនរបស់ខ្លួនដាក់ចូលឡានយកទៅទម្លាក់នៅកែងវត្តទួលសង្កែ ។ ពេលនោះខ្លួនបាននាំកូនខ្លួនទៅផ្ទះ មិនបានយកទៅពេទ្យទេ ហើយខ្លួនបានទៅដាក់ពាក្យបណ្តឹងនៅប៉ុស្តិ៍ទួលសង្កែ ។ ខ្លួនសុំសំណងមរដូចក្នុងកំណត់ហេតុបណ្តឹង ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៩ ទុកដដែល ។

-សំណាកចម្លើយជនរងគ្រោះឈ្មោះ បានឆ្លើយថា ៖ កាលពីថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៩ វេលាម៉ោងប្រហែល ០១ថ្ងៃត្រង់ ខ្លួនកំពុងផឹកការហ្វេនៅហាងការហ្វេនៅម្តុំផ្លូវវាយកូនហ្គោលបឹងសាឡាងជាមួយឈ្មោះ ភេទប្រុស អាយុ១៧ ឆ្នាំ, ឈ្មោះ ភេទប្រុស អាយុ១៦ឆ្នាំ, ឈ្មោះ ភេទប្រុស អាយុ ១៧ឆ្នាំ និងឈ្មោះ ភេទប្រុស អាយុ១៦ឆ្នាំ ។ ពេលនោះខ្លួនបានឃើញម៉ូតូចំនួន ០៥គ្រឿង ដែលម៉ូតូមួយគ្រឿងជិះគ្នា០២នាក់ និងឡានម៉ាកតាកូម៉ាពណ៌ខ្មៅ ជិះគ្នា០៥នាក់ ក្នុងចំណោមនោះខ្លួនស្គាល់ឈ្មោះ ស្រ៊ាង សំណាង និងក្រុមរបស់ឈ្មោះ ដែលខ្លួនស្គាល់តែមុខតែមិនស្គាល់ឈ្មោះទេ បានមកឈប់មុខហាងការហ្វេ រួចចុះសំដៅមកខ្លួន ។ ពេលនោះឈ្មោះ បានចូលមកបោចសក់ក្បាលខ្លួនទាញទៅក្រោយ ហើយគ្នាវាពីរនាក់ទៀតបានចូលមកវាយខ្លួនចំមុខ, ថ្ពាស, ច្រមុះ និងកែងដៃ។ ចំណែកគ្នាវាជាច្រើនទៀតនាំគ្នាឈរមើលនៅជិតនោះ រីឯគ្នាខ្លួនដែលផឹកការហ្វេជាមួយគ្នានោះ មិនហ៊ានចូលជួយខ្លួនទេ ដោយពួកគេគំរាមថា បើហ៊ានចូលជួយនឹងវាយទាំងអស់ ។ ក្រោយមកឈ្មោះ និងបក្ខពួកនោះបានចាប់ខ្លួនដាក់លើឡានតាកូម៉ា បើកចេញពីហាងការហ្វេ ហើយពួកវាបាននាំខ្លួនទៅខណ្ឌស្រះចក តែពេលទៅដល់ស្តុបវត្តទួលសង្កែ ភ្លើងស្តុបពណ៌ក្រហមពួកវាក៏បានទម្លាក់ខ្លួនពីលើឡាន ហើយពួកវាបានបើកឡានចេញបាត់ ។ ពេលនោះគ្នារបស់ខ្លួនក៏បានឌុបខ្លួនមកហាងការហ្វេវិញ រួចខ្លួនបានទូរស័ព្ទប្រាប់ឪពុករបស់ខ្លួន ហើយគាត់ក៏បានមកយកខ្លួនទៅផ្ទះវិញ ។ ខ្លួនទិញថ្នាំពេទ្យអស់ប្រាក់ចំនួន ០២ម៉ឺន ទៅ០៣ម៉ឺនរៀល ។ ខ្លួនមិនធ្លាប់ឈ្លោះជាមួយឈ្មោះ ទេ ខ្លួនមិនដែលមានទំនាស់ជាមួយគាត់ទេ គ្រាន់តែធ្លាប់ឃើញមុខពេលលេងបាល់ តែចំពោះបក្ខពួករបស់ឈ្មោះ ខ្លួនធ្លាប់ប្រាប់ពួកនោះថា កុំឱ្យបោះចោលសំរាមចោល ដោយសារក្នុងសាលាគ្មានសណ្តាប់ធ្នាប់ ហើយខ្ញុំជាកាយរឹទ្ធិ ត្រូវមើលការខុសត្រូវលើសណ្តាប់ធ្នាប់ក្នុងសាលា ប្រហែលជាពួកគេអាចគុំអ៊ីងខ្លួន ។ ខ្លួនស្នើសុំតុលាការផ្តន្ទាទោសជននោះតាមច្បាប់ ។

-សំណាកចម្លើយសាក្សីឈ្មោះ បានឆ្លើយបំភ្លឺនៅដំណាក់កាលសមត្ថកិច្ចថា ៖ នៅថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៩ វេលាម៉ោង១៣ និង ០០នាទី ខ្លួននិងឈ្មោះ , ឈ្មោះ , ឈ្មោះ និងឈ្មោះ ព្រហ្ម កំពុងតែអង្គុយផឹកការហ្វេនៅផ្ទះរបស់ឈ្មោះ ភេទប្រុស ពេលនោះស្រាប់តែកេនរថយន្តមួយគ្រឿងម៉ាក តាកូម៉ា ពណ៌ខ្មៅ មិនចាំផ្លាកលេខ បានឈប់នៅមុខកន្លែងលក់ការហ្វេ ស្រាប់តែមានមនុស្សប្រុសពីរនាក់ចុះពីលើរថយន្ត តែខ្លួនមិនស្គាល់ឈ្មោះទេ ប៉ុន្តែខ្លួនស្គាល់មុខ ដោយបានមកវាយលើឈ្មោះ និងឈ្មោះ ហើយបានចាប់បញ្ចូលរថយន្តដឹកចេញពីកន្លែងលក់ការហ្វេទៅបាត់ ភ្លាមនោះពួកខ្លួនបានជិះម៉ូតូដេញតាមពីក្រោយរហូតដល់វត្តទួលសង្កែ រថយន្តនោះក៏បានឈប់ឱ្យមិត្តភ័ក្តិខ្លួនចុះវិញ ហើយពួកខ្លួនក៏បានជូនឈ្មោះ ទៅផ្ទះវិញតែម្តង ។

-សំណាកចម្លើយសាក្សីឈ្មោះ បានឆ្លើយបំភ្លឺនៅដំណាក់កាលសមត្ថកិច្ចថា ៖ នៅថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៩ វេលាម៉ោង១៣ និង ០០នាទី ខ្លួននិងឈ្មោះ ឈ្មោះ ឈ្មោះ និងឈ្មោះ កំពុងតែអង្គុយផឹកការហ្វេនៅផ្ទះរបស់ឈ្មោះ ភេទប្រុស ពេលនោះស្រាប់តែមានរថយន្តមួយគ្រឿងម៉ាក តាកូម៉ា ពណ៌ខ្មៅ មិនចាំផ្លាកលេខ បានឈប់នៅមុខកន្លែងលក់ការហ្វេ ស្រាប់តែមានមនុស្សប្រុសពីរនាក់ចុះពីលើរថយន្ត តែខ្លួនមិនស្គាល់ឈ្មោះទេ ប៉ុន្តែខ្លួនស្គាល់មុខ ដោយបានមកវាយលើឈ្មោះ និងឈ្មោះ ហើយបានចាប់បញ្ចូលក្នុងរថយន្តដឹកចេញពីកន្លែងលក់ការហ្វេទៅបាត់ ភ្លាមនោះពួកខ្លួនបានជិះម៉ូតូដេញតាមពី

ក្រោយរបស់រហូតដល់វត្តមួយសង្កែ រថយន្តនោះក៏បានឈប់ឱ្យមិត្តភ័ក្តិខ្លួនចុះវិញ ហើយពួកខ្លួនក៏បានជូនឈ្មោះ ឈួ ប៊ុនសាត ទៅផ្ទះវិញតែម្តង ។

-រំលឹកការឆ្លើយសាក្សីឈ្មោះ បានឆ្លើយបំភ្លឺនៅដំណាក់កាលសមត្ថកិច្ចថា ៖ នៅថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៩ វេលាម៉ោង១៣ និង៣០នាទី ខ្លួនបានចេញពីសាលារៀនបានមកអង្គុយផឹកកាហ្វេនៅម្តុំបឹងសាឡាង ស្ពានដាច់មួយសង្កែ ខណ្ឌឫស្សីកែវ មានគ្នាបីនាក់ ។ ពេលអង្គុយផឹកកាហ្វេ ក៏ស្រាប់តែមានរថយន្តមួយគ្រឿង ម៉ាក តាកូម៉ា ពណ៌ខ្មៅ និងមានម៉ូតូចំនួន ០៥គ្រឿង ម៉ាកPCX, ម៉ាកDREAM, ម៉ាកSCOOPY តែមិនចាំផ្លាកលេខ មានគ្នាជិត១០នាក់ បានជិះមករកពួកខ្លួនដែលកំពុងអង្គុយផឹកកាហ្វេ ហើយសួរថាអ្នកណាវាយប្អូនអញ ហើយពួកខ្លួនឆ្លើយថាមិនដឹងទេ រួចពួកគេក៏វាយទៅឈ្មោះ ភេទប្រុស ចំផ្ទៃមុខបណ្តាលឱ្យរបួសធ្ងន់ធ្ងរ និងបានវាយខ្លួនចំនួនមួយដៃចំក្បាល និងបានចាប់ឈ្មោះ និងខ្លួនឡើងរថយន្តម៉ាក តូកូម៉ា ពេលនោះពួកគេគំរាមខ្លួន រួចក៏បើកចេញទៅ តែក៏មានមិត្តភ័ក្តិឈ្មោះ , ឈ្មោះ ឈ្មោះ , បានជិះម៉ូតូតាម បានប្រហែលមួយគីឡូម៉ែត្រ ក៏ពួកគេឈប់រថយន្តរួចឱ្យពួកខ្លួនចុះពីលើឡាន រួចពួកគេក៏ជិះគេចខ្លួនបាត់ ។

-រំលឹកការឆ្លើយសាក្សីឈ្មោះ បានឆ្លើយបំភ្លឺនៅដំណាក់កាលសមត្ថកិច្ចថា ៖ នៅថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៩ វេលាម៉ោង១៣ និង០០នាទី ខ្លួននិងឈ្មោះ ឈ្មោះ ឈ្មោះ កំពុងតែអង្គុយផឹកកាហ្វេនៅផ្ទះរបស់ឈ្មោះ , ។ ពេលនោះស្រាប់តែមានមនុស្សប្រុសពីរនាក់ចុះពីលើរថយន្តតែខ្លួនមិនស្គាល់ឈ្មោះទេ ប៉ុន្តែខ្លួនស្គាល់មុខ ដោយបានមកវាយលើឈ្មោះ និងឈ្មោះ ហើយបានចាប់បញ្ចូលក្នុងរថយន្តដឹកចេញពីកន្លែងលក់កាហ្វេទៅបាត់ ភ្លាមនោះពួកខ្លួនបានជិះម៉ូតូដេញតាមពីក្រោយរហូតដល់វត្តមួយសង្កែ រថយន្តនោះក៏បានឈប់ឱ្យមិត្តភ័ក្តិខ្លួនចុះវិញ ហើយពួកខ្លួនក៏បានជូនឈ្មោះ , ទៅផ្ទះវិញតែម្តង ។

-រំលឹកការឆ្លើយសាក្សីឈ្មោះ ហៅ , បានឆ្លើយបំភ្លឺនៅដំណាក់កាលសមត្ថកិច្ចថា ៖ នៅថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៩ វេលាម៉ោង១៣ និង០០នាទី មុនពេលកើតហេតុ ខ្លួនកំពុងតែលក់កាហ្វេ ហើយឈ្មោះ និងបក្ខពួករបស់វាបានមកផឹកកាហ្វេនៅកន្លែងខ្លួន ពេលនោះមានរថយន្តមួយគ្រឿង ពណ៌ខ្មៅ មិនចាំផ្លាកលេខ បានឈប់នៅមុខហាងកាហ្វេរបស់ខ្លួន ពេលនោះឈ្មោះ និងបក្ខពួកបានរត់ចេញក្រៅ ហើយឡើងទៅលើផ្ទះប្រជាពលរដ្ឋ ប៉ុន្តែម្ចាស់ផ្ទះមិនឱ្យឡើងទេ ហើយក៏ត្រូវបានបក្ខពួកមួយក្រុមទៀតនោះ បានចាប់វាយលើឈ្មោះ ឱ្យចូលក្នុងរថយន្តតែម្តង ។ ដោយឡែកឈ្មោះ ពុំបានចូលរួមចាប់ ឬវាយលើឈ្មោះ ទេ ដោយឈររមើលនៅហាងកាហ្វេរបស់ខ្លួន ។

## សេចក្តីសន្និដ្ឋានបួនសុំរបស់តំណាងអយ្យការ

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា ៖ ក្រោយពីបានស្តាប់ការពិភាក្សាដេញដោលនាពេលសវនាការរួចមកឃើញថាជនជាប់ចោទឈ្មោះ ភេទប្រុស អាយុ១៥ឆ្នាំ ជនជាតិខ្មែរ ពិតជាបានប្រព្រឹត្តអំពើ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយសារមានមនុស្សច្រើននាក់ក្នុងឋានៈជាចារី សហចារី អ្នកផ្តើមគំនិត និងជាអ្នកសមគំនិត បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២១៨ នៃក្រមព្រហ្មទណ្ឌ ដោយតំណាង

អយ្យការសុំតម្កល់ការចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខៈ **២២៨៥ អ.យ.ជ** ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២០ មុកនៅដដែល ។

## សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

-តំណាងអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានថា ៖ កូនក្ដីរបស់ខ្លួនពុំបានចូលរួមមកឆ្លើយបំភ្លឺទេ រាល់ចម្លើយរបស់ជនរងគ្រោះ និងដើមបណ្ដឹងរដ្ឋប្បវេណី គ្រាន់តែជាចម្លើយដែលឆ្លើយ ដោយពុំមានភស្ដុតាង និងសំអាងហេតុណាមួយគ្រប់គ្រាន់ក្នុងការដាក់បន្ទុកដល់កូនក្ដីខ្លួនឡើយ ស្នើសុំតុលាការពិចារណា សម្រេចឲ្យកូនក្ដីខ្លួនរួចផុតបទចោទ ។

-ក្រោយពីបានស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី

-ក្រោយពីបានស្ដាប់អំណានចម្លើយជនរងគ្រោះ

-ក្រោយពីបានស្ដាប់អំណានចម្លើយសាក្សីបំភ្លឺ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើឯកសារ ភស្ដុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## យល់ឃើញថា

១-តាមដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះលេខ ២៩១៧ "៖ ' ជ.ជ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ បានបញ្ជូនជនជាប់ចោទឈ្មោះ ភេទប្រុស អាយុ១៥ឆ្នាំ មកជំនុំជម្រះ ពីបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយសារមានមនុស្សច្រើននាក់ក្នុងឋានៈជាចារី សហចារី អ្នកផ្ដើមគំនិត និងជាអ្នកសមគំនិត ប្រព្រឹត្តនៅចំណុចមុខការ៉ាសសាំងតេលា សង្កាត់ទួលសង្កែ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា២១៨ នៃក្រមព្រហ្មទណ្ឌ ។

២-តាមចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ និងអំណានចម្លើយជនរងគ្រោះឈ្មោះ ៖, អំណានចម្លើយសាក្សីបំភ្លឺ និងរបាយការណ៍សំយោគលេខ ០១៥/១៩ រ.ប.ក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៩ របស់អធិការដ្ឋាននគរបាលខណ្ឌឫស្សីកែវ ព្រមទាំងការពិនិត្យភស្ដុតាងជាឯកសារនានា មានភាពស៊ីសង្វាក់គ្នាអាចឲ្យតុលាការជឿជាក់បានថា ជនជាប់ចោទឈ្មោះ ភេទប្រុស អាយុ១៥ឆ្នាំ ពិតជាបានធ្វើសកម្មភាពហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយសារមានមនុស្សច្រើននាក់ ដោយកាលពីថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៩ ចំណុចមុខការ៉ាសសាំងតេលា សង្កាត់ទួលសង្កែ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ជនជាប់ចោទឈ្មោះ ៖ ភេទប្រុស អាយុ១៥ឆ្នាំ និង និងបក្ខពួក បានជិះរថយន្តមួយគ្រឿងម៉ាកតាកូម៉ា មកវាយលើជនរងគ្រោះឈ្មោះ បណ្ដាលឲ្យរបួសត្រចៀក និងភ្នែក ក្រោមភ្នែកខាងស្ដាំ រួចជនជាប់ចោទឈ្មោះ ] បានចាប់ជនរងគ្រោះឈ្មោះ ដាក់លើរថយន្តតាកូម៉ា រួចបើកចេញប្រហែល១០គីឡូម៉ែត្រ ដល់កែងស្ដុបរត្តទួលសង្កែ ស្រាប់តែជនជាប់ចោទឈ្មោះ និងបក្ខពួកបានរុញជនរងគ្រោះឈ្មោះ ៖ ចេញពីរថយន្តបណ្ដាលឲ្យធ្លាក់របួសត្រង់ ក្បាលដំបែន ។

៣-អំពើរបស់ជនជាប់ចោទខាងលើ បានសំដែងនូវចេតនាទុច្ចរិត ដោយធ្វើសកម្មភាពប្រើប្រាស់អំពើហិង្សាដោយចេតនាទៅលើជនរងគ្រោះ ដែលសកម្មភាពនេះ មើលទៅមានលក្ខណៈឃោរឃៅ បងតូចបងធំ ដូចក្នុងខ្សែភាពយន្តដែលអំពើនេះធ្វើឱ្យប៉ះពាល់ដល់សន្តិសុខ សណ្ដាប់ធ្នាប់ របៀបរៀបរយសាធារណៈក្នុងសង្គម ជាពិសេសប៉ះពាល់ដល់ផលប្រយោជន៍របស់ជនរងគ្រោះ ដែលច្បាប់ព្រហ្មទណ្ឌបានការពារដោយបញ្ញត្តិជាបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយសារមានមនុស្សច្រើននាក់ក្នុងឋានៈជាចារី សហចារី អ្នកផ្ដើមគំនិត និងជាអ្នកសមគំនិត គប្បីឱ្យផ្ដន្ទាទោសតាមមាត្រាមាត្រា២១៨ នៃក្រមព្រហ្មទណ្ឌ ។

៤-តាមសេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ បានរក្សាការចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខ ២២៨៥ អ.យ.ដ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២០ ខុកដូដែល ជាសេចក្ដីសន្និដ្ឋានដែលមានភាពត្រឹមត្រូវគ្រប់ជ្រុងជ្រោយ គប្បីតុលាការពិចារណា និងសម្រេចតាមបាន ។

៥-តាមសេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទនាពេលសវនាការ បានធ្វើសេចក្ដីសន្និដ្ឋានថាកូនក្ដីរបស់ខ្លួនពុំបានចូលរួមទទួលខុសត្រូវទេ រាល់ចម្លើយរបស់ជនរងគ្រោះ និងដើមបណ្ដឹងរដ្ឋប្បវេណី គ្រាន់តែជាចម្លើយដែលឆ្លើយ ដោយពុំមានភស្តុតាង និងសំអាងហេតុណាមួយគ្រប់គ្រាន់ក្នុងការដាក់បន្ទុកដល់កូនក្ដីខ្លួនឡើយ ស្នើសុំតុលាការពិចារណា សម្រេចឱ្យកូនក្ដីខ្លួនរួចផុតបទចោទ ។ គប្បីតុលាការពិចារណា និងសម្រេច ។

៦-ជនជាប់ចោទខាងលើ មានស្មារតីដឹងខុសត្រូវ ដឹងច្បាស់នូវអំពើដែលខ្លួនបានប្រព្រឹត្ត ហេតុនេះត្រូវទទួលខុសត្រូវនូវអំពើល្មើសរបស់ខ្លួនចំពោះមុខច្បាប់ ។

៧-មានពិរុទ្ធភាពគ្រប់គ្រាន់ដើម្បីដាក់បន្ទុកលើជនជាប់ចោទឈ្មោះ ភេទប្រុស អាយុ១៥ឆ្នាំពីរមេ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយសារមានមនុស្សច្រើននាក់ក្នុងឋានៈជាចារី សហចារី អ្នកផ្ដើមគំនិត និងជាអ្នកសមគំនិត ប្រព្រឹត្តនៅចំណុចចំណុចមុខការ៉ាសសាំងតេលា សង្កាត់ទួលសង្កែ១ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា២១៨ នៃក្រមព្រហ្មទណ្ឌ ។

៨-ជនជាប់ចោទឈ្មោះ ពុំបានចូលខ្លួននៅគ្រប់ដំណាក់កាលនៃនីតិវិធីរបស់តុលាការ ទោះបីជាដឹងថា ជនជាប់ចោទរូបនេះរៀននៅវិទ្យាល័យហ៊ុនសែនប៊ុនរ៉ានីវត្តភ្នំក៏ដោយ ក៏សមត្ថកិច្ចពុំព្រមផ្ដល់សវតាជាតិជូនតុលាការឡើយ ម្យ៉ាងទៀតដោយមានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់ដាក់បន្ទុកលើជនជាប់ចោទ ក្នុងការចោទប្រកាន់នេះ និងពិនិត្យលើភាពធ្ងន់ធ្ងរនៃបទល្មើស ដែលជនជាប់ចោទបានប្រព្រឹត្ត ហើយជនជាប់ចោទអាចប្រព្រឹត្តបទល្មើសតទៅទៀត ។ ហេតុនេះគប្បីតុលាការពិចារណាទៅលើការចេញដីកាបង្គាប់ឱ្យចាប់ខ្លួនជនជាប់ចោទយកមកឃុំខ្លួន ដើម្បីអនុវត្តទណ្ឌកម្ម យោងតាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៩-តាមចម្លើយដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ បានទាមទារសំណងជម្ងឺចិត្តចំនួន ៣០.០០០$ (បីម៉ឺនដុល្លារអាមេរិក) ។ ការទាមទារសំណងជម្ងឺចិត្តមានកម្រិតខ្ពស់ហួសពីព្យសនកម្មជាក់ស្ដែង ម្យ៉ាងទៀតដើមបណ្ដឹងរដ្ឋប្បវេណីពុំបានបង្ហាញភស្តុតាងណាមួយ បញ្ជាក់ពីការខូចខាតដែលខ្លួនបានទទួលរង ជូនតុលាការពិនិត្យទេ ។ ហេតុនេះគប្បីតុលាការពិនិត្យពិចារណា និងសម្រេចបន្ធូរបន្ថយសំណង ធ្វើយ៉ាងណាឱ្យមានតុល្យភាពទៅនឹងពន្យសនកម្មដែលបានកើតឡើង ក៏ដូចជាពិចារណាអំពីស្ថានភាពជីវភាពជាក់ស្ដែងរបស់ជនជាប់ចោទផងដែរ ។

## ហេតុដូច្នេះសម្រេច

១-/ផ្ដន្ទាទោសជនជាប់ចោទឈ្មោះ ភេទប្រុស អាយុ១៥ឆ្នាំ សញ្ជាតិខ្មែរ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល **១៨** (ដប់ប្រាំបី) ខែ និងពិន័យជាប្រាក់ចំនួន **៨.០០០.០០០៛** (ប្រាំបីលានរៀល) បង់ចូលថវិការដ្ឋ ។

ពីបទ ហិង្សាដោយចេតនាហុនស្ថានទម្ងន់ទោសដោយសារមានមនុស្សច្រើននាក់ក្នុងឋានៈជាចារី សហចារីអ្នកផ្ដើមគំនិត និងជាអ្នកសមគំនិត ប្រព្រឹត្តនៅចំណុចមុខការ៉ាសសាំងតេលា សង្កាត់ទួលសង្កែ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ ។

២-/បង្គាប់ឱ្យចាប់ខ្លួន និងឃុំខ្លួនឈ្មោះ មានសាវតាជាតិដូចខាងលើ ដើម្បីយកអនុវត្តការវិរណាននៃសាលក្រមនេះ តាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៣-/បង្គាប់ឱ្យឈ្មោះ ភេទប្រុស អាយុ១៥ឆ្នាំ សងថ្លៃព្យាបាលរបួស និងសំណងជម្ងឺចិត្តចំនួន ១៥០០០$ (មួយម៉ឺនប្រាំពាន់ដុល្លារអាមេរិក) ទៅឱ្យដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ ។ ការទាមទារលើសពីនេះ ច្រានចោល ។

សាលក្រមនេះជំនុំជម្រះជាអសាធារណៈនៅថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២១ កំបាងមុខជនជាប់ចោទឈ្មោះ ភេទប្រុស អាយុ១៥ឆ្នាំ និងចំពោះមុខដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ ភេទប្រុស អាយុ៤៤ឆ្នាំ និងជនរងគ្រោះឈ្មោះ ភេទប្រុស អាយុ១៧ឆ្នាំ ប្រកាសជាអសាធារណៈ នៅថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២១ ។

បើកសិទ្ធិប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់កំណត់។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| (ហត្ថលេខា និងត្រា) | (ហត្ថលេខា និងត្រា) | (ហត្ថលេខា និងត្រា) | (ហត្ថលេខា និងត្រា) |

"បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម"
ថ្ងៃចន្ទ ៨កើត ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥
រាជធានីភ្នំពេញ, ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២១
ក្រឡាបញ្ជី

បានឃើញ
ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

ឧបសម្ព័ន្ធទី ១១

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

៙៙៙✵៙៙៙

**សាលាដំបូងរាជធានីភ្នំពេញ**

លេខ ................ "ង១" ល.ក្រ

ចុះថ្ងៃទី.........ខែ........ ឆ្នាំ២០២១

-សំណុំរឿងព្រហ្មទណ្ឌលេខ ៣៤៤៤

ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២០

-សំណុំរឿងជំនុំជម្រះលេខ ៦៨១៤

ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២០

-សាលក្រមលេខ ៦៦១ "ង១"

ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២១

## <u>លិខិតជូនដំណឹងអំពីសាលក្រមកំបាំងមុខ</u>

យើង  ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ប្រាប់មកដើមបណ្តឹងរដ្ឋប្បវេណី ៖

-ឈ្មោះ  ភេទប្រុស អាយុ៣៨ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះលេខ ២៤ ផ្លូវលេខ២០០ ភូមិ១ សង្កាត់បឹងរាំង ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

ឱ្យដឹងថា: តាមសាលក្រមកំបាំងមុខលេខ **៦៦១** "ង១" ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២១ បានសម្រេចសេចក្តីដូចខាងក្រោម៖

**១-/**ផ្តន្ទាទោសជនជាប់ចោទឈ្មោះ  ភេទប្រុស អាយុ៣២ឆ្នាំ សញ្ជាតិខ្មែរ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល **០៣** (បី) ឆ្នាំ និងពិន័យជាប្រាក់ចំនួន **៤.០០០.០០០៛** (បួនលានរៀល) បង់ចូលថវិការដ្ឋ ។

ពីបទ: **អបោក និងមិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ២០១៩ និងឆ្នាំ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **៣៧៧** និងមាត្រា**៣៧៨** នៃក្រមព្រហ្មទណ្ឌ និងមាត្រា**២៣១** នៃច្បាប់ស្តីពីឧបករណ៍ដែលអាចជួញដូរ និងប្រតិបត្តិការទូទាត់សងប្រាក់ ។

**២-/**បង្គាប់ឲ្យឈ្មោះ  សងប្រាក់ចំនួន **១៦២.៣៩៥$** (ដប់ប្រាំមួយម៉ឺនពីរពាន់បីរយកៅសិបប្រាំដុល្លារអាមេរិក) ទៅឲ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ  ។

**៣-/**បង្គាប់ឲ្យឈ្មោះ  បង់សំណងជួសជុលការខូចខាត និងសំណងជម្ងឺចិត្តជាប្រាក់សរុបចំនួន **៣០.០០០.០០០៛** (សាមសិបលានរៀល) ទៅឲ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ  ។ ការទាមទារលើសពីនេះ ច្រានចោល ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទឈ្មោះ  ភេទប្រុស អាយុ៣២ឆ្នាំ និងកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ  ភេទប្រុស អាយុ៣៨ឆ្នាំ ប្រកាសជាសាធារណៈ នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២១ ។

សាម៉ីខ្លួនមានសិទ្ធិប្តឹងទាស់នឹងសាលក្រមនេះក្នុងរយៈពេល ១៥ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលដំណឹង អំពីសាលក្រមនេះ និងមានសិទ្ធិប្តឹងឧទ្ធរណ៍ ក្នុងរយៈពេល ០១ខែ។

ថ្ងៃ........................ ខែ............ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

**បានឃើញ**

**ចៅក្រមជំនុំជម្រះ**

រាជធានីភ្នំពេញ, ថ្ងៃទី......... ខែ........... ឆ្នាំ២០២១

**ក្រឡាបញ្ជី**

យើង...........................................................................................................................

បានប្រគល់លិខិតជូនដំណឹងអំពីសាលក្រមកំបាំងមុខនេះអោយឈ្មោះ....................................
ទីលំនៅសព្វថ្ងៃនៅភូមិ..............................ឃុំសង្កាត់..............................ស្រុកខណ្ឌ....................
ខេត្ត-រាជធានី..................................នៅថ្ងៃទី..............ខែ..............ឆ្នាំ...............ផ្ទាល់រួចរាល់ហើយ។

**អ្នកទទួលលិខិត** **អ្នកប្រគល់**